អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 24-Oct-2011, 08:13

CMS/CFO: Uch Arun

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ស្តីពី ការកំណត់ជាក់លាក់នូវសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី**

**និងសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១**

**សាធារណៈ**

**ម៉ោង ០៩: ០០នាទី**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម យូរ ឧត្តរា

ចៅក្រម ក្លូឌា ហ្វេនស៍ *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី *(M.s Faiza ZOUAKRI)*

លោក ដាវ អានសាន *(Mr.Dav ANSAN)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក វេង ហ៊ត់

លោក ថារីក អាប់ឌុលឡាក់ *(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន *(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ អៀង ធីរិទ្ធ៖**

លោក ផាត់ ពៅស៊ាង

លោកស្រី ដាយអេណា អេលីស
*(Ms. Diana ELLIS)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី ម៉ាទីន ហ្សាកកាំង
*(Ms. Martine JACQUIN)*

លោក សំ សុគង់

លោក វ៉ែន ពៅ

កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ *(Ms.Phillipine SUTZ)*

លោក ហុង គឹមសួន

លោក អ៊ែរវ៉េ យ៉ាគីសេ
*(Mr. Herve DIAKIESE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក ច័ន្ទ តារាស្មី | ខ្មែរ |
| លោក ផាត់ ពៅស៊ាង | ខ្មែរ |
| លោកស្រី ដាយអាណា អេលីស | អង់គ្លេស |
| លោក អាង ឧត្ដម | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក អ៊ែរវេ យ៉ាគីសេ | បារាំង |
| លោក ហុង គឹមសួន | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ស៊ីណា ហ្វាស៊ែល | អង់គ្លេស |
| លោក ហ្លួត លីនណា | ខ្មែរ |
| លោក ឌុច ផារី | ខ្មែរ |

# ឧបសម្ព័ន្ធ

## សាក្សី

### វេជ្ជបណ្ឌិត ហ្វូត លីនណា និង វេជ្ជបណ្ឌិត ស៊ីណា ហ្វាស៊ែល (Dr. seena FAZEL)

សួរដោយលោក ផាត់ ពៅស៊ាង ផ្តើមពី.........ទំព័រ ២
សួរដោយលោកស្រី ដាយអាណា អេលីស ផ្តើមពី .........ទំព័រ ៤
សួរដោយលោក ច័ន្ទ តារាស្មី ផ្តើមពី.........ទំព័រ ២៣
សួរដោយលោក អាប់ឌុលឡាក់ ថារីក ផ្តើមពី .........ទំព័រ ៣៦
សួរដោយលោក ហុង គីមសួន ផ្តើមពី.........ទំព័រ ៤៦
សួរដោយលោក អ៊ែរវេ យ៉ាគីអេសេ ផ្តើមពី.........ទំព័រ ៥១
សួរដោយលោកស្រី ដាយអាណា អេលីស ផ្តើមពី .........ទំព័រ ៥៨

# កិច្ចដំណើរការនីតិវិធី

[០៩:០០:២៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបឋម--

សូមអញ្ជើញលោកមេធាវី ផាត់ ពៅស៊ាង!

**លោក ផាត់ ពៅស៊ាង៖**

សូមគោរពលោកប្រធាន លោក លោកស្រី នៃអង្គជំនុំជម្រះសាលាដំបូង។ ខ្ញុំបាទជាមេធាវីការពារក្តីឲ្យអ្នកស្រី អៀង ធីរិទ្ធ។ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូនលោកប្រធាន លោក លោកស្រីចៅក្រមមេត្តាជ្រាបថា ថ្ងៃនេះដោយសារបញ្ហាសុខភាពកូនក្តីខ្ញុំបាទមិនអាចចូលរួមនូវដំណើរការនីតិវិធីទេ គឺស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងមេត្តាបន្ត ហើយទន្ទឹមនឹងហ្នឹង គឺគាត់ក៏សូមហៅថាលះបង់សិទ្ធិរបស់គាត់ ប្រគល់ជូនមកមេធាវីដើម្បីបន្តនីតិវិធីតាមការគ្រោងទុក។

បាទ, សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ ដែលបានផ្តល់ព័ត៌មាន និងធ្វើការ-- និងសំណើសុំនេះ ហើយអង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំដោយសំណើសុំនេះមានមូលហេតុសមស្រប ដូចមានចែងនៅក្នុងវិធាន៨១ ស្ទួនបួន នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឲ្យជនជាប់ចោទក្នុងករណីបដិសេធ ឬក៏ខនខានមិនបានចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ បន្ទាប់ពីបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ ហើយបានប្រគល់សិទ្ធិដល់មេធាវីរបស់ខ្លួនសម្រាប់ការការពារក្តីចំពោះមុខអង្គជំនុំជម្រះ។

[០៩:០២:៣៤]

ជាកិច្ចបន្តអង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅមេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ ដើម្បីមានឱកាសក្នុងការតាំងសំណួរដល់អ្នកជំនាញចំនួនពីររូប។ ហើយជម្រាបឡើងវិញថា មេធាវីមានពេលវេលាមួយម៉ោងក្នុងការសួរដេញដោលចំពោះអ្នកជំនាញ ចំពោះរបាយការណ៍របស់គាត់ ដែលបានធ្វើចំពោះលោកស្រី អៀង ធីរិទ្ធ កន្លងមកនេះ ពាក់ព័ន្ធជាមួយនឹងសម្បទា បញ្ញាស្មារតី ចូលរួមនៅក្នុងកិច្ច

ដំណើរការសវនាការ។

បាទ, សូមអញ្ជើញ!

[០៩:០៣:១៩]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក ផាត់ ពៅស៊ាង៖**

ខ្ញុំបាទសូមគោរពលោកប្រធាន និងលោក លោកស្រីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងជាថ្មីម្តងទៀត។ គឺនិងសូមគោរពខាងអង្គសវនាការទាំងមូល និងសូមគោរពលោកវេជ្ជបណ្ឌិតខាងផ្នែកជំនាញទាំងពីររូបបាទ សូមគោរព។

**ស៖** ខ្ញុំបាទមានសំណួរប្រាំ ដើម្បីសួរទៅហៅថា លោកវេជ្ជបណ្ឌិត ដើម្បីបំភ្លឺឲ្យខ្ញុំបាទ គឺថាសំណួរទីមួយ ខ្ញុំបាទសូមសួរបញ្ជាក់ថា តើលោកវេជ្ជបណ្ឌិតបានជួបជាមួយនឹងអ្នកស្រី អៀង ធីរិទ្ធ ចំនួនប៉ុន្មានលើក?

**លោក ហ្វួត លីនណា៖**

**ឆ៖** ក្រុមជំនាញយើងខ្ញុំបានជួបលោកស្រី អៀង ធីរិទ្ធ ចំនួនបីលើកបាទ។

**ស៖** ក្រោយពីបានជួប ហើយតើលោកពិនិត្យឃើញជំងឺរបស់អ្នកស្រី អៀង ធីរិទ្ធ ដូចរបាយ-ការណ៍របស់លោកឌុកទ័រ ចន ខាំប៉ែល ដែរឬទេ?

[០៩:០៤:៤៦]

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** បាទ, យើងបានរកឃើញថា ស្ថានភាពសុខភាពរបស់គាត់គឺមានស្ថិរភាព ហើយតាមទស្សនៈរបស់យើង គឺថាបញ្ហានេះគឺឆ្លើយតបទៅតាមរោគវិនិច្ឆ័យ ហើយយើងមើលចំណុចលម្អិតទាក់ទងទៅនឹងបញ្ហាដែលគាត់ឆ្លើយទៅនឹងសំណួរមួយចំនួន ដែលយើងសួរទាក់ទងទៅនឹងការចងចាំរបស់គាត់ផងដែរ។

**ស៖** អ៊ីចឹងតាមអនុសាសន៍របស់លោក ដុកទ័រ ចន ខាំប៉ែល គាត់ឲ្យបន្ថយថ្នាំចំនួនពីរប្រភេទ គឺថ្នាំរម្ងាប់អារម្មណ៍ ហើយនិងថ្នាំដើម្បីសម្រួលនូវហៅថា ដំណេក គឺក្រោយពីបានបន្ថយនូវថ្នាំទាំងពីរមុខនេះ តើលោកបានពិនិត្យឃើញថាជំងឺភ្លេចភ្លាំង និងវង្វេងស្មារតីរបស់អ្នកស្រី អៀង ធីរិទ្ធ មានការធូរស្រាលទេបាទ?

**លោក ហួត លីនណា៖**

**ឆ៖** តាមរបាយការណ៍ពីគ្រូពេទ្យដែលពិនិត្យលោកស្រី អៀង ធីរិទ្ធ ជាប្រចាំនោះ ហើយគាត់បានកត់សម្គាល់ឃើញថា ក្រោយពីអនុសាសន៍របស់លោកសាស្ត្រាចារ្យ ខាំប៉ែល ដែលឲ្យគាត់បន្ថយ ហើយផ្តាច់ថ្នាំងងុយគេងពីរមុខនោះ គាត់សម្គាល់ឃើញថា-- គាត់សង្កេតឃើញថាពីមុនគាត់គេងបាន គាត់សម្រាកបានពីប្រាំបីទៅប្រាំបួនម៉ោង តែដល់ពេលក្រោយពីបន្ថយមកគាត់សម្រាកបានប្រាំមួយម៉ោង។

[០៩:០៦:៣០]

ហើយថ្នាំមួយទៀតដែលលោកសាស្ត្រាចារ្យ ខាំប៉ែល ឲ្យបន្ថយ ហើយផ្តាច់ហ្នឹងគឺពួកថ្នាំប្រភេទគេហៅថា *អែនធី-សាយខលទីក* (anti-psychotic) គឺជាប្រភេទថ្នាំព្យាបាលអាកប្បកិរិយាដែលកាចខឹង ឬក៏ជំងឺវិកលចរិតនោះ ឃើញថាក្រោយពីផ្តាច់ទៅអត់មានរោគសញ្ញាវិកលចរិតឡើងវិញ។ ហើយទាក់ទងនឹងបញ្ហាស្មារតីរបស់គាត់ហ្នឹងអត់មានឃើញប្រែប្រួលអ្វីទេ។ ហើយអានេះតាមៗអ្នកដែលបានតាមដានគេពិនិត្យឃើញអ៊ីចឹង។

**ស៖** សំណួរទីបួន គឺតាមការបញ្ជាក់របស់លោក ហ៊ុន ចំរើន ថាជំងឺភ្លេចភ្លាំងនិងជំងឺវង្វេងវង្វាន់របស់អ្នកស្រី អៀង ធីរិទ្ធ គឺថារឹតតែចុះខ្សោយថែមទៀត តើលោកពិនិត្យឃើញដូចការអះអាងរបស់លោកវេជ្ជបណ្ឌិត ហ៊ុន ចំរើន ដែរឬទេ?

[០៩:០៧:៤១]

**ឆ៖** បើតាមលោក ហ៊ុន ចំរើន បានមាន-- បានកត់សម្គាល់ឃើញថាតាំងពីគាត់ជួបលោកស្រី អៀង ធីរិទ្ធ មកគឺថាគាត់ឃើញ សង្កេតឃើញថាបញ្ហាស្មារតីគាត់ហ្នឹងឃើញមានការថយចុះ ហើយចំណែកឯលោកនៅខាងប្រធានមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក គាត់សង្កេតឃើញអ៊ីចឹងដែរ។ ហើយចំណែកខាងក្រុមជំនាញយើងខ្ញុំក៏បាន-- មិនបានតាមដានគាត់ពីមុនមកទេ គឺថាយើងបានពិនិត្យគាត់នៅពេលដែលជួបគាត់តែម្តង ហើយយើងមានតេស្តដែលខ្ញុំបាទ ដូចបានជម្រាបពីម្សិលមិញអ៊ីចឹងឃើញថាបញ្ហាស្មារតីនេះគឺថា គាត់ធ្លាក់ចុះមកដល់ត្រឹមកម្រិតមធ្យម នៅក្នុងហ្នឹងវាមានកម្រិតស្រាល កម្រិតមធ្យម និងកម្រិតធ្ងន់ធ្ងរ ហើយយើងសង្កេតឃើញ កត់សម្គាល់ យើងរកឃើញថា បញ្ហាស្មារតីគាត់ហ្នឹងធ្លាក់នៅក្នុងកម្រិតមធ្យម។

[០៩:០៨:៤៦]

**ស៖** អាហ្នឹង-- នេះគឺជាសំណួរចុងក្រោយរបស់ខ្ញុំគឺថា តាមការឆ្លើយបំភ្លឺរបស់លោកជូនអ្នកស្រីចៅក្រមម៉្សិលមិញ លោកបាន-- បើខ្ញុំមិនច្រឡំទេ គឺថាលោកបានជម្រាបជូនអ្នកស្រីចៅក្រមថាអ្នកស្រី អៀង ធីរិទ្ធ មានលទ្ធភាពយល់ដឹងអំពីនីតិវិធី អំពីបទចោទ និងអំពីការផ្តល់សក្ខីកម្ម។ ប៉ុន្តែខ្ញុំបានពិនិត្យមើលនៅក្នុងហៅថា កថាខណ្ឌ៥១ នេះ លោកបានសរសេរថា លោកស្រី អៀង ធីរិទ្ធ មិនមានការយល់ដឹងគ្រប់គ្រាន់ទេ។ ដូច្នេះ ខ្ញុំស្នើសុំថា លោកបញ្ជាក់ឡើងវិញមើលថាតើការបំភ្លឺរបស់លោកម៉្សិលមិញហើយនិងកថាខណ្ឌ៥១ ហ្នឹង វាស្របគ្នា និងផ្ទុយគ្នាយ៉ាងដូចម្តេចដែរ?

សូមអរគុណ។

[០៩:០៩:៤២]

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** ខ្ញុំមិនគិតថា យើងបាននិយាយថាគាត់មានលទ្ធភាពតាមដានដំណើរការនីតិវិធីនោះទេ ពីម៉្សិលមិញនោះ។ យើងបាននិយាយថា គាត់មានការយល់ដឹង ការចោទប្រកាន់ ហើយគាត់មានលទ្ធភាពនឹងផ្តល់សក្ខីកម្ម ប៉ុន្តែយើងមានទស្សនៈថា គាត់មានការលំបាកខ្លាំងក្នុងការយល់ដំណើរការនីតិវិធី ពីព្រោះថាការចុះខ្សោយសតិបញ្ញាការចងចាំរបស់គាត់។ មិនមានន័យថា គាត់មិនមានលទ្ធភាពក្នុងការរក្សាទុកព័ត៌មានដែលគាត់បានស្តាប់ក្នុងរយៈពេលវែងមួយ ដើម្បីឲ្យគាត់មានលទ្ធភាពថានឹងឆ្លើយតប ហើយអាចគិត ហើយនិងផ្តល់មតិយោបល់លើព័ត៌មានដែលគាត់បានស្តាប់ ឬក៏អាចគាត់អាចនឹងពិភាក្សាជាមួយនឹងមេធាវីបាននោះទេ។

ដូច្នេះទស្សនៈរបស់យើង គឺថាលទ្ធភាពរបស់គាត់ក្នុងការយល់ដំណើរការនីតិវិធីនោះ គឺត្រូវបានចុះខ្សោយ គឺមិនគ្រប់គ្រាន់ ហើយយើងមានគំនិតថា គាត់នឹងមានការលំបាកក្នុងការតាមដានដំណើរការនីតិវិធី។

**ស៖** សូមអរគុណ។

លោកប្រធាន ខ្ញុំអស់សំណួរហើយ ហើយខ្ញុំស្នើសុំបន្តជូនទៅមេធាវីអន្តរជាតិដើម្បីបន្ត។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សូមអញ្ជើញលោកស្រីមេធាវី!

**សួរដោយលោកស្រី ដាយអាណា អេលីស៖**

សូមលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រមជាទីគោរព!

**ស៖** លោកវេជ្ជបណ្ឌិត ហ្វាស៊ែល ម្សិលមិញលោកបាននិយាយថា លោកគឺជាអ្នកជំនាញនីតិកោសល្យវិច័យ តើលោកយល់ដូចម្តេច? លោកអាចពន្យល់បានដូចម្តេចអំពីមុខងារនេះ?

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** មានន័យថា ខ្ញុំៗទទួលការបណ្តុះបណ្តាលខាងជំនាញនៅក្នុងៗការវាយតម្លៃការព្យាបាលជនជាប់ចោទ ដែលមានជំងឺវិកលចរិត និងមានន័យថាខ្ញុំធ្វើការនៅក្នុងមន្ទីរពេទ្យរបស់អ្នកជំងឺមួយចំនួនដែលថាមានហានិភ័យនៅក្នុងការព្យាបាលអ្នកដែលមានទោស ឬក៏អ្នកដែលរងការចោទប្រកាន់ ហើយក៏ខ្ញុំបានធ្វើការនៅក្នុងមន្ទីរពេទ្យ ធ្វើការវាយតម្លៃ និងព្យាបាលអ្នកទោស ហើយអ្នកដែលមានពិរុទ្ធភាពនោះដែរ។

[០៩:១២:១៥]

**ស៖** តើលោកអាចបង្ហាញ តើបទពិសោធន៍របស់លោកច្រើនប៉ុនណាទាក់ទងទៅនឹងការព្យាបាលខាងផ្លូវវេជ្ជសាស្ត្រ ឬក៏ថាព្យាបាលជំងឺចាស់ជរានោះ មនុស្សចាស់នោះ?

**ឆ៖** បាទ, ខ្ញុំមិនអាចថាជាអ្នកជំនាញខាងព្យាបាលជំងឺចាស់ជរា មនុស្សចាស់នោះទេ ប៉ុន្តែការទទួលការបណ្តុះបណ្តាលជាពេទ្យវិកលវិទ្យានេះ គឺថាខ្ញុំបានទទួលការបណ្តុះបណ្តាលខាងផ្នែកមនុស្សចាស់ ប្រហែលជាបីខែ ហើយក៏បានធ្វើការស្រាវជ្រាវប្រាំមួយខែក្នុងវិស័យនេះ ហើយខ្ញុំក៏អាចនឹងមានឧបករណ៍គ្រប់គ្រាន់ដើម្បីវាយតម្លៃអំពីអ្នកជំងឺ ដែលមានជំងឺប្រភេទនេះបានដែរ។ ហើយយើងបានបោះពុម្ពផ្សាយអត្ថបទសារព័ត៌មានជាច្រើនទាក់ទងនឹងបញ្ហានេះ។

[០៩:១៣:១៤]

ការបណ្តុះបណ្តាលជាមូលដ្ឋានរបស់ខ្ញុំចប់មក ខ្ញុំធ្វើការពីរឆ្នាំ ពិនិត្យមើលរោគវិនិច្ឆ័យអ្នកទោសដែលមានវ័យចាស់ៗ ជាពិសេសបានទៅដល់២០០នាក់ឯណោះ ហើយពិនិត្យមើលជំងឺហៅថា *ឌីមែនស្យា* (dementia) ដែលថាវង្វេងវង្វាន់ស្មារតីនេះឯង។ ហើយជាពិសេស ទាក់ទងទៅនឹងរឿងនេះខ្ញុំបានធ្វើការស្រាវជ្រាវ ហើយនិងសរសេរអត្ថបទជាច្រើនទាក់ទងនឹងបញ្ហានេះ។

បញ្ហានេះ គឺខ្ញុំចូលរួមក្នុងការសម្ភាសន៍ទាក់ទងទៅនឹងរោគវិនិច្ឆ័យពិនិត្យមើលថាតើបុគ្គលនីមួយៗនោះមានជំងឺ *ឌីមែនស្យា* ដែលថាវង្វេងវង្វាន់ស្មារតីដែរឬទេ? ហើយនៅក្នុងអំឡុងការងារនេះ ខ្ញុំបាន

ទទួលការបណ្តុះបណ្តាលប្រហែលជាមួយឆ្នាំទាក់ទងទៅនឹងការ ខាងវិស័យកោសល្យវិទ្យានេះ។

ខ្ញុំមានបទពិសោធន៍មួយចំនួន ខ្ញុំមិនអាចឱ្យគេហៅថាខ្ញុំជាអ្នកជំនាញខាងជំងឺមនុស្សចាស់នោះទេ ប៉ុន្តែខាងវិកលវិទូ ផ្នែកមនុស្សចាស់។

**ស៖** តើលោកអាចយោងទៅរកសាស្ត្រាចារ្យ ខាំប៉ែល ទាក់ទងទៅនឹងបញ្ហាការវាយតម្លៃខាងព្យាបាលអ្នកជំងឺមនុស្សចាស់ដែលមានរោគហៅថា *ឌីមែនស្យា* ជំងឺវង្វេងវង្វាន់ដែលមានបទពិសោធន៍ជាច្រើនឆ្នាំនោះ?

[០៩:១៤:៤៩]

**ឆ៖** ខ្ញុំមុននឹងយោងទៅសាស្ត្រាចារ្យ ខាំប៉ែល ទាក់ទងទៅនឹងការព្យាបាល ចំពោះការវាយតម្លៃវិញ ហើយអាចនឹងបំពេញបន្ថែមគ្នាទៅវិញទៅមកបាន។ ហើយបទពិសោធន៍របស់គាត់ជាអ្នកជំនាញគ្រូពេទ្យព្យាបាលមនុស្សចាស់នោះ គឺថា គាត់អាចបំពេញបន្ថែមមកជំនាញរបស់យើងជាអ្នកគ្រូពេទ្យខាងវិកលវិទ្យា។ អ៊ីចឹងហើយគឺថា ការពិនិត្យលើអ្នកជំងឺម្នាក់ៗ យើងអាចបំពេញបន្ថែមទៅវិញទៅមកបាន។

**ស៖** អ៊ីចឹង ខ្ញុំចង់សួរសំណួរបន្ថែមទាក់ទងទៅនឹងវិធីដែលលោកបានសម្ភាសន៍អ្នកស្រី អៀង ធីរិទ្ធ នោះ តើប្រើវិធីសាស្ត្រដូចម្តេច? លំដាប់លំដោយដែលលោកបានប្រើនោះ គឺហើយនៅក្នុងឯកសារ E111/5 ដែលថា ជនជាប់ចោទគប្បីត្រូវនាំមកបន្ទប់តូចមួយនៅក្នុងសវនាការ ដើម្បីនឹងសម្ភាសន៍។ លោកបានប្រាប់យើងថា លោកបានជួបគាត់បីដង។ ពីរដងនៅក្នុងបន្ទប់របស់គាត់ ហើយម្តងនៅក្នុងបន្ទប់ប្រជុំនៅក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក។ តើហេតុអ្វីបានជាជួបដាច់ដោយឡែកពីគ្នាពីរកន្លែងដូច្នេះ?

**ឆ៖** បាទ, យើងយល់ថា ក្នុងការពិភាក្សាបឋមនៅក្នុងក្រុមការងារ យើងគប្បីសម្ភាសគាត់នៅក្នុងកន្លែងមួយដែលមានន័យថា គាត់អាចមានអារម្មណ៍សុខស្រួល ជាជាងនាំគាត់មកសាលសវនាការ ឬបន្ទប់នៅតុលាការនេះ។ ហើយវាអាចនឹងមានប្រយោជន៍ក្នុងន័យដែលថា ដើម្បីៗមានលទ្ធភាពនិយាយជាមួយគាត់ក្នុងរយៈពេលវែង។ អ៊ីចឹងយើងយល់ថា ការវាយតម្លៃគាត់នៅក្នុងបរិស្ថានដែលគាត់ស៊ាំកន្លែងដែលគាត់ស៊ាំនោះ គឺថាអាចជាចំណុចដែលមានប្រយោជន៍សម្រាប់គាត់ ហើយគាត់មានអារម្មណ៍ស្រួល ហើយគាត់មានផាសុកភាពក្នុងការឆ្លើយតប ដើម្បីឱ្យប្រាកដថា គាត់មិនស្ថិតនៅក្នុងបរិស្ថានមួយដែលធ្វើឱ្យគាត់យល់ច្រឡំ ឬក៏ភ័ន្តភាំងអារម្មណ៍នោះ។

[០៩:១៧:២៥]

**ស៖** អ៊ីចឹងហើយលោកបានជ្រើសរើសយកបរិស្ថានមួយដែលល្អបំផុត ដើម្បីចៀសវាងកុំឲ្យគាត់បាត់ការចងចាំ ឬក៏ភ័ន្តច្រឡំ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ, ត្រឹមត្រូវហើយ ប៉ុន្តែដើម្បីនឹងបង្កើតនូវស្ថានភាពមួយដែលជួយគាត់ដើម្បីឲ្យគាត់មានលទ្ធភាព បើសិនជាកុំឲ្យគាត់មានអារម្មណ៍ថា នៅបន្ទប់តុលាការគាត់អាចមានអារម្មណ៍ផ្សេង។ អ៊ីចឹងហើយបានជាយើងធ្វើបែបនេះ។

**ស៖** អ៊ីចឹងការសម្ភាសទីមួយ គឺធ្វើឡើងនៅថ្ងៃរសៀល តើនៅក្នុងបន្ទប់របស់គាត់ ឬនៅក្នុងបន្ទប់ប្រជុំនៅកន្លែងមន្ទីរឃុំឃាំង?

**ឆ៖** ការជួបនោះនៅបន្ទប់របស់គាត់។

[០៩:១៨:២០]

**ស៖** ការសម្ភាសដែលធ្វើឡើងនៅពេលព្រឹក នៃថ្ងៃ១៣ កញ្ញា តើនៅកន្លែងណា?

**ឆ៖** ការប្រជុំនោះនៅក្នុងបន្ទប់ប្រជុំ។

**ស៖** អ៊ីចឹងគឺថាការប្រជុំនៅពេលល្ងាចជួបជាមួយគាត់ៗនោះនៅបន្ទប់របស់គាត់?

**ឆ៖** បាទ។

**ស៖** អ៊ីចឹង ហើយយើងមើលឱកាស តើអ្នកជំនាញទាំងបួនរូប ឬវេជ្ជបណ្ឌិតទាំងបួននោះមានវត្តមានទាំងអស់ ឬទេ?

**ឆ៖** ខ្ញុំមិនអាចចងចាំជាក់លាក់ទេ គឺថាជាទូទៅគឺយើងមានទាំងបីនាក់ ប៉ុន្តែនៅក្នុងជំនួបមួយប្រហែលជាចុងក្រោយនៅពេលល្ងាចនោះនៃថ្ងៃទីពីរ សមាជិកម្នាក់ប្រហែលជាមិនបានវត្តមាននៅក្នុងពេលចាប់ផ្តើមសម្ភាសន៍ទេ។ មួយផ្នែកដោយហេតុថា ទីកន្លែងនោះវាចង្អៀតពេកនៅក្នុងបន្ទប់ឃុំខ្លួនរបស់គាត់នោះ។ ប៉ុន្តែអ្នកជំនាញនោះ គឺមានការព្រមព្រៀងពី អៀង ធីរិទ្ធ គាត់បានចូលរួមក្រោយបន្ទាប់មក ពីយើងបានជួបមួយភ្លែតមកនោះ។

**ស៖** លោកវេជ្ជបណ្ឌិត លីនណា តើលោកមានអ្វីបន្ថែមទៅនឹងចម្លើយនេះទេ?

**លោក ហ្វួត លីនណា៖**

**ឆ៖** ខ្ញុំដូចអត់ទាន់មានទេបាទ។

[០៩:២០:០០]

**ស៖** នៅពេលដែលលោកសួរសំណួរទៅលោកស្រី អៀង ធីរិទ្ធ នោះ តើសំណួរទាំងអស់នោះអ្នកដដែលជាអ្នកសួរ ឬក៏អ្នកជំនាញម្នាក់ៗ សួរសំណួរខុសៗគ្នា នៅពេលខុសៗគ្នា?

**ឆ៖** សំណួរនេះដូចជា *មីនីមេនសិន ស្តេត អ៊ិចសាមីណេសិន (MMSE)* គឺការដែលសួរធ្វើតេស្តរកកម្រិតនៃៗបញ្ញាស្មារតីនេះ គឺថាខ្ញុំសួរដដែល ដើម្បីចៀសវាងគឺថា កុំឲ្យមានភាពលម្អៀង ហើយសំណួរផ្សេងៗទៀតហ្នឹង គឺដុកទ័រផ្សេងៗទៀតហ្នឹង គាត់បានសួរ។ បាទ, គាត់បានសួរ។ និយាយរួមទៅគឺថា យើងទាំងអស់ ទាំងបួនបានសួរសំណួរទាំងអស់គ្នា។ ដូចជាសំណួរទាក់ទងនឹងបញ្ញាស្មារតីគឺថាខ្ញុំលើកៗ ខ្ញុំសួរទាំងពីរថ្ងៃ សួរដដែលគឺពីរថ្ងៃ។

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** ឆ្លើយតបទៅនឹងសំណួររបស់លោកស្រីមេធាវី យើងពីរនាក់ជាអ្នកដឹកនាំ គឺខ្ញុំនិងដុកទ័រលីនណា ហើយ ប៉ុន្តែសហសេវិកយើងពីររូបទៀតជាអ្នកបំពេញបន្ថែម គឺនៅក្នុងចំណុចនីមួយៗដែលពួកគាត់យល់ឃើញថា ចង់ឲ្យមានការបំភ្លឺគាត់ចូលមកសួរ។ ហើយអ៊ីចឹងជាទូទៅយើងព្យាយាមរៀបចំការសម្ភាសន៍ដែលថាមនុស្សដដែលជាអ្នកចាប់ផ្តើម។ អ៊ីចឹងហើយគឺយើងខ្ញុំទាំងពីរនាក់ជាអ្នកចាប់ផ្តើមនាំមុខនោះ។

**ស៖** តើការសម្ភាសន៍នោះបានថតសំឡេងដែរឬទេ?

**ឆ៖** អត់ទេ។

**ស៖** តើលោកទាំងពីរនាក់នោះ គឺថាបានកត់ត្រាគ្រប់យ៉ាងអំពីអ្វីៗដែលបានសម្ភាសដែរឬទេ?

[០៩:២២:១៥]

**ឆ៖** ខ្ញុំបានកត់ត្រា។ បាទ, ខ្ញុំបានកត់ត្រា។

**លោក ហួត លីនណា៖**

**ឆ៖** ហើយខ្ញុំសូមបន្ថែមបន្តិច ខ្ញុំពេលខ្លះក៏ខ្ញុំបានកត់ ប៉ុន្តែពេលដែលខ្ញុំសួរ ខ្ញុំក៏បានកត់ខ្លះ ហើយសហការីរបស់ខ្ញុំក៏បានកត់។ និយាយរួមទៅយើងកត់បានទាំងអស់គ្នា។

**ស៖** តើក្នុងចំណោមលោកទាំងពីរនាក់ តើនរណាម្នាក់ជាអ្នកចងក្រងប្រមូលផ្តុំរបាយការណ៍ដែលដាក់ជូនតុលាការ ហើយនិងដាក់ជូនមកយើងខ្ញុំនេះ?

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** តាមការចងក្រងរបាយការណ៍ហ្នឹង តើលោកមានន័យថាជាអ្នករៀបចំ?

**ស៖** ខ្ញុំមានន័យថា ការធ្វើសេចក្តីព្រាងរបាយការណ៍។

**ឆ៖** បាទ, ខ្ញុំជាអ្នកធ្វើសេចក្តីព្រាង។

**ស៖** តើលោកធ្វើសេចក្តីព្រាង ហើយលោកបានប្រើសេចក្តីព្រាងហ្នឹងបញ្ជូនទៅវេជ្ជបណ្ឌិតបីនាក់ផ្សេងទៀតដើម្បីឲ្យពួកគាត់ពិចារណាដែរឬទេ?

**ឆ៖** បាទ។

**ស៖** តើក្រោយពីដំណើរការឲ្យគាត់ពិនិត្យរួច ថាតើមានការកែតម្រូវ ឬការបន្ថែមទៅលើសេចក្តីព្រាងៗដំបូងរបស់លោកដែរឬទេ?

**ឆ៖** បាទ, មាន។

**ស៖** តើមានព័ត៌មានណាមួយ ឬក៏បញ្ហាពាក់ព័ន្ធណាមួយដែលត្រូវបានដកចេញៗពីរបាយការណ៍នៅពេលដែលរបាយការណ៍ចុងបញ្ចប់ចេញមកនោះ?

[០៩:២៤:១៤]

**ឆ៖** ចំពោះខ្ញុំ តាមដែលខ្ញុំចាំគឺមិនមានទេការកែប្រែនោះ គឺតាមពិតគឺជាការបន្ថែមនូវផ្នែកហើយថែមនូវសេចក្តីលម្អិតមួយចំនួន។ នេះជាការចងចាំរបស់ខ្ញុំ គឺមិនមានអ្វីជាការកែប្រែ ឬក៏ការលុបចោលចំណុចសំខាន់ណានោះទេ។

**ស៖** លោកបានប្រាប់យើងថា ការងារមួយផ្នែករបស់លោកនោះគឺ លោកបាននិយាយជាមួយដុកទ័រ ហ៊ុន ចំរើន អំពី-- ហើយនិងម្នាក់ទៀតដែលជាអ្នកថែទាំគាត់ ហើយលោកបាននិយាយជាមួយលោក ម៉ៅ សុភារម្យ ដែលជាប្រធានមន្ទីរឃុំឃាំង អ.វ.ត.ក តើការសន្ទនានោះ កើតឡើងមុនពេលសម្ភាសន៍លើកដំបូងទាំងបីរបស់លោកដែរឬទេ?

**ឆ៖** យើងបានជួបជាមួយ ឌុកទ័រ ចំរើន ហ្នឹង គឺមុនជួបលោកស្រី អៀង ធីរិទ្ធ ហើយការជួបជាមួយលោក សុភារម្យ នោះ គឺបានកើតឡើងមុនការសម្ភាសថ្ងៃទី២។ អ៊ីចឹងរវាងសម្ភាសទី១ និងសម្ភាសទី២។

**ស៖** ខ្ញុំពិនិត្យមើលទំព័រទីបួន កថាខណ្ឌ១០ ក្នុងរបាយការណ៍របស់លោក។ អ្វីដែលយើងបានឃើញគឺថានៅក្នុងកថាខណ្ឌ១០នេះ គឺមានចំណុចមួយចំនួនគឺជាការពិចារណារបស់លោកទៅលើរយៈកាលដែលក្នុងរបាយការណ៍នោះ ដែលគួរតែមានការចុះខ្សោយសតិបញ្ញា តើអ៊ីចឹងដែរឬទេ?

**ឆ៖** ខ្ញុំបញ្ជាក់ថា នេះគឺជាសេចក្ដីសង្ខេបនៃប្រវត្តិសុខភាពដែលយើងបានយល់។ ប៉ុន្តែយើងសង្កត់ទៅលើបញ្ហាសុខភាពរាងកាយ ហើយនិងបញ្ហាផ្សេងទៀត ដែលអាចកត់សម្គាល់បានខាងប្រវត្តិសុខភាពតែប៉ុណ្ណឹង។

[០៩:២៦:៣៩]

**ស៖** អ្វីដែលលោកកត់សម្គាល់នៅក្នុងកថាខណ្ឌទី១០ហ្នឹង គឺរោគវិនិច្ឆ័យនៃថាមានជំងឺវិបល្លាសផ្លូវចិត្តដែលបណ្ដាលមកពីផ្នែកសរីរាង្គដែលគេបានរកឃើញថាមានការបាក់ឆ្អឹងត្រគាកនៅឆ្នាំ២០០៦។

**ឆ៖** ដូចដែលបានរៀបរាប់នៅក្នុងចំណុចទី១០ នោះឯង។

**ស៖** ហើយនៅក្នុងកថាខណ្ឌនេះ គឺថាបញ្ហានេះកើតឡើងនៅឆ្នាំ២០០៧ ខែវិច្ឆិកា ហើយដល់ឆ្នាំ២០០៨ ហើយអាកប្បកិរិយារបស់គាត់មានការរំខានរហូតដល់ឆ្នាំ២០០៩ ដល់ ២០១០ តើលោកបានកត់សម្គាល់ឃើញអ៊ីចឹង តើជារឿងត្រូវទេ?

**ឆ៖** បាទ។

**ស៖** លោកបានប្រាប់យើងថា លោកបានមើលតែស្កេនខួរក្បាល ឯកសារស្កេនខួរក្បាលរបស់គាត់តែបីទេ។ ហើយគេបានផ្ដល់ឯកសារមួយចំនួនដែលរៀបចំឡើងដោយមេធាវីការពារ E111/3.2 ហើយតាមឯកសារនេះ គឺជាសេចក្ដីសង្ខេបអ្វីដែលមេធាវីយើងយល់ ថាចំណុចសំខាន់នៅទីនេះ នៅក្នុងកំណត់ត្រានៃមន្ទីរពេទ្យអន្តរជាតិបំរុងរ៉ាត់ នៅបាងកក នោះ ដែលគេបញ្ជាក់-- គាត់ទទួលការព្យាបាលនៅកន្លែងហ្នឹង ក្នុងមួយរយៈកាល។ តើលោកនឹកឃើញថា បានពិនិត្យឯកសារហ្នឹងដែរឬទេ?

[០៩:២៨:២០]

**ឆ៖** ខ្ញុំចាំថា យើងមានឯសារដែលដាក់តាំង-- សំណួរដែលមេធាវីបានស្នើឡើងហ្នឹង គឺយើងបានមើល។

**ស៖** ខ្ញុំនឹងពិនិត្យមើលចំណុចមួយដែលលោកបានពិនិត្យ តើលោកបានវាយតម្លៃដែរឬទេ? គឺថាឯកសារដែលបានបង្ហាញនៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៦ អៀង ធីរិទ្ធ ត្រូវបានចូលព្យាបាលទៅមន្ទីរពេទ្យនោះ ហើយគេកត់សម្គាល់ឃើញថា គាត់បានប្រើថ្នាំមួយចំនួន ដូចជាថ្នាំ កេត្យាពីន(quetiapine) ហាឡូផារ៉ាដុល (haloperidol), ជាប្រភេទថ្នាំ ក្លូណាហ្សេប៉ាម (clonazepam) ហើយនិងថ្នាំមួយទៀត គឺ ប៊ិនហ្សូដាយអ៊ីហ្សេពីន (benzoldiazepine) ផងដែរ។ លោកបានប្រាប់យើងថា កេត្យាពីន នេះ គឺជាថ្នាំព្យាបាលជំងឺផ្លូវចិត្តសាស្ត្រ តើមែនទេ?

[០៩:២៩:៣០]

**ឆ៖** បាទ។

**ស៖** *ហាឡូផារ៉ាដុល* តើគេប្រើសម្រាប់អីដែរថ្នាំហ្នឹង?

**ឆ៖** ហើយថ្នាំនេះ ក៏ជាថ្នាំប្រឆាំងនឹងជំងឺផ្លូវចិត្ត ដើម្បីបញ្ជាក់ដល់លោកស្រីឲ្យច្បាស់ថា គឺជាចំណាត់ថ្នាក់ថ្នាំដែលស្ថិតនៅក្នុងថ្នាំព្យាបាលជំងឺវិកលចរិត ដែលជាថ្នាំធ្វើឲ្យរម្ងាប់អារម្មណ៍ខ្លាំង។ ហើយពេលខ្លះ គឺថាយើងប្រើដើម្បីព្យាបាលអ្នកដែលមានកាយវិការធ្ងន់ធ្ងរ ដូចថា ដូចជាអ្នកមានជំងឺអាកប្បកិរិយាថប់អារម្មណ៍ខ្លាំង កាចខ្លាំង។

**ស៖** ចំពោះថ្នាំ*ក្លូណាហ្សេប៉ាម*វិញ ថាតើធ្វើឲ្យព្យាបាលជំងឺកុំឲ្យមានការគេងមិនលក់ដែរឬទេ?

**ឆ៖** បាទ គឺតាមពិត គឺដើម្បីធ្វើឲ្យបញ្ហាអាកប្បកិរិយាហ្នឹងរម្ងាប់មកទៅលើបុគ្គល។

**ស៖** ចំពោះអ្វីដែលលោកនិយាយនេះ តើត្រូវទេដែលយើងអាចសន្និដ្ឋានថា នៅពេលក្នុងការដែលគាត់ចូលសម្រាកនៅមន្ទីរពេទ្យថ្ងៃទី៥ មករា នោះ គឺគ្រូពេទ្យព្យាបាលគាត់អំពីការព្យាបាលកាយវិការ ឬក៏អាកប្បកិរិយាដ៏រំខានរបស់គាត់។ តើមែនទេ?

**ឆ៖** គឺថា ខ្ញុំគិតថា យើងមានការលំបាកក្នុងការផ្តល់យោបល់រឿងហ្នឹង ដោយមិនបានឃើញកំណត់ត្រា ហើយនិងចំណុចដែលគេ គ្រូពេទ្យដែលបញ្ជាក់ពីចំណុចនេះ ទាក់ទងទៅនឹងការជំនឿ--ព្យាបាលជំងឺរោគវិនិច្ឆ័យនេះ។ ដូច្នេះ ខ្ញុំមានការលំបាកក្នុងការយល់ថា ហេតុអ្វីបានគេប្រើថ្នាំពេទ្យនេះ គ្រូពេទ្យបានចេញឲ្យប្រើថ្នាំពេទ្យនេះ ដោយយើងមិនបានឃើញនូវរោគវិនិច្ឆ័យដំបូង ដែលគ្រូពេទ្យបានចេញវេជ្ជបញ្ជា។

[០៩:៣១:៣១]

**ស៖** ប៉ុន្តែលោកយល់ថានេះជាថ្នាំខ្លាំងដែលខ្លាំងសម្រាប់ធ្វើឲ្យរម្ងាប់អារម្មណ៍ដែលមានបញ្ហា។ តើមែនទេ?

**ឆ៖** អត់ទេ គឺខ្ញុំមិនអាចទស្សន៍ទាយដូច្នោះនោះទេ។ ថ្នាំទាំងអស់នេះអាចចេញដោយសារអាកប្បកិរិយា ក៏ប៉ុន្តែវាអាចពាក់ព័ន្ធទៅនឹងហេតុផលមួយចំនួនផ្សេងទៀត ក៏ប៉ុន្តែដោយសារមិនមានព័ត៌មានគ្រប់គ្រាន់នោះ ខ្ញុំមិនអាចរៀបរាប់បានទេ។

**ស៖** ពាក់ព័ន្ធទៅនឹងបញ្ហារម្ងាប់ផ្លូវចិត្ត ឬក៏បញ្ហាអាកប្បកិរិយា តើថ្នាំហ្នឹងគេចេញដោយសារហេតុផលផ្សេងទៀតដែរឬទេ?

**ឆ៖** បាទ, គឺដូច្នោះមែន។ ថ្នាំទាំងពីរប្រភេទនោះគឺអាចជួយឲ្យគេងលក់ស្រួល ហើយនិងបញ្ហាដែលវាគប់អារម្មណ៍ផងដែរ។ ដូច្នេះហើយវាអាចមានលទ្ធភាពមួយទៀត ដែលថា ថ្នាំហ្នឹងអាចប្រើប្រាស់សម្រាប់-- ថ្នាំទាំងអស់នោះអាចចេញដោយមានលក្ខណៈផ្សេងផងដែរ។ ដូច្នេះហើយខ្ញុំមិនអាចធ្វើការសន្និដ្ឋានអំពីហេតុផលដែលគេចេញថ្នាំនោះឡើយ។

[០៩:៣២:៤២]

**សៈ** នៅថ្ងៃទី៦ ខែមករា លោកស្រី អៀង ធីរិទ្ធ បានធ្វើការថតស៊ីធីស្កេន លោកមិនបានមើលហ្វីលថតស្កេននោះទេ ដោយសារតែអត់មាន។ ក៏ប៉ុន្តែលោកបានមើលចំណុចកំណត់សម្គាល់សេចក្ដីយោង ដែលដាក់នៅក្នុងរបាយការណ៍លោកសាស្ត្រាចារ្យ កា ស៊ុនបូណាត និង ប្រេនឌីត នៅខែវិច្ឆិកាឆ្នាំ២០០៩។ ស៊ីធីស្កេននោះបានបង្ហាញអំពីការរួមតូចនៃខួរក្បាលធម្មតា។ តើលោកចាំទេចំណុចហ្នឹង?

**ឆ៖** ខ្ញុំមិនចាំថាបានអានឯកសារនោះទេ។ ខ្ញុំបានផ្ដោតទៅលើស្កេនដែលយើងខ្ញុំបានពិនិត្យមើល។ យើងក៏បានពិនិត្យមើលផងដែរ ហើយយើងមើលទៅលើបញ្ហាហ្វីលវេជ្ជសាស្ត្រ ក៏ប៉ុន្តែខ្ញុំមិនបានចាំច្បាស់លាស់ទៅលើចំណុចនោះទេ។

**សៈ** តើលោក ឯកភាពដែរឬទេថា ការប្រើថ្នាំប្រឆាំងរោគចិត្តទាំងពីរប្រភេទរួមទាំងការរួមតូចនៃខួរក្បាលធម្មតានោះ វាជាសញ្ញាបង្ហាញអំពីការចុះខ្សោយនៃសតិបញ្ញា តើដូច្នោះដែរឬទេ?

[០៩:៣៤:២៤]

**ឆ៖** អាច និងមិនអាច។ ការរួមតូចខួរក្បាលធម្មតា វាអាចមានភាពស៊ីសង្វាក់គ្នា ហើយជាការពិត អាយុរបស់បុគ្គលនោះវាអាចឲ្យកើតមានបញ្ហានេះ ហើយវាអាចជួយឲ្យមានការចុះថយនៃការចងចាំ។ ប៉ុន្តែវាអាស្រ័យទៅលើពាក្យដែលគេប្រើប្រាស់តែប៉ុណ្ណោះ។ ខ្ញុំមិនគិតថា ថ្នាំទាំង-- ដែលបានចេញទាំងអស់នោះ នៅពេលដែលយើងទាញការសន្និដ្ឋាននោះ យើងមិនអាចធ្វើការសន្និដ្ឋានថាតើវាមានការចុះខ្សោយសតិបញ្ញា ឬក៏មិនចុះខ្សោយនោះទេ។ ក៏ប៉ុន្តែស៊ីធីស្កេនអាចបង្ហាញឲ្យខ្ញុំឃើញថា វាអាចមានការផ្លាស់ប្ដូរក្នុងលក្ខណៈធម្មតាចំពោះបុគ្គលក្នុងវ័យដូច្នេះ។ ដូច្នេះការផ្លាស់ប្ដូរនោះ វាមិនអាចឃើញថា មានធ្ងន់ធ្ងរនៅក្នុងវ័យនោះទេ។ ក៏ប៉ុន្តែ ប្រសិនបើមានការផ្លាស់ប្ដូរធ្ងន់ធ្ងរនោះ វាអាចមានបញ្ហានេះមែន។

**សៈ** ការយល់ឃើញរបស់វេជ្ជបណ្ឌិត ចំរើន និងលោក សុភារម្យ ដែលថា-- ដែលលើកឡើងថា ការចងចាំរបស់លោកស្រី អៀង ធីរិទ្ធ ហ្នឹងមានការចុះខ្សោយក្នុងរយៈពេលពីរឆ្នាំ។ ហើយលោក

ស្រី អៀង ធីរិទ្ធ បានរអ៊ូរទាំអំពីការភ្លេចភ្លាំង ដែលមានសរសេរនៅក្នុងកថាខណ្ឌ១៧ និង១៨។ លោកស្រី អៀង ធីរិទ្ធ ក៏បានលើកឡើងអំពីបញ្ហានៃការចងចាំរបស់គាត់ នៅពេលដែលគាត់ចូលមកក្នុងមន្ទីរឃុំឃាំងលើកដំបូង។ ដូច្នេះហើយនេះជាបញ្ហាលំបាក ដែលលោកស្រីហ្នឹងគាត់ជួបប្រទះក្នុងរយៈបួនឆ្នាំតាំងពីពេលមកក្នុងមន្ទីរឃុំឃាំងនេះ។ តើមែនដែរឬទេ?

[០៩:៣៦:៣៩]

**ឆ៖** ខ្ញុំឯកភាពថា ប្រវត្តិដើមរបស់គាត់នោះ គឺមានការចុះខ្សោយ។ ការចងចាំតាំងពីពេលដែលចូលមន្ទីរឃុំឃាំង។

**ស៖** ដូច្នេះបួនឆ្នាំមកហើយ? មែនទេ?

**ឆ៖** មែន។

**ស៖** ចំពោះលោក សុភារម្យ គឺគាត់បានដឹងអំពីមានអ្វីកើតឡើងនៅក្នុងមន្ទីរឃុំឃាំង។ បានន័យថា ការលំបាករបស់លោកស្រី គឺវាពិបាកក្នុងការស្លៀកពាក់ ត្រូវឲ្យគេជួយស្លៀកពាក់ ហើយគាត់ភ្លេចកន្លែងដាក់ខោអាវ ហើយគាត់ក៏មិនដឹងថា គាត់នៅក្នុងកន្លែងណានៃបន្ទប់ឃុំឃាំងរបស់គាត់។ លោកបានចូលទៅក្នុងមន្ទីរឃុំឃាំង វាជាបន្ទប់មួយតូច តើមែនដែរឬទេ?

**ឆ៖** គឺមែន។

**ស៖** ដូច្នេះការលំបាកទាំងអស់នេះ វាជាសញ្ញាបញ្ជាក់បង្ហាញនូវលក្ខណៈវិនិច្ឆ័យមួយ ដែលលោកបានបង្ហាញថា វាជាបញ្ហាលំបាកខាងផ្នែកចងចាំ និងការចុះខ្សោយសតិបញ្ញា ដែលវាធ្វើឲ្យមានការលំបាកក្នុងការធ្វើសកម្មភាពសង្គម និងសកម្មភាពប្រចាំថ្ងៃ និងសកម្មភាពផ្ទាល់ខ្លួនរបស់ខ្លួន។ តើត្រឹមត្រូវដែរឬទេ? ហើយលោកក៏បានបង្ហាញថា លោកស្រីគាត់ពេលខ្លះទៅនៅលើគ្រែដោយមិនមានសម្លៀកបំពាក់។ ដូច្នេះ តើចំណុចនេះវាជាការព្រួយបារម្ភមួយចំពោះស្ត្រីកម្ពុជា ជាពិសេសលោកស្រីម៉ាដាម លោកស្រី អៀង ធីរិទ្ធ ដែលគាត់មានវ័យ៧៩ឆ្នាំ។ ដោយសារតែនៅលើគ្រែនោះគាត់អាច-- គាត់មាន-- មិនបានស្លៀកសម្លៀកបំពាក់។ តើវាត្រឹមត្រូវដែរឬទេ?

[០៩:៣៨:៣៣]

**លោក ហួត លីនណា៖**

**ឆ៖** បាទ, បើចំពោះស្ត្រីខ្មែរ កាលណាយើងអត់ស្លៀកពាក់អ៊ីចឹង វាមើលទៅវាពិបាកផ្នែកដែរ ហើយវាមិនសមរម្យដែរ។ ប៉ុន្តែតាមដែលលោក សុភារម្យ បានប្រាប់ពួកយើងខ្ញុំហ្នឹង គឺហេតុការណ៍

ហ្នឹងវាកើតឡើងម្តងម្កាលទេ។ ហើយចំណែកឯទីតាំងនៃបន្ទប់នុំង គឺបើតាមសង្កេតមើលទៅ គឺគ្មានអ្នកក្រៅណាអាចមើលឃើញទេ។ ហើយមានតែអ្នកដែលថែទាំដិតដល់អាចមើលឃើញ ហើយអ្នកថែទាំ ខ្ញុំឃើញថា ដូចជាខាងអ្នកយាមជាស្ត្រីទេ ដែលឃើញចូលទៅនោះ ដែលចូលនាំខ្ញុំចូលទៅ។ ខ្ញុំគិតថា បើគាត់អត់ខោអាវនៅលើគ្រែហ្នឹង ប៉ុន្តែដូចគ្មានអ្នកអាចបានឃើញទេ។ ប៉ុន្តែបើក្នុងន័យទូទៅកាលណាស្ត្រីម្នាក់អត់ស្លៀកខោអាវអីចឹង វាមើលទៅអាក្រក់មើល ហើយវាដូចជាមិនសមរម្យមែន។ ប៉ុន្តែក្នុងករណីគាត់ដូចជាគ្មានអ្នកណាអីបានឃើញទេ មានតែលោក សុភារម្យ ហ្នឹងគាត់បាននិយាយ។ ប៉ុន្តែលោក សុភារម្យ ក៏គាត់ឮ តាមដែលគាត់បានប្រាប់ពួកយើងខ្ញុំ គឺថាគាត់បានទទួលរបាយការណ៍ពីបុគ្គលិកគាត់ដែរ ដែលបុគ្គលិកគាត់ថែទាំ ដែលថែទាំហ្នឹង។ ហើយតាមទីតាំងបន្ទប់ដែលយើងមើលទៅ ដែលយើងដើរពីក្រៅទៅ យើងមិនអាចមើលឃើញគាត់សម្រាកនៅក្នុងគ្រែ លើគ្រែគាត់ទេ ទាល់តែយើងចូលក្នុងទ្វារបន្តិច បានយើងមើលឃើញ។ ដូច្នេះអ្នកដែលដើរៗពីក្រៅមិនអាចមើលឃើញទេ។

**ស៖** ក៏ប៉ុន្តែគឺគាត់ងូតទឹកដោយប្រើសារុង តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រង់ចំណុចនេះខ្ញុំដូចជាអត់បានដឹងថា លោក ភារម្យ បានរាយការណ៍ប្រាប់យើងខ្ញុំទេត្រង់ចំណុចនេះ។

**ស៖** លោក ភារម្យ ក៏បានផ្តល់ព័ត៌មានអំពីការលំបាកដែលថា លោកស្រី អៀង ធីរិទ្ធ ពិបាកក្នុងការលើកឡើងអំពីឈ្មោះ លោកក៏បានប្រាប់អំពីករណីដែលលោកស្រីហ្នឹងគាត់មិនចាំពេលវេលា គឺក្នុងកថាខណ្ឌ១៨។ នៅក្នុងនោះលើកឡើងថា លោកស្រីគាត់មានការភ្លេចភ្លាំងដាក់របស់ត្រង់កន្លែងខុសហើយចោទបុគ្គលិកមន្ទីរឃុំឃាំងថាលួច។ ដូច្នេះហើយចំណុចនេះ គឺវាមានលក្ខណៈចម្លែកឬក៏មិនចម្លែកចំពោះអ្នកដែលគាត់មានជំងឺភ្លេចភ្លាំងស្មារតី ជាពិសេសនៅពេលដែលយើង-- គាត់ធ្លាប់ភ្លេចកន្លែងដាក់របស់ ហើយចោទគេថាលួច។

[០៩:៤១:៣០]

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** គឺពិតជាដូច្នោះមែន។

**ស៖** សូមអរគុណ។ ក្នុងពេលដែលលោកធ្វើកិច្ចសម្ភាសន៍ជាមួយនឹងលោកស្រី អៀង ធីរិទ្ធ លោកស្រី អៀង ធីរិទ្ធ បានបង្ហាញក្នុងពេលមួយនោះថា គ្រូពេទ្យដែលសម្ភាសជាគ្រូពេទ្យខ្មែរមួយរូបដែលទៅសម្ភាសនោះ ជាគ្រួសាររបស់គាត់។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** គឺដូច្នោះមែន តាមខ្ញុំចាំមិនខុសទេ គឺមានពីរ ឬក៏បីដងនោះ ដែលគាត់ច្រឡំ ហើយគិតថា វេជ្ជបណ្ឌិតខ្មែរមួយរូបនោះជាសមាជិកក្នុងគ្រួសាររបស់គាត់។

[០៩:៤២:១៧]

**ស៖** ខ្ញុំសូមអនុញ្ញាតឲ្យលោកពិនិត្យកថាខណ្ឌ២១ ដែលក្នុងហ្នឹងគឺនៅក្នុងជួរទីបួន លោកស្រីលើកឡើងថា គាត់មិនអាចឆ្លើយតបទៅនឹងសំណួរអំពីការចំណាំ ហើយក៏មិនអាចចាំវត្ថុទាំងបីក្នុងការធ្វើតេស្តទាំងពីរលើក។ ប្រសិនបើយើងមើលកថាខណ្ឌ២៤ វិញ លោកស្រីគឺគាត់មិនអាចថា តើវត្ថុនោះជាវត្ថុអ្វីទេ ក្រោយពីបីបួននាទីក្រោយមក។ ហើយថាតើចំណុចនេះវាខុសគ្នាទៅនឹងទៅនឹងចំណុច២១យ៉ាងម៉េច? តើលោកឯកភាពដែរឬទេ? តើលោកចាំទៅលើចំណុចនេះដែរឬទេ?

**ឆ៖** យើងបានពិភាក្សាទៅនឹងចំណុចហ្នឹង ដូច្នេះហើយវាជាចំណុចដែលយើងសរសេរមួយខុសនៅក្នុងហ្នឹង។

[០៩:៤៣:១៦]

**ស៖** លោក លីនណា គឺលោកបានលើកឡើងថា គឺគាត់ លោកស្រីមិនអាចចាំវត្ថុទាំងបីនោះថាតើពិតដែរឬទេ?

**លោក ហួត លីនណា៖**

**ឆ៖** នៅក្នុងការពិនិត្យវាស់ស្ទង់កម្រិតនៃការ កម្រិតបញ្ញាស្មារតីរបស់គាត់ ដែលយើងយក *អ៊ិនស្ទ្រូមិន (instrument)* មួយ យកតេស្តមួយយកមកប្រើគេហៅថា *មីនីមេនសិន ស្តេត អ៊ិចសា-មីណេសិន* ហ្នឹង គឺការដែលវត្ថុបីយ៉ាងហ្នឹង គឺថាយើងធ្វើការសាកសួរគាត់មានដំណាក់កាលពីរ។ ដំណាក់កាលទីមួយ យើងឲ្យគាត់ថាតាម។ គាត់ថាតាមបាន។ អាហ្នឹងយើងជាភាសាបច្ចេកទេស ឲ្យគាត់ *រ៉េជិះស្ទ័រ* មានន័យថា ឲ្យគាត់ហ្នឹងកត់សម្គាល់ពាក្យហ្នឹងចូលក្នុងខួរក្បាលគាត់ ហើយដល់ពេលប៉ុន្មាននាទីក្រោយមក យើងក៏ឲ្យគាត់សួរ ប៉ុន្តែក្នុងចន្លោះពេលហ្នឹង យើងសួរសំណួរអីផ្សេង ហើយដល់ពេលពីរបីនាទីក្រោយមក ក៏យើងបានសួរឲ្យគាត់នឹកឃើញឡើងវិញ តើគាត់អាចនឹកឃើញឡើងវិញទេ?

[០៩:៤៤:២៧]

ពេលនោះ គាត់អត់អាចនឹកឃើញវិញទេ។ មានន័យថា តាមភាសាបច្ចេកទេស គឺថាគាត់អាច *រ៉េជិះស្ទ័រ* បាន មានន័យថា គាត់អាច ភ្លាមៗហ្នឹងគាត់អាចថាតាមយើងបាន មានន័យថាពាក្យហ្នឹងគាត់

អាចបានដក់នៅក្នុងខួរក្បាលគាត់មួយរយៈខ្លីហ្នឹងគាត់អាចនិយាយជាមួយយើងបានភ្លាមៗ ដល់តែពេលក្រោយមកទៀតឲ្យគាត់នឹកអាហ្នឹងឡើងវិញ គាត់នឹកអត់ឃើញបាទ។ ហើយខ្ញុំបានឃើញថ្ងៃទីមួយក៏អ៊ីចឹង ដល់ថ្ងៃទីពីរក៏គាត់នឹកអត់ឃើញទេបាទ។ មានន័យថា *អារេជិះស្ទ័រ* (register) គាត់អូខេ ប៉ុន្តែ *អារីខល* (recall) នោះអត់បានទេ អាការដែលដក់អារម្មណ៍ភ្លាមៗ គាត់ចាំបានភ្លាមៗហ្នឹង ប៉ុន្តែដល់ពេលសួរឲ្យគាត់នឹកឡើងវិញហ្នឹង គឺគាត់អត់នឹកឃើញសោះតែម្តង។

**ស៖** វាបង្ហាញយ៉ាងច្បាស់ថា លោកស្រី អៀង ធីរិទ្ធ គឺគាត់មិនចំណាំនូវអ្វីដែលលោកបានលើកឡើង ជាពិសេសចំពោះពេលវេលា និងទីកន្លែង តើលោកឯកភាពដែរឬទេ? នៅក្នុងរបាយការណ៍របស់លោកថាពិតជាដូច្នោះមែន តើអ៊ីចឹងដែរឬទេ?

**ឆ៖** ខ្ញុំសូមចង់បញ្ជាក់ថា នៅក្នុងពាក្យនេះមិនមែនចំណាំទេ គឺការចងចាំ គឺយើងឲ្យគាត់ថាតាមយើងនូវវត្ថុបីយ៉ាង ជាឈ្មោះវត្ថុបីយ៉ាង ហើយវត្ថុនោះយើងជ្រើសរើសយកវត្ថុដែលមិនឲ្យស្រដៀងគ្នាទេ។ ព្រោះកាលណាយើងឲ្យយកវត្ថុស្រដៀងគ្នា វាថានឹងងាយនឹងចងចាំ ហើយចម្លើយរបស់គាត់ថាអាចគេហៅថាមានការច្រឡំ។ ដូច្នេះយើងឲ្យវត្ថុបីយ៉ាងដែលគាត់ ឲ្យគាត់ថាតាមដើម្បីឲ្យគាត់ចងចាំមិនមែនសម្គាល់របស់ទេ។

[០៩:៤៦:០៨]

**ស៖** លោក ហ្វាស៊ែល ខ្ញុំសូមសួរ នៅពេលដែលលោកសម្ភាសន៍ អៀង ធីរិទ្ធ។ លោក អៀង ធីរិទ្ធ ជឿថាគឺគាត់ គិតថាគាត់ហ្នឹងត្រូវបានគេសម្ភាសន៍នៅមន្ទីរពេទ្យក្នុងទីក្រុងភ្នំពេញ។ តើត្រឹមត្រូវដែរឬទេ?

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** គឺត្រឹមត្រូវ។

**ស៖** គឺគាត់នៅក្នុងមន្ទីរឃុំឃាំងនេះរយៈពេលបួនឆ្នាំមកហើយ។ ដូច្នេះគឺគាត់មិនចំណាំកន្លែងដែលគាត់នៅទេ។ តើពិតដូច្នោះដែរឬទេ?

**ឆ៖** គឺពិតជាដូច្នោះមែន

**ស៖** នៅពេលលោកសួរអំពីថ្ងៃកំណើត និងអាយុ គឺគាត់មិនចាំ។ ដូច្នេះហើយវាជាការមិនចាំទៅលើបុគ្គល តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំមិនដឹងថាតើវាជាបញ្ហាបច្ចេកទេស ដែលវាពាក់ព័ន្ធទៅនឹងការចងចាំទៅលើបុគ្គលខ្លួនឯងឬក៏យ៉ាងណានោះទេ ហើយវាជាបញ្ហានៃការចុះខ្សោយសតិបញ្ញា?

**លោក ហ្វូត លីនណា៖**

**ឆ៖** ខ្ញុំសូមអនុញ្ញាតបន្ថែមបន្តិច។ គាត់ចងចាំថ្ងៃខែឆ្នាំកំណើតគាត់ ប៉ុន្តែសួរគាត់ថា អាយុគាត់ គាត់អត់ចាំទេ។ ហើយគាត់និយាយថ្ងៃខែកំណើតរបស់គាត់ជាភាសាបារាំងទៅទៀត គឺនិយាយថា *ឌីសម៉ាស មិលនឹស សង់ ត្រង់ដឺ* (និយាយភាសាបារាំង) មានន័យថា ថ្ងៃ១០ ខែ៣ ១៩៣២។ គាត់និយាយជាភាសាបារាំង គាត់ចាំ។ គាត់ចាំថ្ងៃខែឆ្នាំកំណើតគាត់ ប៉ុន្តែសួរអាយុគាត់ គាត់អត់ដឹង។

[០៩:៤៧:៤៥]

**ស៖** ដូច្នេះហើយ វាជាវិការៈដែលគាត់មិនអាចគិតគូរនូវអាយុរបស់គាត់តាំងពីឆ្នាំ១៩៣២ រហូតមកដល់ពេលបច្ចុប្បន្ន តើត្រឹមត្រូវដែរឬទេ?

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** គឺពិតជាដូច្នោះមែន គឺវាជាការចុះខ្សោយខាងការចំណាំ ពេលវេលាដោយសារតែយើងគិតអំពីឆ្នាំ។

**ស៖** លោកស្រី អៀង ធីរិទ្ធ ក៏មិនអាចរៀបរាប់ឲ្យបានត្រឹមត្រូវអំពីទំនាក់ទំនងរវាងគាត់ ជាមួយនឹងបុគ្គលផ្សេង ថាតើបុគ្គលនោះស្លាប់ ឬក៏នៅរស់? ដូច្នេះហើយចំណុចនេះ វាពាក់ព័ន្ធទៅនឹងការចំណាំដែរឬទេ?

[០៩:៤៨:២៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមជំទាស់ទៅលើការសួរសំណួរបែបនេះ។

លោកប្រធានសំណួរដែលបានសួរឡើងហ្នឹង គឺវាពាក់ព័ន្ធទៅនឹងការសន្និត ពាក់ព័ន្ធទៅនឹងការចងចាំរបស់លោកស្រី អៀង ធីរិទ្ធ។ យើងគួរតែសួរឲ្យបានជាក់លាក់ថាតើមិនចាំតាមរបៀបណា? មិនចាំទៅលើបុគ្គលណា។ ដូច្នោះយើងគួរតែសួរបញ្ជាក់ទៅលើរបាយការណ៍តែប៉ុណ្ណោះបានហើយ កុំឲ្យអ្នកជំនាញធ្វើការផ្តល់ចម្លើយទាក់ទងនឹងការសន្និត។

**លោកស្រី ដាយអាណា អេលីស៖**

ដោយសារតែយើងមិនមានពេលវេលា ដោយសារបញ្ហាពេលវេលា ខ្ញុំផ្អែកទៅលើរបាយការណ៍

តែប៉ុណ្ណោះ នៅពេលដែលខ្ញុំសួរ។ ប្រសិនបើយើងមើលកថាខណ្ឌទីប្រាំបួន ដែលពាក់ព័ន្ធទៅនឹងសំណួរសួរទៅកាន់គាត់ ហើយវាពាក់ព័ន្ធទៅនឹងរបាយការណ៍ លោក សិបប្រា (ប្រកបតាមសំឡេងដើម) នៅកថាខណ្ឌ១៨ ហើយប្រសិនបើយើងមើលទៅលើខ្លឹមសារនៃកថាខណ្ឌ២៣ ឯកសារទាំងអស់នោះ បានលើកឡើងអំពីអលទ្ធភាព។ គាត់មិនមានលទ្ធភាព លោកស្រី អៀង ធីរិទ្ធ មិនមានលទ្ធភាពប្រាប់ឈ្មោះ កំណត់អត្តសញ្ញាណបុគ្គលនុំង ថាតើបុគ្គលនុំងស្លាប់ឬក៏រស់? នេះជាអ្វីដែលសង្ខេបចេញពីរបាយការណ៍តែប៉ុណ្ណោះ។

**សួរដោយលោកស្រី ដាយអាណា អេលីស៖**

**ស៖** ថាតើវាត្រឹមត្រូវដែរឬទេ លោកសាស្រ្តាចារ្យ លោកបណ្ឌិត ហ្វាស៊ែល?

[០៩:៤៩:៤៥]

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** ពាក់ព័ន្ធទៅនឹងការផ្តល់ឈ្មោះ គឺវាបង្ហាញយ៉ាងច្បាស់ថាលោកស្រី គាត់មិនអាចចងចាំឈ្មោះកូនរបស់គាត់ ជាច្រើនសា ហើយពាក់ព័ន្ធទៅនឹងថា តើបុគ្គលមួយចំនួន គាត់ស្លាប់ ឬក៏រស់នោះ យើងក៏បានយល់ឃើញថាវាមានការចុះខ្សោយ និងវិការៈពាក់ព័ន្ធនឹងការគិតរបស់គាត់។ គាត់គិតថាម្តាយរបស់គាត់នៅរស់ ករណីនេះមិនត្រឹមត្រូវនោះទេ។ ដូច្នេះការបកស្រាយរបស់យើង យើងយល់ឃើញថា ការចងចាំរយៈពេលយូររបស់គាត់មានការចុះខ្សោយ ហើយវាបង្ហាញសញ្ញានេះមែន។

**ស៖** លោកវេជ្ជបណ្ឌិត ហ្វាស៊ែល លោកក៏និយាយអំពីបញ្ហាសម្បទា ពាក់ព័ន្ធនឹងការចូលរួមការពារក្តីរបស់ចុងចោទ ដែលក្នុងនោះលើកឡើងដោយ-- លក្ខណៈវិនិច្ឆ័យដោយលោក ហ្វ៊ីន ស៊ិន (Dr. Friersen)។ ដូច្នេះហើយការមិនអាចគិតគូរ ការវិនិច្ឆ័យ និងការផ្តល់ហេតុផលវាពាក់ព័ន្ធទៅនឹងសមត្ថភាពនៃការចូលរួម តើលោកឯកភាពទៅលើចំណុចនេះដែរ ឬទេ?

**ឆ៖** ខ្ញុំឯកភាព។

**ស៖** ការចុះខ្សោយនៃការចំណាំហើយនិងការចងចាំនោះ គឺក៏វាពាក់ព័ន្ធទៅនឹងសមត្ថភាពដែរ តើលោកឯកភាពដែរ ឬទេ?

**ឆ៖** គឺពិតជាដូច្នោះមែន ប៉ុន្តែយើងត្រូវប្រុងប្រយ័ត្ន ដែលថា បុគ្គលមួយចំនួនគាត់មានការចុះខ្សោយពាក់ព័ន្ធនឹងការចំណាំ។ ប៉ុន្តែវាពាក់ព័ន្ធទៅនឹងអ្វីដែលលោកស្រីលើកឡើងអម្បាញ់មិញនោះមែន។

**ស៖** នៅពេលនេះខ្ញុំសូមសួរលោកអំពីការចងចាំ តើលោកឯកភាពដែរ ឬទេដែលថា ការចងចាំនេះវាប៉ះពាល់ទៅដល់សម្បទាដែលយើងមានការព្រួយបារម្ភនៅក្នុងសវនាការនេះ។ តើពិតជាដូច្នោះដែរ ឬទេ?

[០៩:៥១:៥២]

**ឆ៖** ខ្ញុំមិនអាចនិយាយដូច្នេះទេ ប្រសិនបើយើងខ្ញុំមិនធ្វើការវិភាគទៅលើសម្បទានីមួយៗ។ ដូច្នេះហើយខ្ញុំមិនអាចធ្វើការផ្តល់ជាមតិយោបល់ទូទៅនោះទេ។

**ស៖** ខ្ញុំសូមសួរដូច្នេះ។ យើងខ្ញុំមើលទៅលើកថាខណ្ឌ២៣ នៃរបាយការណ៍របស់លោក លោកបានលើកឡើងថា វាមានការចងចាំរយៈពេលយូរដែលនៅល្អខ្លះ នៅក្នុងរបាយការណ៍របស់លោក លោកមិនមានលើកអ្វីទាល់តែសោះ ដែលថាលោកស្រី អៀង ធីរិទ្ធ បានចងចាំអង្គហេតុ ហេតុការណ៍នៅក្នុងអតីតកាលរបស់គាត់។ នៅពេលមួយនោះ គឺគាត់ចាំ លោកស្រីហ្នឹងចាំឈ្មោះម្តាយរបស់គាត់ ក៏ប៉ុន្តែពេលខ្លះអត់ចាំ ថាតើលោកមិនបានសរសេរចំណុចផ្សេងទៀតដែរ ឬទេ ដែលវាពាក់ព័ន្ធទៅនឹងអង្គហេតុមួយចំនួនដែលលោកស្រី អៀង ធីរិទ្ធ គួរតែប្រាប់លោក?

[០៩:៥៣:០១]

**ឆ៖** យើងមិនបានសម្ភាសន៍គាត់ឲ្យលម្អិត និងហ្មត់ចត់នោះទេ ពាក់ព័ន្ធទៅនឹងជីវិតយុវវ័យ និងជីវិតកុមារភាពរបស់គាត់។ យើងបានសួរសំណួរជាក់លាក់មួយចំនួនពាក់ព័ន្ធទៅនឹងបញ្ហានោះមែន ហើយពាក់ព័ន្ធទៅនឹងសំណួរជាក់លាក់លោកស្រី អៀង ធីរិទ្ធ នៅក្នុងពេលសម្ភាសលើកទីពីរ លើកទីបី គឺគាត់បានរំឭកឡើងវិញថា គាត់ចាំថាគាត់ជារដ្ឋមន្ត្រីមួយរូបនៅក្នុងរយៈការទសវត្សរ៍ឆ្នាំ៧០។ នេះគឺជាការចង្អុលបញ្ជាក់មួយដែលយើងបានទទួលពីគាត់ ហើយវាជាចំណុចមួយនៃការចងចាំរបស់គាត់។ ដូច្នេះ ហើយវាមិនមានការចុះខ្សោយទេ បើសិនយើងមិនយកមកវិភាគទៅលើការវិនិច្ឆ័យ។

**ស៖** នៅក្នុងកថាខណ្ឌ៩ លោកបានលើកឡើងថា លោកស្រី គឺគាត់បានលើកឡើងថា គឺគាត់ជារដ្ឋមន្ត្រី ប៉ុន្តែមិនអាចផ្តល់តួនាទីថាធ្វើអ្វី។ ដូច្នេះហើយថា តើលោកបានសួរសំណួរពាក់ព័ន្ធទៅនឹងចំណុចហ្នឹងដែរ ឬទេ? លោកស្រី គាត់បានឆ្លើយតបទៅនឹងសំណួរជាក់លាក់របស់លោក ក៏ប៉ុន្តែវាមិនមែនជាសំណួរមួយសួរផ្សេងទេ គឺសួរចំតែម្តង តើលោកឯកភាពទៅលើចំណុចហ្នឹងដែរ ឬទេ?

**លោក ហួត លីនណា៖**

**ឆ៖** ក្រុមយើងខ្ញុំ គឺបានសួរគាត់ដែរត្រង់ចំណុចហ្នឹង ពេលមួយនោះគាត់បានឆ្លើយថា គាត់

ធ្លាប់ធ្វើជារដ្ឋមន្ត្រី ហើយយើងបានសួរឲ្យគាត់បរិយាយប្រាប់មកថា តើនៅក្នុងពេលដែលគាត់ធ្វើជារដ្ឋមន្ត្រីហ្នឹងគាត់បានធ្វើអីខ្លះ? ហើយរដ្ឋមន្ត្រីខាងអីៗហ្នឹង សួរគាត់ទៅគាត់អត់បានឆ្លើយទេ។ យើងបានចង់ដឹងព័ត៌មានបន្ថែមទាក់ទងនឹងរឿងហ្នឹង ប៉ុន្តែគាត់អត់ឆ្លើយទេបាទ អ៊ីចឹងទាក់ទងនឹងរឿងហ្នឹង ដូច្នេះយើងអត់មានព័ត៌មានអីបន្ថែមទេត្រង់ចំណុចហ្នឹង។

**ស៖** តើលោកឯកភាពដែរឬទេ ដែលថាលោកស្រីហ្នឹងគាត់មិនមានលទ្ធភាពចងចាំក្នុងការរៀបរាប់ឲ្យលម្អិតអំពីហេតុការណ៍ពាក់ព័ន្ធទៅនឹងជីវិតរបស់គាត់តាំងពីទសវត្សរ៍ទី៥០ រហូតមកដល់ពេលបច្ចុប្បន្ន តើពិតជាដូច្នោះដែរឬទេ?

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** យើងខ្ញុំយល់ឃើញថាលោកស្រីអាចមានបញ្ហានៃការចងចាំព័ត៌មានលម្អិតនៃជីវិតយុវវ័យរបស់គាត់។ យើងមិនអាចនិយាយជាក់លាក់នោះទេ ថាតើវាមានការចុះខ្សោយត្រឹមកម្រិតណាក៏ប៉ុន្តែយើងវិភាគទៅលើលក្ខណៈទូទៅនៃហេតុការណ៍សំខាន់ៗនៃជីវិតរបស់គាត់ ក៏ប៉ុន្តែយើងបង្ហាញថា វាមានការចុះខ្សោយនៃការចងចាំរយៈពេលយូររបស់គាត់។ គឺការចងចាំពាក់ព័ន្ធនឹងហេតុការណ៍មុនឆ្នាំទសវត្សរ៍ឆ្នាំទី៥០ ផងដែរ។

[០៩:៥៦:២២]

**ស៖** នៅពេលសួរអំពីសក្ខីកម្មរបស់សាក្សីថាតើលោកឯកភាពដែរឬទេថា លោកស្រី អៀង ធីរិទ្ធ មានការលំបាកក្នុងការរំឭកថា តើគាត់នៅកន្លែងណា? គាត់បានធ្វើអ្វី? ហើយគាត់បាននិយាយអ្វីខ្លះនៅក្នុងរយៈពេលសាមសិបប្រាំឆ្នាំមុន តើលោកឯកភាពទៅលើចំណុចហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំគិតថា គាត់មានការពិបាកច្រើនក្នុងការចងចាំព័ត៌មានលម្អិតនូវអ្វីដែលគាត់បានធ្វើដូចដែលគាត់បានរៀបរាប់។

**ស៖** នៅពេលដែលយើងមើលនូវអ្វីដែលលោកស្រី អៀង ធីរិទ្ធ បានលើកឡើង ជាពិសេសពាក់ព័ន្ធទៅនឹងលទ្ធភាពរបស់គាត់យល់អំពីបទចោទដាក់បន្ទុកមកលើគាត់។ ដូច្នេះថាតើលោកឯកភាពដែរឬទេ ថាការយល់ដឹងទៅលើបទចោទទាំងអស់នោះ វាត្រូវមានភាពសមហេតុផលដើម្បីអាចអនុវត្តសិទ្ធិជំនុំជម្រះដោយយុត្តិធម៌បាន តើពិតដូច្នោះដែរឬទេ?

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមជំទាស់ទៅលើសំណួរហ្នឹង ដោយសារតែសំណួរនេះជាសំណួរផ្លូវច្បាប់ មិនមែនជា

សំណួរឲ្យជំនាញឆ្លើយនោះទេ។

**លោកស្រី ដាយអាណា អេលីស៖**

មិនត្រូវទេ វាមិនមែនជាសំណួរពាក់ព័ន្ធទៅនឹងច្បាប់នោះឡើយ វាជាកម្រិតនៃការយល់ដឹងដែលយើងត្រូវសួរថា តើគាត់អាចមានការយល់ដឹងសមហេតុផលចំពោះអ្វីដែលគេចោទប្រកាន់គាត់ថា ធ្វើខុសនោះដែរឬទេ? ហើយនេះជាសំណួរពាក់ព័ន្ធនឹងវេជ្ជសាស្ត្រដែលលោកអ្នកបណ្ឌិតគាត់អាចឆ្លើយតបបាន។

[០៩:៥៨:១៩]

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់សហព្រះរាជអាជ្ញាមិនមានប្រសិទ្ធភាពទេ ហើយលោកអ្នកជំនាញអាចឆ្លើយនឹងសំណួរនេះបាន។ ហើយទីពីរ គឺសូមរំឭកដល់មេធាវីការពារក្តី អៀង ធីរិទ្ធ ថាលោកស្រីនៅមានពេលវេលាតែប្រាំនាទីប៉ុណ្ណោះ ទៀតប៉ុណ្ណោះក្នុងការសួរសំណួរនេះ។ សូមអញ្ជើញ!

**លោកស្រី ដាយអាណា អេលីស៖**

**ស៖** សូមអរគុណលោកប្រធាន។

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** ខ្ញុំសូមសួរឲ្យលោកស្រីធ្វើការបញ្ជាក់សំណួរឡើងវិញ។

**សួរដោយលោកស្រី ដាយអាណា អេលីស៖**

**ស៖** ខ្ញុំបានសួរលោកថា តើលោកឯកភាពដែរឬទេ វាមិនគ្រប់គ្រាន់ចំពោះបុគ្គលក្នុងការយល់សំណួរនោះទេក្នុងការអនុវត្តឲ្យបានសមហេតុផលចំពោះការចូលរួម ការជំនុំជម្រះដោយយុត្តិធម៌ ការយល់ដឹងនោះទាល់តែមានលក្ខណៈសមហេតុផល តើត្រឹមត្រូវដែរឬទេ? លោកឯកភាពលើចំណុចនេះដែរឬទេ? លោកឯកភាពលើចំណុចនេះដែរឬទេ?

[០៩:៥៩:១៨]

**ឆ៖** ខ្ញុំនឹងឯកភាពថានៅពេលដែលយើងឆ្លើយសំណួរ យើងត្រូវតែប្រើនូវការគិតគូរ និងការចាំរបស់យើង ដើម្បីអាចអនុវត្តសិទ្ធិ និងដើម្បីអាចលើកឡើងអំពីសមត្ថភាពរបស់គាត់ ដូចដែលយើងបានរៀបរាប់នៅក្នុងរបាយការណ៍របស់យើង ពាក់ព័ន្ធទៅនឹងភាពសមហេតុផលនៃការយល់ដឹងនោះ វាមានការលំបាក។ ខ្ញុំយល់ឃើញថា យើងអាចមិនឯកភាព ឬក៏បុគ្គលផ្សេងទៀតឯកភាពអំពីហេតុផល

ដែលបុគ្គលបានលើកឡើង។ ដូច្នេះ ហេតុផលទាំងអស់នោះ វាមិនគិតថា យើងត្រូវជឿជាក់ប៉ុនណានោះទេ ហើយទុកចិត្តបានប៉ុនណានោះទេ។ ដូច្នេះ ប្រសិនបើភាពសមហេតុផល និងហេតុផលនោះ វាផ្តល់មួយ ហើយយើងមិនជឿជាក់នោះ យើងប្រាកដជាយល់ថា មិនមានសមត្ថភាព។ យើងត្រូវតែគិតអំពីការដែលយើងសួរសំណួររបស់យើង ហើយយើងត្រូវគិតអំពីសមត្ថភាពដែលគេអនុវត្ត។

**ស៖** នៅពេលដែលលោកមើលកថាខណ្ឌ៤៤ លោកបានលើកឡើងដែរថា លោកស្រីហ្នឹង គឺថា យើងមិនអាចទុកចិត្តបានទៅលើសមត្ថភាពរបស់គាត់។ ហើយលោកស្រីបានលើកឡើងថា ម្តាយរបស់គាត់នោះ គឺចិញ្ចឹមគាត់ បីបាច់គាត់ល្អ ហើយស្ត្រីកម្ពុជាម្នាក់មិនអាចធ្វើអំពើអាក្រក់ដូច្នេះនោះទេ។ ដូច្នេះ តើលោកឯកភាពដែរឬទេ គឺគាត់ លោកស្រីគាត់មិនបានយល់ដឹងសមរម្យទៅលើការគិតគូររបស់គាត់ ហើយនៅពេលដែលគាត់រៀបរាប់នោះ គឺគាត់មានវ័យ៤៣ឆ្នាំ នៅក្នុងឆ្នាំ១៩៧៥ តើលោកបានគិតទៅលើបញ្ហាហ្នឹងដែរឬទេ?

[១០:០១:៣៥]

**ឆ៖** ដូចដែលយើងបានរៀបរាប់ ចម្លើយដែលបានផ្តល់ជូននោះ មិនគួរឲ្យយើងទុកចិត្តនោះទេ។ យើងយល់ឃើញថា ចម្លើយនោះ វាមិនមែនបង្ហាញអំពីការមិនមានសមត្ថភាពរបស់គាត់នោះទេ។ វាអាចកើតឡើងចំពោះបុគ្គលដែលគាត់ផ្តល់ចម្លើយមួយចំនួន ដែលវាចាំបាច់ ប៉ុន្តែចម្លើយនោះ វាមិនមានន័យថា បុគ្គលហ្នឹង គាត់មិនមានសមត្ថភាពនោះទេ។

**ស៖** ដូច្នេះ ថាតើយើងត្រូវពិនិត្យឲ្យបានហ្មត់ចត់នូវអ្វីដែលយើងដឹងអំពីគាត់ដែរឬទេ ដែលថាវាពាក់ព័ន្ធទៅនឹងលទ្ធភាពរបស់គាត់ក្នុងការផ្តល់ហេតុផលនោះ?

**ឆ៖** វាពិតជាបានបង្ហាញអំពីការខ្វះនូវសមត្ថភាព ការមិនមានសមត្ថភាពក្នុងការផ្តល់ហេតុផល ដោយសារតែយើងបានចង្អុលបញ្ជាក់រួចមកហើយ ដែលថាគឺគាត់បានលើកឡើងចម្លើយមួយដែលមានលក្ខណៈផ្ទុយគ្នា។ លោកស្រីគាត់មិនបានឆ្លើយតបទៅនឹងសំណួរដែលយើងសួរឲ្យគាត់បញ្ជាក់បំភ្លឺ។ យើងឃើញមានហេតុផលដទៃទៀត ដែលបុគ្គលម្នាក់គាត់បដិសេធមិនធ្វើការឆ្លើយតបទៅនឹងសំណួរបញ្ជាក់បំភ្លឺ។ ដូច្នេះ យើងមិនអាចនិយាយមួយរយភាគរយថា បុគ្គលនេះមិនមានសមត្ថភាពក្នុងការផ្តល់ហេតុផលនោះទេ។ ជាពិសេស ចំពោះការពន្យល់ដែលគាត់បានពន្យល់មកកាន់យើងខ្ញុំនោះ។

**ស៖** តាមអ្វីដែលខ្ញុំយល់ លោកមិនឯកភាព មិនជំទាស់ទៅលើខ្លឹមសារ ឬក៏ផលវិបាកដែលវាពាក់ព័ន្ធទៅនឹងសេចក្តីសន្និដ្ឋានរបស់លោក ខាំប៉ែល នោះទេ ដែលក្នុងនោះ បានលើកឡើងថាគ្មាន

ភស្តុតាងណាមួយបង្ហាញថា លោកស្រី អៀង ធីរិទ្ធ ហ្នឹងហាក់ដូចជាធ្វើពើចំពោះ-- ធ្វើពុតជាភ្លេចភ្លាំងនោះទេ តើពិតជាដែរឬទេ?

**ឆ៖** លោក ខាំប៉ែល គាត់បានលើកឡើងអំពីបញ្ហាចោទនៃការធ្វើពុត ហើយយើងឯកភាពជាមួយនឹងលោក ខាំប៉ែល ដែរថាមិនមានភស្តុតាងណាមួយបង្ហាញថាលោកស្រីនោះ គាត់ធ្វើពុតនោះទេ នៅពេលដែលយើងធ្វើការសម្ភាសន៍ជាមួយនឹងគាត់។ ហើយក៏មិនមានភស្តុតាងណាមួយគាត់ធ្វើពុតថាគាត់ចុះខ្សោយនូវសតិបញ្ញារបស់គាត់នោះផងដែរ។ លទ្ធភាពរបស់គាត់មានការឡើងចុះ សមត្ថភាពរបស់គាត់មានការឡើងចុះ។ ដូច្នេះហើយ វាមិនមានលក្ខណៈណាមួយបង្ហាញថា វាអាចគាត់ហ្នឹងធ្វើការ ធ្វើពុតនោះទេ។

[១០:០៥:៤១]

**លោកស្រី ដាយអាណា អេលីស៖**

សូមអរគុណលោកបណ្ឌិត លោកវេជ្ជបណ្ឌិត ហើយនិងលោកវេជ្ជបណ្ឌិត លីនណា។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី អរគុណដល់អ្នកជំនាញ។ ជាកិច្ចបន្ត អង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីមានលទ្ធភាពក្នុងការតាំងសំណួរចំពោះអ្នកជំនាញទាំងពីររូប។

សូមអញ្ជើញ!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ច័ន្ទ តារាវស្នី៖**

សូមគោពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សូមគោរពអង្គសវនាការ សូមគោរពលោកអ្នកជំនាញជាតិ និងអន្តរជាតិ។ នៅពេលនេះ ក្នុងនាមខ្ញុំជាតំណាងសហព្រះរាជអាជ្ញានៅក្នុងពេលនេះ ខ្ញុំសូមបង្ហាញជូននូវសំណួរមួយចំនួន សូមជូនអ្នកជំនាញ ដើម្បីឆ្លើយបំភ្លឺឲ្យបានច្បាស់ជូនអង្គសវនាការនៅពេលនេះ។

**ស៖** សំណួរទីមួយរបស់ខ្ញុំគឺសូមសួរថា យោងតាមរបាយការណ៍របស់លោក ត្រង់កថាខណ្ឌទី២៧ បានសរសេរថា ជនជាប់ចោទ អៀង ធីរិទ្ធ មានរោគសញ្ញានៃជំងឺវង្វេងវង្វាន់ស្មារតី ប៉ុន្តែលោកមិនជឿថា ជនជាប់ចោទ អៀង ធីរិទ្ធ មានទទួលរងនូវជំងឺផ្លូវចិត្តដទៃទៀតនោះទេ ដូចជាជំងឺរោគចិត្តជាដើម។ សំណួរសួរថា តើលោកអាចពន្យល់អំពីភាពខុសគ្នារវាងជំងឺស្មារតី និងជំងឺរោគចិត្តបានដែរឬទេ?

[១០:០៦:២៣]

**លោក ហួត លីនណា៖**

**ឆ៖** បាទ, ខ្ញុំសូមអនុញ្ញាតឆ្លើយនូវសំណួរនេះដូចតទៅ។ ក្នុងការធ្វើរោគវិនិច្ឆ័យនេះ យើងឃើញ យើងរកឃើញថា គាត់មានជំងឺគេហៅថា តាមបច្ចេកទេសហៅថា *ឌីមែនស្យា* ហើយបកជាខ្មែរមកថា ជាជំងឺវង្វេងវង្វាន់ ហើយជាធម្មតាក្នុងការអនុវត្តមុខរបរប្រចាំថ្ងៃជាគ្រូពេទ្យនោះ កាលណាយើងរកធ្វើរោគវិនិច្ឆ័យមួយ យើងតែងតែគិតទៅរកជំងឺផ្សេងៗទៀត ដែលស្រដៀងៗនឹងជំងឺហ្នឹង ដើម្បីយើងឲ្យប្រាកដថា គ្មានជំងឺអីផ្សេងទៀតទេ អត់ច្រឡំជាមួយនឹងជំងឺអីផ្សេងទៀតទេ។ ហើយនៅក្នុងចំណោមជំងឺដែលយើងអាចច្រឡំជាមួយជំងឺ *ឌីមែនស្យា* ដែលយើងបកជាខ្មែរថា ជំងឺវង្វេងវង្វាន់នោះ ដូចមានជាជំងឺ*ឌីប្រេសសិន (depression)* ដែលយើងបកថាជា ជំងឺធ្លាក់ទឹកចិត្ត ហើយនិងជំងឺវិកលចរិតផ្សេងៗទៀត។ តែក្នុងនេះយើងក្នុងការពិនិត្យនោះ ខ្ញុំបាទ និងក្រុមខ្ញុំបាទនោះ បានសាកសួរថាតើឧទាហរណ៍ថាដូចជាជំងឺធ្លាក់ទឹកចិត្តអ៊ីចឹង គាត់មានពិបាកចិត្ត ធ្លាក់ទឹកចិត្ត គាត់មានអារម្មណ៍ស្រងេះស្រងោចមានអារម្មណ៍អត់ចង់ធ្វើអ្វី ហើយគាត់មានគំនិតចង់សម្លាប់ខ្លួន យើងអាចសួរ-- យើងបានសួរសំណួរច្រើនណាស់ទាក់ទងនឹងជំងឺធ្លាក់ទឹកចិត្តហ្នឹង។

[១០:០៧:៥៦]

ហើយសូម្បីតែទឹកមុខ ហើយនិងកាយវិការ ហើយនិងលក្ខណៈខាងក្រៅនោះ ក៏យើងអាចកត់សម្គាល់ឃើញថា គាត់អត់មានជំងឺធ្លាក់ទឹកចិត្តហ្នឹងទេ ហើយយើងក៏បានសួរបន្ថែម ហើយក៏គ្រប់អ្នកជំនាញទាំងបួននាក់ក៏ពិនិត្យទៅឃើញថា ក៏អត់មានជំងឺធ្លាក់ទឹកចិត្តហ្នឹងដែរ។ ហើយតាមរបាយការណ៍ពីខាង តាមដែលខ្ញុំសាកសួរលោក ចំរើន ហ្នឹងក៏គាត់ថា ដូចអត់-- មើលទៅដូចអត់មានសញ្ញាណាដែលគាត់ថ្ងូរថា គាត់ពិបាកចិត្តថាអី ដូចអត់មានគាត់បានរាយការណ៍ថា ថ្ងូរថា ពិបាកចិត្តណាស់ គាត់អស់អង្ហឹម អីៗដូចអត់មានទេ។

ប៉ុន្តែយើងបានពិនិត្យទៅ យើងមានបានសាកសួរៗ គឺអត់មានឃើញទេបាទ។ ពីព្រោះថា ជំងឺ *ឌីប្រេសសិន* ហ្នឹង ចួនកាលអាចកើតព្រមពេលជាមួយគ្នា ចួនកាលអ្នកជំងឺមនុស្សចាស់ម្នាក់ហ្នឹងអាចកើតជំងឺ *ឌីមែនស្យា* ដែលហៅថា ជំងឺវង្វេងវង្វាន់ហ្នឹងអាចកើតជាមួយជំងឺ*ឌីប្រេសសិន* ដែលថាធ្លាក់ទឹកចិត្តអាចកើតជាមួយគ្នា ឬក៏កើតមួយ អត់មួយ។ យើងខំផ្ទៃកមើលដែរ ផ្ទៃកមើល សាកសួរមើលដែរ គឺថា អត់មានទេ។ ហើយជំងឺមួយទៀត ដូចជាគេហៅថា *សាយខលទីក អៀលណេស* (ប្រកបតាម

សំឡេងដើម) ហ្នឹង បកប្រែជាខ្មែរថា អានេះបកប្រែខ្មែរថាជាជំងឺប្រភេទមួយថា ដូចជាឡប់សតិហើយ ហើយយើងសាកសួរមើលទៅ យើងអត់ឃើញមានទេ។

យើងបានចាប់អារម្មណ៍ដែរ ចាប់អាម្មរណ៍ដូចថា កាលពីគាត់ធ្លាប់ព្យាបាលនៅបំរុងវ៉ាត់នោះ គាត់ធ្លាប់មានរោគសញ្ញានៃការឡប់សតិខ្លះ ដូចជាភាសាបច្ចេកទេសហៅថា *ហាលុយហ្សុីណេស៊ិន* (hallucinations) ហ្នឹងបកប្រែខ្មែរមកដូចថា គាត់ការយល់ដឹងដោយវិញ្ញាណរបស់គាត់ហ្នឹងខុស។

[១០:០៩:៤៣]

ហើយយើងខំបានសាកសួរមើលដែរ ក្រែងលោមានរោគសញ្ញាហ្នឹងវានៅសល់បន្តទៀត ហើយខ្ញុំសូមបន្ថែមបន្តិចដែរដូចថា គាត់ចោទនៅក្នុងៗរបាយការណ៍អ្នកពីលោកប្រធានផ្នែកពន្ធ-- មន្ទីរឃុំឃាំងនៅ អ.វ.ត.ក ហ្នឹង ថាបាត់របស់អី គាត់ចោទថាគេលួចរបស់គាត់។ អាការនេះក៏ជារោគសញ្ញាមួយវាអាចស្រដៀងហ្នឹងរោគសញ្ញានៃជំងឺឡប់សតិ ដែលយើងដែលកំពុងស្រាវជ្រាវរកហ្នឹង តើមានអត់? ដូចជា *សាយខលទីក អៀលណេស* (ប្រកបតាមសំឡេងដើម) ។ ប៉ុន្តែអាការដែលគាត់បាត់របស់ ហើយចោទថាគេលួច ចោទថាអីហ្នឹង ឃើញមានតែម្ដងម្កាល ហើយអត់មានតទៅទៀតទេ។ ប្រសិនបើគាត់ពិតជាមានរោគសញ្ញាឡប់សតិមែន រោគសញ្ញានេះនឹងមានយូរជាងហ្នឹង មិនមែនបាត់អីចឹងទេ ហើយវាមានជាប់អីចឹង។ ហើយហេតុផលមួយទៀត ដែលយើងឃើញនៅពេលដែលយើងបន្ថយថ្នាំ *កេត្យាពីន* ហើយ រួចហើយ គេបន្ថយមក ប្រសិនជាគាត់មានរោគសញ្ញាអី ឡប់សតិហ្នឹងវាហ្នឹងកើតឡើងវិញអីហើយ។

[១០:១០:៥៧]

ហេតុផលទាំងអស់ហ្នឹងមក យើងសួរមានរោគសញ្ញាដទៃទៀត យើងសួរទៅ យើងកត់សម្គាល់ឃើញថា គាត់អត់មានជំងឺប្រភេទ ជំងឺឡប់សតិទេ ហើយជំងឺធ្លាក់ទឹកចិត្តហ្នឹងក៏អត់មានទេ។ ហើយជំងឺទាំងអស់នេះជាធម្មតាតែងតែច្រឡំជាមួយនឹងជំងឺ *ឌីមែនស្យា* ឬក៏កើតមានព្រមពេលជាមួយគ្នា ជាមួយនឹងជំងឺវង្វេងវង្វាន់របស់គាត់។ ប៉ុន្តែយើងបានខិតខំផែកមើលទៅ ហើយពិភាក្សាគ្នាមើលទៅឃើញថាអត់មានទេ ប៉ុន្តែយើង តាមពិតគ្រាន់តែតាមបទពិសោធន៍ដែលខ្ញុំធ្លាប់ធ្វើការនេះ គ្រាន់តែក្រឡេកឃើញអ្នកជំងឺ យើងអាចមានអារម្មណ៍ថា អ្នកជំងឺហ្នឹងមានអីហើយ។ ក៏ប៉ុន្តែក្នុងន័យបច្ចេកទេសយើងមិនអាចជឿលើអារម្មណ៍យើងទេ យើងត្រូវតែសួរ។ ប៉ុន្តែយើងបានធ្វើតាមបច្ចេកទេសទៅ គឺថាអត់មានទេបូកផ្សំទាំងព័ត៌មានពីគ្រូពេទ្យ លោក ចំរើន អ្នកនៅមន្ទីរឃុំហ្នឹង ក៏អត់មានឃើញរោគសញ្ញាហ្នឹងដែរ។

បាទៗ ខ្ញុំសូមបញ្ចប់ប៉ុណ្ណឹង។

[១០:១២:០៣]

**ស៖** អរគុណលោកវេជ្ជ ហួត លីនណា។ ខ្ញុំសូមបន្តសួរចំពោះលោកបន្តទៀត។ តើជំងឺដែលលោកបានលើកឡើងអម្បាញ់មិញ ទាក់ទងនឹងជំងឺវង្វេងវង្វាន់ហ្នឹង។ តាមបច្ចេកទេស តើជំងឺនេះអាចព្យាបាលជាដាច់ដែរឬទេ? ប្រសិនបើជាមិនដាច់ទេ តើយើងអាចកាត់បន្ថយបានឲ្យក្នុងកម្រិតទាប តើត្រូវការប្រើពេលវេលាប៉ុន្មានដែរបាទ?

សូមអរគុណ។

[១០:១២:៣០]

**ឆ៖** លោកដូចតទៅ បើយើងនិយាយអំពី*ឌីមែនស្យា* នេះ ជាជំងឺវង្វេងវង្វាន់។ ហើយខ្ញុំសូមជម្រាបអង្គសវនាការថា ពាក្យជំងឺ *ឌីមែនស្យា* នេះមានន័យមួយទូលំទូលាយ បើយើងបកជាភាសាខ្មែរថាជំងឺវង្វេងវង្វាន់តែមួយទេ។ ប៉ុន្តែនៅក្នុងន័យបច្ចេកទេស នៅក្នុងជំងឺ*ឌីមែនស្យា* នេះ ជំងឺ-- វាមានជំងឺតូចៗតទៅទៀត។ ហើយនៅក្នុងជំងឺ*ឌីមែនស្យា* ហ្នឹងមានជំងឺច្រើនទៀត ដែលយើងអាចព្យាបាលបានព្យាបាលឲ្យជាដាច់ស្រឡះ ហើយយើងបានខិតខំរុករកដែរ តើមានជំងឺ*ឌីមែនស្យា* ណាមួយ ដែលអាចព្យាបាលជា។ ដូចជា ជំងឺហ្នឹងដែលបង្កឡើងដោយសារការខ្វះវីតាមីនបេ១២ ខ្វះដូចជាពួក*អាស៊ីតហ្វូលិក* ឬក៏ជំងឺហ្នឹងកើតឡើងដោយសារក្រពេញបញ្ចេញក្នុងទីរ៉ូអ៊ីត នេះ វាចុះខ្សោយ ឬក៏អ្នកជំងឺនេះមានការបង្ករោគ គេហៅថា *អ៊ីនហ្វិកសិន (infection)* ហ្នឹង មានការបង្ករោគនៅត្រង់កន្លែងណាមួយដែលធ្វើឲ្យគាត់វង្វេងវង្វាន់។ ហើយតើគាត់ហ្នឹងអាចមានដុំនៅក្នុងខួរក្បាលជាមហារីក ឬដុំអីទេ? ដែលអាចធ្វើឲ្យគាត់វង្វេងវង្វាន់អ៊ីចឹងដែរ។ យើងខិតខំរកមើល ហើយឃើញ-- ពួកយើងខ្ញុំជំនាញនេះក៏បានផ្អែកមើលរបាយការណ៍នៅមន្ទីរកាល់ម៉ែតហ្នឹង គឺគេបានពិនិត្យមើលឈាម ហើយគេបានពិនិត្យមើលមុខងារនៃក្រពេញបំពង់ក ក្រពេញបញ្ចេញក្នុងគេហៅ ក្រង់*ទីរ៉ូអ៊ីត* ឬ*ថាយរ៉ថខ្លែន* (thyroid glands) ហ្នឹង មើលទៅ ឃើញថា វាធម្មតាទេ។ ហើយយើងមើលខាងអាស៊ីតហ្វូលីក-- ហ្វូលីកអាស៊ីតហ្នឹង ហើយនិងវីតាមីនបេ១២អី យើងមើលទៅដូចអត់មានទេ។

[១០:១៤:២៥]

ដូច្នេះគ្មានមូលហេតុណាមួយដែលថា យើងអាចព្យាបាលទៅឲ្យគាត់បាត់វង្វេងវង្វាន់ អត់មានមូលហេតុហ្នឹងទេ។ ហើយសូម្បីតែស៊ីធីស្កេន ហ្នឹង យើងសង្កេតមើលទៅ អត់មានបង្ហាញថា អ្នក--

លោកស្រី អៀង ធីរិទ្ធ ហ្នឹងគាត់មានដុំអីណាមួយដែលយើងត្រូវព្យាបាលអីឲ្យជាដាច់ទេ។ ហើយ ចំណែកការបង្ករោគអីហ្នឹង គឺមើលនៅក្នុងរបាយការណ៍ហ្នឹង ក៏អត់មានដែរ ហើយយើងពិនិត្យមើលទៅ ឃើញថា គ្មានមូលហេតុណាមួយដែលយើងព្យាបាលទៅឲ្យជា ហើយធ្វើឲ្យគាត់បាត់វង្វេងទេ អត់មាន ទេ។

[១០:១៥:00]

ដូច្នេះនៅសល់តែ១ជំងឺមួយ ដូចដែលលោក ឌុចទ័រ ហ្វាស៊ែល ហើយនិងក្រុមយើងខ្ញុំ បានឯកភាពហ្នឹង គឺថារោគសញ្ញាដែលយើងគិតថាប្រហែលបំផុតនុ៎ង គឺជាជំងឺវង្វេងវង្វាន់ ដែល បណ្តាលមកពី អាល់ហ្សៃមើ ជាជំងឺ *អាល់ហ្សៃមើ ឌីស៊ីស* ហ្នឹង ជំងឺ*អាល់ហ្សៃមើ*ហ្នឹង។ ហើយនៅ ក្នុងជំងឺ*អាល់ហ្សៃមើ*ហ្នឹង គឺយើងអាចព្យាបាលហ្នឹង គឺថាយើងអាចជួយបានខ្លះ។ ជួយឲ្យ ជួយលើកគឺ ថាឲ្យការចង-- បញ្ហាស្មារតីគាត់បានធូរស្រាលខ្លះ។ ប៉ុន្តែគ្រាន់ឲ្យជាដាច់តែម្តងហ្នឹង ដូចតាមដែលខ្ញុំដឹង តាមដែលអ្នកវិទ្យាសាស្ត្រក្នុងលោកកំពុងស្រាវជ្រាវនោះ មិនទាន់មានថ្នាំណាដែលថាព្យាបាលឲ្យជាដាច់ ប៊ិតនោះទេ។

ព្រោះហេតុអីបានអ៊ីចឹង? ដោយសារមូលហេតុដែលបង្កឡើងដោយ បង្កឲ្យកើតមានជំងឺហ្នឹង គឺថាគេមិនដឹងច្បាស់ទេ ថាស្អីបានបង្កឡើង? គេដឹងថាគ្រាន់តែថានៅក្នុងកោសិកាខួរក្បាលគាត់ហ្នឹង គឺ គេថា ខ្ញុំមិនដឹងជាខ្មែរគេថាម៉េចទេ ដោយសារមានកោសិកាខួរក្បាលហ្នឹង បើនិយាយសរុបឲ្យស្រួល ណា កោសិកាខួរក្បាល គាត់ខូចតែម្តង ហើយគេសួរថា ខូចដោយសារអី? អ្នកវិទ្យាសាស្ត្រក្នុងលោក ហ្នឹងរកមិនទាន់ឃើញទេ។ ប៉ុន្តែគេគ្រាន់តែគេរកថ្នាំខ្លះ ដើម្បីជួយឲ្យការ ចងចាំអីគាត់ហ្នឹងបានធូរស្រាលខ្លះ។ ប៉ុន្តែការធូរស្រាលនោះ ក៏នៅមានកម្រិតនៅឡើយ មិនគួរជាទីពេញចិត្តសម្រាប់គ្រួសារ ក៏ដូចជាគ្រូពេទ្យនៅឡើយទេ។ ខ្ញុំសូមអស់យោបល់។

[១០:១៦:៤៥]

**ស៖** អរគុណ។ ខ្ញុំសូមអនុញ្ញាតលោកប្រធានដើម្បីសួរសំណួរបន្តទៀត។ សំណួរបន្តទៀត គឺសុំ សួរថាតើមានលទ្ធភាពដើម្បីវិនិច្ឆ័យរោគចុងក្រោយទៅលើមូលហេតុនានានៃជំងឺវង្វេងស្មារតីនៅលើអ្នក ជំងឺណាម្នាក់បានដែរឬទេ? យើងអាចនិយាយម្យ៉ាងទៀតថា តើមានលទ្ធភាពដើម្បីដាក់បញ្ចូលនូវមូល ហេតុច្បាស់លាស់ជាក់លាក់មួយចំនួនបានដែរឬទេ ក្នុងខណៈដែលផាត់ចោលនូវមូលហេតុដទៃទៀត?

**ឆ៖** សូមទោស ខ្ញុំដូចអត់ទាន់យល់។ សូមសួរឲ្យច្បាស់ម្តងទៀត។ សូម--

**ស៖** បាទ, ខ្ញុំចង់ដឹងថា តើមានលទ្ធភាពដើម្បីរកឲ្យឃើញនូវមូលហេតុនានានៃជំងឺវង្វេងស្មារតីហ្នឹង។ ហើយក្នុងមូលហេតុហ្នឹង តើយើងអាចយកមូលហេតុណាមួយដើម្បីធ្វើការវិនិច្ឆ័យ ហើយដើម្បីព្យាបាលឲ្យចំប្រភេទនៃរោគវិនិច្ឆ័យហ្នឹងដែរឬទេ? ប្រសិនបើមាន តើលោកវេជ្ជបណ្ឌិតឲ្យយោបល់ថាគួរប្រើវិធីសាស្ត្រព្យាបាលបែបណា ឬក៏ត្រូវការពេលយ៉ាងដូចម្តេចដើម្បីព្យាបាលក្នុងករណីនេះបាទ? សូមអរគុណ។

**ឆ៖** តាមដែលខ្ញុំយល់សំណួររបស់លោក លោកសួរថា តើដើម្បីរកឲ្យឃើញមូលហេតុនានាមូលហេតុផ្សេងទៀត ដែលធ្វើឲ្យគាត់វង្វេងវង្វាន់នោះ តើយើងមានលទ្ធភាពច្រើនជាងហ្នឹង មានបន្ថែមជាងហ្នឹងដើម្បីរកឲ្យឃើញ ឲ្យប្រាកដថាគាត់ពិតជាមានមូលហេតុផ្សេងទៀតដែលធ្វើឲ្យឃើញវង្វេងវង្វាន់អ៊ីចឹងមែនទេបាទ? តាមដែលខ្ញុំពិនិត្យមើលឯកសាររបស់មន្ទីរពេទ្យកាល់ម៉ែត មើលទៅឃើញថាដូចជាលទ្ធភាពដែលយើងរកនោះសព្វគ្រប់ដែរហើយ។ ដូចជាយើងសង្ស័យថាក្រែងលោមានដុំអីនៅក្នុងខួរក្បាល ដែលវារំខានទៅដល់ដំណើរការប្រក្រតីរបស់ខួរក្បាល ដែលធ្វើឲ្យគាត់វង្វេងវង្វាន់ហ្នឹងយើងអត់ឃើញមានទេដែរ។

[១០:១៨:៥២]

ប្រសិនបើមានគឺថាតាមរយៈ ស៊ីធីស្កេន ឬក៏*អ៊ិមរ៉ាយ*ហ្នឹង គឺថាយើងអាចឃើញហើយ។ ហើយនេះតាមរយៈរូបភាពវេជ្ជសាស្ត្រ។ ហើយតាមរយៈរោគសញ្ញាខាងក្រៅប្រសិនបើ គាត់មានរោគ មានដុំខួរក្បាលអ៊ីចឹងមែន វាអាចមានរោគសញ្ញាមកដៃអី មកជើងអី ដែលតាមរយៈសរសៃប្រសាទហ្នឹង យើងអាចស្ដែងជឿឃើញរូបភាពខាងក្រៅហើយ។ ប៉ុន្តែយើងសង្កេតតាមការពិនិត្យឃើញទៅថាអាសញ្ញាខាងក្រៅហ្នឹង វាអត់មាន ហើយយើងមើលហ្វីលរូបថតហ្នឹង លោកជំនាញហ្នឹងក៏បញ្ជាក់ថាដូចអត់មានដុំអីទេ ដែលយើងសង្ស័យអត់ទេ។ ហើយរោគសញ្ញានៃការបង្ករោគ ដែលភាសាបារាំងហៅថា *អាំងហ្វិកស្យុង* ហើយភាសាអង់គ្លេសហៅថា *អ៊ីនហ្វិកស៊ិន* ហ្នឹង ខ្មែរថា ការបង្ករោគ ដូចជាមានជំងឺដូចថាមានមេរោគបាតេរី ឬក៏វីរុស ស្អីដែលធ្វើឲ្យគាត់ឈឺហ្នឹង គឺថាអត់មានទេ។ ប្រសិនបើមានអ្នកជំងឺត្រូវក្តៅខ្លួន ឬក៏មានក្អក មានអី រលាក ឈឺអីត្រង់ណាមួយអ៊ីចឹង ឬក៏ឈឺតម្រង់នោម ឈឺអីហ្នឹង គឺថាអត់មានរោគសញ្ញាហ្នឹងទេ។

[១០:២០:០០]

ហើយយើងអាចមើលដឹងឈាមអាចដឹង ហើយគ្រូពេទ្យដែលព្យាបាលគាត់ប្រចាំថ្ងៃហ្នឹង គួរ

ដូចអត់មានបញ្ហាក់ថាមានអីមានរោគសញ្ញាអីធំដុំ ហើយបើមានតិចតួច ក៏លោកវេជ្ជបណ្ឌិតដែលព្យាបាលគាត់រាល់ថ្ងៃ គាត់ព្យាបាលបាត់ហើយ។ ហើយយើងឃើញថាគាត់នៅតែវង្វេងដដែល ដូច្នេះអត់មានមូលហេតុ *អ៊ីនហ្វិកស៊ិន* ហ្នឹង អត់មានមូលហេតុបង្ករោគហ្នឹង ដែលយើងត្រូវគិតថា ប្រហែលជាអាហ្នឹង បានធ្វើឲ្យគាត់វង្វេងវង្វាន់ហ្នឹង គឺអត់មានទេ។ ហើយដូចជាមូលហេតុដោយសារការបង្ករោគ-- ការវង្វេងវង្វាន់ដោយសារក្រពេញបញ្ចេញក្នុង ទីរ៉ូអ៊ីត នេះ គេហៅ ដោយសារមូលហេតុ ក្លង់ទីរ៉ូអ៊ីតហ្នឹង *ថាយរ៉ូថក្លែន* ហ្នឹង គឺក៏ឃើញ-- យើងអាចដឹងបានថា វាខុសធម្មតា ឬធម្មតា តាមរយៈការពិនិត្យឈាមនោះ។ ក៏យើងឃើញក្នុងរបាយការណ៍នៅមន្ទីរពេទ្យកាល់ម៉ែត ដែលគេឆែកមើលទៅហ្នឹងគេពិនិត្យមើលក៏អត់មានឃើញអីដែលថាមិនធម្មតាគួរឲ្យកត់សម្គាល់ដែរ។

[១០:២០:៥៨]

ហើយសូម្បីតែនៅក្នុងរបាយការណ៍របស់លោក ខាំប៊ែល តាមដែលខ្ញុំបានអានហ្នឹង គាត់ក៏បានលើកដែរថា គាត់ឆែកមើលដែរ គឺគាត់អត់មានឃើញដែរ។ ហើយមូលហេតុដូចជាខ្វះ ដូចជាវីតាមីនបេ១២ ឬក៏អាស៊ីហ្វូលិក--ហ្វូលិកអាស៊ីអីហ្នឹង ក៏ដូចខ្ញុំឃើញនៅក្នុងរបាយការណ៍ការវិភាគរបស់មន្ទីរពិសោធន៍ មើលទៅគឺដូចអត់មានឃើញអីដែរ។ ហើយយើងសង្កេតមើលទៅឃើញថា ដូចអត់ៗមានមូលហេតុណាទៀត ដែលយើងត្រូវរកទៀតទេ។ ហើយបើសិនជាមាន យើងៗជឿថាយើងនឹងមានលទ្ធភាពរក ដូចថាឥឡូវហ្នឹងគឺថា វិទ្យាសាស្ត្រយើងក៏ជឿនលឿនគួរសមដែរ ហើយមន្ទីរពេទ្យនៅស្រុកខ្មែរយើងក៏ដូចជាមានម៉ាស៊ីនអី ប្រដាប់ប្រដាអីថតហ្នឹង វាទំនើបគួរសមដែរ យើងនឹងអាចរកបានហើយ។ ប៉ុន្តែតាមរយៈអ្នកជំនាញមុនៗមក ក៏គេបានគិតគូរខ្លះដែរពីបញ្ហាហ្នឹង។ ហើយមកដល់ខាងវេនយើងខ្ញុំហ្នឹង ក៏យើងខ្ញុំបានគិតគូរដែរ។ គិតគូរថា តើមូលហេតុណាដែលយើងអាចព្យាបាលឲ្យជាដាច់ ដើម្បីឲ្យគាត់ឈប់វង្វេងវង្វាន់ ប៉ុន្តែអត់មានទេ អត់មានមូលហេតុទេ។ ហើយឃើញថាលទ្ធភាពដែលយើងមាននោះ គឺគ្រប់គ្រាន់នឹងស្រាវជ្រាវរកហើយ ប៉ុន្តែវាអត់មានមូលហេតុណាទៀត ដែលយើងសង្ស័យថា មូលហេតុដែលព្យាបាលជានោះ វាអត់-- ដែលព្យាបាលជាដាច់នោះ អត់មានទេ ដែលភាសាបច្ចេកទេស គេថា *អាន់ដឺឡាយអ៊ីង ខន់ឌីសិន* (inderlying condition) ហ្នឹង គឺវាអត់មានទេ។ ចង់និយាយថា មូលហេតុដែលនៅពីក្រោយអាការវង្វេងវង្វាន់ហ្នឹង យើងអត់មានទេ។ បាទៗ យើងសង្ខេបមក យើងគិតថា ប្រហែលជាគឺថាដែលជា-- ប្រហែលជាងគេនោះ អង់គ្លេសថា *ម៉ូសឡៃលី* គឺរោគវិនិច្ឆ័យនេះ គឺថាវា *ឌីមែនស្យា* នៅក្នុងទម្រង់មួយ គេថា *អាល់ហ្សៃមើ*។ ហេតុម៉េចបាន ខ្ញុំកន្លែង

នេះ ខ្ញុំចង់ទាញអារម្មណ៍ ថាហេតុម៉េចបើយើងនិយាយថាប្រហែល ពីព្រោះពាក្យថា ដូចលោកហ្វាស៊ែល គាត់បានមានប្រសាសន៍ហើយ អារោគ ការធ្វើរោគវិនិច្ឆ័យថាមួយរយភាគរយ *អាល់ហៃស្សមើ* នោះ លុះត្រាតែយើងយកកោសិកាខួរក្បាលយើងទៅពិនិត្យនៅមន្ទីរពិសោធ។

[១០:២៣:១៣]

ហើយបានយើងអាចធ្វើរោគវិនិច្ឆ័យមួយរយភាគរយថា គាត់ប្រាកដជា *អាល់ហៃស្សមើ* ជាជំងឺវង្វេងវង្វាន់ប្រភេទ *អាល់ហៃស្សមើ* បាន។ ប៉ុន្តែក្នុងការអនុវត្ត យើងមិនអាចយកសាច់ខួរក្បាលមនុស្សទៅពិនិត្យអ៊ីចឹងបានទេ។ គេធ្វើបាននៅពេលអ្នកជំងឺហ្នឹងស្លាប់ហើយ គេយក គេថា *ផូសម័រធឹម* ហ្នឹង គឺថាគេយកខួរក្បាលហ្នឹង យកទៅពិនិត្យបាន។ ប៉ុន្តែទោះបីជាយើងមិនអាចយកកោសិកាខួរក្បាលរបស់មនុស្សនោះទៅពិនិត្យបានក៏ដោយ តាមរយៈការពិនិត្យខាងក្រៅ គឺថាមូលហេតុហ្នឹង គឺថាសមរម្យល្មមនឹងអាចយើងធ្វើរក-- នឹងទទួលយកបាន ថាយើងអាចធ្វើរោគវិនិច្ឆ័យថា គាត់ជា*អាល់ហៃស្សមើ* បាន។ បើសិនជាព័ត៌មានមិនគ្រប់ លោកអាចសួរបន្ថែមបាន។

[១០:២៤:១០]

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញ! ម៉េចហើយ?

**លោក អាង ឧត្តម៖**

សូមលោកប្រធានមេត្តាអនុញ្ញាតឲ្យលោក អៀង សារី ចូលរួមសវនាការនៅជាន់ក្រោម គឺគាត់អង្គុយលែងបានតទៅទៀតហើយ ទាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណលោកមេធាវី។ អង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំ។ អនុរក្សមន្ទីរឃុំឃាំងអាចនាំគាត់ទៅតាមដានដំណើរការសវនាការនៅបន្ទប់រង់ចាំ ដែលមានបន្តផ្ទាល់ដោយសោតទស្សន៍នៅខាងក្រោមនេះ។ សូមអញ្ជើញ!

សូមអញ្ជើញលោកអ្នកជំនាញអន្តរជាតិ ដើម្បីបន្តនូវការឆ្លើយបន្ថែម បាទ។

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** បាទ ខ្ញុំសូមបន្ថែម អ្វីដែលយើងបានធ្វើនោះ យើងចង់ដកចេញនូវមូលហេតុមួយចំនួនទាក់ទងទៅនឹងជំងឺ *ឌីមែនស្យា* ដែលយើងរកមើលឃើញដូចជា ខ្វះវីតាមីនបេឌូ(B12) ហើយនិងអាស៊ីតហ្វូ

លិក ។ល។ ប៉ុន្តែសេចក្តីសន្និដ្ឋានជំងឺនេះ គឺថាអាចជាជំងឺផ្លូវឈាមផងដែរ គឺថាដើម្បីឲ្យឃើញច្បាស់ដូចដែលខ្ញុំជម្រាបអ៊ីចឹង គឺអាចនឹងពិនិត្យខួរក្បាលក្រោយពេលដែលស្លាប់ឯណោះទេ។ ដូច្នេះ ហើយយើងរកឃើញថាតើជំងឺសរសៃឈាមនៅក្នុងខួរក្បាលអាចជាមូលហេតុដែរឬទេ? អ៊ីចឹងក្នុងការរកដំណោះស្រាយ ឬការព្យាបាលនោះយើងបញ្ជាក់នៅក្នុងរបាយការណ៍យើងខ្ញុំហើយ គឺថាវិធីមួយចំនួនដែលអាចនឹងបង្កើនគុណភាពជីវិត ប៉ុន្តែអាចនឹងធ្វើឲ្យសម្បទារបស់អ្នកជំងឺមានជំងឺ*ឌីមែនស្យា* វង្វេងវង្វាន់នេះបានខ្លះ ក៏ប៉ុន្តែដូចជាវិធីដែលសាស្ត្រាចារ្យ ខាំប៊ែល បានស្នើហ្នឹងកាត់បន្ថយការប្រើថ្នាំ ឬការប្រើថ្នាំ ហើយនិងការកែប្រែនូវបរិស្ថាន បរិយាកាសជុំវិញ កម្មវិធីមួយចំនួន ដើម្បីជំរុញនូវការចងចាំការគិតគូររបស់គាត់ដែលអាចប្រើបាន។ ដូច្នេះចំណុចនោះទាំងអស់នោះ យើងខ្ញុំបានបញ្ជាក់នៅក្នុងរបាយការណ៍ស្រាប់។

[១០:២៦:៣៣]

**ស៖** អរគុណលោកអ្នកជំនាញទាំងពីរដែលបានឆ្លើយសំណួររបស់ខ្ញុំ។ ខ្ញុំសូមអនុញ្ញាតបន្តសំណួរតទៅទៀត។ ជាទូទៅ តើជំងឺវង្វេងស្មារតីដែលជាមូលហេតុបណ្តាលមកពីជំងឺបាត់ការចងចាំ ឬវង្វេងវង្វាន់ អង់គ្លេសហៅថា *អាល់ហ៊ែមើ* នោះអាចមានមូលហេតុផ្សេងណាទៀតដែលធ្វើឲ្យវាមានសភាពកាន់តែយ៉ាប់យ៉ឺនទៅទៀតដែរឬទេ?

**ឆ៖** ដូច្នេះកាលដែលយើងបង្ហាញឲ្យឃើញដែលអាចនឹង ថាអ្នកជំងឺអាចមានជំងឺរាងកាយដូចជាការបង្កជំងឺ ឬក៏ការឈឺចាប់អ្វីខ្លាំងដែលធ្វើឲ្យអ្នកជំងឺមានរោគសញ្ញាជំងឺវង្វេងវង្វាន់ បើសិនជាអាការៈហ្នឹងធ្ងន់ យើងមើលឃើញតាមអាការៈខាងក្រៅ។ ប៉ុន្តែបើយើងមើលមុខងារសតិបញ្ញាវិញ គឺថាមនុស្ស ឬក៏បុគ្គលតែងតែវាមានការឡើងចុះនៅក្នុងបញ្ញា ប្រសិនបើជំងឺហ្នឹងមិនបានព្យាបាលទេ។ ដោយរាប់បញ្ចូលអ្វីដែលវេជ្ជបណ្ឌិត លីនណា ថាដូចជំងឺធ្លាក់ទឹកចិត្ត ហើយជាពិសេស គឺយើងពិនិត្យមើលកត្តាផ្សេងៗទៀតនោះឯង។

**ស៖** អរគុណអ្នកជំនាញដែលបានឆ្លើយ។ ខ្ញុំសូមបន្តទៀត តើជំងឺវង្វេងស្មារតីដែលមានសភាពមធ្យមមានរោគសញ្ញាយ៉ាងដូចម្តេចខ្លះទៅដែលស្តែងឲ្យឃើញនូវរូបភាពខាងក្រៅ ដែលយើងអាចមើលឃើញ ហើយវាអាចប៉ះពាល់យ៉ាងខ្លាំងក្លាទៅដល់ការនិយាយស្តី ឬអង្គុយ ឬក៏ជីវិតធម្មតារបស់គាត់ហ្នឹងយ៉ាងដូចម្តេចខ្លះទៅបាទ?

[១០:២៨:៤២]

**លោក ហួត លីនណា៖**

**ឆ៖** ទាក់ទងនឹងការ-- ខ្ញុំសូមបញ្ជាក់ថា ការដែលគាត់ធ្លាក់ចុះផ្នែកបញ្ញាស្មារតីគាត់ហ្នឹង មានន័យថា អង់គ្លេសថាជា *ខគនីធីវ ហ្វាំងសិន* (cognitive function) គាត់ធ្លាក់ចុះបន្តិចហ្នឹង គាត់ចុះខ្សោយបន្តិចហ្នឹង ហើយដូច-- អាហ្នឹងជារោគសញ្ញាមួយនៃជំងឺ *អាល់ហ្សៃមើ* ហ្នឹង ហើយតាមដែលខ្ញុំយល់សំណួរលោក លោកបានសួរថា តើវាមានរោគសញ្ញាអ្វីខ្លះដែលវាចុះថយមធ្យមហ្នឹង។ ការៗដែលខ្ញុំបានធ្វើតេស្តដូចខ្ញុំបានជម្រាប ពីម្សិលមិញហ្នឹង គឺយើងបានធ្វើតេស្ត យើងធ្វើ *មីនីមេនសិន ស្តេត អ៊ិចសាមីណេសិន* យើងធ្វើទៅយើងសួរតាំងពីការដឹងពេលវេលា ទីកន្លែង ខែ ឆ្នាំ ថ្ងៃរដូវអីហ្នឹង។ សួរគាត់ទៅគឺថា គាត់មានការចុះថយ យើងសរុបនិយាយទៅវាមិនមែនតែរោគសញ្ញាមួយអីដែលយើងអាចសន្និដ្ឋានបានទេ។

[១០:៣០:០៣]

យើងមានរោគសញ្ញាច្រើនផ្សំគ្នាទើបយើងអាចសន្និដ្ឋានថា ការចុះថយផ្នែកបញ្ញាស្មារតីនោះកម្រិតណា។ ហើយចំពោះលោកស្រី អៀង ធីរិទ្ធ ដែលគាត់មានការចុះខ្សោយបញ្ញាស្មារតីដែលយើងកំណត់ថាគាត់នៅក្នុងកម្រិតមធ្យមនោះ ដោយសារយើងបានធ្វើតេស្តទៅ ហើយគាត់បានពិន្ទុត្រឹមតែពី ១៥លើ៣០ នៅថ្ងៃទីមួយ ហើយ ១៨លើ៣០ នៅថ្ងៃទីពីរ។ ហើយការដែលយើងធ្វើនេះ យើងកត់សម្គាល់ឃើញថា គាត់ចុះខ្សោយខ្លាំងជាងគេនៅផ្នែកខាងការដឹងពេលវេលា ទីកន្លែង និងមនុស្ស។ បាទ យើងធ្វើតេស្តទៅ យើងសួរពីរដូវ ឆ្នាំ រដូវ កាលបរិច្ឆេទ ថ្ងៃ ខែ ប្រទេស ខេត្ត ទីក្រុង ផ្លូវ ការិយាល័យ ឬក៏កន្លែងដែលគាត់នៅហ្នឹង គឺគាត់មានការចុះខ្សោយមែនទែន។ ហើយគាត់ចុះខ្សោយមួយទៀត គឺការចុះខ្សោយការដែលគាត់រំឭកឡើងវិញនូវៗវត្ថុបីយ៉ាងដែលយើងឲ្យគាត់ថាតាម មិនមែនគាត់ចំណាំវត្ថុទេ មិនមែនទេ គឺថាយើងឲ្យគាត់និយាយ ឧទាហរណ៍ជាវត្ថុបីយ៉ាងដែលមិនទាក់ទងគ្នា ពីព្រោះចៀសវាងការឆ្លើយនោះ ចម្លើយដែលគាត់យកមកគឺថាវាអត់បានការ។ ដូច្នេះយើងឲ្យសួរគាត់ឲ្យគាត់ថាតាមពាក្យបីម៉ាត់ដែលពាក្យហ្នឹងមិនទាក់ទងគ្នាទេ។ មានន័យថា បើយើងចាំពាក្យមួយ អាពាក្យមួយហ្នឹងមិនអាចជួយឲ្យយើងចាំ នឹកឃើញពាក្យមួយហ្នឹងទេ។ ហើយបើសិនជាអាពាក្យទីពីរ បើយើងនឹងឃើញអាពាក្យទីពីរៗហ្នឹងមិនជួយឲ្យយើងនឹកឃើញដល់ពាក្យទីបីទេ គឺយើងសួរពាក្យដាច់ៗគ្នាអ៊ីចឹង ហើយគាត់ថាតាមបាន ដូច្នេះអាហ្នឹងបានពិន្ទុ ហើយ ប៉ុន្តែដល់ពេលគាត់រំឭកឡើងវិញ គាត់នឹកអត់ឃើញទេ។ បាទ នឹកអត់ឃើញទេ ត្រង់ចំណុចហ្នឹង ហើយក៏គាត់ខ្សោយត្រង់ពីរចំណុចហ្នឹង។ ហើយពេលដែលគាត់

ឲ្យៗគាត់សរសេរជាឃ្លាអីហ្នឹង គឺថ្ងៃទីមួយសរសេរបាន ថ្ងៃទីពីរគាត់សរសេរអត់បាន ដូច្នេះគាត់អត់បានពិន្ទុទេ។ គឺថាសរុបមកហ្នឹងគឺគាត់បាត់ពិន្ទុច្រើនណាស់ បាត់ពិន្ទុច្រើន ដូច្នេះ បានចន្លោះពី ១៥ ១៨ ទោះបីជាកើនឡើងបន្តិចនៅថ្ងៃទីពីរ ក៏ប៉ុន្តែវាស្ថិតនៅក្នុងកម្រិតមធ្យមដែលចន្លោះពីដប់ទៅម្ភៃដដែល។

[១០:៣២:៥៤]

ហើយយើងបានធ្វើការបែងចែកថា គាត់ហ្នឹងនៅក្នុងកម្រិតទីប្រាំដូចលោកចៅក្រមពីម្សិលមិញគាត់បានសួរនៅកម្រិតទីប្រាំហ្នឹង គឺក្នុងនេះគឺថាវាមាន ដោយសារភាសាបច្ចេកទេសគេថា *អីលីឌីមែនស្យា* មានន័យថាគាត់ទើបតែចាប់វង្វេងវង្វាន់ទេ។ ហើយត្រង់ចំណុចនេះ ខ្ញុំជឿថាអង្គសវនាការក៏ប្រហែលជាឆ្ងល់ថា ចុះបើថាប្រាំបាន ចុះម៉េចមិនថាបួន ម៉េចមិនព្រមថាប្រាំមួយ ម៉េចក៏នឹកឃើញអីថាចំប្រាំ។ ពីព្រោះនៅក្នុងនេះយើងឃើញថា ខ្ញុំមានចំណុចមួយចំនួនដែលយើងខ្ញុំទាំងគ្នាបានពិភាក្សាគ្នាទៅ ហើយឯកភាពគ្នាជាឯកច្ឆន្ទថា គាត់ប្រហែលជានៅក្នុងកម្រិតទីប្រាំនៅក្នុងចំណោមកម្រិតទាំងប្រាំពីរ ប្រាំពីរហ្នឹងគឺធ្ងន់ធ្ងរជាងគេហើយ។ ហើយគាត់ទើបតែទីប្រាំទេ ដោយសារអី? ដោយសារនៅក្នុងហ្នឹងគឺថា គាត់ក្នុងនេះ ខ្ញុំសូម គាត់ថា គាត់មិនអាចនឹកឃើញនូវហេតុការណ៍សំខាន់ៗជាច្រើនដែលទាក់ទងនឹងជីវិតរបស់គាត់ ដូចជាអាសយដ្ឋាន ហើយលេខតេឡេហ្វូន ឬក៏ឈ្មោះ ប៉ុន្តែលេខតេឡេហ្វូនកន្លែងនេះ ក្នុងករណីនេះគឺគាត់មិនអាចទាក់ទងទេ ប៉ុន្តែចាំឈ្មោះ គឺគាត់អត់ចាំឈ្មោះរបស់ៗសាច់ញាតិដែលជិតៗ មានន័យថាដូចជាកូន ដូចជាអីហ្នឹង គាត់អត់ចាំ ដូច្នេះគឺថា-- ហើយឈ្មោះរបស់សាលាដូចជាសាលាបឋមសិក្សាអី សួរគាត់ គាត់អត់ចាំ។ ហើយៗការដឹងពីពេលវេលាហ្នឹង គាត់អត់សូវច្បាស់ ហើយទីកន្លែងគឺសួរគាត់ទៅ គាត់អត់ដឹងថាកន្លែងហ្នឹងជាកន្លែងអី? គាត់ថាកន្លែងហ្នឹងជាកន្លែងជាន់ទីមួយ ហើយកន្លែងដែលយើងសម្ភាសន៍គាត់ហ្នឹង គាត់អត់ដឹងថាកន្លែងហ្នឹងជាមន្ទីរឃុំឃាំងទេ។

[១០:៣៥:០០]

ហើយយើងសង្កេតឃើញថា គាត់ហ្នឹងគាត់នៅក្នុងកម្រិតទីបួន ហើយយើងថា ម៉េចមិនព្រមថាកម្រិតទីប្រាំ ថាអីត្រឹមទីបួន។ ពីព្រោះថានៅក្នុងកម្រិតទីប្រាំ ម៉េចមិនថាទីប្រាំ ម៉េចមិនថាទីបួន។ តែកាលណានៅក្នុងកម្រិតទីបួនហ្នឹង គឺគាត់អត់មានការវង្វេងវង្វាន់ទេ។ នៅក្នុងនេះគឺចែងថា ការវង្វេងវង្វាន់ទាក់ទងនឹងពេលវេលា និងមនុស្សហ្នឹង គាត់អាហ្នឹងគាត់អត់មាន។ ហើយគេស្គាល់ បុគ្គលហ្នឹងស្គាល់គ្រួសារ ស្គាល់គ្រួសារបងប្អូនអីចឹង ស្គាល់ឈ្មោះ ស្គាល់អីហ្នឹង។ ហើយដោយសារលោកស្រី

អៀង ធីរិទ្ធ ហ្នឹងគាត់មាន គាត់ថាគាត់អត់ស្គាល់ គាត់អត់ដឹង ដូច្នេះគាត់មានន័យថា គាត់ឆ្លង គាត់ហួសអាកម្រិតហ្នឹងហើយ។ ដូច្នេះវាហួសពីបួន គឺថាចូលប្រាំហើយ ចុះម៉េចមិនថា យើងអាចថា យើងអាចឆ្ងល់ថា ម៉េចក៏មិនប្រាំមួយ។ អាប្រាំមួយនេះ គឺថាវាមានរោគសញ្ញាបន្ថែម មានរោគសញ្ញាបន្ថែម ដូចជាការយល់ដឹងខុស ភាសាអង់គ្លេសហ្នឹង គេហៅថា *ឌីលីស៊ីណល ប៊ីហេវីយ័រ* ហ្នឹង គឺថាការគិត ការជឿជាក់ហ្នឹងខុស។

[១០:៣៦:១៤]

ហើយគាត់មានការដែលធ្វើអីដដែលៗ ហើយគាត់អាចមានអារម្មណ៍អីឡេះឡះអ៊ីចឹង។ ប៉ុន្តែនៅក្នុងពេលដែលយើងទៅពិនិត្យគាត់ហ្នឹង គាត់អត់មានរោគសញ្ញាហ្នឹងទេ។ ហើយកន្លែងទាក់ទងត្រង់ហ្នឹងធ្វើឱ្យខ្ញុំនឹកឃើញដល់ពាក្យដែលថា គាត់ទុកអីរបស់អី ដែល-- ទុករបស់អីមានគេលួចមានអីនោះ។ អាហ្នឹងឃើញថាពីមុនទេ ពេលដែលខ្ញុំបច្ចុប្បន្នខ្ញុំទៅមើលគាត់អត់មានទេ។ ហើយដូចចង់បញ្ជាក់ថា រោគសញ្ញាបន្ថែមដែលខ្ញុំលើកឡើងនៅក្នុងដំណាក់ទីប្រាំមួយគាត់អត់មានទេ។ ហើយអ៊ីចឹងបានជាក្រុមយើងខ្ញុំហ្នឹងគិតថា គាត់មិនចូលដល់ទីប្រាំមួយទេ ហើយគាត់ក៏មិនទីបួន គឺហួសអាទីបួនហើយ។ ដូច្នេះវាចូលអាទីប្រាំហ្នឹងហើយបាទ។

[១០:៣៧:០២]

**ស៖** បាទ សូមអរគុណលោកវេជ្ជបណ្ឌិត ហួត លីនណា។ ខ្ញុំសូមអនុញ្ញាតបន្តសំណួរទៅទៀត ខ្ញុំចង់ដឹង ការយល់ឃើញរបស់លោក យោងទៅលើសុខភាពរបស់ជនចាប់ចោទ អៀង ធីរិទ្ធ។ ថាតើជនជាប់ចោទ អៀង ធីរិទ្ធ ហ្នឹង អាចអង្គុយ ឬក៏និយាយ ឬក៏អាចឈរហ្នឹង បានក្នុងរយៈម្ដងប្រហែលជាបានប៉ុន្មាននាទីដែរ? តាមលោកយល់ឃើញទៅលើកាយសម្បទា ឬក៏សុខភាពរបស់គាត់។ បាទ ខ្ញុំចង់ដឹងបញ្ហានេះ។ សូមអរគុណ។

[១០:៣៧:៣៤]

**លោក ស៊ីណា ហ្វាសែល៖**

**ឆ៖** យើងអាចនិយាយតាមបទពិសោធន៍របស់យើង លោកស្រីអាចឱ្យយើងសម្ភាសន៍រយៈពីរម៉ោងបាន ដោយមិនឃើញសម្ដែងនូវអាការៈអ្វីទេ។ ហើយក៏មិនចាំបាច់សម្រាកផងដែរក្នុងរយៈពេលពីរម៉ោងនោះ ហើយលោកស្រីក៏មិនបានលើកឡើងថា គាត់ចង់សម្រាកដែរក្នុងរយៈពេលសម្ភាសន៍ពីរម៉ោងនោះ។

**សៈ** អរគុណលោកអ្នកជំនាញ។ ចំពោះសំណួរបន្តខ្ញុំចង់ដឹងអំពីការយល់ឃើញរបស់លោកទៅលើការវាយតម្លៃសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ។ នៅក្នុងកថាខណ្ឌទី៤៦ កថាខណ្ឌទី៤៦ លោកបានសរសេរនៅក្នុងរបាយការណ៍របស់លោកថា លោកស្រី អៀង ធីរិទ្ធ ពិតជាមានសមត្ថភាពដើម្បីយល់ដឹងអំពីបទចោទប្រកាន់បាន។ អ៊ីចឹងនៅក្នុងចំណុចនេះ ខ្ញុំចង់ដឹងថា លោកអ្នកជំនាញទាំងពីរនៅតែមានជំនឿថា សមត្ថភាពរបស់គាត់នៅតែយល់ដឹងច្បាស់អំពីបញ្ហាបទចោទប្រកាន់ហ្នឹង ពិតប្រាកដមែន ហើយនៅតែមានជំនឿហ្នឹងតទៅទៀត ឬយ៉ាងម៉េច?

បាទ, សូមអរគុណ។

[១០:៣៨:៥១]

**ឆៈ** មួយផ្នែកនោះ គឺវាអាស្រ័យទៅលើលក្ខខណ្ឌដែលយើងប្រើប្រាស់ក្នុងការវិនិច្ឆ័យដូច្នេះ។ ជាការពិត អ្វីដែលយើងបានរៀបរាប់នៅក្នុងរបាយការណ៍របស់យើងនោះ គឺថាលោកស្រីគាត់មានលទ្ធភាពមួយចំនួនក្នុងការយល់បទចោទ ទោះបីជាលោកស្រីគាត់មិនបានបដិសេធមិនពិភាក្សាលម្អិតទៅលើបទចោទទាំងអស់នោះជាមួយយើងខ្ញុំក៏ដោយ។ បទចោទមួយចំនួនគាត់មិនបានពិភាក្សាជាមួយយើងនោះទេ។ យើងបានរៀបរាប់រួចមកហើយ ដូចដែលយើងបានលើកឡើងកាលពីម្សិលមិញ ពាក់ព័ន្ធទៅនឹងសំណួរជាក់លាក់ ដែលលោកស្រីបានឆ្លើយតបមកកាន់យើង។

ដូច្នេះជាសរុបមក គឺថាលោកស្រីមានសមត្ថភាពខ្លះនៅក្នុងយល់ទៅលើបទចោទ។

[១០:៣៩:៤៥]

**សៈ** អរគុណលោកប្រធាន អរគុណលោកអ្នកជំនាញជាតិ និងអន្តរជាតិដែលបានឆ្លើយសំណួររបស់ខ្ញុំយ៉ាងក្បោះក្បាយ។ ដោយសារពេលវេលាអត់មាន ខ្ញុំសូមអនុញ្ញាតបញ្ចប់ការសួរសំណួររបស់ខ្ញុំនៅពេលនេះ ហើយសូមអនុញ្ញាតបន្តទៅសហការីអន្តរជាតិរបស់ខ្ញុំ គឺលោក ថារីក នឹងបន្តសួរសំណួរមួយចំនួនទៀត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណតំណាងសហព្រះរាជអាជ្ញាជាតិ ហើយដោយសារពេលសមល្មម ហើយនឹងឈប់សម្រាកហើយ។ ដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការរបស់យើង។

**លោក ឌុច ផារី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤១ នាទី ដល់ម៉ោង ១១:០៦ នាទី)*

[១១:០៦:៣១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ដេញដោលអ្នកជំនាញតទៅទៀត។ ហើយអម្បាញ់មិញនេះមុនសម្រាក គឺសហព្រះរាជអាជ្ញាជាតិបានតាំងសំណួររួចហើយៗបានចំណាយពេលវេលាអស់៣៥នាទី។ អ៊ីចឹងជាបន្តនេះ គឺសូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញាអន្តរជាតិ ដែលមានពេលរយៈពេល២៥នាទីក្នុងការសួរទៅអ្នកជំនាញនេះ។ សូមអញ្ជើញ!

[១១:០៧:១៧]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**ស៖** សូមជម្រាបលោកវេជ្ជបណ្ឌិត លីនណា ហើយនិងវេជ្ជបណ្ឌិត ហ្វាស៊ែល។ ខ្ញុំមានពេលកម្រិតណាស់ ដូច្នេះខ្ញុំថា សូមលោកផ្តល់អារម្មណ៍បើសិនជាខ្ញុំចាកប្រធាន សូមលោកប្រាប់ខ្ញុំផង។ ខ្ញុំនឹងព្យាយាមអស់ពីលទ្ធភាពដើម្បីធ្វើដូច្នោះ សួរឲ្យបានត្រង់ៗ។ ខ្ញុំនិយាយដោយសង្ខេបទាក់ទងទៅនឹងបញ្ហាដែលយើងបានបញ្ជាក់ពីព្រឹកមិញនេះហើយ ដែលនិយាយអំពីលទ្ធភាពនៃការឡើងចុះនៃផ្លូវអារម្មណ៍របស់គាត់ របស់អ្នកស្រី អៀង ធីរិទ្ធ នោះ ហើយខ្ញុំគិតថាវេជ្ជបណ្ឌិត លីនណា និយាយពីម្សិលមិញថា អ្នកស្រី អៀង ធីរិទ្ធ គឺថាអាចបំពេញបីដំណាក់កាល នៃការបត់ក្រដាស ដូចជាការយកក្រដាសបត់មកជាពីរ ហើយទម្លាក់ទៅលើកម្រាលឥដ្ឋ។ តើត្រូវដែរឬទេ?

[១១:០៨:៣៣]

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** បាទ, ត្រឹមត្រូវ។

**ស៖** តើលោកនៅចងចាំទេ តើសាស្ត្រាចារ្យ ខាំប៊ែល បានធ្វើដូចម្តេចនៅក្នុងរបាយការណ៍របស់គាត់? គាត់បានប្រើតេស្តជាក់លាក់បែបនេះដែរឬទេ?

**ឆ៖** ទេ, ខ្ញុំមិនចាំទេ។

**ស៖** ប្រហែលជាខ្ញុំចង់បញ្ជាក់ថា តើនៅក្នុងរបាយការណ៍នៅក្នុងកថាខណ្ឌ២៥ និយាយថា គាត់អាចបំពេញដំណាក់កាលពីរដំបូង ហើយនិងដំណាក់កាលទីបីធ្វើមិនបាន។ តើលោកនៅចាំការណែនាំដែរឬទេ? តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ។

[១១:០៩:១៤]

**ស៖** ហើយក៏លោកបានធ្វើតេស្តមួយទៀត ខ្ញុំជឿថា ដោយមានការណែនាំទៅគាត់ ហើយបង្ហាញនូវលោកស្រី អៀង ធីរិទ្ធ នូវក្រដាសដែលសរសេរថា បិទភ្នែកដែលឲ្យអ្នកអានហ្នឹងធ្វើតាម ហើយខ្ញុំជឿថា វេជ្ជបណ្ឌិត លីនណា និយាយពីម្សិលមិញនោះ គឺថាគាត់អាចធ្វើបែបនោះបានតាមការណែនាំនោះ តើមែនទេ?

**ឆ៖** បាទ, ពិតជាត្រឹមត្រូវ។

**ស៖** ជាថ្មីម្តងទៀតយើងពិនិត្យមើលកថាខណ្ឌ២៥ នៃរបាយការណ៍ទីមួយរបស់សាស្ត្រាចារ្យខាំប៉ែល។

[១១:១០:០០]

តើលោកឯកភាពជាមួយខ្ញុំទេនៅពេលដែលគាត់បានធ្វើការតេស្តហ្នឹង គឺគាត់បានសរសេរ ប៉ុន្តែគាត់មិនបានយល់ទេ ថាឲ្យបិទភ្នែក ប៉ុន្តែគាត់មិនបានធ្វើ?

**ឆ៖** បាទ, អ៊ីចឹងមែន។

**ស៖** ថាតើមានភាពខុសគ្នាមួយចំនួន នៅក្នុងការសម្ភាសរបស់លោកជាមួយគាត់ បញ្ហាមួយចំនួនទាក់ទងទៅនឹងការធ្វើតេស្តរបស់លោក។ ខ្ញុំជឿថាវេជ្ជបណ្ឌិត លីនណា និយាយម្សិលមិញថា គាត់អាចសរសេរពាក្យ “ពិភពលោក” ជាភាសាអង់គ្លេសបាន តើត្រូវដែរឬទេ គាត់សរសេរបញ្ច្រាសមកវិញ?

**លោក ហ្វួត លីនណា៖**

**ឆ៖** គាត់ៗអត់សរសេរទេ ប៉ុន្តែគាត់ប្រកប គាត់ថាគាត់ប្រកប គាត់ថាគាត់*ស្ពេលលីង* គាត់ប្រកប គាត់មិនមែនសរសេរទេ។ គាត់ប្រកប គាត់មិនមែន *រ៉ាយធីងទេ គាត់ស្ពេលៗ ស្ពេលប៉េកវើក* (និយាយភាសាអង់គ្លេស)។ អាហ្នឹងភាសាខ្មែរ គាត់ប្រកបអក្សរ មិនមែនគាត់សរសេរទេ។

**ស៖** តើនោះជាករណីថា យើងមិនអាចធ្វើដូច្នេះបាននៅក្នុងសម្ភាសទីមួយ។ ប៉ុន្តែនៅក្នុងសម្ភាសទីពីរ អាចធ្វើបានដើម្បីឲ្យបានចម្លើយហ្នឹង តើមែនទេ?

[១១:១១:១៧]

**ឆ៖** ក្នុងសម្ភាសទីមួយគាត់ធ្វើបានហើយ ប៉ុន្តែគាត់ធ្វើបានត្រូវបានតែមួយពាក្យទេ ហើយពេលនោះយើងបានមួយពិន្ទុ។ ហើយថ្ងៃទីពីរ គាត់ធ្វើត្រូវទាំងអស់ គឺគាត់បានប្រាំពិន្ទុ។ គាត់ធ្វើបានដែរ ប៉ុន្តែទីមួយ ថ្ងៃទីមួយគាត់ធ្វើបានមិនល្អ ហើយថ្ងៃទីពីរគាត់ធ្វើបាន បានត្រូវទាំងអស់។

**ស៖** សំណួរនេះដោយសារតែ ការបំពេញមុខងារនៅក្នុងសម្ភាសទីពីរហ្នឹងបានល្អជាងទីមួយ តើអ៊ីចឹងមែនទេ?

**ឆ៖** តាមការកត់សម្គាល់របស់យើង យើងឃើញថាលទ្ធផលរបស់គាត់គឺបានថ្ងៃទីពីរ គឺល្អជាងថ្ងៃទីមួយ គឺពិន្ទុកើនឡើងពី១៥ ទៅ១៨ លើ៣០។

**ស៖** សូមអរគុណ។ ខ្ញុំសួរតទៅទៀត។ ឥឡូវនេះ គឺថាលោកអាចបានដឹង សូមកែខ្ញុំបើខ្ញុំខុស គឺវាអាចមានការព្រួយបារម្ភ ទាក់ទងទៅនឹងការប្រើប្រភេទតេស្ដ អឹម.អឹម.អេស.អ៊ី នៅក្នុងបរិបទដែលថាគេរៀបចំឧបករណ៍ហ្នឹងមក គឺត្រូវប្រើបរិស្ថានផ្សេងទៀត។ តើលោកយល់ដូចម្ដេចពីបញ្ហានេះ?

**លោក ស៊ីណា ហ្វាស៊ែស៖**

**ឆ៖** បាទ, គឺយើងបានប្រើតាមវិធីមួយ ដែលយើងពិនិត្យមើលទៅតាមស្ថានភាពដែរ ថាយើងប្រើកម្រិតណា ដើម្បីធ្វើឲ្យយើងធ្វើរោគវិនិច្ឆ័យតាមវិធីណាមួយ ឬក៏ប្រើវិធីនេះ។

**ស៖** ម្យ៉ាងវិញទៀត គឺថាមិនមែនជាឧបករណ៍ធ្វើរោគវិនិច្ឆ័យដាច់ណាត់ ដែលត្រូវតែប្រើទេ គឺថាអាចប្រើអ្វីផ្សេង។ តើអ៊ីចឹង ឬយ៉ាងម៉េច?

**ឆ៖** គឺបាទមែនហើយ។ គឺថាមិនមែនជាវិធីតែមួយ នៃការធ្វើរោគវិនិច្ឆ័យនោះទេ។

[១១:១៣:១៨]

**ស៖** គឺថាជាវិធីដែលលោកបានប្រើ គឺថាអាចនឹងបញ្ជាក់ថា តើវាអាចនឹងការបំពេញការងារហ្នឹងល្អជាង គឺថាក្នុងកម្រិតមួយខ្ពស់ជាង។ ឧទាហរណ៍ថា បើ២០ វាខ្ពស់ជាងស្រាល ឧទាហរណ៍ថាបើសិនជាវាមានមាត្រដ្ឋានខ្ពស់ជាងហ្នឹង វាអាចនឹងវាយតម្លៃខ្ពស់ជាង?

**ឆ៖** ទាក់ទងទៅនឹងការចុះខ្សោយសតិបញ្ញាដែលរកឃើញតាមវិធី អឹម.អឹម.អេស.អ៊ី នេះ។

**ស៖** លោកបានបញ្ជាក់នៅក្នុងកថាខណ្ឌ៣៤ នៃរបាយការណ៍របស់លោក ហើយជាថ្មីម្តងទៀត តាមនៅក្នុងប្រធានបទនៃការឡើងចុះនៃមុខងារសតិបញ្ញារបស់ អៀង ធីរិទ្ធ ហ្នឹង គឺថាការផ្តល់អារម្មណ៍ ការយកចិត្តទុកដាក់ទូទៅ ដែលអាចនឹងកែលម្អ បើសិនជាមានការហាត់សម ហ្វឹកហាត់នោះ។ ហើយ លោកបានបញ្ជាក់ប្រាប់តុលាការពីមុននោះថា លោកមិនបានសម្ភាសគាត់លម្អិត អំពីជីវិតកុមារភាព និង ពីគាត់នៅក្មេងវ័យនោះទេ។ តើមែនឬទេ?

**ឆ៖** បាទ, មែនហើយ។

**ស៖** តើយើងអាចនិយាយបានទេថា ប្រសិនបើដើម្បីយើងធ្វើរំឭកការចងចាំ ឬក៏បង្ហាញ ឯកសារទៅគាត់ជាវិធី ដើម្បីរំឭកគាត់ ដូចជារូបថត ឬក៏ឯកសារវីដេអូ តើធ្វើឲ្យគាត់ចងចាំ ឬក៏ធ្វើឲ្យ ការចងចាំរបស់គាត់អាចប្រសើរឬទេ?

**ឆ៖** គឺថាអាច។

[១១:១៥:០៥]

**ស៖** ខ្ញុំនឹងនិយាយដោយសង្ខេបទាក់ទងទៅនឹងបញ្ហាអំពីការប្រាស្រ័យទាក់ទងរបស់គាត់ដែល តុលាការបានពិនិត្យមួយជំហានមកហើយ ដើម្បីរក្សាពេលវេលាខ្ញុំនិយាយឲ្យបានខ្លីផ្តោតទៅលើតែអ្វី ដែលបាន លោកបានរកឃើញ។ នៅក្នុងកថាខណ្ឌ២០ ក្នុងរបាយការណ៍ដែលលោកបាននិយាយថា មិន មានភាពមិនប្រក្រតីនៅក្នុងចង្វាក់នៃការនិយាយ ឬក៏រលកសំឡេង ហើយមិនមានថា ឃើញភាព មមើមមាយ ឬក៏ការភ្លេចភ្លាំងនោះទេ។ ទោះបីជាវេជ្ជបណ្ឌិតរកឃើញថា គាត់មានការចុះខ្សោយខាង ចងចាំ ឬក៏គាត់មានការឈឺចាប់ខ្លះនោះក៏ដោយ។ នៅក្នុងកថាខណ្ឌ៣២ នៃរបាយការណ៍របស់លោកៗ និយាយថា មិនមានឃើញថា គាត់មានការលំបាកអំពីការបង្កើតប្រយោគ ឬក៏ការបំពេញសកម្មភាព នោះទេ។ តើខ្ញុំសង្ខេបហ្នឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** នោះគឺត្រឹមត្រូវហើយ។

[១១:១៦:១៣]

**ស៖** តើលោករកឃើញថា គាត់អាចបង្ហាញអំពីដូចថាភាពស្មោះត្រង់ ឬក៏បង្ហាញអំពីការ សប្បាយរីករាយ ឬក៏កំប្លែងអ្វីបានទេក្នុងសម្ភាសនោះ?

**ឆ៖** បាទ។

**ស៖** តើចង្អុលបង្ហាញថា គាត់អាចយល់ហើយនិងដំណើរការនូវព័ត៌មានដែលគាត់ស្ដាប់ហើយ គាត់អាចឆ្លើយតបទៅនឹងអ្វីដែលគាត់ស្ដាប់បាននោះដែរឬទេ?

**ឆ៖** គឺថា វាមានសមត្ថភាពមួយចំនួនដើម្បីធ្វើដូច្នោះបាន ប៉ុន្តែមានកម្រិត។

**ស៖** វេជ្ជបណ្ឌិត លីនណា បានបញ្ជាក់ម្សិលមិញថា នៅក្នុងអំឡុងពេលនៃការធ្វើតេស្តរបស់លោក។បានធ្វើការពិនិត្យការលំហាត់មួយឲ្យគាត់សរសេរប្រយោគ ដែលមានប្រធានកិរិយាស័ព្ទ និងកម្មបទ ហើយលោកថា គាត់អាចធ្វើបាននៅតេស្តទីមួយសម្អាសទីមួយ ប៉ុន្តែទីពីរគាត់មិនព្រមធ្វើ។ តើអ៊ីចឹងមែនឬទេ?

**ឆ៖** មែនបាទ។

**ស៖** តើនេះចង្អុលបង្ហាញអំពីលទ្ធភាពក្នុងការបង្ហាញពីលទ្ធភាពខ្លួន ឬក៏សម្បទាផ្ទាល់ខ្លួនដើម្បីកាត់បន្ថយលទ្ធភាពក្នុងការសរសេរ ដោយនៅពេលដែលគាត់បានយល់ពីអ្វីដែលសុំសំណួរ-- សុំឲ្យគាត់ធ្វើបែបនោះនោះ?

[១១:១៧:៤១]

**ឆ៖** បាទ។

**ស៖** លោកបាននិយាយក្នុងកថាខណ្ឌ២០ ថា គាត់និយាយប្រយោគជាភាសាបារាំង និងភាសាអង់គ្លេសខ្លី។ ប៉ុន្តែអាចស្ដាប់បាន យល់បាន។ តើត្រូវដែរឬទេ?

**ឆ៖** បាទ។

**ស៖** គឺថា លោកនិយាយថា គាត់អានភាសាអង់គ្លេសដោយមិនមានបញ្ហា។ តើលោកអាចពិពណ៌នារបៀបដែលលោកវាយតម្លៃដូចម្ដេចពីការអានរបស់គាត់នោះ?

**ឆ៖** គាត់បានអានមួយផ្នែកនៃសារព័ត៌មានដែលសរសេរជាភាសាអង់គ្លេស ដែលគាត់មាន ហើយគាត់។បានអានឲ្យយើងស្ដាប់មួយផ្នែកនៃសារព័ត៌មានតាមអ៊ីនធឺណេត ដែលយើងបានបង្ហាញឲ្យគាត់មើលនោះ។

**ស៖** នោះគឺអាចទៅដល់សំណួរមួយទៀត ទាក់ទងទៅនឹងការអានកាសែត តើត្រូវដែរឬទេ លោកបានដំណឹងពីប្រធាន ហើយនិងឌុកទ័រ ចំរើន ប្រាប់លោកថា លោក អៀង ធីរិទ្ធ គឺបានអានកាសែតទៀងទាត់ ឬមិនទៀងទាត់នោះ?

[១១:១៩:០០]

**ឆ៖** បាទ, យើងបានទទួលដំណឹងមែន។

**ស៖** តើដុកទ័រ ហ៊ុន ចំរើន បានប្រាប់ទៅលោកអំពីបញ្ហាមួយចំនួន ដែលថា អ្នកជំងឺប្រាប់ទៅគាត់ថា គាត់អានចំណុចណា ព័ត៍មានអីទេ នៅក្នុងកថាខណ្ឌ១៧ នៃរបាយការណ៍របស់លោក?

**ឆ៖** បាទ, ពិតហើយ។ ប៉ុន្តែ ខ្ញុំមិនបានចាំពេលវេលាដែលគាត់និយាយថាបានកើតឡើង។ ប៉ុន្តែគាត់និយាយជាទូទៅថា ម្តងម្កាលនោះ គឺថា លោកស្រី អៀង ធីរិទ្ធ បានពិភាក្សាពីការអានកាសែតជាមួយដុកទ័រនោះ។

**ស៖** ថាតើព័ត៍មាននោះត្រឹមត្រូវ ឬក៏ជាព័ត៍មានដែលច្រឡូកច្រឡំមិនសមស្របទៅតាមការពិតឬក៏ដូចម្តេច?

**ឆ៖** ទេ, គាត់មិនបាននិយាយពីគំនិតនេះទេ។ គាត់គ្រាន់តែនិយាយថា ពេលខ្លះគាត់និយាយពីថាគាត់បានអានកាសែតប្រាប់វេជ្ជបណ្ឌិតនោះតែប៉ុណ្ណឹងទេ។

[១១:២០:០៧]

**ស៖** ពិនិត្យមើលហេតុការណ៍មួយចំនួន ដែលលោកពិចារណា ដែលកើតឡើងពីឆ្នាំ២០០៨ ២០០៩ ករណីដែលថា គាត់មានអាការៈច្រឡោងខាមខឹងច្រឡោត។ តើលោកបានមើលរបាយការណ៍ហ្នឹងទេ?

**ឆ៖** គឺមើលជាសេចក្តីសង្ខេបតែប៉ុណ្ណឹងទេ។

**ស៖** តើជាករណីដែលឬទេ ថាហេតុការណ៍ទាំងអស់នេះ គឺឆ្ពោះបញ្ចាំង ឬក៏ប្រតិកម្មទៅនឹងបុគ្គលណាម្នាក់ទេ?

**ឆ៖** ខ្ញុំមិនដឹងសំណួរទៅនឹងចម្លើយនេះទេ។

[១១:២០:៥១]

**ស៖** តើលោកមានលទ្ធភាពដោយសង្ខេបទៅនឹង ខ្ញុំគួរតែបង្ហាញឯកសារនៅលើអេក្រង់ ប៉ុន្តែខ្ញុំអានឯកសារហ្នឹងផ្នែកដែលពាក់ព័ន្ធនៃរបាយការណ៍របស់វេជ្ជបណ្ឌិត ប្រេនឌីត និងប្រូហ្វេស័រ កាស៊ុនបូណាត។ គឺថាឯកសារនៅក្នុងទំព័រទី D19/9/8 ដែលគាត់និយាយថា គាត់មានលទ្ធភាពទៅនឹងរបាយការណ៍ដូចគ្នាក្នុងឆ្នាំ២០០៩ របាយការណ៍ហ្នឹង។ គេបាននិយាយថា នៅក្នុងកថាខណ្ឌទីពីរ ការថប់អារម្មណ៍របស់គាត់ គឺឆ្ពោះបញ្ចាំងទៅនឹងជនចាប់ចោទម្នាក់ គឺមិនមានបង្ហាញពីភាពភ័យខ្លាចទេ គឺបង្ហាញពីទំនាក់ទំនងស្មុគស្មាញ គឺទំនាក់ទំនងហេតុការណ៍ដែលបានកើតឡើងនៅតាមប្រវត្តិសាស្ត្រ។

ក្នុងកម្រិតមួយដែលថា ហេតុការណ៍ទាំងអស់នេះវាកើតឡើងចំពោះគាត់ ដោយសារគាត់សម្ដែងអាការៈច្រឡោងខាម ឬខឹងសម្បាចំពោះជនជាប់ចោទម្នាក់។ តើលោកឯកភាពជាមួយទេ គឺថាហេតុការណ៍ហ្នឹងគឺវាឆ្លុះបញ្ចាំងអំពីទំនាក់ទំនងមិនល្អកើតមានឡើងក្នុងអតីតរវាងជនជាប់ចោទទាំងពីរនាក់ នៅក្នុងកថាខណ្ឌទីបី នៅក្នុងឯកសារនេះ?

[១១:២២:១៧]

**ឆ៖** យើងបានយល់ថា យើងបានយោងទៅរកទំនាក់ទំនងទៅនឹងមន្ត្រីនៃមន្ទីរឃុំឃាំងហ្នឹងផងដែរ។ លោក ម៉ៅ សុភារម្យ បានប្រាប់យើងថា នៅពីដំបូងនោះ ដែលគាត់មកដល់មន្ទីរឃុំឃាំង គាត់ក៏បានប្រើពាក្យទ្រគោះបោះបោក គឺថាពាក្យមិនសមរម្យមួយចំនួនដែរទៅកាន់មន្ត្រីមន្ទីរនោះ មន្ទីរឃុំឃាំង។ ប៉ុន្តែមិនមែនថា ជាហេតុការណ៍ទាក់ទងទៅនឹង ហេតុការណ៍នោះចំពោះតែជនជាប់ចោទម្នាក់។

**ស៖** ប៉ុន្តែរបាយការណ៍ឆ្នាំ២០១០ និងឆ្នាំ២០១១ តើលោកបានមើលឃើញទេ?

**ឆ៖** អត់ទេ។ របាយការណ៍ដែលយើងមាននោះ គឺថាថ្ងៃ១៩ ឧសភា ឆ្នាំ២០១០ គឺថាសេចក្ដីរៀបរាប់នៅក្នុងរបាយការណ៍វេជ្ជសាស្ត្រ ដែលថាគាត់មានអាការៈថប់អារម្មណ៍ និងខឹងសម្បានិយាយអាក្រក់ច្រើននោះ។

[១១:២៣:២៦]

**ស៖** អ៊ីចឹង គឺថាយើងមើលការវាយតម្លៃដែលធ្វើឡើងដោយ នៅក្នុងរយៈកាលបួនឆ្នាំកន្លងមកនេះ ដែលថាគាត់មកដល់មន្ទីរឃុំឃាំង នៅក្នុងកថាខណ្ឌ៣៦ របស់លោកហ្នឹង ការកើតឡើងនៃជំងឺនេះ គឺយើងពិបាកក្នុងការវាយតម្លៃ ដោយសារមិនមានការវាយតម្លៃពីមុនលម្អិតនោះមក។ តើនេះករណីដែរទេ មិនអាចធ្វើទៅរួចក្នុងការកំណត់ថា កាលបរិច្ឆេទថា ជំងឺ *អាល់ហ្សៃមើ* ដែលថាវង្វេងស្មារតីនោះកើតពេលណា ឬអីពេលណា? តើកំណត់ឬទេ? ខ្ញុំមិនទាន់ឯកភាពជាមួយអ្វីដែលលោកនិយាយទេ ប៉ុន្តែកថាខណ្ឌ៣៦ នៃរបាយការណ៍ គឺថាអ្វីដែលមានហ្នឹងកម្រិតក្នុងការឲ្យលោកវាយតម្លៃថា ការកើនឡើងនៃជំងឺបែបនេះនោះ។

[១១:២៤:១៨]

**ឆ៖** តាមពិតវាមានកម្រិតលើលទ្ធភាពនៃការវាយតម្លៃ អំពីការឲ្យពិន្ទុ អំពីភាពធ្ងន់ធ្ងរ ពីព្រោះថាចំណុចមួយចំនួនដែលត្រូវយកមកប្រើក្នុងការវាស់តម្លៃពីភាពធ្ងន់ធ្ងរ គឺអាចធ្វើតែក្នុងករណីនៅក្នុងរបៀបមួយ ដែលអ្នកជំងឺមានសេរីភាពច្រើនក្នុងការធ្វើការងារអ្វី។

**ស៖** ហើយយើងអាចពិនិត្យមើលនូវកត្តាសក្ដានុពលបន្ថែមទៀត ដែលថាអាចប៉ះពាល់ទៅដល់សតិបញ្ញាចងចាំ។ តើលោកបាននិយាយថា នៅក្នុងកថាខណ្ឌ៣៧ នៃរបាយការណ៍របស់លោក លោកឯកភាពថា ការកាត់បន្ថយនៃ *កេត្យាពីន (Quetiapine)* គឺថាអាចនឹងជាកត្តាសម្រាល។ តើត្រូវដែរឬទេ?

[១១:២៥:០៤]

**ឆ៖** បាទ, ត្រឹមត្រូវ។

**ស៖** *កេត្យាពីន* គឺថាធ្វើឲ្យគាត់មានការលំបាកក្នុងការគិត ហើយនិងការផ្ចង់អារម្មណ៍ តើមែនទេ?

**ឆ៖** វាអាចធ្វើមួយផ្នែកការប្រើ កេត្យាពីន នោះគឺថា ធ្វើឲ្យគាត់រម្ងាប់អារម្មណ៍ ប៉ុន្តែវាក៏អាចធ្វើឲ្យប៉ះពាល់ដល់សតិបញ្ញា និងការចងចាំនោះដែរ។ អ៊ីចឹងគឺថា វាអាចនឹងប៉ះពាល់ដល់ខួរក្បាល។

**ស៖** បាទ, អ៊ីចឹង គឺថាវាអាចដកចេញ ប្រសិនវាជាកត្តាចូលរួមក្នុងការធ្វើឲ្យចុះខ្សោយក្នុងការចងចាំ។

**ឆ៖** ប៉ុន្តែវាអាចជាកត្តារួបរួមចូលនឹងការកើនឡើងនៃជំងឺរបស់គាត់។ ប៉ុន្តែខ្ញុំយល់ថា វាជាមូលហេតុមួយទៀតនៃជំងឺ*ឌីមែនស្យា (dementia)*-- វង្វេងវង្វាន់ ហ្នឹងវាជាកត្តាសំខាន់នៃការធ្វើឲ្យបាត់ការចងចាំ។

[១១:២៦:០៤]

**ស៖** ហើយយើងនិយាយថា លក្ខខណ្ឌនៃការរស់នៅក្នុងមន្ទីរឃុំឃាំងហ្នឹង គឺថាគាត់មានកម្រិតក្នុងការចូលរួមក្នុងសកម្មភាពមួយចំនួន បើយើងត្រូវធ្វើតេស្តផ្សេង។ តើត្រូវដែរឬទេ?

**ឆ៖** បាទ, មែន។

**ស៖** ហើយវាអាចនឹងជាកត្តាមួយដែលស្ថានភាពផ្លូវចិត្តទូទៅ គឺមុខងារសតិបញ្ញារបស់គាត់ក៏ត្រូវរងប៉ះពាល់មិនអាចតេស្តបានដែរ?

**ឆ៖** វាជាកត្តាចូលរួម ដោយហេតុថា ការជំរុញនូវសតិបញ្ញាចងចាំនោះ គឺថាអាចធ្វើឲ្យអាចនឹងត្រូវកាត់បន្ថយនូវល្បឿន នៃការចុះថយនៃសតិបញ្ញាបាន គ្រាន់តែធ្វើឲ្យយឺតកុំឲ្យចុះខ្សោយលឿនពេកអាហ្នឹងគឺវាអាចមានវិធី។

**ស៖** ចំណុចមួយទៀតទាក់ទងទៅនឹងអនុសាសន៍មួយចំនួន ដែលសាស្ត្រាចារ្យ ខាំប៉ែល បានផ្ដល់ជូនអង្គជំនុំជម្រះពីមុន គឺថាដុកទ័រ ខាំប៉ែល បានយោងទៅរកមតិរបស់គាត់ទាក់ទងទៅនឹងការព្យាបាល។ តើលោកឯកភាពជាមួយគាត់ទេអំពីការប្រើថ្នាំនេះ?

[១១:២៧:១២]

**ឆ៖** យើងមិនមែនជំទាស់ជាមួយគាត់ទេ ទាក់ទងទៅនឹងការប្រើថ្នាំមួយប្រភេទ *ដូនេណេប៉េហ្ស៊ីល* (*Donepezil*) គឺថាយើងមិនមានបទពិសោធន៍ប្រើទេ។

**ស៖** តើលោកឯកភាពជាមួយគាត់ទេ គឺថាលទ្ធភាពមួយចំនួនដែលថាយើងអាចជាកត្តាមួយដែលថាជួយកំណត់ឲ្យមានស្ថានភាពធម្មតា ឬក៏អាចនឹងកែប្រែជាងធម្មតាហ្នឹងបន្តិចល្អដែរឬទេ?

**ឆ៖** ហើយខ្ញុំនឹងអាចនឹងយោងទៅរកមតិរបស់សាស្ត្រាចារ្យ ខាំប៉ែល។ ខ្ញុំមិនអាចទុកចិត្តថាអាចនិយាយអំពី*ដូនេណេប៉េហ្ស៊ីល* នេះជាមួយលោកឲ្យលម្អិតនោះទេ គឺខ្ញុំទុកបញ្ហានេះអាចពិភាក្សាជាមួយសាស្ត្រាចារ្យ ខាំប៉ែល ចុះ។ ខ្ញុំមិនដឹងថាសហសេវិករបស់ខ្ញុំ អាចនឹងជួយបន្ថែមទៅនឹងបញ្ហានេះយ៉ាងម៉េច ឬក៏គាត់មិនចង់។

[១១:២៨:២៤]

**ស៖** បាទ, អ៊ីចឹងអាចអញ្ជើញបាន។ ដោយសារតែពេលវេលាជិតអស់ហើយ ខ្ញុំសូមចូលទៅដល់ចំណុចមួយទៀត។ នៅពេលដែលយើងពិចារណាទៅលើការកាត់ទោស និងការយល់ទៅលើបទចោទថាតើវាជាករណីដែរឬទេ នៅពេលដែលលោកបង្ហាញអត្ថបទមួយដែលបង្ហាញអំពីបញ្ហាវង្វេងវង្វាន់ស្មារតី ឬឆ្កួតនោះ ថាតើជាអត្ថបទនៅក្នុងកិច្ចដំណើរការនីតិវិធីនេះដែរឬទេ?

**ឆ៖** បាទ, គឺអត្ថបទនោះបង្ហាញអំពីកិច្ចដំណើរការនីតិវិធីនេះ។

**ស៖** ថាតើលោកស្រី អៀង ធីរិទ្ធ មានប្រតិកម្មយ៉ាងម៉េចទៅនឹងអត្ថបទនោះ? ជាពិសេសនៅក្នុងកថាខណ្ឌ៤៦ លោកស្រីបានលើកឡើងថា "លោកបានចោទយើងថា គេចោទថាឆ្កួត ដូច្នេះគ្មាននរណាធ្វើអ្វីចំពោះមនុស្សឆ្កួតនោះទេ"។ ថាតើលោកអាចពន្យល់ទៅលើចំណុចនេះបានដែរឬទេ?

**ឆ៖** ខ្ញុំបកស្រាយបញ្ហានេះថា លោកស្រីគាត់យល់អំពីផលវិបាកយ៉ាងហោចណាស់ យល់អំពីផលវិបាកមួយនៃលទ្ធផលជំនុំជម្រះនេះ ហើយខ្ញុំក៏អាចឃើញដែរថាលទ្ធភាពរបស់លោកស្រី អាចយល់អំពីផលវិបាកនៃបញ្ហាមួយចំនួនផ្សេងទៀត។ ដូច្នេះហើយ ផ្អែកទៅលើឧទាហរណ៍ជាក់លាក់មួយនេះដូចជាករណីដែលគាត់បដិសេធមិនឆ្លើយទៅនឹងសំណួរ ពាក់ព័ន្ធទៅនឹងផលវិបាកនៃការរកឃើញពិរុទ្ធ

ភាពនោះគឺយើងអាចយល់ដូច្នេះបាន។

[១១:៣០:០៥]

**ស៖** ដូច្នេះប្រសិនបើការសន្និដ្ឋានរបស់លោកត្រឹមត្រូវនោះ បានន័យថាលោកស្រី គាត់យល់អំពីគោលបំណង ហើយនិងកិច្ចដំណើរការនីតិវិធីនេះ រួមទាំងផលវិបាកនៃកិច្ចដំណើរការកិច្ចនីតិវិធីនេះផងដែរ?

**ឆ៖** ខ្ញុំឯកភាពជាមួយនឹងលោកពាក់ព័ន្ធទៅនឹងការយល់អំពីផលវិបាកនៃកិច្ចដំណើរការនីតិវិធីនេះ។

**ស៖** ខ្ញុំមានសំណួរចុងក្រោយមួយទៀត។ នៅក្នុងកថាខណ្ឌ៤១ នៃរបាយការណ៍របស់លោក លោកបានលើកឡើងថា លោកបានអានផ្នែកមួយចំនួននៃបទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី អៀង ធីរិទ្ធ។ នៅក្នុងការអាននោះថាតើលោកបានពិភាក្សាលម្អិតជាមួយនឹងលោកស្រី អៀង ធីរិទ្ធ ពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលបានចោទប្រកាន់គាត់អំពីតួនាទី និងបទចោទជាក់លាក់ដែរឬទេ?

**ឆ៖** ខ្ញុំចាំថាយើងមិនបានពិភាក្សាលម្អិតនោះទេ ទៅលើបញ្ហាទាំងនោះ យើងបានអានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក៏ប៉ុន្តែយើងមិនបានពិភាក្សាលម្អិតនោះទេ តាមអ្វីដែលខ្ញុំចាំ។ ដូច្នេះ ខ្ញុំសួរទៅខាងអ្នកជំនាញដែលជាសហសេវិករបស់ខ្ញុំ ថាតើយើងបានពិភាក្សាគ្នាលម្អិតទេលើចំណុចហ្នឹង?

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណ។ ដោយសារតែយើងអស់ពេលវេលាហើយ ដូច្នេះខ្ញុំសូមបញ្ឈប់ការតាំងសំណួរត្រឹមទេ។ សូមអរគុណលោកវេជ្ជបណ្ឌិត។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណសហព្រះរាជអាជ្ញារងអន្តរជាតិ។ ហើយជាកិច្ចបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសនៅក្នុងការតាំងសំណួរសួរដល់អ្នកជំនាញទាំងពីររូប ប្រសិនបើមាន។ ហើយសហមេធាវីនាំមុខអាច និងសហការីអាចមានពេលវេលាសាមសិបនាទីនៅក្នុងការសួរនេះ។ សូមអញ្ជើញប្រសិនបើមាន។

[១១:៣២:១៨]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន អស់លោក លោកស្រីចៅក្រម លោក លោកស្រីទាំងអស់ និងព្រះអង្គ

គ្រប់ព្រះអង្គដែលវាមានវត្តមាននៅទីនេះ។ មេធាវីនាំមុខសូមអនុញ្ញាតទុកឱកាសឲ្យលោកមេធាវី ហុង គឹមសួន ដែលជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបឡើងលើកជាសំណួរ បន្ទាប់មកជូនទៅលោកមេធាវី អ៊ែរវ៉េ យ៉ាគីយ៉សេ ដើម្បីលើកជាសំណួរបន្ត។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោកមេធាវី!

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ហុង គឹមសួន៖**

បាទ, ជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់លោកប្រធាន និងលោក លោកស្រីចៅក្រមនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាំងមូល។ សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសួស្ដីលោកអ្នកជំនាញ។

**ស៖** តទៅនេះខ្ញុំសូមសួរលោក ដោយសារយើងមានពេលខ្លីដែរ។ ទាក់ទងនឹងការលើកឡើងរបស់លោកអំពីការពន្យល់ទៅលើរបាយការណ៍សុខភាពរបស់លោកស្រី អៀង ធីរិទ្ធ។ ខ្ញុំសូមសួរលោកថា តើមនុស្សទូទៅដែលមានវ័យចំណាស់ចាប់ពីអាយុប៉ុន្មានទៅដែលមានខួរក្បាលរួម ឬក៏ស្វិត? ខ្ញុំមិនយល់ន័យពាក្យវេជ្ជសាស្ត្រទេ ប៉ុន្តែបានស្ដាប់ឮថា ខួរក្បាលនៃមនុស្សមានវ័យចំណាស់គឺរួមតូច។ អ៊ីចឹងតើពាក្យរួមតូចនេះ មានន័យថាវាធ្វើឲ្យមនុស្សគ្រប់គ្នាដែលមានខួរក្បាលរួមតូច វាបាត់បង់ការចងចាំ ឬក៏វាវង្វេងស្មារតី? ខ្ញុំនិយាយមនុស្សទូទៅ សូមលោកពន្យល់ខ្ញុំកន្លែងនេះបន្តិចបាទ។

[១១:៣៤:០៦]

**លោក ហ្គូត លីនណា៖**

**ឆ៖** បាទ, ខ្ញុំបាទសូមឆ្លើយសំណួររបស់លោកដូចតទៅ។ ចំពោះមនុស្សទូទៅតែកាលណាដែលយើងចាស់ទៅគឺថា យើងមានការថយសូម្បីតែកម្ពស់ក៏យើងថយដែរ។ ក្មេងយើងលូតកម្ពស់ដល់ពេលចាស់ទៅថយៗកំពស់យើងថយ ដោយសារអី? ដោយសារយើងកោងខ្នង យើងថយកម្ពស់។ ហើយដូចជាសាច់ដុំ ពេលយើងក្មេង សាច់ដុំយើងរីកលូតលាស់ធំ ដល់ពេលយើងចាស់ទៅសាច់ដុំយើងខាងក្រៅក៏ឃើញយើងរួមតូចស្វិតដែរ ហើយសូម្បីតែខួរក្បាលយើងក៏វាមានការរួមថយអ៊ីចឹងដែរ។ អាហ្នឹងវាជាលក្ខណៈ តាមលក្ខណៈសរីរវិទ្យាគឺវារួមថយតូចបែបនេះ។ ហើយទន្ទឹមនឹងការចងចាំក៏មានបានថយចុះខ្លះដែរ ហើយក៏ប៉ុន្តែវាទាក់ទងទៅនឹងការវង្វេង (សុំទោសៗ) ទាក់ទងនឹងការវង្វេង ការដែលខួរ

ក្បាលរួមតូចហ្នឹងមិនមានន័យស្មើនឹងវង្វេងទេ។ ចង់និយាយថា រាល់មនុស្សចាស់ទាំងអស់មិនមែនសុទ្ធតែវង្វេងទាំងទេ ហើយដូចជាអង្គសវនាការ ក៏ដូចជាប្រជាពលរដ្ឋយើងដែលបានតាមដាន គាត់ដឹងថាមានមនុស្សចាស់ខ្លះអាយុ៨០ មិនទាន់វង្វេងផង ប៉ុន្តែមនុស្សខ្លះអាយុ៦០ ហ្នឹងគាត់វង្វេង។ ដូច្នេះមានន័យថាការដែលខួរក្បាលគាត់រួមតូចហ្នឹងមិនមែនមានន័យថាស្មើនឹងវង្វេងទេ ប៉ុន្តែការចងចាំអាចភ្លេចខ្លះ។ ដូចដែលយើងអាចដឹងហើយ មនុស្សទូទៅកាលនៅក្មេងរៀនពូកែ រៀនយល់ជាងមុន ដល់ពេលចាស់បន្តិចទៅខួរក្បាលវាមិនសូវចងចាំជាងមុន។ អាហ្នឹងជារឿងដែលថាលក្ខណៈធម្មតា គឺថាលក្ខណៈតាមសរីរវិទ្យាគឺអ៊ីចឹងបាទ។ បើសិនជាខ្ញុំឆ្លើយទៅមិនគ្រប់គ្រាន់ លោកអាចសួរខ្ញុំបានទៀត។

[១១:៣៦:១៥]

**ស៖** បាទ, សូមអរគុណ។ ខ្ញុំបាទសូមសួរលោកបន្ថែមទៀតថាពាក្យថា “វង្វេង” និងពាក្យថា “ចុះខ្សោយបញ្ញាស្មារតី” តើនៅក្នុងន័យនេះចំពោះអ្នកស្រី អៀង ធីរិទ្ធ គាត់ចុះខ្សោយបញ្ញាស្មារតី ឬបាត់បង់បញ្ញាស្មារតី?

**ឆ៖** នៅក្នុងគឺថា គាត់មិនទាន់បាត់បង់ទេ គាត់គ្រាន់តែមានការចុះខ្សោយ។

**ស៖** បាទ, សូមអរគុណ។ អម្បាញ់មិញ ខ្ញុំ-- មុននឹងពេលសម្រាកហ្នឹងលោកបានជម្រាបនៅក្នុងអង្គសវនាការអំពីលក្ខខណ្ឌទាំងប្រាំពីរ ដែលការវាយតម្លៃ ឬការធ្វើតេស្តទៅលើមនុស្សដែលមានសញ្ញា*អាល់ហ្សៃមើ* ហើយលោកបានជម្រាបអង្គសវនាការថា គាត់ស្ថិតនៅក្នុងការវាយតម្លៃនៅចំណុចទីប្រាំ តើលោកអាចជម្រាបបានទេថា ក្នុងចំណុចទាំងប្រាំនោះ ដូចនៅក្នុងនេះដែរ នៅក្នុងរបាយការណ៍របស់លោក នៅក្នុងកថាខណ្ឌ៣៩ មួយទាក់ទងទៅនឹងសមត្ថភាពឆ្លើយតបទៅនឹងបទចោទ។ អ៊ីចឹងនៅក្នុងនេះដែរ នៅក្នុងកថាខណ្ឌ៤១ ដែលលោកសន្និដ្ឋាន ឬក្រុមរបស់លោកសន្និដ្ឋានថា លោកស្រីអៀង ធីរិទ្ធ ពិតជាមានសមត្ថភាពដើម្បីឆ្លើយតបទៅនឹងបទចោទប្រកាន់បាន។ អ៊ីចឹង សមត្ថភាពជាមួយនឹងការចងចាំនេះ តើវាទាញគ្នា ឬវាអាចមានភាពខុសយ៉ាងម៉េចខ្លះ?

[១១:៣៨:១៦]

**លោក ស៊ីណា ហ្វាសែល៖**

**ឆ៖** ដើម្បីជាការបញ្ជាក់បំភ្លឺបុគ្គលម្នាក់អាចមានការចុះខ្សោយសតិបញ្ញា ហើយនិងជំងឺវង្វេងវង្វាន់ស្មារតីដូចគ្នា។ ដើម្បីឲ្យមានការវង្វេងវង្វាន់ យើងត្រូវតែមានការចុះខ្សោយសតិបញ្ញា។ យើងឃើញមានបញ្ហាដទៃទៀតដែលវាអាចប៉ះពាល់ទៅដល់ជំងឺនេះ ជាពិសេសចំពោះការវង្វេងវង្វាន់ចុះ

ខ្សោយសតិបញ្ញានេះ វាឲ្យមានបញ្ហាដូចជាការស្ទៀកពាក់ ការគិតគូរ។ ដូច្នេះហើយការចុះខ្សោយបញ្ញាដែលនាំទៅដល់ការវង្វេងវង្វាន់ស្មារតីនោះ វាអាចប៉ះពាល់ទៅដល់ជីវិតរបស់យើង។ វាបន្ថយនូវលទ្ធ-ភាពរបស់យើងក្នុងការបំពេញសកម្មភាពជាក់លាក់មួយចំនួន។ ដូច្នេះហើយពាក្យដែលយើងប្រើប្រាស់នេះ វាប្រើប្រាស់ផ្លាស់ប្តូរគ្នាទៅវិញទៅមក។

[១១:៣៩:១៩]

ការវង្វេងវង្វាន់ស្មារតី គឺជាការវិនិច្ឆ័យតាមរោគសញ្ញា ហើយការចុះខ្សោយសតិបញ្ញានោះ គឺវាជាការចុះខ្សោយទៅតាមដំណាក់កាលរបស់វា ដូច្នេះហើយយើងយល់ឃើញថាជំងឺ *អាល់ហ្សៃមើ* និងជំងឺវង្វេងស្មារតីនេះ គឺជាបញ្ហាពាក់ព័ន្ធទៅនឹងសិរីរាង្គ។ ចំពោះលក្ខណៈវិនិច្ឆ័យដែលលោកបានលើកឡើងនោះ ថាតើការចងចាំវាអាចប៉ះពាល់ទៅដល់សមត្ថភាពក្នុងការឆ្លើយតបទៅនឹងបទចោទដែរឬទេ?

យើងបានពិនិត្យមើលឡើងវិញលើគន្លឹះសំខាន់ៗពាក់ព័ន្ធទៅនឹងលក្ខណៈវិនិច្ឆ័យចំពោះការយល់ដឹង ថាតើបុគ្គលម្នាក់អាចយល់អំពីពាក្យថា ពិរុទ្ធភាព ឬមិនមានពិរុទ្ធភាពដែរឬទេនោះ? យើងយល់ឃើញថា គាត់អាចយល់បាន។ លោកស្រីគាត់បានផ្តល់នូវការយល់ឃើញរបស់គាត់ដោយស៊ីសង្វាក់គ្នាហើយថាតើគាត់ឯកភាព ឬក៏មិនឯកភាពជាមួយនឹងបទចោទដាក់បន្ទុកទៅលើគាត់នោះ គឺគាត់ផ្តល់ការយល់ឃើញស៊ីសង្វាក់គ្នាផងដែរ។ ហើយលោកស្រីបានបង្ហាញថា គាត់មិនដែលធ្លាប់បានធ្វើសកម្មភាពទាំងអស់នោះទេនៅពេលនុ៎ង។ ដូច្នេះ ចំណុចពីរនេះ ធាតុពីរនេះ គឺគាត់មានលទ្ធភាពមួយចំនួនក្នុងការឆ្លើយតបទៅនឹងបទចោទ។

**ស៖** បាទ, សូមអរគុណ។ ខ្ញុំសូមសួរលោកទាក់ទងនឹងកថាខណ្ឌ៤៦ នៃរបាយការណ៍របស់ក្រុមវេជ្ជសាស្ត្ររបស់លោក ដែលលោកបានបង្ហាញថា អ្នកស្រី អៀង ធីរិទ្ធ គាត់យល់ ហើយនិងចង្អុលទៅត្រង់ពាក្យជាភាសាអង់គ្លេស *ឌីមែនស្យា* គឺក្នុងនេះភាសាខ្មែរសរសេរថា “ឆ្កួត” ហើយគាត់យល់អំពីផលវិបាកនៃពាក្យថា “ឆ្កួត” ទៅទៀត។ តើអ៊ីចឹងមែនទេ?

**លោក ហួត លីនណា៖**

**ឆ៖** បាទ, ពិតមែនបាទ។

**ស៖** បាទ, សូមអរគុណ។ លោកបានជម្រាបអង្គសវនាការអំពីការមិនចងចាំអំពីពេលវេលាឬកាលបរិច្ឆេទនៅពេលដែលលោកធ្វើសម្ភាសជាមួយអ្នកស្រី អៀង ធីរិទ្ធ នៅបន្ទប់របស់គាត់ រហូតថាបន្ទប់តូចមានការចង្អៀតទៅទៀត។ អ៊ីចឹងនៅពេលដែលលោកធ្វើការសាកសួរហ្នឹង តើពេលហ្នឹងគាត់

មានមើលទៅក្នុងប្រតិទិន ឬក៏គាត់មើលនាឡិកាគាត់ទេ ដែលបង្ហាញថាគាត់មើល តែគាត់អត់ចាំ ឬគាត់អត់ដឹង? អ៊ីចឹងនៅពេលដែលសម្ភាសហ្នឹង គាត់មានបានមើលទៅលើប្រតិទិន ឬក៏មើលម៉ោងដើម្បីឆ្លើយតបមកលោកវិញដែរឬទេ?

**ឆ៖** គាត់អត់បានមើលនាឡិកា ឬប្រតិទិនទេ។

**ស៖** បាទ, សូមអរគុណ។ នេះជាសំណួរទូទៅមួយដែរទាក់ទងនឹងមនុស្សចាស់ បើនិយាយពីមនុស្សចាស់ទូទៅការចងចាំ ឬក៏ការចាំពីប្រវត្តិរបស់ខ្លួនម្នាក់ៗដែលមានរយៈពេលជាង៥០ឆ្នាំមកហើយនោះ តើមនុស្សចាស់ទូទៅងាយនឹងចងចាំរំឭកនូវអតីតកាល ឬក៏ប្រវត្តិរបស់ខ្លួនបានល្អប្រសើរដែរឬទេ?

[១១:៤៣:២០]

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** បាទ, គឺដូច្នេះបុគ្គលដែលមានវ័យចំណាស់នោះ គឺគាត់អាចចងចាំអំពីជីវិតពីដំបូងៗរបស់គាត់ដែលវាពាក់ព័ន្ធទៅនឹងការចងចាំរយៈពេលយូរ ហើយយើងគិតថាអ្នកទាំងអស់នោះគាត់អាចចងចាំអ៊ីចឹងបាន វាមិនខុសពីអ្នកដែលមានការវង្វេងវង្វាន់។

**ស៖** បាទ, សូមអរគុណ។ លោកបានជម្រាបនៅក្នុងអង្គសវនាការនិយាយអំពីការសម្ភាសអ្នកស្រី អៀង ធីរិទ្ធ អស់រយៈពេលដល់ទៅពីរម៉ោង ដោយគ្មានការជំទាស់គ្មានការត្អូញត្អែរពីគាត់។ អ៊ីចឹងតើលោកអាចជម្រាបជូនបានទេថា បើសិនជាមានការចូលរួមក្នុងដំណើរការនីតិវិធីសវនាការ យើងមិនចង់បានដល់ពីរម៉ោងនោះទេ។ តើគាត់មានសមត្ថភាពអាចចូលរួម និងស្តាប់ និងឆ្លើយនៅក្នុងពេលដំណើរការសវនាការរយៈពេលខ្លីបានដែរឬទេ?

**ឆ៖** ប្រសិនបើលោកមានន័យថា តើគាត់មានលទ្ធភាពខាងរូបរាងកាយចូលរួមក្នុងសវនាការដែរឬទេ? ខ្ញុំឯកភាពតាមកិច្ចសម្ភាសរបស់យើងជាមួយគាត់ គឺគាត់មានលទ្ធភាពក្នុងការអង្គុយនៅក្នុងតុលាការនេះបាន ដូច្នេះវាមិនមានបញ្ហាអ្វីសម្រាប់គាត់នោះឡើយ។

**ស៖** បាទ, អរគុណ។ ខ្ញុំសួរសំណួរចុងក្រោយមួយទៀត ទាក់ទងជាមួយនឹងកថាខណ្ឌទី៥១ នៃរបាយការណ៍។ តាមសំណួររបស់ខ្ញុំបាទសួរពីមុន លទ្ធផលឆ្លើយមកគឺស្របគ្នានៅក្នុងរបាយការណ៍នេះ ខ្ញុំសូមសួរលោកទាក់ទងនឹងពាក្យថា "មិនផ្តល់ភាពប្រសើចាំបាច់"។ ខ្ញុំសូមអានឡើយវិញបន្តិចសិនជាភាសាខ្មែរ។

[១១:៤៥:១០]

នៅក្នុងកថាខណ្ឌ៥១ ខ្ញុំអានអំពីថា "យើងខ្ញុំយល់ឃើញថា មធ្យោបាយដោះស្រាយដូចបានស្នើឡើងនៅក្នុង កថាខណ្ឌ១១នៃសំណួររបស់សហព្រះរាអាជ្ញា ដែលរួមមានការធ្វើសង្ខេបដោយផ្ទាល់មាត់ ការប្រាស្រ័យទាក់ទងនជាប្រចាំ និងបន្តបន្ទាប់នៅក្នុងអំឡុងពេលសវនាការ ដែលមានការចូលរួមរបស់មេធាវីនិយាយភាសាខ្មែរនៅក្នុងគ្រប់ពិគ្រោះយោបល់ទាំងអស់នោះ នឹងមិនផ្ដល់ភាពប្រសើរចាំបាច់ដែលអាចឲ្យ លោកស្រី អៀង ធីរិទ្ធ អាចយល់ដឹងក្នុងកម្រិតគ្រប់គ្រាន់មួយ ដែលអាចឲ្យគាត់តាមដានការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធីនោះបានឡើយ"។

ដូច្នេះ ក្នុងនេះវាមានពាក្យសំខាន់ពីរពាក្យត្រង់ថា "នឹងមិនផ្ដល់ភាពប្រសើរចាំបាច់"។ អ៊ីចឹងសំណួរសួរថាតើពាក្យថា ភាពប្រសើរចាំបាច់កម្រិតណាដែលគាត់មិនអាចផ្ដល់បាន? ហើយនិងពាក្យថាអាចយល់ដឹងក្នុងកម្រិតគ្រប់គ្រាន់មួយ ត្រង់ចំណុចនេះទាក់ទងនឹង ដូចម្ដេចដែលហៅថាកម្រិតគ្រប់គ្រាន់? ព្រោះអម្បាញ់មិញខ្ញុំបាទទើបនឹងសួរទាក់ទងនឹងមនុស្សចាស់ដែលមានការថយសមត្ថភាពបាទ។ សូមអរគុណ។

[១១:៤៦:៣០]

**ឆៈ** នេះគឺជាគំនិតកើតចេញពីការវិនិច្ឆ័យរោគ និងការធ្វើកោសល្យវិច័យផ្អែកទៅលើការសម្ភាសរបស់យើង ដោយយើងគិតអំពីការជាប់ពាក់ព័ន្ធនឹងផលវិបាក ទៅលើបញ្ហាសតិបញ្ញារបស់គាត់។ យើងព្យាយាមឆ្លើយតបទៅនឹងសំណួរដែលលើកឡើងថា ការឆ្លើយរបស់គាត់នោះមានសមហេតុផល ឬគ្រប់គ្រាន់ដែរឬទេ? ផ្អែកទៅលើការធ្វើកោសល្យវិច័យ ថាតើគាត់អាចមានភាពប្រសើរឡើងដែរឬទេ ដើម្បីឲ្យគាត់ចូលរួមក្នុងសវនាការបាន? យើងយល់ឃើញថា ការលើកឡើងរបស់យើងគឺអាចជួយឲ្យគាត់ដោះស្រាយទៅលើការចុះខ្សោយសតិបញ្ញារបស់គាត់ ដែលវាពាក់ព័ន្ធនឹងកើតឡើងចំពោះគាត់ ទោះបីជាគាត់មិនអាចរក្សាទុកព័ត៏មានបានយូរក៏ដោយ គឺការដែលយើងស្នើឡើងនេះវាអាចជួយឲ្យគាត់ហ្នឹងអាចផ្ដល់ហេតុផល ហើយឲ្យគាត់យល់ថាវាមានន័យយ៉ាងម៉េច? ថាតើការស្នើឡើងរបស់យើងទៅលើចំណុចចំនួនបី។ ទីមួយ មានមេធាវីនិយាយភាសាខ្មែរ ហើយនិងចំណុចពីរទៀតនោះ ការធ្វើដូច្នេះគឺអនុញ្ញាតឲ្យលោកស្រី និងជួយឲ្យលោកស្រីអាចប៉ះប៉ូវជំនះទៅដល់បញ្ហាសតិបញ្ញារបស់គាត់ ដើម្បីអាចឲ្យលោកស្រីនោះចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី។

[១១:៤៨:៣០]

ចំពោះសំណួរទីពីរ ដែលលោកបានសួរថាតើមានន័យយ៉ាងម៉េចពាក្យថា“គ្រប់គ្រាន់”។ យើងមានន័យថា ពាក្យដែលយើងប្រើប្រាស់នេះជាពាក្យមួយសមហេតុផល ហើយយើងមិនចង់បកស្រាយបន្ថែមទៅលើពាក្យថា“គ្រប់គ្រាន់”នោះទេ។ យើងប្រើប្រាស់ពាក្យហ្នឹងទៅតាមការវិនិច្ឆ័យ និងកោសល្យវិច័យរបស់យើង ហើយថាតើអ្វីដែលយើងស្នើឡើងនេះវាអាចជួយទៅដល់គាត់ក្នុងការចូលរួម និងតាមដានកិច្ចដំណើរការនីតិវិធីនោះ គឺខ្ញុំសូមមិនលើកឡើងបន្ថែមទៅលើអ្វីដែលយើងបានសរសេរនេះទេ។

**លោក ហុង គីមសួន៖**

បាទ, សូមអរគុណលោកប្រធាន។ ខ្ញុំបាទមានសំណួរត្រឹមនេះ ហើយនិងអនុញ្ញាតលោកប្រធានបន្តទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបរទេស បន្តពីខ្ញុំបាទទៀតបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ហុង គីមសួន។

សូមអញ្ជើញលោកមេធាវី!

[១១:៤៩:២៧]

**សួរដោយលោក អ៊ែរវ៉េ យ៉ាគីសេ៖**

លោកប្រធាន លោកស្រីចៅក្រមជាទីគោរព ដែលបានផ្តល់វេទិកាមកឲ្យខ្ញុំ។

**ស៖** សូមជម្រាបសួរលោក *ដុកទ័រ* ហ្វាស៊ែល លោក *ដុកទ័រ* លីនណា។ បាទខ្ញុំឈ្មោះ អ៊ែរវ៉េ យ៉ាគីសេ ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំចង់ចោទសំណួរពីរបីសំណួរ ទាក់ទងទៅនឹងរបាយការណ៍របស់លោក។ យោងទៅកថាខណ្ឌ៤០ របាយការណ៍របស់លោក លោកនិយាយអំពីការលំបាករបស់អ្នកស្រី អៀង ធីរិទ្ធ ក្នុងការយល់នីតិវិធីក្នុងការការពារខ្លួនរបស់គាត់នោះ។ តើការលំបាកទាំងអស់នេះមិនមែន គឺថាមិនចំពោះមនុស្សទាំងអស់គ្នានោះទេ ដែលថាគេមិនយល់ច្បាប់ ឬក៏ថាលក្ខណៈបច្ចេកទេសនៃនីតិវិធីនោះ?

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** វាអាចពិតដូច្នេះមែន អ្វីដែលយើងចាប់អារម្មណ៍ និងព្រួយបារម្ភនោះ ក្រោយពេលដែលយើងពន្យល់ទៅកាន់គាត់ គាត់ហាក់ដូចជាមិនយល់អំពីនីតិវិធីដេញដោលគ្នា។ ដូច្នេះយើងគិតថាបុគ្គលដែលគាត់មានការអប់រំមួយកម្រិតនេះ គឺគាត់អាចយល់អំពីការពន្យល់របស់យើង។ ក៏ប៉ុន្តែ ខ្ញុំចាត់ទុកថាប្រជាជនទូទៅគឺគាត់មិនយល់អំពីកិច្ចដំណើរការនីតិវិធីដេញដោលនេះទេ។ ទោះបីជាពេលខ្លះយើងធ្វើ

ការពន្យល់ទៅដល់គាត់ក៏ដោយ។ ដូច្នេះហើយតាមអ្វីដែលយើងយល់នោះ គឺថាគាត់ហាក់ដូចជាមិនយល់អំពីការដេញដោលដោយផ្ទាល់មាត់នេះ។

**ស៖** បាទ, គឺថាគាត់មានបញ្ហាច្បាប់នេះ គឺថាត្រូវរៀនបួនប្រាំឆ្នាំ ដើម្បីយល់ ហើយអ្នកខ្លះនិស្សិតខ្លះមិនយល់ច្បាប់នោះផង។ អ៊ីចឹងគឺថាមិនមែនសម្រាប់តែមនុស្សគាត់ម្នាក់នោះទេ?

**ផ៖** ដូចដែលខ្ញុំបានជម្រាបដូច្នោះ យើងមិនសង្ស៊ឹម និងរំពឹងនូវព័ត៌មានលម្អិតពីគាត់នោះទេចំពោះការពន្យល់នូវនីតិវិធីដេញដោលចំពោះមុខ។ អ្វីដែលគាត់ពន្យល់មកកាន់យើងនោះគឺថា មានភាគីសងខាង គឺខាងមេធាវីការពារក្តី និងខាងសហព្រះរាជអាជ្ញា ហើយគាត់ដឹងថា គាត់ និងមេធាវីរបស់គាត់នឹងសួរសំណួរគាត់។ នេះគឺជាការដេញដោលពីខាងមេធាវីការពារក្តីទាក់ទងទៅនឹងសាក្សី។ ដូច្នេះហើយ ខ្ញុំគិតថាអ្នកដែលគាត់ទទួលបានការពន្យល់រួចមកហើយពីយើងនោះ គឺគាត់គួរតែយល់អំពីអ្វីដែលយើងពន្យល់ ប៉ុន្តែគាត់ហាក់ដូចជាមានការលំបាកយល់នូវអ្វីដែលយើងពន្យល់ទៅកាន់គាត់។

[១១:៥២:៤៦]

**ស៖** អរគុណ។ ខ្ញុំយោងទៅកថាខណ្ឌ៤៤នៃរបាយការណ៍របស់លោកនោះ គឺថាតើលោកអាចបញ្ជាក់បានទេថាតើ វាមិនមែនជារឿងកម្រទេ ដែលថាអ្នកដែលប្រឈមមុខទៅនឹងការចោទប្រកាន់ដូចអ្នកស្រី អៀង ធីរិទ្ធ ប្រកាន់ដល់ធ្ងន់ធ្ងរនោះ គឺថាអាចស្ថិតនៅក្នុងស្ថានភាពមួយដែលថា ភ្លេចភ្លាំងនៅក្នុងស្ថានភាពបែបនេះនោះ។

**ផ៖** ខ្ញុំគ្រាន់តែចង់បញ្ជាក់ថា ចំពោះបុគ្គលម្នាក់គាត់ខ្វះឈាម ចំពោះបុគ្គលម្នាក់គាត់ស្លេកស្លាំង គឺគាត់មិនយល់ ឬក៏គាត់មិនយល់អំពីបទចោទទៅលើគាត់នោះ មិនមែនថាគាត់មិនមានសមត្ថភាពក្នុងការយល់អំពីនីតិវិធីនោះទេ។ ពេលវេលាទាក់ទងទៅនឹងការចោទប្រកាន់ទៅលើគាត់ និងការចូលរួមនៅក្នុងសកម្មភាព គឺមិនមែនវាជំរុញមិនឲ្យគាត់យល់នោះទេ។ ដូច្នេះគំនិតទូទៅនៅក្នុងលក្ខណៈវិនិច្ឆ័យថាតើគាត់យល់ទៅលើបទចោទដែរឬទេ គឺដោយសារតែបុគ្គលមួយចំនួន គឺគាត់មិនអាចចងចាំព័ត៌មានលម្អិត ហើយការដែលមិនចងចាំ មិនមែនថាគាត់មិនមានសមត្ថភាពនោះឡើយ។ ហើយចំពោះថាតើគាត់អាចផ្តល់យោបល់នូវអ្វីដែលគាត់បានលើកឡើងក្រោយពីមេធាវីការពារក្តីបានបញ្ជាក់ គឺយើងអាចជឿជាក់ថាទុកចិត្តទៅលើអ្វីដែលគាត់ផ្តល់ជូនមកយើងបាន។

[១១:៥៤:៥០]

**ស៖** បាទ, សូមអរគុណ។ អ្វីដែលខ្ញុំយល់ កថាខណ្ឌ៤៨ នៃរបាយការណ៍របស់លោក គឺយើង

ទាញយកការសន្និដ្ឋានថា តាមរបាយការណ៍របស់លោកនេះ គឺថាអ្នកស្រី អៀង ធីរិទ្ធ មាន នីតិសម្បទានៅក្នុងការយល់ពាក្យថា មានពិរុទ្ធភាព ឬក៏អត់ ហើយនិងយល់ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលគេចោទប្រកាន់ទៅលើគាត់ ហើយយល់ប្រភេទនៃការជម្រះសេចក្តីដែលថាគេកំពុងតែជម្រះសេចក្តីលើគាត់នោះ ហើយយល់នូវខ្លឹមសារនូវពាក្យអ្វីដែលហៅថា ជំងឺវង្វេងវង្វាន់ ឬក៏ឆ្កួតនោះ ហើយក៏មានសមត្ថភាពក្នុងការធ្វើការជាមួយមេធាវីរបស់គាត់។ តើចំពោះលោកនេះ មិនមានមានន័យថា គាត់អាចចូលរួមក្នុងការជម្រះសេចក្តីបានដែរឬទេ?

**ឆ៖** ខ្ញុំគិតថា យើងបានបង្ហាញនៅក្នុងរបាយការណ៍របស់យើងហើយ យើងឃើញថាវាមានតុល្យភាព ហើយខ្ញុំក៏បានលើកឡើងអំពីចំណុចហ្នឹងដែរក្រោយពីការរកឃើញរបស់យើងថា វាមានតុល្យភាព។ ចំណុចនោះហើយគឺជាការរកឃើញរបស់យើងជារួម។ ចំពោះយោបល់ដែលលោកបានលើកឡើង និងការដែលលោករៀបរាប់នោះ បញ្ហាចោទសំណួរនោះ ពាក់ព័ន្ធទៅនឹងអ្វីដែលលោកបានលើកឡើង ថាតើគាត់អាចប្រាស្រ័យទាក់ទងជាមួយនឹងមេធាវីរបស់គាត់ដែរឬទេនោះ គឺបុគ្គលម្នាក់គាត់អាចមានលទ្ធភាពប្រាស្រ័យទាក់ទងជាមួយនឹងមេធាវីរបស់គាត់ ហើយថាតើគាត់មានលទ្ធភាពប្រាស្រ័យទាក់ទងជាមួយនឹងមេធាវីក្នុងការចូលរួមការជំនុំជម្រះដោយយុត្តិធម៌នោះ វាជាគន្លឹះមួយសំខាន់។

[១១:៥៦:៥៨]

ចំណុចមួយទៀត ថាតើគាត់យល់អំពីកិច្ចដំណើរការនីតិវិធី លក្ខណៈនៃនីតិវិធីដែរឬទេ? វាអាស្រ័យទៅលើលក្ខខណ្ឌ ដែលយើងកំណត់នៅក្នុងលក្ខណៈវិនិច្ឆ័យរបស់យើង។ ដោយសារតែយើងបានចង្អុលបញ្ជាក់ហើយថា យើងពិតជាជឿថា លោកស្រី អៀង ធីរិទ្ធ មានការលំបាកច្រើនក្នុងការរក្សាទុកនូវព័ត៌មានមួយចំនួន នៅពេលដែលគាត់ចូលរួមក្នុងសវនាការនេះ។ ហេតុដូច្នេះហើយ វាពិបាកក្នុងការលើកឡើងថាតើ លោកស្រីនុំងគាត់អាចយល់ទាំងស្រុងទៅលើលក្ខណៈនៃកិច្ចដំណើរការនីតិវិធីនេះ ឬក៏យ៉ាងណា ឬក៏គាត់យល់អំពីតួនាទីរបស់ចៅក្រម។

ព័ត៌មានលម្អិតទាំងឡាយនោះ យើងបានលើកឡើងនៅក្នុងរបាយការណ៍របស់យើងហើយៗ យើងយល់អំពី ការដែលគាត់មិនយល់អំពីកិច្ចដំណើរការនីតិវិធីដេញដោលគ្នា ហើយក៏ប៉ុន្តែយើងយល់ខ្លះថាគាត់មានសមត្ថភាពមួយចំនួនក្នុងការយល់កិច្ចដំណើរការនីតិវិធីនៅក្នុងតុលាការ។ ដូច្នេះហើយសេចក្តីសម្រេចដែល អាចជាតុល្យភាពមួយទៅលើករណីនេះ។

[១១:៥៨:២៥]

ចំពោះចំណុចដែលលោកបានលើកឡើងពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងជាមួយនឹងមេធាវីការពារក្ដី និងយល់អំពីលក្ខណៈនៃកិច្ចដំណើរការនីតិវិធី ដោយមិនមានបញ្ហាចំពោះគាត់នោះ គឺវាអាច ក៏អាចមានបញ្ហាសម្រាប់គាត់។

**ស៖** បាទ, សូមអរគុណ។ នេះជាសំណួរចុងក្រោយរបស់ខ្ញុំ យើងយោងទៅលើកថាខណ្ឌ៣៩ នៃរបាយការណ៍របស់លោកទាក់ទងទៅនឹងលក្ខណៈវិនិច្ឆ័យនៃរឿងក្ដី *ស្ត្រូហ្កា* ដែលលោកបានបញ្ជាក់អំពីកម្រិតនៃការវាយតម្លៃលើកាយនីតិសម្បទាក្នុងការចូលរួមក្នុងការសវនាការនេះ។ លោកឲ្យតម្លៃលើលក្ខណៈវិនិច្ឆ័យណាមួយ ឬក៏ស្មើគ្នាទាំងអស់?

[១១:៥៩:៣២]

**ប្រធានអង្គជំនុំ៖**

សំណួរនេះ គឺជាសំណួរបច្ចេកទេសខាងផ្លូវច្បាប់ទេ ហើយមិនមែនជាមុខងាររបស់អ្នកជំនាញទេ។ អ៊ីចឹង សំណួរនេះអ្នកជំនាញមិនបាច់ឆ្លើយនឹងសំណួរនេះចំពោះមេធាវីទេ។

**លោក អ៊ែរវេ យ៉ាគីសេ**

បាទ, សូមអរគុណលោកប្រធាន។ ខ្ញុំពុំមានអ្វីចោទសួរទៀតទេ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកសហមេធាវី។ អរគុណអ្នកជំនាញ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកពិសាអាហារថ្ងៃត្រង់ហើយ ប៉ុន្តែមុននឹងសម្រាកអង្គជំនុំជម្រះសូមជម្រាបរំឭកដល់ភាគី និងមេធាវី ក្រុមមេធាវីដែលអង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យផ្ដល់នូវមតិយោបល់នៅរសៀលនេះដូចខាងក្រោម៖

តាមផែនការដែលបានគ្រោងទុកក្រុមមេធាវីការពារក្ដីដទៃទៀត រួមមានមេធាវីការពារក្ដីលោក អៀង សារី និងមេធាវីការពារលោក នួន ជា ត្រូវបានអង្គជំនុំជម្រះអញ្ជើញឲ្យចូលរួមនៅក្នុងការបញ្ចេញមតិយោបល់ពាក់ព័ន្ធនឹងស្ថានភាពរបស់ អៀង ធីរិទ្ធ និងដោយគិតទៅដល់ទិដ្ឋភាពរបស់ជនជាប់ចោទផ្សេងទៀតក្នុងការទទួលបាននូវសវនាការឆាប់រហ័ស។ ក្រុមមេធាវីគួរគិតពិចារណាថា តើវាមានជាប្រយោជន៍នៃយុត្តិធម៌ដែរឬទេ? ដែលជនជាប់ចោទ អៀង ធីរិទ្ធ គួរតែត្រូវបានបំបែកចេញពីកិច្ចដំណើរការនីតិវិធីនេះ។

[១២:០១:២៣]

អនុលោមតាមវិធាន៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសូមរំឭកដល់ក្រុមមេធាវីការពារ

ក្តីទាំងពីរក្រុមថា គោលបំណងនៃការធ្វើអន្តរាគមន៍នេះ គឺត្រូវកំហិតត្រឹមតែ ថាតើការបំបែកកិច្ចដំណើរការនីតិវិធីចំពោះជនជាប់ចោទ អៀង ធីរិទ្ធ គួរតែត្រូវបានទទួលយកដែរឬទេ? បើគិតទៅដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវសវនាការមួយប្រកបដោយយុត្តិធម៌ សវនាការនេះ-- សវនាការពីមុនៗដែលបានពិចារណាលើបញ្ហាថាតើជនជាប់ចោទ នួន ជា មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការដែរឬទេ? នោះបញ្ហានេះពុំមែនជាកម្មវត្ថុដែលអាចលើកឡើងយកមកពិចារណានៅក្នុងថ្ងៃនេះទេ។

[១២:០២:១៦]

អង្គជំនុំជម្រះសូមជម្រាបថា ក្រុមមេធាវីនីមួយៗអង្គជំនុំជម្រះនឹងផ្តល់ពេលវេលាដប់ប្រាំនាទីក្នុងការធ្វើការបញ្ជាក់អំពីបញ្ហានេះ ហើយគឺចាប់ផ្តើមមុនគេតែម្តង គឺនៅពេលដែលចូលមកត្រឡប់មកវិញ គឺចាប់ផ្តើមនូវបញ្ហានេះតែម្តង ប្រសិនបើមានមតិយោបល់។ ហើយទន្ទឹមនឹងនេះអង្គជំនុំជម្រះក៏សូមដូចជាជម្រាបរំឭកដល់ភាគីផ្សេងទៀតដែរ គឺអង្គជំនុំជម្រះនឹងផ្តល់វេទិកាទៅជូនមេធាវីការពារក្តី អៀង ធីរិទ្ធ រយៈពេល៤០នាទី សហព្រះអាជ្ញារយៈពេល៤៥នាទី មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី១៥នាទី ក្នុងការធ្វើសេចក្តីសន្និដ្ឋានចប់នៃកិច្ចពិភាក្សាដេញដោលអ្នកជំនាញនេះ ដោយខ្ញុំសូមបញ្ជាក់ថា រួមទាំងការធ្វើសង្កេតលើមតិយោបល់ដែលមេធាវីពីរក្រុមនឹងបង្ហាញនៅរសៀលនេះផងដែរ។

[១២:០៣:៣៨]

ខ្ញុំនិយាយអំមិញ គឺត្រឹមត្រូវហើយ ប៉ុន្តែតាមព័ត៌មានអំមិញថា មានការបកប្រែខុស។ ខ្ញុំប្រឹងអានយ៉ាងយឺតៗ ប៉ុន្តែនៅតែខុសអំពីរយៈពេលវេលានេះច្រើនលើកច្រើនសាហើយ។ សូមបញ្ជាក់ឡើងវិញ មេធាវី អៀង ធីរិទ្ធ មានរយៈពេល៣០នាទី សហព្រះរាជអាជ្ញាមានរយៈពេល៤៥នាទី មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេល១៥នាទី។ ការធ្វើសន្និដ្ឋាននេះ គឺរួមទាំងការកត់សម្គាល់ទៅលើមតិយោបល់ដែលនឹងបញ្ចេញមតិយោបល់ដោយមេធាវីពីរក្រុម គឺមេធាវី នួន ជា និងមេធាវី អៀង សារី ដែលគាត់នឹងធ្វើការបង្ហាញនូវដើមម៉ោងបន្ទាប់ពីចូលមកដំណើរការសវនាការនៅរសៀលនេះ។ ហើយដោយឡែកគឺអង្គជំនុំជម្រះ--

សូមអញ្ជើញ!

**លោកស្រី ដាយអាណា អេលីស៖**

ខ្ញុំសូមអនុញ្ញាតពេលមួយចំនួនក្រោយពេលអាហារថ្ងៃត្រង់ ដើម្បីឲ្យយើងដេញដោលទៅលើវេជ្ជបណ្ឌិតទាំងពីរលើសំណួរចំនួនដែលវាពាក់ព័ន្ធក្រោយពេលធ្វើកោសល្យវិច័យ។ នេះជាសំណើរបស់

ខ្ញុំទីមួយ។

សំណើរបស់ខ្ញុំទីពីរ គឺខ្ញុំសូមបញ្ជាក់ ថាតើយើងមានរយៈពេលតែ៣០នាទី ឆ្លើយតបទៅនឹងសំណួរទាំងប្រាំ ដែលអង្គជំនុំជម្រះចោទសួរមកលើយើងខ្ញុំ ឬក៏យ៉ាងម៉េច? តើនេះជាការត្រឹមត្រូវដែរឬទេ?

[១២:០៥:២៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០៧:២២]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយធ៍៖**

លោកប្រធានបានស្នើខ្ញុំឲ្យឆ្លើយតបទៅនឹងសំណើទាំងពីររបស់លោកស្រីមេធាវី ដាយអាណា អេលីស។ ជាការពិត លោកស្រីមានសិទ្ធិក្នុងការដេញដោលលោកវេជ្ជបណ្ឌិតទាំងពីរ ក៏ប៉ុន្តែការដេញដោលនោះសូមឲ្យខ្លី ដោយសង្ខេប។ ដោយសារហេតុថា យើងចង់បញ្ចប់សេចក្តីសន្និដ្ឋានពីភាគីទាំងអស់ក្នុងរសៀលនេះ ជាផលប្រយោជន៍សម្រាប់លោកស្រី ភាគីទាំងអស់ និងអ្នកជំនាញ។

[១២:០៧:៤៨]

ចំណុចទីពីរ រយៈពេលសន្និដ្ឋានសាមសិបនាទី សម្រាប់លោកស្រី គឺដើម្បីបន្ថែមទៅលើការដែលលោកស្រីដេញដោលទៅលើគំនិតមតិយោបល់របស់អ្នកជំនាញ ហើយនិងផ្តល់ឲ្យលោកស្រីឆ្លើយទៅនឹងការលើកឡើងមេធាវីការពារក្តីពីរផ្សេងទៀតផងដែរ ដែលយើងត្រូវការស្តាប់ការបង្ហាញ និងសេចក្តីសន្និដ្ឋានរបស់គាត់ ឆ្លើយតបទៅនឹងសំណួរបស់លើកឡើងដោយអង្គជំនុំជម្រះសាលាដំបូង។ ថាតើច្បាស់ដែរឬទេ ចំពោះលោកស្រី?

**លោកស្រី ដាយអាណា អេលីស៖**

ជាការពិត គឺខ្ញុំយល់ច្បាស់ហើយ។ ដូច្នេះហើយខ្ញុំយល់ថា យើងមិនផ្តល់ពេលឆ្លើយតបទៅនឹងសំណួរទាំងប្រាំរបស់អង្គជំនុំជម្រះនោះទេ។ តើពិតជាត្រឹមត្រូវដែរឬទេ?

[១២:០៨:៥៧]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយធ៍៖**

តើសំណួរទីមួយនោះយ៉ាងម៉េច? ខ្ញុំហាក់ដូចជាភ័ន្តភាំងហើយ។

**លោកស្រី ដាយអាណា អេលីស៖**

សំណួរទីមួយ គឺពាក់ព័ន្ធទៅនឹង ថាតើលទ្ធភាពផលវិបាកកើតចេញពីដីកាបំបែកកិច្ចដំណើរការនីតិវិធីនោះ?

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

គឺអាចលើកអ្វីដែលលោកស្រីគិតថាលោកស្រីចង់លើកឡើងនោះ។ អ៊ីចឹងច្បាស់ដែរឬទេសម្រាប់ភាគីទាំងអស់គ្នា?

[១២:០៩:២៥]

**លោកស្រី ដាយអាណា អេលីស៖**

ច្បាស់ហើយ។ អរគុណលោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

បាទ, ឥឡូវហ្នឹងច្បាស់ហើយ ហើយដល់ពេលត្រូវសម្រាកពិសាអាហារថ្ងៃត្រង់ផង។ ដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាដើម្បីពិសាអាហារថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់បី និងសាមសិបនាទីរសៀលនេះ សូមអញ្ជើញភាគី អ្នកត្រូវចូលរួម ហើយនិងសាធារណជនចូលមកកាន់ទីកន្លែងរៀងៗខ្លួនឲ្យបានមុនម៉ោងដប់បី និងសាមសិបនាទីជាកំហិត ដើម្បីបន្តកិច្ចដំណើរការរបស់យើង។

**លោក ឌុច ផារី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:១១ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣២:០៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុនពេលសម្រាកពិសាអាហារថ្ងៃត្រង់ យើងខ្ញុំបានជម្រាបជូនអំពីកិច្ចដំណើរការនីតិវិធីដែលគ្រោងនឹងប្រព្រឹត្តទៅនៅរសៀលនេះ ដោយចាប់ផ្ដើមពីមេធាវីពីរក្រុម គឺមេធាវី នួន ជា និងមេធាវី អៀង សារី។ ប៉ុន្តែ ដោយមានការស្នើសុំមេធាវីការពារក្ដីឲ្យលោកស្រី អៀង ធីរិទ្ធ ក្នុងការសួរពាក់ព័ន្ធនឹងបញ្ហាមួយចំនួនក្នុងគោលបំណងសួរបន្ថែម ដូច្នេះ

អង្គជំនុំជម្រះដាក់បញ្ហានេះមុន ដោយប្រគល់វេទិកានេះជូនទៅមេធាវីការពារក្ដីលោកស្រី អៀង ធីរិទ្ធ ដើម្បីមានឱកាសសួរទៅអ្នកជំនាញចំនួនពីររូប ហើយការកំណត់ពេលវេលាមិនឲ្យលើសពីដប់នាទីទេ ក្នុងការសួរបន្ថែមនេះ។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោកស្រី ដាយអាណា អេលីស៖**

សូមអរគុណលោកប្រធាន។

**ស៖** ជាបឋមខ្ញុំសូមកែតម្រូវថា ភស្តុតាងពីរដែលបង្ហាញថាខ្វែងគ្នានៅក្នុងរបាយការណ៍របស់សាស្ត្រាចារ្យ ហ្វាស៊ែល តើលោកមើលកថាខណ្ឌលេខ១៨។ កថាខណ្ឌ១៨ នៅក្នុងរបាយការណ៍លោកនិយាយថា លោក សុភារម្យ កត់សម្គាល់ឃើញថា ម្ដងម្កាល គាត់ដាក់កន្លែង ខុសកន្លែង ហើយចោទប្រកាន់បុគ្គលិកមន្ទីរឃុំឃាំងថាបានលួច។ ថាតើនេះជាហេតុការណ៍តែមួយ ឬក៏មានច្រើនលើក? តើលោកនៅចាំទេ?

[១៣:៣៤:១២]

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** ខ្ញុំត្រូវយោងទៅកំណត់ហេតុរបស់ខ្ញុំ ថាតើមានឱកាសបែបហ្នឹងប៉ុន្មានដង? ខ្ញុំអាចពិនិត្យមើលនៅទីនេះ។

**ស៖** ខ្ញុំដូចជាមានពេលខ្លី អ៊ីចឹងខ្ញុំសូមចូលទៅដល់ចំណុចមួយទៀតនៅក្នុងកំហុសនៅក្នុងមួយទៀតនៅក្នុងកថាខណ្ឌលេខ២៣ ដែលនិយាយថា អៀង ធីរិទ្ធ បានផ្តល់សម្ភាសដោយលោក ហើយនិងសមាជិករបស់លោក ហើយគាត់មិនអាចបញ្ជាក់ពីអាសយដ្ឋានជាក់លាក់របស់គាត់ទេ គាត់គ្រាន់តែដឹងថាគាត់នៅភ្នំពេញ។ តើបានបញ្ជាក់នៅក្នុងឯកសារច្បាស់អ៊ីចឹងដែរឬទេ?

**ឆ៖** ខ្ញុំពិនិត្យមើលឃើញកំហុសឆ្គង។

[១៣:៣៥:០៣]

**ស៖** ឌុកទ័រ លីនណា បាននិយាយថា គាត់មិនចាំអាសយដ្ឋានរបស់គាត់ទេ។ អ៊ីចឹង សូមឲ្យអ្នកជំនាញកែតម្រូវទៅតាមនោះ។

**ឆ៖** ខ្ញុំសូមឆ្លើយទៅនឹងសំណួរទាំងពីរនេះ នៅក្នុងកំណត់ហេតុរបស់ខ្ញុំនោះ គឺខ្ញុំសរសេរផ្ទាល់ដែរ៖ ម្ដងម្កាលគាត់ដាក់របស់ខុសកន្លែង។

**ស៖** អ៊ីចឹងគ្មានកត់ត្រានៅក្នុងរបាយការណ៍ទេ។ ខ្ញុំចង់កែតម្រូវកំហុសនៅកន្លែងហ្នឹង។

**ធ៖** ខ្ញុំមិនយល់។ វេជ្ជបណ្ឌិត លីនណា បញ្ជាក់ថាកើតឡើងតែម្តងទេ ហេតុការណ៍ដែលថាគាត់ភ្លេចភ្លាំងរបស់មិនដឹងទុកកន្លែងណានោះ។

[១៣:៣៥:៥០]

**ស៖** ខ្ញុំចង់បានបញ្ជាក់ថា បើលោករកមិនទាន់ឃើញ ខ្ញុំបន្តទៅមុខ។

**ធ៖** ទាក់ទងទៅនឹងសំណួរទីពីរ គាត់មិនចាំអាសយដ្ឋានជាក់លាក់ទេគាត់គ្រាន់តែចាំថាគាត់នៅផ្លូវធំមួយនៅភ្នំពេញដែលយើងយល់ថាត្រឹមត្រូវ ប៉ុន្តែគាត់មិនចាំអាសយដ្ឋានជាក់លាក់ដែលមានលេខផ្លូវលេខផ្ទះនោះទេ។ នេះហើយជាចំណុចដែលយើងរកឃើញ ដែលយើងបញ្ជាក់ថាគាត់មិនចាំអាសយដ្ឋានពិស្តារ។

**ស៖** ទាក់ទងពីរឿងស្ថានភាពសុខភាពនិយាយពីសតិបញ្ញារបស់គាត់ថា តើជាបញ្ហាជាសតិបញ្ញាទូទៅ ឬក៏ទាំងស្រុងយ៉ាងណា?

**ធ៖** គឺបាទ។

**ស៖** អ៊ីចឹង មានន័យថាទាក់ទងទៅនឹងមុខងារខួរក្បាលទាំងអស់ឬក៏យ៉ាងម៉េច?

**ធ៖** វាប៉ះពាល់ទៅដល់មុខងារខួរក្បាល ខ្ញុំមិននិយាយថាគ្រប់មុខងារនៃខួរក្បាលទាំងអស់នោះទេ ហើយមិនមានភស្តុតាងច្បាស់លាស់ថា មានចំណុចមួយឬពីរដែលថា យើងយោងទាក់ទងទៅនឹងការវាស់ស្ទង់តាមការវាយតម្លៃស្ថានភាពផ្លូវចិត្តអតិបរមានេះ ហៅថា អ៊ឹម.អេស.អេស.អ៊ី នេះ។

[១៣:៣៧:១៣]

**ស៖** ទាក់ទងទៅនឹងវេជ្ជសាស្ត្រគឺការប្រើប្រាស់ថ្នាំដែលលើកឡើងដោយសាស្ត្រាចារ្យ ខាំប៉ែលដែលត្រូវបានប្រើយ៉ាងត្រឹមត្រូវនៅក្នុងតំបន់ផ្សេងៗទៀត ដូចនៅក្នុងប្រទេសអង់គ្លេស តើអ៊ីចឹងមែនទេ?

**ធ៖** ប្រាកដហើយគេបានប្រើនៅក្នុងចក្រភពអង់គ្លេស។ ប៉ុន្តែខ្ញុំពិបាកនឹងបញ្ជាក់ថាបានត្រូវប្រើដោយបញ្ញាណត្រឹមត្រូវទេ ប៉ុន្តែវាត្រូវផ្អែកទៅលើគោលការណ៍ការណែនាំខាងវេជ្ជសាស្ត្រ ហើយយើងត្រូវតាមដានឲ្យល្អិតល្អន់។ ដូច្នេះទស្សនៈរបស់ខ្ញុំហ្នឹង គឺមិនអាចបញ្ជាក់ថាគេប្រើយ៉ាងត្រឹមត្រូវនោះទេ។

[១៣:៣៧:៥៤]

**ស៖** តើជាការព្រួយបារម្ភទេ ទាក់ទងនឹងករណី អៀង ធីរិទ្ធ ដែលគាត់មិនប្រើថ្នាំលើស ឬថ្នាំដែលបះពាល់ទៅលើសុខភាពផ្សេងទៀតនោះ?

**ធ៖** នេះជាការព្រួយបារម្ភរបស់ក្រុមការងាររបស់យើង។

**ស៖** ដូចដែលយើងបានឮពីសាស្ត្រាចារ្យ ខាំប៊ែល ប្រហែលជាលោកអាចបញ្ជាក់ថា តើមានផលប្រយោជន៍អីមួយទេ គឺផលប្រយោជន៍នោះគឺលក្ខណៈបណ្ដោះអាសន្នទេ?

**ធ៖** បាទ, ហ្នឹងហើយខ្ញុំយល់បែបនោះដែរ។

**ស៖** ការស្នើនូវការកែលម្អលក្ខខណ្ឌរបស់លោកស្រី អៀង ធីរិទ្ធ ថាតើយើងត្រូវទេ ដែលថាវាអាចទំនងជាថាវាមានផលបះពាល់ទៅលើអ្នកជំងឺដែលមានវ័យក្មេង តែចំពោះអ្នកចាស់មិនមានទេ?

**ធ៖** ខ្ញុំមិនដឹងចម្លើយទៅនឹងសំណួរនេះទេ។

**ស៖** លោកបានប្រាប់យើងថា មានកត្តាចង្អុលបង្ហាញប្រាប់លោកថា អៀង ធីរិទ្ធ គាត់បានអានកាសែត តើត្រឹមត្រូវទេដែលថាគាត់មិនអាចឆ្លើយទៅនឹងសំណួរណាមួយដែលលោកសួរសំណួរទៅគាត់ទាក់ទងទៅថា តើព័ត៌មានអ្វីនៅក្នុងសារព័ត៌មានអន្តរជាតិ ឬក៏ជាតិនោះ?

**ធ៖** បាទ, ត្រឹមត្រូវហើយ។

**ស៖** តើលោកឯកភាពដែរឬទេ វាមានការខុសគ្នាទេ លទ្ធភាពនៃការអានពាក្យនៅលើទំព័រហើយនិងអាចប្រមូលយល់អត្ថន័យខ្លឹមសារនៅក្នុងមួយទំព័រនោះ?

**ធ៖** បាទ។

[១៣:៣៩:៣២]

**ស៖** តើលោកធ្វើតេស្តអីពិស្ដារដើម្បីឲ្យប្រាកដថា តើគាត់អាចយល់លទ្ធភាពអ្វីៗទាំងអស់ តាមរយៈការអានដែរឬទេ នៅក្នុងពេលយោងព័ត៌មាន នៅពេលដែលលោកអានឲ្យគាត់ស្ដាប់ ថាតើគាត់បានសួរសំណួរអ្វីទេ?

**ធ៖** យើងបានយោងទៅរកប្រយោគមួយដែលយើងបាន យើងសូមឲ្យគាត់ធ្វើតាម ហើយយើងក៏បានសូមឲ្យគាត់ឲ្យបកប្រែសុភាសិតមួយ។ យើងបានសុំឲ្យគាត់ពន្យល់អំពីរបស់ផ្សេងៗដែលស្រដៀងនឹងគ្នា ហើយយើងបានផ្ដល់វត្ថុបីឲ្យគាត់ពន្យល់។ ការឆ្លើយតបទៅនោះគឺថា នៅក្នុងរបាយការណ៍យើងមានជាសេចក្ដីសង្ខេប គាត់មានលទ្ធភាពផ្ដល់របស់ពីរ ដែលថាបីស្រដៀងគ្នា គាត់បានផ្ដល់តែពីរ គាត់មិនអាចពន្យល់ពីសុភាសិតនោះបានទេ។ ប្រហែលជាវេជ្ជបណ្ឌិត លីនណា លោកអាចបញ្ជាក់បន្ថែម។

[១៣:៤០:៣៧]

**សៈ** សូមអរគុណ។ លោកគិតថា គាត់យល់អំពីផលវិបាកនៃការកាត់ទោស។ តើមានកត្តាអ្វីបង្ហាញដល់លោកទេថា លោកយល់ថា គាត់ត្រូវបានគេឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំង ប៉ុន្តែផ្ទុយទៅវិញគាត់គិតថា ជាមន្ទីរពេទ្យទៅវិញទេ?

**ផៈ** ហើយខ្ញុំសូមពេលពីរបី*សេហ្គុង* ដើម្បីមើលកំណត់ហេតុរបស់ខ្ញុំ។ ខ្ញុំមិនចាំថា គាត់ទទួលស្គាល់ថា គាត់ថិតនៅក្នុងមន្ទីរឃុំឃាំងនោះទេ។

**សៈ** លោកនិយាយថា គាត់មានសមត្ថភាពក្នុងការឆ្លើយតបទៅនឹងបទចោទ។ អ៊ីចឹងគឺថា នៅក្នុងករណីខ្លះនេះ តើលោកអាចវាយតម្លៃថា គាត់មិនមានការចងចាំអំពីហេតុការណ៍នៅក្នុងជីវិតរបស់គាត់នៅក្នុងទសវត្សរ៍ឆ្នាំ៧០ ថាតើគាត់អាចនឹងកំណត់ អាចនឹងធ្វើការឆ្លើយតបទៅនឹងការចោទប្រកាន់ដោយមានអត្ថន័យដូចម្តេចបាន?

**ផៈ** តាមទស្សនៈរបស់ខ្ញុំ សមត្ថភាពជាក់លាក់មួយនេះ គឺមិនអាស្រ័យទៅលើការចងចាំទេ ដែលហៅថា អ្វីៗដែលកើតឡើងក្នុងទសវត្សរ៍ឆ្នាំ៧០ហ្នឹងគឺថា វាជាហេតុការណ៍ដែលថាតើគាត់ជឿជាក់ថាតើពិតមិនពិតថាគាត់មានពិរុទ្ធភាពពីបទល្មើសនោះ។ នេះជាទស្សនទានមួយ នេះហើយជាលក្ខណៈវិនិច្ឆ័យដែលខ្ញុំយល់បាន។ ដូច្នេះទស្សនៈរបស់យើង គឺបានបញ្ជាក់នៅក្នុងរបាយការណ៍នោះហើយ។

[១៣:៤៣:១០]

**សៈ** សមត្ថភាពក្នុងការណែនាំមេធាវី លោកបាននិយាយថាគាត់មានលទ្ធភាពក្នុងការសហការជាមួយមេធាវី ប៉ុន្តែគាត់សហការជាមួយលោកដែរឬទេពេលនោះ?

**ផៈ** បាទ។

**សៈ** តើលោកឯកភាពទេ តើវាខុសគ្នាទេក្នុងការមានលទ្ធភាពក្នុងការរៀបចំការការពារខ្លួនរបស់គាត់ ដែលតម្រូវឲ្យគាត់ផ្តល់នូវអង្គហេតុ រឿងរ៉ាវដែលគាត់ធ្វើអ្វី មុខងារអី ជាមួយអ្នកណា នៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ នោះ?

**ផៈ** នៅក្នុងកម្រិតនៃសហការ គឺថានៅក្នុងទស្សនៈរបស់ខ្ញុំគឺក្នុងកម្រិតមួយគឺថា អាចនឹងឆ្លើយតបបាន។

[១៣:៤៣:៥៥]

**សៈ** ក្នុងអ្វីដែលលោកបានប្រាប់យើងគឺថា គាត់មិនបានបំពេញទៅតាមសមត្ថភាពនៅក្នុងន័យមួយដែលគាត់មិនអាចនឹកឃើញពីអ្វីៗ ដែលកើតក្នុងជីវិតអតីតកាលរបស់គាត់ទេ។

**ឆ៖** ខ្ញុំគិតថា ពាក្យរបស់យើង គឺថាយើងដាក់ថា មានការលំបាកច្រើនក្នុងការបំពេញទៅតាមសមត្ថភាពនោះ ព្រោះមានការចុះខ្សោយខាងបញ្ញា។

**ស៖** តើគាត់មានសមត្ថភាពក្នុងការផ្ដល់សក្ខីកម្មទៅលើអង្គហេតុ ដែលកើតឡើងយូរណាស់មកហើយ ដែលជាហេតុការណ៍កើតឡើងរវាងឆ្នាំ១៩៧៥ ដល់៧៩ ដោយហេតុថា ការចងចាំរបស់គាត់ថាគាត់បានធ្វើអ្វីខ្លះនៅពេលនោះ។ បើវាមានការចុះថយ តើលោកយល់ដូចម្ដេច?

[១៣:៤៤:៤២]

**ឆ៖** ទស្សនៈដែលយើងបានប្រកាន់យក ហើយយើងរកឃើញនោះគឺ គាត់អាចយល់ការចោទប្រកាន់ បទចោទប្រកាន់ផ្អែកលើមូលដ្ឋានថា ការយល់ជាសាមញ្ញទៅលើការចោទប្រកាន់នោះ ហើយមានលទ្ធភាពក្នុងការឆ្លើយទៅនឹងសំណួរតាមរបៀបមួយ ដែលយើងបានសួរគាត់ក្នុងរយៈពេលពីរម៉ោងក្នុងរវាងពេលពីរថ្ងៃ គាត់អាចផ្ដល់ចម្លើយបានជាចម្លើយដែលត្រឹមត្រូវ ហើយក្នុងកម្រិតហ្នឹង យើងអាចយល់ថាគាត់មានសមត្ថភាពនឹងផ្ដល់សក្ខីកម្មបាន។ ប៉ុន្តែការចងចាំ ឬការបាត់បង់ការចងចាំមិនមែនជាកត្តាសំខាន់នៅក្នុងសមត្ថភាពមួយនេះទេ។ ដូចជាមនុស្សដែលមានជំងឺភ្លេចភ្លាំង ពេលខ្លះវាសមត្ថភាពមួយបាត់ ប៉ុន្តែសមត្ថភាពមួយទៀតវាមិនទាន់បាត់ទេ ក្នុងករណីខ្លះ។

**ស៖** ចំពោះជំងឺភ្លេចភ្លាំងវិញ ដែលយើងដូចជា ជាជំងឺដែលកើតឡើងដោយប្រើគ្រឿងញៀនស្រវឹងច្រើនពេក តើវាអាចប៉ះពាល់ទៅដល់ការចងចាំជាទូទៅ សតិបញ្ញាទូទៅដែលគេហៅថា ជំងឺវង្វេងវង្វាន់ដែរឬទេ? វាខុសពីបុគ្គលដែលថាមានមនុស្សជំងឺភ្លេចភ្លាំង? តើលោកយល់ដូចម្ដេច?

**ឆ៖** ខ្ញុំនឹងយល់ព្រមទៅតាមហ្នឹង ដែលថាមនុស្សអ្នកដែលមានជំងឺបាក់ស្បាត ក៏តែងតែមានជំងឺភ្លេចភ្លាំងនៅក្នុងពេលមួយដែល ឧទាហរណ៍ថានៅពេលដែលមានការចោទប្រកាន់ពីបទល្មើស ដូចថាអ្នកដែលមានជំងឺភ្លេចភ្លាំងដែលទាក់ទងទៅនឹងស្ថានភាពមួយដែលវាអាចនឹងឈានចូលទៅដល់*ឌីមែនស្យា* ។

**ស៖** អ៊ីចឹង យើងចូលទៅដល់ហេតុការណ៍កើតឡើងក្នុងឆ្នាំ១៩០០-- ទសវត្សរ៍១៩៧០ ដែលថាគាត់មានលទ្ធភាព ថាគាត់អាចនឹងផ្ដល់សក្ខីកម្ម ដោយគាត់ផ្ទាល់ដែលថា ឧទាហរណ៍ថានៅក្នុងឆ្នាំ១៩៧៥ ខែមេសា ថ្ងៃទី១៧។ បើគាត់មិនមានការចងចាំទាំងអស់ តើគាត់ផ្ដល់សក្ខីកម្មម៉េចបាន តើដូចម្ដេច?

[១៣:៤៧:១០]

**ឆ៖** វាមួយផ្នែក វាអាស្រ័យទៅលើលក្ខណៈវិនិច្ឆ័យណាមួយ ជាពិសេសជាឧទាហរណ៍ដែល

យើងបានឲ្យក្នុងករណីនេះ ហើយយើងគិតថាដូចជាការតាមដានដំណើរការនីតិវិធី ក្រៅពីអ្វីលទ្ធភាពក្នុងការផ្តល់សក្ខីកម្ម។ នេះជាកាលៈទេសៈ លក្ខណៈវិនិច្ឆ័យមានកម្រិតមួយ ដែលថាផ្តោតតែទៅលើសំណួរ ហើយនិងឆ្លើយសំណួរប្រយោគដែលថាអាចនឹងមានន័យ ទាក់ទងទៅនឹងវេយ្យាករណ៍ ហើយនិងរចនាសម្ព័ន្ធប្រយោគ ហើយយើងឯកភាពជាមួយ យល់ស្របជាមួយលោកស្រីថា ជាឧទាហរណ៍ដែលលោកស្រី យើងលើកឡើងពី បើសិនជាការតាមដានដំណើរការនីតិវិធីដ៏មានខ្លឹមសារនោះ យើងបញ្ជាក់ថាវាមានការលំបាកខ្លាំង ដូចជាការឲ្យគាត់ផ្តល់យោបល់ពិភាក្សាលើបញ្ហាដែលលើកឡើងនៅក្នុងដំណើរនោះ នៅតុលាការ។ នេះហើយគឺជាសមត្ថភាពមួយដែលចុះខ្សោយដោយសារការបាត់បង់សតិបញ្ញាការចងចាំនោះ។

**លោកស្រី ដាយអាណា អេលីស៖**

សូមអរគុណច្រើន។

[១៣:៤៨:២០]

**ប្រធានអង្គជំនុំ៖**

សូមអរគុណមេធាវី។ អរគុណលោកអ្នកជំនាញទាំងពីររូបដែលបានប្រឹងប្រែងអស់ពីលទ្ធភាពឆ្លើយតបទៅនឹងសំណួរ និងសំណើឲ្យបង្ហាញផ្សេងៗពាក់ព័ន្ធនឹងរបាយការណ៍របស់លោករយៈពេលមួយថ្ងៃជាងកន្លងមកនេះ។ ហើយកិច្ចដំណើរការនៃការពិភាក្សាដេញដោលលើរបាយការណ៍របស់លោកទាំងពីរ ឃើញថាដល់ទីបញ្ចប់ហើយ ហើយឲ្យលោក អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកត្រឡប់ទៅលំនៅដ្ឋានឬក៏គោលដៅដែលលោកអាចចង់ទៅបានហើយ។ ហើយតាមព័ត៌មានគឺលោក ហ្វាស៊ែល ត្រូវត្រឡប់ទៅមាតុភូមិរបស់លោកវិញនៅល្ងាចនេះផង។ ហើយសូមអញ្ជើញទៅចុះ ហើយជូនពរលោកឲ្យធ្វើដំណើរប្រកបដោយសុវត្ថិភាព។

បាទ, អរគុណ។ សូមអញ្ជើញ!

មន្ត្រីតុលាការសម្រួលឲ្យគាត់បានត្រឡប់ទៅវិញផង!

[១៣:៥០:០០]

ជាកិច្ចបន្តអង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅមេធាវីការពារក្តីលោក អៀង សារី ប្រសិនបើលោកមានបំណងនៅក្នុងការធ្វើការកត់សម្គាល់អំពីបញ្ហាដែលអង្គជំនុំជម្រះជម្រាបជូនកាលពីព្រឹកមិញពាក់ព័ន្ធជាមួយទៅនឹងស្ថានភាពរបស់ អៀង ធីរិទ្ធ ក្នុងករណីដែលមានការបំបែកកិច្ចដំណើរនីតិវិធី

តើទទួលយកបានដែរឬទេ? ហើយគិតដល់សិទ្ធិរបស់ជនជាប់ចោទផ្សេងទៀតក្នុងការទទួលបានសវនាការមួយប្រកបដោយឆាប់រហ័ស និងយុត្តិធម៌នោះ។ អស់លោកមានរយៈពេលដប់ប្រាំនាទីក្នុងការធ្វើកំណត់សម្គាល់នេះ។ សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន សូមអរគុណលោក លោកស្រីចៅក្រម។ ខ្ញុំនឹងនិយាយដោយសង្ខេបទេ អំពីបញ្ហានេះ។

ចំណុចទីមួយ ខ្ញុំសូមអរគុណលោក លោកស្រីចៅក្រមដែលបានផ្តល់ឱកាសឲ្យយើងខ្ញុំបានចូលរួម ហើយយើងយល់យ៉ាងច្បាស់ថា អំពីកម្រិតដែលយើងនឹងត្រូវឆ្លើយតបនៅក្នុងបញ្ហាជាក់លាក់នេះ។

យើងខ្ញុំគ្រាន់តែចង់ជម្រាបថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ សាលាដំបូងទាក់ទងទៅនឹងបញ្ហានេះ គឺនឹងត្រូវបានគោរពយ៉ាងជ្រាលជ្រៅ ហើយយើងមិនជំទាស់ទៅនឹងការពិតនោះ ក៏ប៉ុន្តែវាឆ្លុះបញ្ចាំងអំពីចេតនានៃអគ្គនោម័តិទៅលើរឿងក្តី។ តាមន័យនេះ ខ្ញុំចង់និយាយថា ប្រសិនបើជនជាប់ចោទមួយនៅក្នុងការជំនុំជម្រះនេះ ដែលត្រូវបង្ហាញខ្លួន ដែលថាបើវាមានបញ្ហាប្រាកដ ដែលគឺថាមិនអាចមានលទ្ធភាពតាមផ្លូវបញ្ញាស្មារតី និងសតិបញ្ញា មិនចូលរួមពេញលេញ ហើយគ្រប់ទិដ្ឋភាពនៃរឿងក្តីទាំងអស់។ ហើយប្រសិនបើទុកឲ្យគាត់ចូលរួមដោយជាក់ស្តែងនោះ វាអាចនឹងជាអយុត្តិធម៌មួយសម្រាប់គាត់។

[១៣:៥២:១៧]

មាត្រា៣៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក នោះចែងថា៖ “អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនតាមស្តង់ដារអន្តរជាតិ ហើយនិងដំណើរការនីតិវិធីត្រឹមត្រូវនៃច្បាប់ដែលមានចែងនៅក្នុងមាត្រា១៤, ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ហើយបុគ្គលគ្រប់រូបមានសិទ្ធិនៅក្នុងការជំនុំជម្រះដោយឆាប់រហ័ស ហើយមានការពិភាក្សា ថាតើមានន័យដូចម្តេច?

គឺថា ការជំនុំជម្រះត្រូវធ្វើឡើងឲ្យបានឆាប់ដែលអាចធ្វើបាន ថាតើយើងត្រូវមានការជំនុំជម្រះខ្លីល្មម ឬក៏ឆាប់បំផុត។ អ៊ីចឹងគឺថា ត្រូវឲ្យចាប់ផ្តើមឆាប់បំផុត ឬក៏ចាប់ផ្តើមហើយឲ្យឆាប់តាមដែលអាចធ្វើបាន ដើម្បីបញ្ចប់ក្នុងករណីហ្នឹង។

[១៣:៥៣:១៨]

អ៊ីចឹង ខ្ញុំពិនិត្យឃើញថានៅក្នុងកត្តាមួយដែលថា នៅក្នុងដំណាក់កាលដំបូងយើងមើលឃើញថា នឹងត្រូវប្រើប្រហែលមួយឆ្នាំ ឬពីរឆ្នាំនៅក្នុងរឿង-- ដែលយើងមើលឃើញមានឧបសគ្គបញ្ហាប្រឈមមួយចំនួន ប្រសិនបើមានការរំខានដោយជាក់ស្តែង យើងនឹងត្រូវប្រើពេលជាច្រើន។

ឥឡូវហ្នឹងចាប់ផ្តើមសក្ខីកម្មរបស់វេជ្ជបណ្ឌិត ហើយនិងភស្តុតាងផ្សេងៗដែលភាគីបានដាក់ជូនមកហ្នឹង គឺវេជ្ជបណ្ឌិតទាំងឡាយ។ ចំណុចមួយដែលយើងបានឃើញច្បាស់នោះ គឺថាគាត់ទទួលការព្យាបាល ដែលថាៗគាត់អាចតាមដានដំណើរការនីតិវិធី ប៉ុន្តែខ្ញុំស្តាប់ឮបញ្ហានេះ។ នៅសហរដ្ឋអាមេរិក ខ្ញុំនឹកឃើញថា គេអាចធ្វើការវិភាគបែបនេះដែរទាក់ទងនឹងរដ្ឋមួយចំនួន ដែលថាជនមួយចំនួនត្រូវបានកាត់ទោសឃើញថាមានពិរុទ្ធភាព ហើយត្រូវកាត់ទោសប្រហារជីវិត។ ប៉ុន្តែក្រោយមកគេដឹងថាអ្នកហ្នឹងមិនមានសម្បទា ប៉ុន្តែតុលាការកំពូលយើងថា យើងអាចព្យាបាលជនដែលគ្មានសម្បទាឲ្យរយៈពេលគ្រប់គ្រាន់ដើម្បីឲ្យជននោះអាចនឹងគេប្រហារជីវិតបាន តើយើងព្យាបាលបុគ្គលណាម្នាក់ ហើយតាមដានស្ថានភាពហ្នឹងទៅតាមមូលដ្ឋានមួយជាក់លាក់មួយដើម្បីធានាថា ដើម្បីកុំឲ្យរំខានដល់នីតិវិធី ហើយដើម្បីឲ្យជននោះកុំឲ្យគាត់បាត់បង់សិទ្ធិក្នុងការចូលរួមក្នុងការជំនុំជម្រះដោយយុត្តិធម៌នោះ។

[១៣:៥៤:៥៦]

ហើយយើងបានពិភាក្សាសេចក្តីសម្រេចរបស់អង្គជំនុំ គឺវាស្ថិតនៅក្នុងឆន្ទានុសិទ្ធិទៅតាមការពិចារណារបស់ចៅក្រម ដូចជា បើនិយាយការកាត់ផ្តាច់នីតិវិធីនោះ គឺជាវិធីមួយដែលជាគោលបំណងតាមអត្តនោម័តិមួយដែលថា យើងត្រូវបញ្ជាក់ថាធ្វើបែបនោះវាអាចនឹងជាកត្តាមួយ ទោះបីជាយើងមានការលំបាកចំពោះមុខយើងក៏ដោយ យើងមិនប្រកាន់យកជំហានដែលងាយនោះទេ ពីព្រោះថាមិនមានផ្លូវណាមួយដែលងាយទេក្នុងរឿងនេះនោះ ពីព្រោះថាអ្វីៗទាំងអស់សុទ្ធតែលំបាក ជម្រើសក៏លំបាក។ យើងត្រូវតែជ្រើសជំរើសដ៏លំបាកដែលយើងត្រូវ-- ហើយជម្រើសខ្លះ គឺថាអ្នកខ្លះមិនពេញចិត្តទេ ប៉ុន្តែយើងនឹងត្រូវពិនិត្យមើលនោះដែរ ដោយយើងពិនិត្យ។ ហើយយើងគិតថា ដូច្នេះខ្ញុំយល់ថាគួរតែកាត់ដកអ្នកស្រី អៀង ធីរិទ្ធ ចេញពីដំណើរការនីតិវិធីឲ្យនីតិវិធីដំណើរទៅ ដើម្បីកុំឲ្យមានការរំខាន។

សូមអរគុណ។

[១៣:៥៦:១៥]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណលោកមេធាវី។

ជាបន្តសូមអញ្ជើញក្រុមមេធាវីលោក នួន ជា ប្រសិនបើមាន ចង់ធ្វើបទបង្ហាញ ឬក៏ធ្វើការសង្កេតបញ្ហានេះ។ សូមអញ្ជើញបាទ!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។

ខ្ញុំនឹងនិយាយដោយសង្ខេបផងដែរ យើងយល់អំពីការថ្លៃប្រឹខិតរបស់អង្គជំនុំជម្រះ ហើយយើងស្វាគមន៍ចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ធ្វើការបំបែកទៅលើរឿងករណីនេះជាពីរផ្នែក។ ខ្ញុំគិតគួរអំពីសវនាការពីរដំណាក់កាល។ ទីមួយ សវនាការទីមួយគឺចំពោះជនជាប់ចោទទាំងឡាយ ដែលគាត់អាចតាមដាន និងអង្គុយក្នុងសវនាការពេញមួយថ្ងៃបាន ដើម្បីចូលរួមការជំនុំជម្រះក្តី។ ហើយសវនាការមួយទៀត គឺគួរតែសម្រាប់ជនជាប់ចោទណា ដែលយើងត្រូវតែធ្វើការរកយុត្តិធម៌សម្រាប់គាត់ គឺបុគ្គលដែលគាត់មិនមានសម្បទាគ្រប់គ្រាន់ ពេញលេញក្នុងការចូលរួមសវនាការ។

[១៣:៥៧:៣៥]

ដូច្នេះហើយលទ្ធភាពដែលថា ការបំបែកការជំនុំជម្រះទៅលើករណី អៀង ធីរិទ្ធ នោះគួរតែអនុវត្តចំពោះករណីកូនក្តីរបស់ខ្ញុំផងដែរ។ កូនក្តីរបស់ខ្ញុំគាត់ក៏ត្រូវការ ការជួយជ្រោមជ្រែងផ្នែកពេទ្យជាដរាបផងដែរ។ ហើយក៏អាចកើតឡើងការឡើងចុះនៃស្ថានភាពសុខភាពរបស់គាត់ជារៀងរាល់ថ្ងៃផងដែរ។ ដូច្នេះហើយដើម្បីជាប្រយោជន៍របស់ អៀង សារី និង ខៀវ សំផន ជាពិសេសដើម្បីជាប្រយោជន៍សិទ្ធិរបស់ជនជាប់ចោទជនទាំងពីរ និងដើម្បីពន្លឿននីតិវិធី យើងគួរតែបំបែកការជំនុំជម្រះករណី នួន ជា ឲ្យដាច់ដោយឡែកពីគេផងដែរ។

សូមអរគុណច្រើនលោកប្រធាន លោក លោកស្រីចៅក្រម។

[១៣:៥៨:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណលោកមេធាវី។

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅមេធាវីការពារក្តីឲ្យលោកស្រី អៀង ធីរិទ្ធ ដើម្បីឡើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់នូវកិច្ចពិភាក្សានេះ។ ហើយអង្គជំនុំជម្រះបានជម្រាបជូនព្រឹកមិញហើយថា ក្រុមមេធាវីរបស់លោកស្រី អៀង ធីរិទ្ធ ហ្នឹងមានពេលវេលាសរុបហ្នឹង៣០នាទី នៅក្នុងការធ្វើសេចក្តីសន្និដ្ឋាននេះ។ សូមអញ្ជើញបាទ!

[១៣:៥៩:១១]

**លោក ផាត់ ពៅស៊ាង៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គជំនុំជម្រះសាលាដំបូងជាទីគោរព។ សូមគោរពតំណាងអយ្យការ នៃអង្គជំនុំជម្រះនៃ អ.វ.ត.ក។ សូមគោរពសហភាតា និងសូមគោរពអង្គសវនាការទាំងមូល។ គឺខ្ញុំបាទជាមេធាវីការពារក្តីឲ្យអ្នកស្រី អៀង ធីរិទ្ធ សូមអនុញ្ញាតធ្វើសេចក្តីសន្និដ្ឋានចំពោះការវាយតម្លៃសម្បទារបស់ជនជាប់ចោទ ដើម្បីចូលរួមសវនាការជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូង ប្រហែលជាត្រូវពិចារណាលើបន្ទុកនៃការបង្ហាញភស្តុតាង និងបទដ្ឋាននៃភស្តុតាងក៏ដូចជាប្រព័ន្ធច្បាប់ខំមិនឡដែរ បន្ទុកនៃការបង្ហាញភស្តុតាងធ្លាក់មកលើអ្នកដែលកំពុងលើកបញ្ហានេះ ដោយផ្អែកទៅលើការថ្លឹងថ្លែងនឹងភាពអាចជឿជាក់បានរបស់ភស្តុតាង។

មេធាវីការពារក្តីយល់ឃើញថា វិធីសាស្ត្រត្រឹមត្រូវមួយ គឺមានចែងនៅក្នុងរឿងក្តីរដ្ឋអាជ្ញាតទល់ជាមួយ *ហ្សូកស៊េប ណាហាក* *(Josep Nahak)*តុលាការលើកឡើងនៅក្នុងរឿងក្តី *ហ្សូកស៊េប ណាហាក* ថាបញ្ហាដែលត្រូវដោះស្រាយ គឺភស្តុតាងដែលត្រូវបង្ហាញនូវលក្ខណៈការពិត ដែលបញ្ជាក់ថា ជនជាប់ចោទនោះមិនមានសម្បទាក្នុងការចូលរួមសវនាការជំនុំជម្រះ។

ចំពោះករណីនេះ តុលាការត្រូវសម្រេចដោយវាយតម្លៃលើភស្តុតាង ដោយគ្មានការយោងទៅលើបន្ទុកនៃការបង្ហាញភស្តុតាង។ ហេតុដូច្នេះ បន្ទុកនៃការបង្ហាញភស្តុតាងទាក់ទងនឹងបញ្ហាសម្បទាក្នុងការចូលរួមសវនាការនោះ មិនមែនជាបន្ទុករបស់មេធាវីការពារក្តីឡើយ។ សេចក្តីសម្រេចនៅក្នុងរឿងក្តី *ហ្សូកស៊េប ណាហាក* កើតនៅមុនការយល់ឃើញរបស់អង្គជំនុំជម្រះ តុលាការក៏បានលើកបញ្ហានេះនៅក្នុងរឿងក្តីរដ្ឋអាជ្ញាតទល់នឹង*ស្ត្រូហ្កា*។ ប៉ុន្តែសមាជិកនៃគណៈកម្មាធិការពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ហាក់ដូចជាបានជឿជាក់ថា ពួកគេអនុវត្តតាមវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿង*ស្ត្រូហ្កា*។

[១៤:០១:៣៤]

ចំណុចនេះអាចបណ្តាលមកពីការដែលថា វិធីសាស្ត្រពីរខុសគ្នាអាចត្រូវបានរកឃើញនៅក្នុងរឿង *ស្ត្រូហ្កា* នៅអង្គជំនុំជម្រះសាលាដំបូង។ ជាបឋមអង្គជំនុំជម្រះសាលាដំបូង បានលើកឡើងនូវបន្ទុកនៃការបង្ហាញភស្តុតាងថាជនជាប់ចោទមិនមានសម្បទានៅក្នុងការចូលរួមសវនាការ អាចជាបន្ទុករបស់មេធាវីការពារក្តី។ ប៉ុន្តែ នៅសាលាឧទ្ធរណ៍ពុំមានចំណុចណាមួយបង្ហាញថាបន្ទុកនៃការបង្ហាញភស្តុតាង

ធ្លាក់មកលើភាគីណាមួយឡើយ។

អង្គជំនុំជម្រះតុលាការកំពូលគាំទ្រវិធីសាស្ត្ររបស់តុលាការជាន់ទាប ជាពិសេសអង្គជំនុំជម្រះតុលាការកំពូលបានធ្វើការកត់សម្គាល់ពីការយល់ស្របរបស់ខ្លួន ជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងថា ជនជាប់ចោទដែលបានអះអាងថា ពុំមានសម្បទាក្នុងការចូលរួមសវនាការត្រូវមានបន្ទុកបង្ហាញតាមរយៈភស្តុតាងឧត្តមានុភាព ហើយដែលចំណុចនេះស្របនឹងយុត្តាធិការរបស់ប្រព័ន្ធខំមិនឡូ។

[១៤:០២:៤៤]

អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា គណៈកម្មាធិការពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅក្នុងរឿង *ហ្សៀកសើប ណាហាក* បដិសេធ និងមិនបានកំណត់ថា អ្នកណាត្រូវមានបន្ទុកបង្ហាញភស្តុតាងឡើយ ហើយក៏បានសម្រេចលើការវាយតម្លៃភស្តុតាងនេះដោយគ្មានសំអាងលើបន្ទុកណាមួយនៃការបង្ហាញភស្តុតាង ដែលអាចធ្លាក់មកលើចុងចោទវិញ។

មេធាវីការពារក្តីយល់ឃើញថា ដោយអនុលោមតាមការអនុវត្តធម្មតានៅក្នុងយុត្តាធិការនៃប្រព័ន្ធស៊ីវិលឡូ នៅពេលដែលបញ្ហាសម្បទាក្នុងការចូលរួមសវនាការត្រូវបានលើកឡើង អង្គជំនុំជម្រះសាលាដំបូងត្រូវវាយតម្លៃភស្តុតាងដែលមាននៅចំពោះមុខ ដើម្បីកំណត់ថា តើភស្តុតាងមានលក្ខណៈពិត ដែលបង្ហាញថាជនជាប់ចោទមិនមានសម្បទាក្នុងការចូលរួមសវនាការ។

ច្បាប់ដែលពាក់ព័ន្ធ អាស្រ័យហេតុនេះ មេធាវីការពារក្តីសូមលើកឡើងនូវចំណុចខាងក្រោមទាក់ទងនឹងយុត្តិសាស្ត្រអន្តរជាតិ លើបញ្ហានេះ ជាបឋមបន្ទុកនៃការបង្ហាញភស្តុតាង និងបទដ្ឋាននានា និងភស្តុតាងត្រូវបានពិភាក្សាដោយសង្ខេបនៅក្នុងសេចក្តីសម្រេចចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤ លើញត្តិរបស់មេធាវីការពារក្តីសូមបញ្ឈប់ដំណើរការនីតិវិធីក្នុងរឿងក្តីរដ្ឋអាជ្ញា តទល់នឹង*ស្ត្រូហ្គា* នៅក្នុងតុលាការ អាយ.ស៊ី.ធី.វ៉ាយ។

[១៤:០៤:១០]

១) បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងលើកឡើងថា បន្ទុកនៃការបង្ហាញភស្តុតាងជនជាប់ចោទមិនមានសម្បទាក្នុងការចូលរួមសវនាការត្រូវធ្លាក់មកលើមេធាវីការពារក្តីក៏ដោយ វាហាក់ដូចជាផ្ទុយទៅនឹងសេចក្តីសម្រេចក្រោយៗរបស់ខ្លួននៅពេលដែលអង្គជំនុំជម្រះសម្រេចថា អង្គជំនុំជម្រះរកឃើញថា ជនជាប់ចោទមានសម្បទាដើម្បីចូលរួមសវនាការ ហើយចំណុចនេះក៏ក្លាយទៅជាជំហរនៅ

ក្នុងការជំនុំជម្រះក្តីរហូតដល់ពេលនេះ។

សូមកត់សម្គាល់ថា ការរកឃើញនេះ មិនបានផ្អែកទៅលើបន្ទុកនៃការបង្ហាញភស្តុតាងឡើយ។ ម្យ៉ាងវិញទៀត វាជាការសំខាន់ក្នុងការកត់សម្គាល់ដែរថា តុលាការ អាយ.ស៊ី.ធី.វ៉ាយ អនុវត្តប្រព័ន្ធនីតិវិធីដែលបើកឱ្យភាគីតទល់គ្នាដែល--

[១៩:០៥:00]

**អ្នកបកប្រែ៖**

ពីអ្នកបកប្រែ លោកប្រធានសូមអនុញ្ញាតណែនាំឱ្យលោកមេធាវីអានឱ្យបានលឿន(?)បន្តិច។

**ប្រធានអង្គជំនុំ៖**

ឈប់ៗ សិនលោក ផាត់ ពៅស៊ាង ញាប់។ អ្នកបកប្រែអត់អាចបកប្រែបានទេ ហើយមើលដៃប្រធានសវនាការផង ធ្វើយូរហើយអត់មើលសោះ។ សូមបន្ថយល្បឿន ដើម្បីឱ្យអ្នកបកប្រែអាចបកប្រែភាសាបានល្អ។

**លោក ផាត់ ពៅស៊ាង៖**

សូមទោស។

...របស់ខ្លួន ដែលអង្គជំនុំជម្រះសម្រេចថា អង្គជំនុំជម្រះរកឃើញថា ជនជាប់ចោទមានសម្បទាដើម្បីចូលរួមសវនាការ។ ហើយចំណុចនេះក៏ក្លាយទៅជាជំហរក្នុងការជំនុំជម្រះក្តីរហូតដល់ពេលនេះ។

[១៩:០៥:៥៥]

សូមកត់សម្គាល់ថា ការរកឃើញនេះមិនបានផ្អែកលើបន្ទុកនៃការបង្ហាញភស្តុតាងឡើយ។ ម្យ៉ាងវិញទៀត វាជាការសំខាន់ក្នុងការកត់សម្គាល់ដែរថា តុលាការ អាយ.ស៊ី.ធី.វ៉ាយ អនុវត្តប្រព័ន្ធនីតិវិធីដែលបើកឱ្យភាគតទល់គ្នា ដែលតម្រូវឱ្យភាគីមានបន្ទុកបង្ហាញភស្តុតាងលើបញ្ហាដែលមានវិវាទ។ ប៉ុន្តែករណីបែបនេះវាមិនមានទេនៅ អ.វ.ត.ក ដែលអនុវត្តប្រព័ន្ធដឹកនាំដោយចៅក្រម។ សូមកត់សម្គាល់បន្ថែមទៀតថា តាមការពិតទៅក្តីកង្វល់ពីសម្បទារបស់អ្នកស្រី អៀង ធីរិទ្ធ ត្រូវបានលើកឡើងដោយមន្ទីរឃុំឃាំង។

[១៩:០៦:៤២]

៧) នៅក្នុងសាលក្រមថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨ ក្នុងរឿងរដ្ឋអាជ្ញាទល់នឹង*ស្ត្រូហ្គា* អង្គជំនុំជម្រះតុលាការកំពូលក៏បានលើកសំអាងនូវបន្ទុកនៃការបង្ហាញភស្តុតាងផងដែរ។ មួយ បើទោះបីជា

តុលាការបានកត់សម្គាល់ពីការយល់ស្របរបស់ខ្លួន ជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាប់ចោទដែលអះអាងថាមិនមានសម្បទា ត្រូវមានបន្ទុកបង្ហាញភស្តុតាងពីការមិនមានសម្បទានេះ ក៏អង្គជំនុំជម្រះហាក់ដូចជាធ្វើចំណាត់ការនីតិវិធីដោយផ្អែកលើមូលដ្ឋានថា បន្ទុកនៃការបង្ហាញភស្តុតាងមិនធ្លាក់មកលើមេធាវីការពារក្តី ដោយបានគូសបញ្ជាក់ថា ដោយផ្អែកលើភស្តុតាងនៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តយ៉ាងត្រឹមត្រូវនូវក្នុងឆន្ទានុសិទ្ធិរបស់ខ្លួន នៅពេលដែលអង្គជំនុំជម្រះបានរកឃើញថាសមត្ថភាពរបស់ *ស្រួហ្កា* ដើម្បីចូលរួមសវនាការត្រូវបានបំពេញ។ ពីរ បន្ថែមពីលើនេះ បន្ទុកនៃការបង្ហាញភស្តុតាងមិនបានបង្កើតជាផ្នែកនៃបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទទេ។ ហេតុដូច្នេះ វាមិនមែនជាកម្មវត្ថុនៃការជំទាស់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលនោះឡើយ។ វាបានកាត់បន្ថយមកត្រឹមមួយកថាខណ្ឌនៅក្នុងសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល។

[១៤:០៨:៣០]

៨) ការវិភាគដ៏ស៊ីជម្រៅបំផុត អំពីបញ្ហាទាក់ទងនឹងបន្ទុកនៃការបង្ហាញភស្តុតាងត្រូវធ្វើឡើងដោយគណៈកម្មាធិការពិសេស សម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅក្នុងរឿងក្តីរដ្ឋអាជ្ញាទល់នឹង*ណាហាក* នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៥ ស្តីពីការរកឃើញ និងដីកាសម្រេចលើសមត្ថភាពរបស់ចុងចោទដើម្បីចូលរួមសវនាការ។ ខណៈដែលរឿងនេះបានកើតនៅមុនសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី*ស្រួហ្កា* តុលាការបានពិនិត្យដោយលម្អិតលើវិធីសាស្ត្រ ដែលអង្គជំនុំជម្រះប្រកាន់យក និងធ្វើការកត់សម្គាល់ដូចខាងក្រោម៖

[១៤:០៩:១៨]

១) ជាបឋម ដោយបញ្ហានេះជាច្បាប់ទូទៅនិងច្បាប់ទម្លាប់ បន្ទុកនៃការបង្ហាញភស្តុតាងនូវតែជាបន្ទុករបស់ព្រះរាជអាជ្ញា។ គោលការណ៍នេះកើតចេញពីការសន្មតទុកជាមុនថាគ្មានទោស នៅក្នុងលក្ខន្តិកៈនៃតុលាការ អាយ.ស៊ី.ធី.វ៉ាយ, អាយ.ស៊ី.ធី.អ័រ និងលក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការ អាយ.ស៊ី.ស៊ី។

២) ទោះបីជាអង្គជំនុំជម្រះក្នុងរឿងក្តី*ស្រួហ្កា* បានលើកឡើងថា បន្ទុកនៃការកបង្ហាញភស្តុតាងថាជនជាប់ចោទគ្មានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ ត្រូវធ្លាក់មកលើមេធាវីការពារក្តីក៏ដោយក៏តុលាការនេះមិនបានអះអាងពីការយល់ឃើញរបស់ខ្លួនថា ជាការផ្ទុះបញ្ចាំងពីច្បាប់ទូទៅ ឬច្បាប់ព្រហ្មទណ្ឌអន្តរជាតិឡើយ។ ហើយក៏មិនបានលើកឡើងពីទ្រឹស្តី ឬយុត្តិសាស្ត្រអន្តរជាតិណាមួយដោយផ្ទាល់លើបញ្ហាសម្បទានេះដែរ។

[១៤:១០:២៧]

ទី៣) នៅចុងបញ្ចប់នៃសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះក្នុងរឿងក្តី *ស្ត្រូហ្កា* បានដកខ្លួនចេញពីការចង្អុលភស្តុតាងរបស់ខ្លួន ដែលថាជនជាប់ចោទមានបន្ទុកបង្ហាញភស្តុតាងថា ខ្លួនមិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ។

ឈានទៅដល់ការសន្និដ្ឋាននេះ តុលាការក្នុងរឿងក្តី *ណាបាក* បានលើកឡើងថា បើនិយាយដោយប្រយោល វាហាក់ដូចជាអង្គជំនុំជម្រះសាលាដំបូងបានពិចារណាទៅលើរាល់ភស្តុតាងទាំងអស់ដែលដាក់នៅចំពោះមុខ និងបានសម្រេចថាភស្តុតាងនេះមានលក្ខណៈពិត ដែលបញ្ជាក់ថាជនជាប់ចោទមិនមានសមត្ថភាពដើម្បីចូលរួមសវនាការ។ ស្របគ្នានឹងការបែងចែកបន្ទុកនៃការបង្ហាញភស្តុតាងដោយជនជាប់ចោទ គេរំពឹងថាតុលាការនេះនឹងសម្រេចដោយជនជាប់ចោទខកខាន មិនបានបង្ហាញពីការគ្មានសម្បទារបស់ខ្លួន។ ដូច្នេះសវនាការនឹងបន្តទៅមុខ។

[១៤:១១:៣៩]

ម្យ៉ាងវិញទៀត ក្នុងឧទាហរណ៍ចុងក្រោយតុលាការបានយល់ឃើញថា ចុងចោទមានសម្បទាដើម្បីចូលរួមសវនាការ ដោយមិនបានផ្អែកលើបន្ទុកនៃការបង្ហាញភស្តុតាង ជាពិសេសក្នុងតុលាការក្នុងរឿងក្តី*ស្ត្រូហ្កា* បានសន្និដ្ឋានថា ព្រះរាជអាជ្ញាបានបំពេញបន្ទុកនៃការបង្ហាញភស្តុតាង ដែលតាមពិតតុលាការមិនបានតម្រូវឲ្យធ្វើបែបនេះទេ។

ជាបន្តទៅទៀត ខ្ញុំសូមស្នើសុំឲ្យមេធាវីអន្តរជាតិដើម្បីបន្ត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណមេធាវី។ សូមអញ្ជើញលោកស្រីមេធាវី!

[១៤:១២:១៨]

**លោកស្រី ដាយអាណា អេលីស៖**

សូមគោរពលោកប្រធាន និងលោក លោកស្រីចៅក្រម។

ខ្ញុំនឹងផ្តល់តែឈ្មោះនៃរឿងក្តីទេ ខ្ញុំមិនលើកសេចក្តីស្រង់នោះទេ។ ខ្ញុំនឹងផ្តល់នៅពេលក្រោយ។ យើងខ្ញុំសន្និដ្ឋានថា លោកស្រី អៀង ធីរិទ្ធ មិនមានសម្បទាក្នុងការចូលរួមការជំនុំជម្រះ និងកិច្ចដំណើរការនីតិវិធីនេះមិនគួរបន្តនោះឡើយ។ ភស្តុតាងរបស់អ្នកជំនាញ ដែលបានផ្តល់ជូនអង្គជំនុំជម្រះគឺវាមានបង្ហាញច្បាស់លាស់។ លោកសាស្ត្រាចារ្យ ខាំប៉ែល គឺជាពេទ្យខាងមនុស្សចាស់ ហើយក៏គាត់មាន

ជំនាញយ៉ាងល្បីល្បាញ។ លោកបានសន្និដ្ឋានថា លោកស្រី អៀង ធីរិទ្ធ គាត់មានការចុះខ្សោយសតិបញ្ញាជារួម ជាពិសេសវាបានបង្ហាញអំពីភស្តុតាង ដែលថាគាត់គ្មានការចងចាំ...។ល។ ហើយគាត់មិនមានហេតុផល និងសមត្ថភាពក្នុងការវិនិច្ឆ័យរៀបចំផែនការ ការគិតគូរ និងការធ្វើទំនាក់ទំនងជាលក្ខណៈបុគ្គល...។ល។

ការរកឃើញនេះ គឺបានបង្ហាញថា ដំណើរការនៃការចុះខ្សោយ និងខួក្បាលរបស់គាត់សតិបញ្ញាមានការកើតឡើង ហើយវាងអាចជាជំងឺ*អាល់ហ្សៃមើ* ហើយវាគ្មានមធ្យោបាយណាមួយដែលយើងអាចធ្វើឱ្យវាប្រសើរឡើងក្នុងកម្រិតណាមួយជាក់លាក់នោះឡើយ។

[១៤:១៣:៤៦]

នៅក្នុងមតិយោបល់របស់លោកសាស្ត្រាចារ្យ ខាំប៊ែល ការចុះខ្សោយសតិបញ្ញា វារារាំងសមត្ថ-ភាពរបស់លោកស្រីក្នុងការយល់សំណួរ ការតាមដានទៅលើការណែនាំ និងការផ្តល់ទៅលើហេតុការណ៍ផ្លូវអារម្មណ៍ និងការផ្តល់ការគិតគូរស្របគ្នាមួយ។ លោកស្រីគាត់មិនចំណាំ មិនចងចាំពេលវេលា និងទីកន្លែង ហើយនិងក៏មិនចាំបុគ្គលផងដែរ។ ដូច្នេះ ការចុះខ្សោយនេះ យើងសូមលើកឡើងថា វាបានបង្ហាញយ៉ាងច្បាស់លាស់ថា វានឹងប៉ះពាល់យ៉ាងខ្លាំងទៅដល់សមត្ថភាពរបស់គាត់ក្នុងការចូលរួមដោយមានអត្ថន័យនៅក្នុងការជំនុំជម្រះក្តី រួមទាំងសមត្ថភាពក្នុងការអនុវត្តសិទ្ធិក្នុងការជំនុំជម្រះក្តីដោយយុត្តិធម៌ផងដែរ ដូចដែលគេបានលើកឡើងក្នុងរឿងក្តី*ស្ត្រូហ្កា*។

អង្គជំនុំជម្រះសាលាដំបូងបានធ្វើការស្នើសុំមតិយោបល់របស់អ្នកជំនាញចំនួនបួនបន្ថែមទៀតដែលគាត់ត្រូវធ្វើកោសល្យវិច័យ យើងឃើញថា របាយការណ៍មិនមានការខុសប្លែកណាមួយនៅក្នុងសេចក្តីសន្និដ្ឋានរបស់គាត់នោះទេ ហើយពាក្យពេចន៍ដែលគាត់ប្រើប្រាស់ ក៏មានលក្ខណៈស៊ីសង្វាក់គ្នាគឺមិនមានខុសពីរបាយការណ៍មុននោះទេ។

[១៤:១៥:០៥]

ដូច្នេះ គាត់បានន័យថា គាត់ឯកភាពថា វាមានការចុះខ្សោយសតិបញ្ញាដែលមានលក្ខណៈធ្ងន់ធ្ងរមធ្យម។ ការវិនិច្ឆ័យរោគ គឺបានបញ្ជាក់ដោយលោកសាស្ត្រាចារ្យ កា ស៊ុនបូណាត ដែលនៅក្នុងខែវិច្ឆិកាឆ្នាំ២០០៩ គាត់យល់ឃើញថាការចុះខ្សោយខាងសតិបញ្ញានោះគឺស្រាល។ នៅក្នុងឆ្នាំនេះ លោកសាស្ត្រាចារ្យ ខាំប៊ែល មតិរបស់លោកសាស្ត្រាចារ្យ ខាំប៊ែល រួមទាំងវេជ្ជបណ្ឌិត ចក់ ធីតា ដែលយើងស្តាប់ក្នុងឆ្នាំនេះ គឺបង្ហាញថា លោកស្រី អៀង ធីរិទ្ធ គឺគាត់បានពិនិត្យ លោកវេជ្ជបណ្ឌិតទាំងអស់លោកបាន

ពិនិត្យឡើងវិញទៅលើរបាយការណ៍របស់លោកសាស្ត្រាចារ្យ ខាំប៊ែល ដែលគាត់មានមតិយោបល់ដូចគ្នាទៅនឹងលោកសាស្ត្រាចារ្យ ខាំប៊ែល។ នៅក្នុងការវិភាគវិនិច្ឆ័យគឺគេរកឃើញដោយផ្អែកទៅលើកត្តាមួយចំនួន ហើយគេបានធ្វើកោសល្យវិច័យទៅលើប្រវត្តិរបស់លោកស្រី អៀង ធីរិទ្ធ ធ្វើតេស្តផ្លូវការ ការសង្កេត និងការតាមដានផ្សេងៗរួមទាំងការថតស៊ីធីស្កេនផងដែរ។

[១៤:១៦:២៧]

ដូច្នេះ ផ្អែកទៅលើឯកសារទាំងអស់នេះ យើងឃើញថាស៊ីធីស្កេន ដែលត្រូវបានពិនិត្យមើលឡើងវិញដោយអ្នកវិទ្យុសាស្ត្រ បានបង្ហាញថា វាមានការចុះខ្សោយនៅក្នុង-- វាមានការកើតឡើងនៃការរួមតូចនៃខួរក្បាលធម្មតា។ ដូច្នេះហើយការសង្កេត និងការពិនិត្យកោសល្យវិច័យទាំងអស់បានបង្ហាញឲ្យឃើញថា ដូចដែលលោកវេជ្ជបណ្ឌិតបានរកឃើញនៅក្នុងមន្ទីរឃុំឃាំង ហើយលោកប្រធានមន្ទីរឃុំឃាំង ហើយនិងលោកសាស្ត្រាចារ្យ កា ស៊ុនបូណាត ក៏គាត់បានបង្ហាញអំពីករណីទាំងអស់នេះ។ លោកសាស្ត្រាចារ្យ កា ស៊ុនបូណាត បានបង្ហាញថាលោកស្រីគាត់មានការចុះខ្សោយនៅក្នុងសមត្ថភាពសតិបញ្ញារបស់គាត់ ជាពិសេសនៅក្នុងសមត្ថភាពនៃការគ្រប់គ្រងអាកប្បកិរិយាសង្គមរបស់គាត់។

[១៤:១៧:២៧]

ដូច្នេះ យើងខ្ញុំសន្និដ្ឋានថាឯកសាររបាយការណ៍ទាំងអស់ឡាយដែលបានដាក់ជូនដោយអ្នកជំនាញដល់អង្គជំនុំជម្រះដែលក្នុងនោះបានធ្វើការសន្និដ្ឋានអំពីសម្បទាក្នុងការចូលរួមជំនុំជម្រះ។ របាយការណ៍ទាំងអស់នោះអាចឲ្យយើងជឿជាក់បាន ដែលបង្ហាញថាលោកស្រី អៀង ធីរិទ្ធ មិនអាចអនុវត្តសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌ឲ្យបានពេញលេញនោះឡើយ ជាពិសេសការរកឃើញដែលគេសិក្សាទៅលើបុគ្គលមានជំងឺវង្វេងវង្វាន់ គេបានលើកទៅលើបញ្ហាហ្នឹងផងដែរ។

[១៤:១៨:០៧]

ករណីទាំងអស់នេះបានបង្ហាញឲ្យយើងឃើញថា វាមានការចុះខ្សោយខាងការចំណាំ និងការចងចាំ ហើយករណីទាំងអស់នេះ វាបង្ហាញនូវការមិនមានសមត្ថភាពនៅក្នុងការចូលរួមដំណើរការក្តី។ ការដែលសំខាន់ និងពិសេសជាក់លាក់នៅក្នុងករណីនេះ គឺយើងខ្ញុំសូមលើកឡើងថា យើងគ្មានអ្វីសង្ស័យនោះទេថា លោកស្រី អៀង ធីរិទ្ធ គាត់មិនមានសមត្ថភាពក្នុងការរំឭកឡើងវិញនូវហេតុការណ៍កើតឡើងនៅក្នុងជីវិតរបស់គាត់ ការចូលរួមការជំនុំជម្រះក្តីនៅចំពោះមុខអង្គជំនុំជម្រះនេះបានទេ។ នៅចំពោះមុខអង្គជំនុំជម្រះនេះ យើងធ្វើយ៉ាងណាឲ្យលោកស្រី អៀង ធីរិទ្ធ អាចរំឭកឡើងវិញអំពីហេតុការណ៍

នៅក្នុងជីវិតរបស់គាត់ ជាពិសេសហេតុការណ៍ឆ្នាំ៧៥ ដល់ ឆ្នាំ៧៩ ហើយក៏អាចធ្វើយ៉ាងណាឲ្យគាត់មានសមត្ថភាពពិចារណាដីកាដំណោះស្រាយ ដែលបានលើកឡើងហេតុការណ៍មុនឆ្នាំ៧៥ និង ៧៩ ជាពិសេស ព័ត៌មានទាក់ទងទៅនឹងការវិវត្តន៍ និងការកើតឡើងនៃបក្សកុម្មុយនីស្តកម្ពុជា។ លោកស្រីគាត់មិនបានចងចាំ ហើយមិនអាចផ្តល់ការរំឭកឡើងវិញអំពីហេតុការណ៍ទាំងអស់នេះ។

[១៤:១៩:២៩]

ខ្ញុំសូមបញ្ជាក់ចំណុចលម្អិតថា លោកស្រី អៀង ធីរិទ្ធ គាត់មិនមានសមត្ថភាពក្នុងការរំឭកឈ្មោះ ចងចាំឈ្មោះបុគ្គលដែលគាត់ ដែលនៅកៀកនឹងគាត់។ លោកស្រីមិនចងចាំអំពីតួនាទីរបស់បុគ្គល និងតួនាទីរបស់គាត់នៅក្នុងជីវិតរបស់គាត់ គាត់មិនចាំឈ្មោះអ្នកដែលមកទស្សនកិច្ចគាត់។ ហើយគាត់ក៏មិនមានសមត្ថភាពរំឭកអំពីសមាជិកគ្រួសាររបស់គាត់ ដែលបានទទួលមរណភាពជាយូរមកហើយ។

លោកស្រី អៀង ធីរិទ្ធ មិនមានសមត្ថភាពចងចាំរយៈពេលយូរ និងរយៈពេលខ្លីទៅលើករណីនានា ដូចដែលបានផ្តល់ជូនតាមរយៈព័ត៌មានដល់អង្គជំនុំជម្រះសាលាដំបូងនេះ។ ដូច្នេះហើយ យើងខ្ញុំសូមសន្និដ្ឋានថា វាជាការមិនត្រឹមត្រូវ ក្នុងការកោះហៅគាត់មកចូលរួមការជំនុំជម្រះក្តីនៅទីនេះ។

[១៤:២០:២៦]

នៅពេលនេះ ខ្ញុំសូមចូលទៅដល់ការឆ្លើយតបទៅនឹងសំណួរនីមួយៗដែលអង្គជំនុំជម្រះបានសួរ។ ថាតើជនជាប់ចោទមានសមត្ថភាពខាងសតិបញ្ញាក្នុងការចូលរួមការជំនុំជម្រះក្តីដែរឬទេ? ហើយថាតើវាបំពេញទៅតាមលក្ខខណ្ឌនៅក្នុងរឿងក្តី *ស្ត្រូហ្គា* ដែរឬទេ? យើងត្រូវតែធ្វើការវិភាគលក្ខខណ្ឌទាំងអស់នេះ មុនពេលដែលយើងចូលទៅដល់ការវិនិច្ឆ័យ។

យើងខ្ញុំលើកឡើងថា លក្ខខណ្ឌមួយដែលបានចែងនៅក្នុងរឿងក្តី *ស្ត្រូហ្គា* វាអត់មានទេ។ ដូច្នេះយើងរកឃើញថា ជនជាប់ចោទរូបនេះមិនមានសម្បទាក្នុងការចូលរួមការជំនុំជម្រះក្តីនោះទេ។

[១៤:២១:១៥]

តថភាពជាក់ស្តែងពាក់ព័ន្ធទៅនឹងបុគ្គលរូបនេះ គឺយើងឃើញមានការចែងលក្ខខណ្ឌចំនួនបួន។ ចំណុចដែលកើតឡើងទីមួយនោះ គឺអង្គជំនុំជម្រះសាលាដំបូងត្រូវការបំបែកករណីនីមួយៗទៅជាផ្នែកតូចៗ។ ការត្រូវបំបែកបទចោទនីមួយៗ ការឆ្លើយទៅនឹងបទចោទរបស់ជនចោទ ការតាមដានរឿងក្តីរបស់ជនជាប់ចោទ។ ជនជាប់ចោទផ្តល់នូវព័ត៌មានលម្អិតនៅអ្វីដែលបានកើតឡើង និងមិនបានកើតឡើង និងការណែនាំមេធាវីរបស់គាត់ក្នុងឥរិយាបថមួយសមស្រប។

យើងបានយល់អំពីផលវិបាកនៃកិច្ចដំណើរការនីតិវិធីនេះ។ ប្រសិនបើជនជាប់ចោទមិនអាចយល់អំពីលក្ខណៈនៃបទចោទ ដូច្នេះយើងសូមសន្និដ្ឋានថា ជនជាប់ចោទមិនមានសម្បទាក្នុងការឆ្លើយថាខ្លួនសារភាពទោស ឬមិនសារភាពទោសនោះទេ។ ដូច្នេះហើយទាក់ទងទៅនឹងបញ្ហាទាំងអស់នេះ យើងខ្ញុំសូមលើកឡើងថា វាបង្ហាញយ៉ាងច្បាស់លាស់ទៅលើករណីទាំងអស់នេះ។

[១៤:២២:២៧]

ដើម្បីធ្វើការវាយតម្លៃទៅលើសិទ្ធិនីមួយៗទាំងអស់នេះ យើងត្រូវតែចោទសួរក្នុងលក្ខណៈផ្សេងពីនេះ។ ថាតើការជំនុំជម្រះមានភាពយុត្តិធម៌ដែរឬទេ ប្រសិនបើជនជាប់ចោទគាត់មិនអាចឆ្លើយទៅនឹងបទចោទផងនោះ? ថាតើបទចោទវាយុត្តិធម៌ដែរឬទេ ប្រសិនបើជនជាប់ចោទគាត់មិនយល់អំពីលក្ខណៈនៃបទចោទផងនោះ? ប្រសិនបើជនជាប់ចោទមិនអាចចូលរួមនីតិវិធី មិនអាចណែនាំទៅដល់មេធាវី និងមិនអាចយល់អំពីកិច្ចដំណើរការនីតិវិធី។ ដូច្នេះយើងសន្និដ្ឋានថា ការជំនុំជម្រះមិនមានភាពយុត្តិធម៌នោះទេ។ ជនជាប់ចោទដែលបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ គឺមានកម្រិតនៃការយល់ដឹងរបស់គាត់។ ហើយកម្រិតនៃការយល់ដឹងរបស់គាត់ហ្នឹង គួរតែធ្វើយ៉ាងណាឲ្យមានសមត្ថភាពគ្រប់គ្រាន់ដើម្បីយល់អំពីការចោទប្រកាន់ចំពោះគាត់។

[១៤:២៣:២៤]

បញ្ហាដែលបានពិចារណានៅក្នុងរឿង *ណាហាក* ដែលវាជារឿងក្តីនៅប្រទេសអ៊ីស្តទីម័រ ទីម័រខាងកើត ដែលក្នុងនោះលើកឡើងថា ជនជាប់ចោទត្រូវតែមានសម្បទាគ្រប់គ្រាន់ក្នុងការយល់អំពីធាតុផ្សំនីមួយៗ ដើម្បីអាចឲ្យជនជាប់ចោទគាត់មានសម្បទាក្នុងការចូលរួមក្នុងការជំនុំជម្រះក្តី។ ដូច្នេះហើយយើងសូមបញ្ជាក់ថា វាជាលក្ខខណ្ឌសំខាន់នៅក្នុងរឿងក្តីនោះ គឺគេលើកឡើងថា ការយល់ដឹងនោះមិនមែនយល់ដឹងតែលើអង្គហេតុនោះទេ។ ការយល់ដឹងនោះ ត្រូវតែមានភាពសមហេតុផលចំពោះបញ្ហាដែលតុលាការលើកឡើងផងដែរ។

[១៤:២៤:០៤]

យើងឃើញថា វាជាបទដ្ឋានណែនាំដែលយើងត្រូវពិនិត្យមើលទៅលើរឿងក្តីនានាផ្សេងទៀតដែលគេលើកឡើងអំពីបញ្ហាសម្បទាទាំងអស់នេះ។ ជាពិសេសយើងត្រូវយកចិត្តទុកដាក់ទៅលើពាក្យដែលគេប្រើប្រាស់នៅក្នុងរឿងក្តីទាំងអស់នេះ។ ដោយសារតែយើងមើលឃើញថាអ្វីដែលគេយោងទៅលើបញ្ហាទាំងអស់នេះ គឺពាក់ព័ន្ធទៅនឹងសិទ្ធិនិងសម្បទា ដែលគេប្រើជាទម្រង់ពហុវចនៈ។ គេគួស

បញ្ជាក់ថាសិទ្ធិទាំងឡាយត្រូវតែធានាឲ្យមានលក្ខណៈអប្បបរមា ដើម្បីឲ្យការជំនុំជម្រះមានភាពយុត្តិធម៌ ហើយសិទ្ធិទាំងអស់នោះត្រូវតែធានានូវសមត្ថភាពរាងកាយ និងសតិបញ្ញាដល់ជនជាប់ចោទ ដើម្បីឲ្យជនជាប់ចោទមានលទ្ធភាពក្នុងការចូលរួមការជំនុំជម្រះក្តី។

[១៤:២៤:៥២]

រឿងក្តី *ស្រ្តូហ្កា* គឺគេបានដាក់នៅចំពោះមុខតុលាការកំពូល និងសាលាដំបូងផងដែរ។ សាលាដំបូងគឺបានយោងទៅលើលក្ខខណ្ឌធានាអប្បរមាក្នុងការគោរពទៅលើសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌។ នៅក្នុងរឿងនោះ គឺគេបានអនុវត្តតាមមាត្រាច្បាប់នៅក្នុងលក្ខន្តិកៈតុលាការ អាយ.ស៊ី.ធី.វ៉ាយ ដែលវាជាអានុភាពទាញចេញពីមាត្រា១៥ និង ១៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

សេចក្តីសម្រេចរបស់តុលាការជាន់ទាបនៅក្នុងរឿងក្តី*ស្រ្តូហ្កា* រួមទាំងតុលាការកំពូល គឺគេបានថែងយោង និងលើកសំអាងអំពីសិទ្ធិទាំងឡាយ គឺពហុវចនៈ។ ដូច្នេះ ហើយយើងគួរតែកត់សម្គាល់ថា នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងយោងទៅលើលក្ខខណ្ឌអប្បបរមានៃសមត្ថភាពជារួម គឺយើងគួរតែយល់ថា ការយោងដូច្នោះគឺគេយោងជាការយល់ឃើញ ជាលក្ខណៈសាកល ហើយចំណុចហ្នឹងគឺមានការរិះគន់ដោយតុលាការកំពូលដែលថាជនជាប់ចោទត្រូវមានសមត្ថភាពពេញលេញ និងអាចអត្ថន័យគ្រប់គ្រាន់ ដើម្បីឲ្យគាត់អនុវត្តសិទ្ធិទទួលការជំនុំជម្រះក្តីដោយយុត្តិធម៌បាន។

[១៤:២៦:១៥]

នៅក្នុងរឿងក្តី *ណាហាក* បានលើកឡើងថា ដើម្បីឲ្យចុងចោទ ជនជាប់ចោទមានលទ្ធភាពក្នុងការយល់ និងអនុវត្តសិទ្ធិរបស់គាត់ក្នុងពេលជំនុំជម្រះ ជាពិសេសសិទ្ធិនៅក្នុងច្បាប់។ សិទ្ធិទាំងអស់នោះគឺមិនអាចធ្វើយ៉ាងណាឲ្យវាបាត់បង់នូវអត្ថន័យរបស់វានោះទេ។ អង្គជំនុំជម្រះសាលាដំបូងនៅរឿងក្តី *ស្រ្តូហ្កា* បានលើកឡើងថា ការទទួលបានសិទ្ធិនោះ គឺការសន្មតទៅលើសិទ្ធិ សមត្ថភាពសម្បទា និងរាងកាយ និងសតិបញ្ញា ដែលត្រូវយ៉ាងណាឲ្យជនជាប់ចោទមានសម្បទាទាំងពីរនេះ អនុញ្ញាតឲ្យគាត់អនុវត្តសិទ្ធិរបស់គាត់បាន។

ដូច្នេះជាថ្មីម្តងទៀត ខ្ញុំលើកឡើងសាជាថ្មី។ យើងសង្ឃឹមថាបទដ្ឋាន និងរឿងក្តីទាំងអស់នេះជាបទដ្ឋានណែនាំ និងអាចយកមកធ្វើជាចំណុចយោងផងដែរ នៅក្នុងរឿងក្តី ពីណូចេ ដែលវាពាក់ព័ន្ធទៅនឹងអង្គការលើកលែងទោសអន្តរជាតិ។ នៅក្នុងនុំងគេបានលើកឡើងអំពីលក្ខណៈវិនិច្ឆ័យច្បាស់លាស់ពាក់ព័ន្ធទៅនឹងការចងចាំ និងលទ្ធភាពរបស់ជនជាប់ចោទក្នុងការវិនិច្ឆ័យទៅលើកិច្ចដំណើរនីតិវិធី។

នៅក្នុងរឿងក្តីនោះគេបានលើកឡើងអំពីសម្បទាដែរ ក៏មានចែងនៅក្នុងរឿងក្តីស្រ្ទហ្កា ផងដែរ នៅក្នុងនោះគឺមានសមត្ថភាពចំនួនបួនដែលយើងត្រូវតែរកឲ្យឃើញនៅក្នុងជនជាប់ចោទ។

[១៤:២៧:៤៨]

ដូច្នេះករណីទាំងអស់នេះសិទ្ធិរបស់ជនជាប់ចោទ គឺជាសិទ្ធិអប្បបរមាដែលជនជាប់ចោទទទួលបាននៅក្នុងរឿងក្តីនេះ។ ដូច្នេះ ចំពោះសំណួរទីមួយដែលបានចោទសួរឡើង យើងសូមលើកឡើងថាវាមិនត្រឹមត្រូវនោះទេ ប្រសិនបើសិទ្ធិមួយចំនួនរបស់ជនជាប់ចោទមិនអាចប្រើប្រាស់ដោយជនជាប់ចោទ។ សិទ្ធិទាំងអស់នោះ វាមានការជាប់ពាក់ព័ន្ធគ្នា ប្រសិនបើគ្មានសិទ្ធិណាមួយការជំនុំជម្រះនឹងមិនមានភាពយុត្តិធម៌នោះឡើយ។ ប្រសិនបើនៅពេលនេះ ខ្ញុំសូមអនុញ្ញាតចូលដល់សំណួរទីពីរ។ ថាតើការចុះខ្សោយសតិបញ្ញារបស់ជនជាប់ចោទ ដែលសាស្ត្រាចារ្យបានរកឃើញនោះ អនុញ្ញាតឲ្យគាត់មានសិទ្ធិក្នុងការទទួលការជំនុំជម្រះដោយយុត្តិធម៌ស្របតាមតម្រូវការចាំបាច់នៅក្នុងសំណុំរឿងស្រ្ទហ្កា ដែរឬទេ?

[១៤:២៨:៤២]

យើងខ្ញុំសូមលើកឡើងថា ការចងចាំរបស់ជនជាប់ចោទ គឺវាទទួលរងនូវការប៉ះពាល់ដូចដែលហេតុផលបានលើកឡើងរួចមកហើយ មានការចុះខ្សោយទៅលើជនជាប់ចោទ ជាពិសេសការចងចាំរយៈពេលខ្លី ហើយការចងចាំរយៈពេលវែងនោះក៏មានបញ្ហានៅក្នុងជនជាប់ចោទ។ ដូច្នេះហើយផ្អែកទៅលើកាលៈទេសៈទាំងអស់នេះ លោកស្រី អៀង ធីរិទ្ធ គាត់មិនអាចមានសមត្ថភាពដោយពេញលេញនិងមានអត្ថន័យក្នុងការចូលរួមនូវក្នុងការជំនុំជម្រះក្តី ដូចដែលគេបានកំណត់នៅក្នុងលក្ខណៈវិនិច្ឆ័យនៅក្នុងសំណុំរឿងក្តីស្រ្ទហ្កា។

នៅក្នុងរឿងក្តីនោះគេលើកឡើងថា សមត្ថភាពរបស់ជនជាប់ចោទគឺនឹងប៉ះពាល់ទៅដល់មេធាវីការពារក្តី ជាពិសេសដោយសារតែជនជាប់ចោទមិនមានលទ្ធភាពក្នុងការណែនាំមេធាវីការពារក្តីដោយសារបញ្ហាសមត្ថភាព។ ហេតុដូច្នេះ ជនជាប់ចោទគឺត្រូវតែមានសមត្ថភាពក្នុងការរៀបរាប់នូវរឿងរ៉ាវដែលគាត់បានប្រព្រឹត្តអ្វីដែលគាត់បានដឹង ហើយថាតើការងារ និងសម្តីមួយចំនួននោះគាត់ពិតជាបាននិយាយដែរឬទេ?

[១៤:២៩:៥៥]

នៅក្នុងរឿងក្តីស្រ្ទហ្កា បានយោងលើរឿងក្តីមួយនៅចំពោះមុខតុលាការសិទ្ធិមនុស្សអឺរ៉ុប នៅក្នុងចក្រភពអង់គ្លេស ដែលក្នុងនោះគេបានលើកឡើងអំពីការចូលរួមដោយប្រសិទ្ធិភាពរបស់ជនជាប់ចោទ។

គេសន្មតថា ជនជាប់ចោទធ្វើយ៉ាងណាអាចពន្យល់មេធាវីការពារក្ដីរបស់ខ្លួន ហើយយល់ចំពោះសំណួរដែលបានដាក់នៅចំពោះមុខសក្ខីកម្មដែលបានលើកឡើង ធ្វើយ៉ាងណាឲ្យជនជាប់ចោទអាចឯកភាព និងមិនឯកភាពទៅលើសក្ខីកម្មទាំងអស់នោះ ហើយអាចជួយទៅដល់មេធាវីការពារក្ដីផងដែរ។ ដូច្នេះហើយបញ្ហាទាំងអស់នេះវាបានលើកឡើងយ៉ាងច្បាស់នៅក្នុងរឿងក្ដីហ្នឹង និងរឿងក្ដីណាហាក ផងដែរ។

[១៤:៣០:៤០]

ដូចដែលខ្ញុំបានលើកឡើងវាមានលក្ខណៈវិនិច្ឆ័យយ៉ាងជាក់លាក់ ដែលគេកំណត់អំពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមការជំនុំជម្រះក្ដី ជាពិសេសគេលើកឡើងអំពីការចងចាំ។ ដូច្នេះ ខ្ញុំសូមលើកឡើងថា ជនជាប់ចោទគាត់មិនបានចងចាំនូវហេតុការណ៍ដែលបានកើតឡើង ហើយគាត់មិនអាចចង្អុលបញ្ជាក់អំពីហេតុការណ៍ទាំងអស់នោះ។ ដូច្នេះ វាជាការចុះខ្សោយសតិបញ្ញារបស់គាត់មិនអាចធ្វើការឆ្លើយទៅនឹងបទចោទ ហើយវាប៉ះពាល់ទៅដល់សម្បទារបស់គាត់ដូចដែលច្បាប់តម្រូវ។ យើងយល់យ៉ាងច្បាស់ដោយគ្មានការសង្ស័យពីអ្នកជំនាញថា ការចងចាំរបស់ជនជាប់ចោទ គឺពិតជាមានការចុះខ្សោយមែន។ ការបាត់បង់នេះ គឺពិតជាប៉ះពាល់ដល់សមត្ថភាពរបស់គាត់ក្នុងការចូលរួមក្នុងសវនា-ការដោយយុត្តិធម៌ ហើយគាត់មិនចងចាំ ហើយទោះបីជាសួរដដែលៗ ហើយគាត់នៅតែមិនចាំ នៅពេលដែលគាត់និយាយទៅកាន់សាស្ត្រាចារ្យ ខាំប៉ែល គាត់មិនចាំថា គាត់បានធ្វើអ្វីនៅពេលពាក់ព័ន្ធនោះទេ ហើយខ្ញុំច្បាស់ថា លោក លោកស្រីចៅក្រមដឹងថា ទោះបីជាទទួចយ៉ាងណាគាត់មើលទៅក្រដាស ប៉ុន្តែក្រដាសមិនពាក់ព័ន្ធទៅនឹងអ្វីដែលបានសួរ។ នេះហើយដែលអ្នកជំនាញថា គាត់ព្យាយាមរកអ្វីបំពេញបន្ថែមចន្លោះការចងចាំរបស់គាត់។ ដូច្នេះ គាត់មិនមានការចងចាំឈ្មោះសមាជិកគ្រួសារ ទីកន្លែងដែលគាត់តាំងនៅ ហើយគាត់បានវង្វេង ហើយទាក់ទងនឹងចំណុចនេះ ដោយសារយើងពេលកម្រិត។ ខ្ញុំសូមអនុញ្ញាតពីរបីមីនុតទៀត។

[១៤:៣២:២៣]

បញ្ហាទីបី អំពីសំណួរចុងក្រោយដែលអាចថានឹងខ្លីទេ។ ជាសំណួរទីបី តើកម្រិតនៃការចុះខ្សោយដែលសាស្ត្រាចារ្យ ខាំប៉ែល លើកឡើង ហើយនិងអ្នកជំនាញវិកលវិទ្យាហ្នឹងទាក់ទងទៅនឹងសមត្ថភាពរបស់លោកស្រី អៀង ធីរិទ្ធ ហ្នឹងក្នុងការឆ្លើយតបនឹងបទចោទ ណែនាំមេធាវី ហើយការពារខ្លួន ហើយតាមដានដំណើរការនីតិវិធី ហើយភស្តុតាង ហើយនិងផលវិបាកនៃដំណើរការ ហើយទាំងសមត្ថភាពក្នុងការចូលរួមក្នុងសវនាការហ្នឹង គឺត្រូវបង្ហាញនៅក្នុងហ្នឹង គឺថាវាមានទំនាក់ទំនងទៅនឹងសិទ្ធិរបស់គាត់។

[១៤:៣៣:០២]

ខ្ញុំសូមសន្និដ្ឋានថា បញ្ហាទាំងអស់នេះ គឺយើងឃើញច្បាស់ថាជាករណីដែលមានស្ថានភាពមួយ ដែលក្នុងនោះដូចនឹងករណីរបស់ស្ត្រូហ្កា ដែរ គឺបញ្ហាគឺបែបនោះ គឺថាដោយមានការជំនួយអំពីមេធាវី ដែលអាច ដែលថាឲ្យបុគ្គលនោះ អាចនឹងចូលរួមបាននៅក្នុងដំណើរការនីតិវិធី ហើយនិងប្រើសិទ្ធិរបស់គាត់បាននៅក្នុងដំណើរការនីតិវិធី។ ហើយដើម្បីឲ្យវាមានយុត្តិធម៌ទៅបាន ការបំពេញបន្ថែមនោះ យើងប្រមើលមួយភ្លែតធ្វើបាន ប៉ុន្តែ ស្ត្រូហ្កា ហ្នឹងនិយាយថា វត្តមានរបស់មេធាវី គឺអាចនឹងជួយឲ្យជនជាប់ចោទ គឺថាអាចដោះស្រាយបញ្ហាខាងលើនោះបានមួយចំនួនអំពីសិទ្ធិ ហើយនៅក្នុងករណីជាក់លាក់ គឺថាអាចនឹងបំពេញបន្ថែមនូវភាពខ្វះខាត នូវសមត្ថភាពដែលបាត់បង់។

[១៤:៣៤:០០]

ការប្រើប្រាស់មេធាវី ត្រូវការ ប៉ុន្តែជនជាប់ចោទត្រូវមានសមត្ថភាពណែនាំមេធាវីឲ្យបានគ្រប់គ្រាន់ក្នុងគោលបំណងនេះ។ ក្នុងករណីរឿងក្តីណាហាក គឺថាចំណុចហ្នឹងគេបានលើកឡើងថា មុខងារសំខាន់របស់មេធាវី គឺជួយជនជាប់ចោទ ប៉ុន្តែមិនអាចជំនួសគាត់បានទេ ហេតុការណ៍ដែលថា មេធាវីជាអ្នកតំណាងដោយមេធាវីតំណាងឲ្យជនជាប់ចោទនោះ មិនមែនមានន័យថា ជនជាប់ចោទបាត់សមត្ថភាពឲ្យមេធាវីជំនួសបាននោះទេ។ ដូច្នេះគឺថា នេះជាលទ្ធភាពតាមទ្រឹស្តីមិនត្រឹមតែឲ្យគាត់ឆ្លើយថា បាទ/ទេ ទៅមេធាវី នោះចាត់ទុកថាជាសេចក្តីសម្រេចមកគាត់ត្រឹមត្រូវក្នុងការណែនាំមេធាវីនោះទេ។ ក្នុងករណីនេះ ទោះបីជាពេលដែលគាត់មេធាវីនោះបម្រើផលប្រយោជន៍ល្អបំផុតកូនក្តីក៏ដោយ មិនមែនមានន័យថា លុបបំបាត់នូវសមត្ថភាពក្នុងការណែនាំមេធាវីនោះទេ។ អ៊ីចឹងហើយមានការយល់ស្របទៅតាមមេធាវីក្តីគឺថា ហើយក៏មិនអាចរៀបរាប់ថា ការដែលឯកភាពយល់ស្របទៅតាមមេធាវីហ្នឹងគឺ គាត់មានសមត្ថភាពនោះទេ។ អ៊ីចឹងគឺថាត្រូវមានសមត្ថភាពក្នុងការណែនាំ ហើយនិងលើកពីការការពារខ្លួនរបស់គាត់បាន។ នេះជាកត្តាដ៏សំខាន់ នៃសម្បទារបស់ជនជាប់ចោទរបស់ចុងចម្លើយនោះ។ នេះហើយជាចំណុចដែលបានលើកឡើងនៅក្នុងតុលាការសិទ្ធិមនុស្សរបស់អឺរ៉ុបនោះផងដែរ។

[១៤:៣៥:៥០]

ការគ្មានការចងចាំ មានន័យថា មេធាវីមិនមានលទ្ធភាពក្នុងការជួយទាក់ទងទៅនឹងការធានាសិទ្ធិអប្បបរមានោះទេ ពីព្រោះថា ផ្ទុយទៅនឹងការជឿជាក់ជាទូទៅគឺថា មេធាវីមិនអាចប្រឌិតការការពារទេ មេធាវីមិនអាចបំពេញចំណុចចន្លោះទេ ប្រសិនបើជនជាប់ចោទមិននិយាយអ្វី មេធាវីមិនអាចធ្វើបានទេ

ពីព្រោះថា ជនជាប់ចោទជាអ្នកណែនាំមេធាវី ជាអ្នកផ្តល់ដំណើររឿង អង្គហេតុ ហើយនិងអ្វីៗដែលគាត់អាចយកមកប្រើជាទីបង្អែក។ មេធាវីត្រូវទទួលមតិយោបល់ពីខ្លឹមសារនៃសេចក្តីថ្លែងការណ៍របស់សាក្សី ទំនាក់ទំនងអំពីហេតុការណ៍ទៅនឹងជនជាប់ចោទ អ្វីដែលគាត់ទទួលយក អ្វីដែលគាត់ច្រានចោលទៅនឹងសេចក្តីប្រកាសនោះ ហើយដែលយើងមើលឃើញថា អ្វីដែលនិយាយហ្នឹង គឺធ្វើឲ្យច្រឡំដែរឬទេ គាត់ត្រូវតែមានលទ្ធភាពហ្នឹង។ ហើយជនជាប់ចោទអាចបញ្ជាក់ថា អ្វីដែលសាក្សីលើកឡើងហ្នឹង ត្រូវឬខុសបាន។ តើទីកន្លែងហ្នឹងត្រឹមត្រូវទេ កន្លែងហ្នឹងដែលគេនិយាយថាគាត់នៅហ្នឹង គាត់នៅឬទេ? ថាតើតួនាទីគាត់អ៊ីចឹងត្រូវ ឬមិនត្រូវ ដែលសាក្សីនិយាយអ៊ីចឹង។ គាត់ត្រូវតែមានលទ្ធភាពអ៊ីចឹង។ ប៉ុន្តែ អៀង ធីរិទ្ធ មិនមានលទ្ធភាពធ្វើបែបនោះបានទេ។ ប្រសិនបើយើងឃើញចម្លើយសាក្សីរាប់រយ ហើយអ្វីៗដែលនិយាយក្នុងពេលនេះ ពេលនោះក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គាត់មិនអាចណែនាំដល់មេធាវីបានទាល់តែសោះក្នុងករណីនេះ។ ហើយយើងត្រៀមខ្លួនជាស្រេច ដើម្បីជួយគាត់ កាលណាគាត់ជួយមតិរបស់យើង។ ប៉ុន្តែយើងមិនអាចនិយាយជំនួសគាត់ទាំងស្រុងបានទេ បើគាត់មិនអាចជួយយើងបានផងនោះ។

[១៤:៣៧:៤៥]

ហើយយើងសូមជម្រាបជូនអង្គជំនុំជម្រះថា គឺថាយើងមិនមានលទ្ធភាពអ្វីលើសពីព័ត៌មានដែលបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍ ហើយប៉ុន្តែបើគាត់មិនអាចបញ្ជាក់ថា សេចក្តីថ្លែងការណ៍ទាំងនោះត្រូវ ឬមិនត្រូវដោយសារគាត់មិនមានលទ្ធភាពនិយាយទេ គាត់មិនអាចជួយដល់ការរៀបចំ ឬការបង្ហាញក្នុងរឿងក្តីរបស់គាត់ទេ។ នេះជាអ្វីដែលអ្នកជំនាញសាស្ត្រាចារ្យ ខាំប៊ែល ហើយនិងអ្នកជំនាញទាំងបួនទទួលស្គាល់នៅក្នុងរបាយការណ៍បន្ថែម ឬក៏របាយការណ៍នេះ។ មិនមែនគឺថាគំនិតរបស់គាត់ទេ គឺគាត់ត្រូវបានបាត់បង់ការចងចាំពីខួរក្បាលរបស់គាត់ ហើយមិនអាចនឹងជួសជុលបាន ហើយចំណុចដែលពេញលេញនោះគឺ ខួរក្បាលរបស់គាត់ៗមិនអាចប្រមូលព័ត៌មានហ្នឹង នឹកឃើញឡើងវិញយកមកឆ្លើយ ឬមកសួរបានទេ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតចូលទៅដល់សំណួរទីបួន។

[១៤:៣៨:៥៧]

ដូចដែលអ្នកជំនាញរកឃើញថាលក្ខខណ្ឌនៃស្ថានភាពរបស់ អៀង ធីរិទ្ធ នោះគឺថា កាន់តែធ្ងន់ គឺថាអាចនឹងបន្តពន្យារពេលដល់ដំណើរការនីតិវិធីគាត់ទ្រុឌទ្រោមទៅ ហើយស្ថានភាពដែលអាចកើតឡើង។ ដូច្នេះហើយយើងស្នើឲ្យពិចារណាក្នុងអត្ថប្រយោជន៍នៃយុត្តិធម៌ សុំឲ្យមានការបំបែកចេញពី

ដំណើរការនីតិវិធីពីដីកាដំណោះស្រាយ។ អង្គជំនុំជម្រះគឺថា មានសិទ្ធិអំណាចតាមវិធាន៨១ ស្ទួនពីរ ដើម្បីនឹងធ្វើដូច្នោះបាន ដូចដែលបានលើកឡើង។ ដូច្នេះយើងខ្ញុំស្នើថា មិនគ្រាន់តែដកចេញពីសំណុំអង្គហេតុហ្នឹងទេ ប៉ុន្តែសុំឱ្យបញ្ឈប់ដំណើរការនីតិវិធីប្រឆាំងនឹងគាត់ ពីព្រោះថាគាត់មិនអាចនឹងមានសម្បទាចូលរួមសវនាការ ដោយមានអត្ថន័យបានទេ។

[១៤:៣៩:៥១]

ហើយខ្ញុំយល់ថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង ប្រកាន់ទស្សនៈថា គាត់មិនមានសម្បទាដោយផ្អែកទៅតាមសំណើដែលបានលើកឡើងហ្នឹង គឺវាមានការគ្រប់គ្រាន់ទៅតាមអ្នកជំនាញ អ៊ីចឹងគឺថាអាចនឹងជាកត្តាមួយដែលថា ការបំបែកនីតិវិធីគាត់ហ្នឹងអាចនឹងសមស្រប បើសិនជាអាចនឹងកែប្រែបាន។ ប៉ុន្តែយើងយល់ថា មិនមែនជាករណីដូចនោះបានទេ គឺថាបញ្ហាគាត់ចេះតែធ្ងន់ទៅ។ ហើយជនជាប់ចោទបីរូបទៀត គឺអាស្រ័យទៅលើសេចក្តីរបស់អង្គជំនុំជម្រះ ថាតើត្រូវធ្វើដូចម្តេចដើម្បីពន្លឿននីតិវិធី គោរពគោលការណ៍យុត្តិធម៌ ហើយដែលតម្រូវក្នុងករណីនេះ។

ប្រសិនបើគាត់មានសម្បទា ត្រូវមានការពិចារណាដោយឡែកមួយទៀត។ ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា គាត់មានការលំបាកនៅក្នុងបញ្ជាក់អំពីអ្វីដែលយើងបានលើកឡើងហ្នឹងហើយ។ គាត់គប្បីបំបែកពីនីតិវិធីផ្សេង ប៉ុន្តែវាមិនមែនមិនសមហេតុផល ឬក៏មិនត្រឹមត្រូវ ឬក៏មិនមានយុត្តិធម៌ ឬក៏មិនសមស្របទៅតាមភាពចាំបាច់នៃការបំពេញបន្ថែមនូវបញ្ហាជាក់លាក់ដែល អៀង ធីរិទ្ធ គាត់បានទទួលរងនោះ។

[១៤:៤១:២៦]

ហើយចំណុចចុងក្រោយនៅក្នុងបញ្ហា-- សំណួរដែលសួរនោះ ថាតើផលវិបាកអ្វីដែលជនជាប់ចោទនឹងជួបប្រទះប្រសិនបើបំបែកចេញអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ? យើងខ្ញុំសូមបញ្ជាក់ថា លក្ខខណ្ឌ គឺថាបើបសិនជាមានការបំបែកនីតិវិធីនេះ គឺវាកើតចេញមកអំពីមូលហេតុ ដែលថាអង្គជំនុំជម្រះសាលាដំបូងសម្រេចថា មិនអាចបន្តបាន។ ហើយបើសិនជាការបំបែកនោះវាសមស្រប ហើយវាមានយុត្តិធម៌ដែរឬទេក្នុងការធ្វើដូច្នោះ។

[១៤:៤២:១៣]

ប្រសិនបើជនជាប់ចោទបំបែកពីដំណើរការអ្នកផ្សេងទៀតដោយសារគាត់មិនមានសម្បទា ហើយអង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចជាបឋមមុន។ កាលណាមានលទ្ធភាពមួយដែលសមស្រប ដែលថាអាចនឹងត្រូវមានអាចនឹងមានការកែប្រែក្នុងស្ថានភាពរបស់គាត់។

ប៉ុន្តែភស្តុតាងមិនបានគាំទ្រគំនិតនេះទេ គឺថាអាចនឹងមានការកាត់ផ្តាច់នីតិវិធីដោយសារសម្បទារបស់គាត់ ហើយតុលាការនេះគឺថាត្រូវតែសម្រេចតាមភស្តុតាង លើកលែងតែមានភស្តុតាងផ្ទុយពីនេះ។ ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា មិនមានសម្បទាទេជាបញ្ហាបន្ទាប់ គឺថាយល់ថាមានបញ្ហាអាចកែប្រែបាន គឺថាទស្សនៈដែលពិនិត្យមើលគឺត្រូវកើតឡើងក្រោយពីការពិនិត្យ ដែលថាវិធានការផ្សេងៗដែលមាន ហើយការព្យាបាលនេះដែលត្រូវបានបញ្ជាឲ្យប្រើតាមដាន បន្ទាប់មកយើងត្រូវការថាតើ អៀង ធីរិទ្ធ នឹងត្រូវឃុំខ្លួនតទៅទៀត នៅក្នុងពេលការវាយតម្លៃបែបនេះ ឬក៏បើមិនមានដូច្នេះទេ ត្រូវមានការដោះឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន។ បើសិនជាលក្ខខណ្ឌរបស់គាត់ប្រសើរជាងនៅបរិស្ថានផ្សេង អាហ្នឹងគឺជាករណីមួយផ្សេង។

[១៤:៤៣:៣៥]

ដូចគ្នានោះដែរ ប្រសិនបើគាត់មានសម្បទា យើងត្រូវរង់ចាំថាតើត្រូវពិចារណា កត្តាពិចារណាពីរហ្នឹង គឺថាត្រូវការជំនួយ ត្រូវជំនុំជម្រះគាត់ដាច់ដោយឡែកពីរឿងក្តីផ្សេង គឺថាអាចនឹងគាត់ត្រូវការជំនួយច្រើនជាង ឬក៏តិចជាងដែលត្រូវការធម្មតា។

ដូច្នេះប្រសិនបើគាត់នៅក្រៅឃុំបណ្តោះអាសន្ន នៅកន្លែងផ្សេង អ៊ីចឹងគឺថាវាអាស្រ័យទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ហើយយើងជឿជាក់ថា យើងនឹងទទួលបានសេចក្តីសម្រេចពីអង្គជំនុំជម្រះពីករណី។ ហើយនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ហើយខ្ញុំសម្រាកពីរបីមីនុត។

បាទ, សូមអនុញ្ញាត។

[១៤:៤៤:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ, ឥឡូវនេះដល់ពេលសមល្មមដែលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះទៅរហូតដល់ម៉ោងបី និងដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីកិច្ចដំណើរការនីតិវិធី។ ហើយនីតិវិធីបន្ទាប់ហ្នឹង គឺសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដែលអង្គជំនុំជម្រះកំណត់ជូន ៤៥ នាទី ហើយបន្ទាប់មក គឺសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដប់ប្រាំនាទី។

សូមសម្រាកចុះ!

**លោក ឌុច ផារី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៦ នាទី ដល់ម៉ោង ១៥:១០ នាទី)*

[១៥:១១:២៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ជាបន្តនេះអង្គជំនុំជម្រះប្រគល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីឡើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់នៃកិច្ចពិភាក្សាដេញដោលអង្គសវនាការនេះ។

សហព្រះរាជអាជ្ញាមានរយៈពេលសែសិបប្រាំនាទី។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន សួស្តីលោក លោកស្រីចៅក្រមជាទីគោរព។ ខ្ញុំអនុញ្ញាតសូមឆ្លើយតបទៅនឹងសំណួរនីមួយៗក្នុងសំណួរទាំងប្រាំដែលលោក លោកស្រីចៅក្រមបង្គាប់នៅក្នុងដីកា ហើយខ្ញុំក៏សូមផ្តល់ជា បង្ហាញជាដូចជាផែនទីណែនាំផ្លូវអ៊ីចឹង។ ឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលប្រហែល ជាអាចផលប្រយោជន៍សម្រាប់លោក លោកស្រីចៅក្រម។

ជាបឋម ខ្ញុំសូមលើកឡើងថា ក្នុងរយៈពេលប៉ុន្មានថ្ងៃ ក្នុងរយៈពេលកន្លងមកនេះ គឺយើងបានពិនិត្យទៅលើបញ្ហានេះយ៉ាងប្រុងប្រយ័ត្ន។ សហព្រះរាជអាជ្ញាគាំទ្រសិទ្ធិទាំងឡាយរបស់ជនជាប់ចោទដែលត្រូវទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សហព្រះរាជអាជ្ញាគោរពសិទ្ធិទាំងអស់នោះ។ យើងជាស្ថាប័នមួយនៅក្នុងតុលាការ ហើយមានតួនាទីគឺដើម្បីជួយជ្រោមជ្រែងទៅដល់ចៅក្រម ហើយជាពិសេសនៅចុងក្រោយនោះគឺធ្វើយ៉ាងណាឲ្យជនជាប់ទទួលបានការជំនុំជម្រះមួយដោយយុត្តិធម៌។

[១៥:១៣:១៧]

ដូចដែលខ្ញុំបានលើកឡើង យើងបានពិចារណាទៅលើភស្តុតាងយ៉ាងលម្អិតរួមទាំងសក្ខីកម្មដែលលើកឡើងនៅក្នុងថ្ងៃនេះ និងថ្ងៃម្សិលមិញផងដែរ។ យើងខ្ញុំសូមដាក់ជូនដោយគោរពថា នៅក្នុងដំណាក់កាលនេះ យើងមិនអាចធ្វើការសម្រេចថាលោកស្រី អៀង ធីរិទ្ធ មានសម្បទាមិនគ្រប់គ្រាន់ក្នុងការចូលរួមក្នុងការជំនុំជម្រះក្តីនោះទេ។ ខ្ញុំនឹងធ្វើការផ្តល់ហេតុផល ហេតុអ្វីបានជាលើកឡើងដូច្នេះ។ ខ្ញុំសូមលើកឡើងចំណុចលម្អិតដែលបង្ហាញផ្ទុះបញ្ចាំងអំពីភាពធ្ងន់ធ្ងរ ដែលផ្ទុះបញ្ចាំងនៅក្នុងសេចក្តីសម្រេចរបស់លោក លោកស្រីចៅក្រម ហើយជាពិសេសលើការពិចារណាទៅលើរឿងក្តីព្រហ្មទណ្ឌ

ដែលមានលក្ខណៈធំធេងទាំងអស់នេះ ក្រោយពីយើងមានតុលាការ នូរឹមបើក។

[១៥:១៤:០៧]

ជនជាប់ចោទគឺត្រូវបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្ម ដែលបានកើតលើប្រជាជនរាប់លាននាក់ លោកស្រីគាត់មានសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ពាក្យសុំបង្ហាញថាគាត់មិនមានសម្បទាគ្រប់គ្រាន់នោះ គឺយើងត្រូវតែពិចារណាឲ្យបានហ្មត់ចត់។ ហើយប្រសិនបើយើងពិចារណាទៅលើសេចក្តីសម្រេចទៅលើគាត់នោះ យើងត្រូវក៏ពិចារណាអំពីផលប៉ះពាល់ និងសេចក្តីសម្រេចទៅលើជនរងគ្រោះនៅក្នុងឧក្រិដ្ឋកម្មនេះ រួមទាំងសហគមន៍ទាំងមូលផងដែរ។

យើងបានស្តាប់ឮរួចមកហើយអំពីសេចក្តីសង្ខេបទៅលើភស្តុតាង ដូចដែលបានដាក់ជូនពាក់ព័ន្ធទៅនឹងការចុះខ្សោយការចងចាំរបស់ស្រី អៀង ធីរិទ្ធ ហើយសហព្រះរាជអាជ្ញាសូមលើកឡើងថា វាមានការចុះខ្សោយនៅក្នុងការចងចាំរបស់លោកស្រី អៀង ធីរិទ្ធ ហើយមានការលំបាកសម្រាប់គាត់។ យើងឃើញមានភស្តុតាងបង្ហាញដូច្នេះនៅចំពោះមុខអង្គសវនាការ។ ក៏ប៉ុន្តែភស្តុតាងនៅចំពោះមុខអង្គចៅក្រមក៏បង្ហាញថា ជនជាប់ចោទគឺគាត់បានបំពេញទៅលើលក្ខខណ្ឌប្រាំ ក្នុងចំណោមលក្ខខណ្ឌទាំងប្រាំពីរ ដែលលោកចៅក្រមបានបង្គាប់។

ទីមួយគឺការឆ្លើយតបទៅនឹងបទចោទ យល់អំពីលក្ខណៈនៃបទចោទ យល់អំពីព័ត៌មានលម្អិតនៃភស្តុតាង និងយល់អំពីផលវិបាកនៃកិច្ចដំណើរការនីតិវិធី រួមទាំងផ្តល់សក្ខីកម្មផងដែរ។ ទាំងអស់នេះគឺជាសម្បទាដែលលោកអ្នកជំនាញរកឃើញថាបានបំពេញ។

ដូច្នេះហើយ ខ្ញុំសូមសន្និដ្ឋានថាចំពោះភស្តុតាងនៅចំពោះមុខតុលាការ លោកអ្នកជំនាញបានបង្ហាញការរកឃើញរបស់ខ្លួនទៅលើលក្ខខណ្ឌទាំងប្រាំនេះ ហើយបានពិចារណាយ៉ាងត្រឹមត្រូវ។ យើងខ្ញុំនឹងលើកឡើងបន្ថែមលក្ខខណ្ឌវិនិច្ឆ័យចំនួនពីរទៀត បន្ថែមទៅលើលក្ខខណ្ឌវិនិច្ឆ័យចំនួនប្រាំនោះ។

[១៥:១៦:១៧]

ពាក់ព័ន្ធទៅនឹងការចុះខ្សោយនូវការចងចាំ ខ្ញុំគិតថាវាសមស្របដែលយើងត្រូវពិចារណា ដែលថា រូបភាពដែលបង្ហាញជូនយើងនោះមិនមែនស-ខ្មៅ ឲ្យយើងឃើញជាក់លាក់នោះទេ។ យើងឃើញមានហេតុការណ៍មួយចំនួនដែលថាមុខនាទីសតិបញ្ញារបស់លោកស្រី អៀង ធីរិទ្ធ នៅតែមានកម្រិតល្អមួយចំនួន។

លោក លោកស្រីចៅក្រមបានចងចាំនូវសក្ខីកម្មរបស់អ្នកជំនាញរួចហើយ ដែលលោកស្រី អៀង

ធីរិទ្ធ គាត់អាចចូលរួមនៅក្នុងកិច្ចសម្ភាសន៍ក្នុងរយៈមួយយូរ។ ការរកឃើញនេះ គឺវាសមស្របទៅតាមរបាយការណ៍របស់លោកសាស្ត្រាប្រេនខិត និង កា ស៊ុនបូណាត ផងដែរ។

អាការៈទូទៅរបស់លោកស្រី អៀង ធីរិទ្ធ គឺធម្មតា គាត់រីករាយនឹងចូលរួមចូលរួមការសម្ភាស គាត់ក៏អាចបង្ហាញនូវអារម្មណ៍របស់ខ្លួនឯង ហើយលោកស្រីមិនមានការពិបាកក្នុងការរកនឹកពាក្យនោះទេ។

[១៥:១៧:២៦]

ដូច្នេះចំណុចសំខាន់នោះ យើងខ្ញុំសន្និដ្ឋាន និងសូមលើកឡើងថា លោកស្រីគាត់និយាយភាសាបរទេសពីរភាសា ហើយគាត់ក៏អាចនិយាយដោយរអិលផងដែរ។ ភស្តុតាងបង្ហាញពីអ្នកជំនាញនៅក្នុងថ្ងៃនេះក៏បង្ហាញឲ្យយើងឃើញថា ជារួមមុខនាទីសតិបញ្ញា និងការចងចាំរបស់គាត់ គឺវាមាន-- អាចកែប្រែបាន និងប្រសើរជាងមុខ ហើយវាអាចជួយទៅដល់ការចុះខ្សោយនៃសតិបញ្ញារបស់គាត់។ ហើយជាពិសេសនៅក្នុងដំណាក់កាលដែលគាត់នៅទីនេះរយៈពេលបួនឆ្នាំកន្លងមកហើយ ហើយសមត្ថភាពទូទៅរបស់គាត់នោះ គឺនៅក្នុងការបំពេញសកម្មភាពមួយចំនួនត្រូវបានតាមដាន និងត្រួតពិនិត្យ។ កាលៈទេសៈមួយចំនួន គឺវាមានកើតឡើង ធ្វើឲ្យគាត់ពិបាកសម្រាប់គាត់។

លើលពីនេះទៀត វាបង្ហាញឲ្យច្បាស់ ឲ្យយើងឃើញច្បាស់ថា ថ្នាំទាំងឡាយដែលបានផ្ដល់ជូនគាត់ក្នុងរយៈពេលបួនឆ្នាំកន្លងមកនេះ វាមានអានុភាព ហើយផលប៉ះពាល់របស់វានោះ គឺវាមិនច្បាស់លាស់នោះទេ ប៉ុន្តែវាមានផលប៉ះពាល់មែន។ ថ្នាំមួយប្រភេទត្រូវបានបញ្ឈប់រួចទៅហើយ ជាពិសេសថ្នាំរម្ងាប់អារម្មណ៍ដែលវាប៉ះពាល់ទៅដល់ការផ្ដង់អារម្មណ៍របស់គាត់។

[១៥:១៨:០៩]

យើងឃើញមានការពិភាក្សាអំពីសមត្ថភាពរបស់ អៀង ធីរិទ្ធ ក្នុងការវាយតម្លៃ ថាតើមានអ្វីកើតឡើងក្នុងតុលាការ និងនៅក្នុងកិច្ចដំណើរការនីតិវិធី។ ខ្ញុំគិតថា ប្រតិកម្មរបស់លោកស្រី អៀង ធីរិទ្ធ ដូចដែលយើងបានរៀបរាប់នៅក្នុងថ្ងៃនេះ វាជាចំណុចសំខាន់ដែលយើងត្រូវចងចាំ។

ជនជាប់ចោទ គឺគាត់ដឹងថា នៅថ្ងៃនេះ នៅក្នុងរយៈពេលនេះ គឺយើងកំពុងពិចារណាអំពីសម្បទាអំពីការចូលរួម ការជំនុំជម្រះក្ដីរបស់គាត់។ គាត់យល់អំពីគោលបំណងទាំងអស់នេះ។ ហើយប្រសិនបើយើងសម្រេចថា គាត់មិនមានសម្បទាមិនគ្រប់គ្រាន់នោះ គឺវាផ្ទុយពីករណីនេះ ដោយសារតែគាត់បានបានឆ្លើយតបទៅនឹងការលើកឡើងអត្ថបទសារព័ត៌មានពាក់ព័ន្ធទៅនឹងការចោទប្រកាន់ទៅលើគាត់។

[១៥:២០:០០]

យើងខ្ញុំសូមសន្និដ្ឋានដោយសាមញ្ញថា ដើម្បីជាផលប្រយោជន៍ទៅដល់សុខមាលភាពរបស់ អៀង ធីរិទ្ធ និងដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ តុលាការនេះ គឺត្រូវតែប្រើប្រាស់ជម្រើសឲ្យអស់លទ្ធភាព។ ពាក់ព័ន្ធទៅនឹងសម្បទានៃការចូលរួមការជំនុំជម្រះក្តី វាមានភាពយុត្តិធម៌ក្នុងការលើកឡើងថា វាមានសញ្ញាបញ្ជាក់ថា គាត់មានការលំបាកមែន ហើយមានការលំបាកច្រើន ប្រសិនបើជនជាប់ចោទ គាត់មិនអាចរំឭកនូវបញ្ហាណាមួយ ដែលដាក់បន្ទុកទៅលើគាត់។ ក៏ប៉ុន្តែវាក៏បង្ហាញជាករណីផងដែរ ថាការចងចាំរបស់គាត់អាចប្រសើរឡើង ហើយជាពិសេសការផ្តល់សក្ខីកម្មរបស់អ្នកជំនាញ នៅក្នុងថ្ងៃនេះ គឺថាការតេស្តទៅលើការចងចាំវាមានលក្ខណៈកម្រិត។ ដូច្នេះខ្ញុំឯកភាពជាមួយនឹងមេធាវីការពារក្តីថា វាបង្ហាញយ៉ាងច្បាស់ថា លោកស្រី អៀង ធីរិទ្ធ មិនចងចាំនូវហេតុការណ៍ដែលកើតឡើងក្នុងចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩។ ក៏ប៉ុន្តែអ្វីបង្ហាញឲ្យយើងឃើញច្បាស់នោះ តាមការសន្និដ្ឋាន និងលើកឡើងរបស់យើង យើងមិនអាចធ្វើការសម្រេចឲ្យរឹងមាំ និងជាក់លាក់លើចំណុចនេះទេ។

[១៥:២១:១៦]

ការបង្ហាញជាក់លាក់នៅក្នុងការសន្និដ្ឋានរបស់យើង ប្រហែលជាលោកស្រី អៀង ធីរិទ្ធ គាត់ធ្វើអាចមានប្រតិកម្មជាក់លាក់ទៅនឹងការលើកឡើងរបស់យើង ដូចដែលគាត់បានអាននូវអត្ថបទសារព័ត៌មាន ដែលគាត់បានទទួលនៅក្នុងមន្ទីរឃុំឃាំង។ វាក៏បង្ហាញឲ្យយើងឃើញផងដែរ លោកវេជ្ជបណ្ឌិតបានបង្ហាញនៅក្នុងថ្ងៃនេះ ថាការចងចាំរបស់លោកស្រីគឺអាចនឹងល្អប្រសើរឡើងវិញ ប្រសិនបើយកភស្តុតាងរូបភាពវីដេអូយកទៅបង្ហាញដែលបញ្ជាក់អំពីហេតុការណ៍ដែលកើតឡើង ហើយវាអាចជួយដល់ក្នុងកិច្ចដំណើរការនីតិវិធីនេះ។

នៅក្នុងពេលនេះ ខ្ញុំសូមលើកឡើងដោយសង្ខេបជូនអង្គសវនាការពាក់ព័ន្ធទៅនឹងសំណួររបស់អង្គសវនាការ។ ខ្ញុំមិនស្នើសុំឲ្យអនុញ្ញាតឲ្យខ្ញុំធ្វើការលើកឡើងដោយលម្អិតនោះទេ ដោយសារតែមេធាវីការពារក្តី និងក្រុមផ្សេងទៀត បានលើកឡើងដោយលម្អិតរួចមកហើយ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតលើកឡើងដោយសង្ខេប។ ពាក់ព័ន្ធទៅនឹងសំណួរទីមួយ ថាតើជនជាប់ចោទត្រូវចាត់ទុកថាពុំមានសម្បទាផ្នែកសតិបញ្ញាគ្រប់គ្រាន់ដែរឬទេ ក្នុងការចូលរួមសវនាការ ប្រសិនបើគ្រាន់តែរកឃើញលក្ខណៈវិនិច្ឆ័យមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងឡាយ? យើងបានឯកភាពគ្នារួចហើយក្នុងចំណោមយើងខ្ញុំ និងខាងមេធាវីការពារក្តីថា ប្រសិនៗបើលក្ខខណ្ឌមួយ គឺមិនមានទេនោះ ឧទាហរណ៍ថា ជនជាប់ចោទមិន

មានលទ្ធភាពផ្ដល់សក្ខីកម្មបាន ឬក៏ជនជាប់ចោទមិនអាចយល់ទាំងស្រុងទៅលើបទចោទ និងភស្តុតាងបាននោះ ដូច្នេះ វាមានភាពសមហេតុផលត្រូវលើកឡើងថា ជនជាប់ចោទមិនមានសិទ្ធិក្នុងការអនុវត្ត--សិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌នោះទេ ក៏ប៉ុន្តែករណីនេះ មិនបង្ហាញជាភស្តុតាងឲ្យយើងឃើញដូច្នោះនោះទេ។

[១៥:២៣:១៨]

អ្នកជំនាញបានលើកឡើង ថាជនជាប់ចោទមានការលំបាកច្រើនលើករណីនេះ ក៏ប៉ុន្តែមិនមែនថាសមត្ថភាពរបស់គាត់គឺអត់មានទាំងស្រុងនោះឡើយ។ ជាការពិតលក្ខណៈវិនិច្ឆ័យទាំងប្រាំពីរដែលជាសញ្ញាបញ្ជាក់ឲ្យយើងឃើញផ្អែកទៅតាមការពិចារណាទៅលើសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌ ដូចមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ដូច្នេះហើយ វាមិនមែនជាសញ្ញាបញ្ជាក់សំខាន់ដាច់ខាតនៅក្នុងការជំនុំជម្រះព្រហ្មទណ្ឌនោះទេ។ ចំពោះបរិបទនៅក្នុងទីនេះ យើងខ្ញុំសូមលើកឡើងថា លោក លោកស្រីចៅក្រម ត្រូវពិចារណាអំពីនីតិវិធីនៅក្នុងតុលាការនេះ។ វាជាបញ្ហាពាក់ព័ន្ធដែលយើងត្រូវពិចារណា។

[១៥:២៤:១១]

យើងឃើញមានភាពខុសគ្នារវាងវិធីដែលជនជាប់ចោទបង្ហាញភស្តុតាងនៅក្នុងតុលាការនេះ និងវិធីដែលជនជាប់ចោទបង្ហាញភស្តុតាងនៅក្នុងតុលាការអន្តរជាតិផ្សេងទៀត។ ឧទាហរណ៍ នៅតុលាការអាយ.ស៊ី.ធី.វ៉ាយ ដែលរឿងក្ដីមួយចំនួនយើងយកមកធ្វើជាបទដ្ឋាន។ ជនជាប់ចោទគឺគាត់មិនទាមទារនូវភស្តុតាងណាដែលត្រូវជូនគាត់នោះទេ លើកលែងតែមានដីកាចោទប្រកាន់ជនជាប់ចោទ។ ប៉ុន្តែនៅទីនេះ គឺយើងផ្ដល់ភស្តុតាងគ្រប់បែបយ៉ាងទៅដល់ជនជាប់ចោទ រួមទាំងដំណាក់កាលមុនអង្គសេចក្ដី។ រួមបន្ថែមទៀតនោះ គឺយើងត្រូវផ្ដល់ភស្តុតាងផ្សេងទៀត ក្នុងអំឡុងពេលសវនាការ។ នៅតុលាការអាយ.ស៊ី.ធី.វ៉ាយ គឺវាមានការងារច្រើនដែលវាពាក់ព័ន្ធទៅដល់ជនជាប់ចោទ អៀង ធីរិទ្ធ បានចូលរួមនៅក្នុងកិច្ចស៊ើបសួររបស់ចៅក្រម ភស្តុតាងបានប្រមូលបានក្នុងដំណាក់កាលនោះ ក្នុងការបង្ហាញ និងបញ្ជាក់ទៅលើការពិត។ តែបង្ហាញទៅលើភស្តុតាងចោទប្រកាន់ ដាក់បន្ទុកដោយសហព្រះរាជអាជ្ញា។ កិច្ចស៊ើបសួរទាមទារឲ្យធ្វើការរកភស្តុតាងទាំងដាក់បន្ទុក និងដោះបន្ទុកឲ្យបានស្មើគ្នា។

នៅក្នុងសវនាការចៅក្រមជំនុំជម្រះនឹងធ្វើការរកភស្តុតាង និងបង្ហាញភស្តុតាង។ នៅក្នុងកិច្ចដំណើរការនេះ គឺជាដំណើរការមួយដែលយើងរកភស្តុតាង។ ភស្តុតាងមិនមែនដាក់ជូនថ្មីៗភ្លាមៗដោយ

សហព្រះរាជអាជ្ញានោះទេ គឺរឿងក្តី និងភស្តុតាងទាំងអស់មាននៅក្នុងសំណុំរឿងរួចមកហើយ ហើយក៏ត្រូវបានពិចារណាដោយខាងមេធាវីការពារក្តីក្នុងរយៈពេលបួនឆ្នាំកន្លងមកនេះផងដែរ។

[១៥:២៦:០៣]

ដោយសារតែពេលវេលាមានកំណត់សម្រាប់ខ្ញុំ ខ្ញុំសូមចង្អុលបញ្ជាក់ដោយសង្ខេបថាតើយើងនឹងគិតយើងដូចម្តេច? ហើយប្រហែលជាវាអាចជាការយល់ខុសពីខាងអ្នកជំនាញនៅពេលដែលគាត់ពិចារ-ណាលក្ខខណ្ឌមួយ ក្នុងចំណោមលក្ខខណ្ឌទាំងពីរ ជាពិសេសចំពោះការយល់ដឹងរបស់ជនជាប់ចោទទៅលើកិច្ចដំណើរការនីតិវិធី។

លោក លោកស្រីចៅក្រមបានចោទសួរលោកអ្នកជំនាញ នៅក្នុងកថាខណ្ឌទី២នៃដីកាបង្គាប់របស់លោក លោកស្រីចៅក្រមនៅខែតុលា ឆ្នាំ២០១១ ថាតើជនជាប់ចោទមានការយល់ដឹងគ្រប់គ្រាន់ទៅលើកិច្ចដំណើរការនីតិវិធីដែរឬទេ? ចំណុចនេះ គឺវាស្របគ្នាទៅនឹងយុត្តិសាស្ត្រអន្តរជាតិ។ អ្នកជំនាញបានបកស្រាយករណីនេះថា ជាការយល់អំពីកិច្ចដំណើរការនីតិវិធី មានលើកឡើងនៅក្នុងកថាខណ្ឌ៤៣ នៃរបាយការណ៍របស់អ្នកជំនាញ។ នៅពេលដែលយើងឃើញនៅក្នុងរបាយការណ៍ លោក លោកស្រីចៅក្រមត្រូវពិចារណាទៅលើសេចក្តីសម្រេច *ខូវ៉ាសេវិក* (Kovacevic) ដែលនៅក្នុងកថាខណ្ឌ៥ អនុកថាខណ្ឌ២ ដែលយើងត្រូវពិចារណាទៅលើលក្ខណៈវិនិច្ឆ័យទាំងអស់នោះ។ វាមិនមែនជាការយល់ដឹងទៅលើកិច្ចដំណើរការនីតិវិធីឲ្យបានពេញលេញទាំងស្រុងនោះទេ។ គឺមិនមែនសម្បទាសមត្ថភាពក្នុងការផ្តល់យោបល់គ្រប់បែបយ៉ាងទៅលើកិច្ចដំណើរការនីតិវិធីនោះទេ។ គឺគ្រាន់តែឲ្យយល់អំពីភាគីមានតួនាទីអ្វី? ការចោទប្រកាន់មានអ្វីខ្លះ? ហើយនិងកិច្ចដំណើរការនីតិវិធីដែលបានដំណើរការទៅតែប៉ុណ្ណោះ។

[១៥:២៨:០៨]

ខ្ញុំសូមលើកឡើងបញ្ហានេះដោយសង្ខេបដែរ ទាក់ទងនឹងបន្ទុកនៃការបង្ហាញភស្តុតាង យើងខ្ញុំសូមសន្និដ្ឋានថា មេធាវីការពារក្តី មិនលើកឡើងមិនត្រឹមត្រូវនោះទេនៅពេលដែលលើកឡើងថា ខាងសហព្រះរាជអាជ្ញាមានបន្ទុកក្នុងការបង្ហាញភស្តុតាង។ យើងខ្ញុំសូមបញ្ជាក់ថា វាជាសេចក្តីសម្រេចដែលអង្គជំនុំជម្រះជាអ្នកត្រូវរក ហើយវាជាបន្ទុកដាច់ដោយឡែកពីគ្នា។ ហើយស្ត្រូហ្កា នៅក្នុងរឿងក្តីស្ត្រូហ្កាក៏បានលើកឡើងអំពីករណីនៃបន្ទុកនៃការបង្ហាញភស្តុតាងផងដែរ។

នៅពេលដែលយើងពិចារណាទៅលើការចុះខ្សោយការចងចាំ វាពាក់ព័ន្ធទៅនឹងសំណួរទីពីរនៅ

ក្នុងការបង្គាប់របស់អង្គសវនាការឲ្យយើងខ្ញុំទាំងអស់គ្នាពិចារណា។ យើងខ្ញុំសូមធ្វើការឆ្លើយតបដោយសាមញ្ញដូចដែលយើងបានបញ្ជាក់ថា វាមិនអាចមានលទ្ធភាពសម្រាប់ចៅក្រមនៅពេលនេះ ក្នុងការសម្រេចដោយជាក់លាក់ ថាតើការចុះខ្សោយនៃការចងចាំធ្វើឲ្យគាត់មិនមានលទ្ធភាពក្នុងការអនុវត្តសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នោះទេ។

យើងត្រូវចងចាំថា អ្នកជំនាញរួមទាំងលោកសាស្ត្រាចារ្យ ខាំប៉ែល និងសាស្ត្រាចារ្យទាំងបួនដែលបានដាក់របាយការណ៍របស់ខ្លួននោះ គឺមិនបានដកចេញនូវលទ្ធភាព មិនឲ្យព្យាបាលទៅដល់ជនជាប់ចោទ ដែលការព្យាបាលនេះអាចជួយឲ្យស្ថានភាពនេះប្រសើរឡើងវិញ។

ខ្ញុំចូលទៅដល់ចំណុចទីបី ថាតើការចុះខ្សោយបានបង្ហាញថាជនជាប់ចោទ អៀង ធីរិទ្ធ មិនមានសមត្ថភាពក្នុងការចូលរួមសវនាការដែរឬទេ ដោយយើងពិចារណាទៅលើគាត់មានមេធាវីតំណាង។

យើងត្រូវពិចារណាដោយសង្ខេប ថាតើការចុះខ្សោយអ្វីខ្លះ ដែលតុលាការបានរកឃើញចំពោះ អៀង ធីរិទ្ធ ដែលថា អាចសម្រេចជនជាប់ចោទមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះក្តីនោះ។

[១៥:៣០:១៦]

ខ្ញុំជឿថា មានរឿងក្តីចំនួនពីរ ដែលជាសេចក្តីសម្រេចបានធ្វើឡើងដោយតុលាការអន្តរជាតិគឺរឿងក្តី ខូវ៉ាសេវិក របស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ ហើយនិងរឿងក្តី ណាហាក (Nahak) ដោយធ្វើការសម្រេចនៅតុលាការពិសេសរបស់ទីម័រខាងកើត។ សេចក្តីសម្រេចទាំងអស់នោះ វាពាក់ព័ន្ធទៅនឹង ណាហាក រឿងក្តីណាហាក។ ណាហាក ត្រូវបានតុលាការរកឃើញថា មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះក្តី ហេតុផលដែលខ្ញុំលើកឡើងករណីនេះដោយសារតែ វាមានលក្ខណៈលម្អិតលើកឡើងនៅក្នុងហ្នឹង ដោយសារតែ ខូវ៉ាសេវិក គឺគាត់បានមិនពិចារណាលម្អិតទៅលើសម្បទា។ សេចក្តីសម្រេចនៅក្នុងរឿងក្តី ណាហាក បានបង្ហាញថា ក្នុងឆ្នាំ១៩៩៩ មុនពេលតុលាការសម្រេចអ្នកនៅជុំវិញលោក ណាហាក លើកឡើងថាគាត់ឆ្កួត។ បីឆ្នាំមុនពេលដែលរឿងក្តីនេះចូលមកតុលាការសហព្រះរាជអាជ្ញាស្នើសុំឲ្យដោះលោក ណាហាក ការស្នើសុំនេះនៅចំពោះមុខចៅក្រមស៊ើបអង្កេតដោយសារតែអាកប្បកិរិយារបស់លោក ណាហាក មានលក្ខណៈមិនសមរម្យ។

[១៥:៣១:៣៥]

ប៉ុន្តែការពិនិត្យលើកោសល្យវិច័យវិកលវិទ្យា១៥ខែ មុនពេលតុលាការចេញសេចក្តីសម្រេច

លោក ណាហាក បានលើកឡើងអំពីយោបល់របស់ខ្លួន ហើយគឺគាត់ក៏បានលើកឡើងអំពីការដែលគេចាប់បុគ្គលម្នាក់ត្រង់កញ្ជឹងក ហើយនៅពេលនោះគេមានសួរអំពីកិច្ចដំណើរការនីតិវិធី។ លោក ណាហាក បានលើកឡើងថា គាត់យល់អំពីតុលាការធ្វើអ្វី មេធាវីធ្វើអ្វី ហើយនៅក្នុងការជំនុំជម្រះនោះគេធ្វើយ៉ាងម៉េច។ ដូច្នេះ យើងគួរតែយល់អំពីករណីនេះ។ គោលការណ៍នៅក្នុងរឿងក្តីណាហាក នោះវាអាចអនុវត្តនៅទីនេះបាន។ យើងត្រូវពិចារណាអំពីកម្រិត នៃការចុះខ្សោយសតិបញ្ញា នៅពេលដែលយើងធ្វើការតតាំងចំពោះសម្បទារបស់ជនជាប់ចោទ ក្នុងការចូលរួមការជំនុំជម្រះក្តី។ យើងសូមលើកឡើងថា ជំហរស្ថានភាពពាក់ព័ន្ធនឹង អៀង ធីរិទ្ធ ខុសពីស្ថានភាពនានា។

[១៥:៣២:៥៣]

ហើយក៏ទាក់ទងទៅនឹងបញ្ហាមួយដោយសង្ខេបដែរ ដែលទាក់ទងទៅនឹងថាមេធាវីលើកឡើងហ្នឹងគឺថា យើងសូមជម្រាបថា យើងចាត់ទុកបញ្ហានេះដោយពិនិត្យមើលដំណើរការពិសេស ដែលត្រូវប្រើនីតិវិធីនៅទីនេះដោយនៅក្នុងខណៈដែលចៅក្រម ដើរតួសំខាន់ក្នុងការកំណត់ ឬក៏ក្នុងការអនុវត្តដំណើរការនីតិវិធីនេះ។ ហើយយើងខ្ញុំក៏កត់សម្គាល់ឃើញថា បញ្ហាដែលថា មេធាវីមិនអាចជួយគាត់បាននោះ គឺមិនអាចធ្វើទៅបានទេ ពីព្រោះថាបញ្ហានេះលើកឡើងនៅក្នុងខែកុម្ភៈឆ្នាំនេះ ហើយមានចំណុចមួយមេធាវីបញ្ជាក់ថា ដែលខ្លួនលើកឡើងថា គាត់មានការលំបាកក្នុងការទទួលការណែនាំនោះ ប៉ុន្តែភស្តុតាងហ្នឹងនៅចុងឆ្នាំ២០០៩ លោកស្រី អៀង ធីរិទ្ធ គឺថា បញ្ហាសតិបញ្ញារបស់គាត់មិនមានការចុះខ្សោយទេ គាត់បានណែនាំមេធាវីឲ្យធ្វើការ។

[១៥:៣៣:៥៨]

អ៊ីចឹងសេចក្តីសន្និដ្ឋានរបស់ខ្ញុំគឺថា ពិនិត្យមើលស្ថានភាពទាំងអស់នេះគឺថា តើគាត់មានសិទ្ធិអ្វីខ្លះនៅក្នុងការប្រើសិទ្ធិ ឬក៏លទ្ធភាពរបស់គាត់នោះ។ ហើយនិងខ្ញុំចូលទៅដល់បញ្ហាទាក់ទងទៅនឹងការបំបែកដំណើរការនីតិវិធីសម្រាប់គាត់ ហើយមេធាវីការពារបានលើកឡើងថា អង្គជំនុំជម្រះមានសេចក្តីសម្រេចថាអាចបំបែក ឬក៏បញ្ឈប់ដំណើរការនីតិវិធីប្រឆាំងនឹងរូបលោកស្រី អៀង ធីរិទ្ធ ប៉ុន្តែក្នុងករណីថាទោះជាការបំបែកនីតិវិធី ឬការបញ្ចប់នីតិវិធីគឺក្នុងកាលៈទេសៈណាក៏មិនសមស្របដែរ។ ហើយយើងបានទទួលការណែនាំពីច្បាប់ថា មិនមានរឿងក្តីអន្តរជាតិណាមួយ ដែលកើតមានឡើងទេ ដែលថាជនជាប់ចោទ ឬក៏មេធាវីជនជាប់ចោទ អាចស្នើសុំឲ្យបញ្ឈប់នីតិវិធីហ្នឹងបានទេ ដោយសារតែគាត់មានជំងឺ ឬក៏មានជំងឺ ក៏ប៉ុន្តែនៅក្នុងតុលាការ អាយ.ស៊ី.ធី.វ៉ាយ គឺថាក្នុងរឿងក្តីថាឡិក (Talic) ហើយនិង យូគិក

(Jokic) ត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ប៉ុន្តែមិនមែនមានន័យថា បញ្ឈប់ដំណើរការនីតិវិធីប្រឆាំងនឹងអ្នកទាំងនោះទេ។ នៅពេលក្រោយមកនៅក្នុងរឿងក្តីយូគិក វិញ តុលាការ អាយ.ស៊ី.ធី.វ៉ាយ មិនបានចែងថាឲ្យលើកលែងការចោទប្រកាន់ ឬក៏បញ្ចប់ដំណើរការនីតិវិធីប្រឆាំងគាត់នោះទេ។ ខ្ញុំលើកឡើងរឿងក្តីនេះគឺថា ច្បាប់ដែលអនុវត្តចំពោះតុលាការយើងនេះក៏មិនមានចែងថា ឲ្យបញ្ចប់នីតិវិធីប្រឆាំងនឹងជនជាប់ចោទណាមួយ នៅពេលដែលជនជាប់ចោទនោះ តុលាការរកឃើញថាមិនមានសម្បទាក្នុងការជំនុំជម្រះនោះទេ។

[១៥:៣៥:៥១]

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ គឺមានចែងនៅក្នុងមាត្រា៧ និង៨ ដែលនិយាយថា បើរកឃើញថាមិនមានសម្បទាក្នុងការចូលរួមជំនុំជម្រះ មិនមែនមានន័យថាបញ្ចប់នីតិវិធីនោះទេ។ អ៊ីចឹងនិយាយពីផលប៉ះពាល់ ទាក់ទងទៅនឹងជនជាប់ចោទផ្សេងៗទៀត។ យើងខ្ញុំសូមជម្រាបជូនថា នៅដំណាក់កាលនេះ រាល់ការពន្យារពេលណាមួយ ហើយនិងការពិចារណាដើម្បីពន្យារពេលនោះ គឺថាអាចនឹងនាំឲ្យមានការយល់ខុស ដោយថាជនជាប់ចោទទាំងបួនសុទ្ធតែជាជនចាស់ជរា។ ហើយជនជាប់ចោទផ្សេងទៀតក៏មានបញ្ហាសុខភាព ហើយជនជាប់ចោទណាម្នាក់គឺថា អាចនឹងស្នើសុំឲ្យសលើកសវនាការ ឬក៏សុំទទួលការព្យាបាល ហើយគឺមិនមានការខុសគ្នាពីលោកស្រី អៀង ធីរិទ្ធ ទេ ហើយនៅក្នុងចំណោមជនជាប់ចោទទាំងបួននោះ។

ភាពខុសគ្នានោះគឺថា នៅដំណាក់កាលនេះគឺ ដែលថា អៀង ធីរិទ្ធ នៅក្នុងសំណើរបស់យើងគឺថាយើងតម្រូវឲ្យមានការព្យាបាលពិសេស ហើយការព្យាបាលនោះត្រូវបានផ្តល់ដើម្បីជាអត្ថប្រយោជន៍របស់គាត់ និងដំណើរការរបស់នីតិវិធី។ ប៉ុន្តែលោក លោកស្រីចៅក្រមនឹងប្រឈមមុខពីពេលមួយទៅពេលមួយក្នុងដំណើរការនីតិវិធី។ វាមិនសមស្របទេនៅក្នុងទស្សនៈរបស់យើង បើសិនជាតុលាការបំបែកសំណុំរឿងគាត់នោះ នៅពេលនោះ ហើយនិង/ឬក៏ត្រូវសម្រេចថាបញ្ចប់នីតិវិធីដោយរកឃើញថាគ្មានសម្បទាចូលរួមជំនុំជម្រះ ដោយមិនបានព្យាបាលកែលម្អជាមុនទេនោះ។

[១៥:៣៧:៤៤]

ខ្ញុំគិតថា ខ្ញុំបានជម្រាបជូនអំពីអ្វីដែលជាផលវិបាកដែលថា បើបំបែកសំណុំរឿងគាត់ទៅ តើវាមានផលវិបាកដូចម្តេចនោះ? ហើយខ្ញុំបានជម្រាបគ្រប់គ្រាន់ លើកលែងតែលោកចៅក្រមចង់បានអ្វីលើសពីនោះ ប៉ុន្តែខ្ញុំសូមបញ្ជាក់ដោយសង្ខេបថាជំហររបស់យើងនោះគឺថា មិនមានភស្តុតាងគ្រប់គ្រាន់

គួរឲ្យជឿជាក់បានថា អៀង ធីរិទ្ធ មិនមានសម្បទានោះទេ។ ទោះបីជាគាត់មានជំងឺការចុះខ្សោយសតិបញ្ញាហើយដោយមានជំងឺវង្វេងស្មារតីខ្លះ ប៉ុន្តែយើងមិនដឹង តើជំងឺហ្នឹងវាចុះ វាមានស្ថានភាពធ្ងន់ធ្ងរល្បឿនប៉ុនណានោះទេ ហើយយើងក៏មិនដឹងថា ជំងឺនេះធ្វើឲ្យគាត់បាត់បង់សតិបញ្ញាទាំងស្រុងនៅក្នុងដំណាក់កាល ដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយនោះដែរ។

[១៥:៣៨:៤១]

ហើយយើងពិនិត្យឃើញថា បញ្ហានេះគឺថាអាចនឹងដោះស្រាយបាននៅក្នុងដំណាក់កាលមួយក្នុងការផ្តល់នូវកត្តាជំរុញសតិបញ្ញា ហើយនិងការជំនួយខាងផ្លូវចិត្តរបស់គាត់ដោយមានការកែប្រែការព្យាបាលតាមមតិរបស់សាស្ត្រាចារ្យ ខាំប៊ែល ហើយខ្ញុំនឹកឃើញថាដើម្បីកត់ត្រាឲ្យបានត្រឹមត្រូវនៅក្នុងការផ្តល់សក្ខីកម្ម សាស្ត្រាចារ្យ ខាំប៊ែល និយាយថា វិធានការទាំងអស់ត្រូវតែអនុវត្តមុននឹងចូលដល់សេចក្តីសម្រេចចុងក្រោយលើករណីគាត់នេះ ទៅលើបញ្ហានេះ។

មានសេចក្តីយោង ហើយនិងមានការប្រៀបធៀបដែលបានលើកឡើងនៅក្នុងស្ថានភាពនៅនេះក្នុងសហរដ្ឋអាមេរិក នៅពេលដែលអ្នកជំងឺទទួលបានការព្យាបាល ដើម្បីឲ្យគេមានស្ថានភាពឲ្យៗមានស្ថានភាពល្អប្រសើរ បញ្ហាគ្រប់គ្រាន់នឹងទទួលការជំនុំជម្រះ។ ប៉ុន្តែនៅករណីយើងនេះ មិនដូចករណីទាំងនោះទេ សាស្ត្រាចារ្យ ខាំប៊ែល បានផ្តល់ភស្តុតាងថា ប្រសិនបើ *ដុនណេប៉េហ្ស៊ីល* ត្រូវបានប្រើគ្រប់គ្រាន់ គឺថាវាអាចនឹងមានផលប៉ះពាល់ក្នុងរយៈពេលបីខែ អាចកែប្រែ ប៉ុន្តែវាអាចមានប្រសិទ្ធភាពគាត់បាននិយាយថា ក្នុងរយៈពេលមួយឆ្នាំ ពីរឆ្នាំ ឬវែងជាងហ្នឹង គឺថានេះជាមតិដ៏ត្រឹមត្រូវ នេះក្នុងអត្ថប្រយោជន៍របស់ អៀង ធីរិទ្ធ ដើម្បីប្រើអស់លទ្ធភាពទាំងអស់ ដើម្បីធានាថា ដើម្បីឲ្យគាត់ទទួលបានការព្យាបាលដែលគាត់ត្រូវការ ដើម្បីសម្រាលជំងឺរោគសញ្ញាដែលគាត់បានមាន ហើយក៏នៅក្នុងអត្ថប្រយោជន៍នៃយុត្តិធម៌ផងដែរ។ ហើយដំណើរ-- ដល់ដំណើរការនីតិវិធីផងដែរ ដើម្បីនឹងធ្វើកិច្ចប្រឹងប្រែងទាំងអស់ដើម្បីធានាឲ្យគាត់ចូលរួមក្នុងរយៈពេលយូរ ហើយតាមពិត-- ហើយយើងខ្ញុំសូមជម្រាបថា ភស្តុតាងដែលអង្គជំនុំជម្រះទទួលបានហើយមិនទាន់ដល់កម្រិតមួយដែលថា អង្គជំនុំជម្រះអាចសម្រេចបានថាគាត់គ្មានសម្បទាក្នុងការចូលរួមជំនុំជម្រះនោះទេ។

[១៥:៤០:៥៤]

នេះជាគឺជាសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ខ្ញុំនឹងជូនវេទិកាទៅដល់សហសេវិករបស់ខ្ញុំ។ សូមអរគុណលោកតុលាការ។

**លោក ច័ន្ទ តារាស្មី៖**

សូមអរគុណ។ សូមគោរពឯកឧត្តមប្រធាន!

លោកប្រធាន សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ ហើយសូមគោរពអង្គសវនាការទាំងមូល។ នៅពេលនេះខ្ញុំក្នុងនាមសហព្រះរាជអាជ្ញា ខ្ញុំសូមបង្ហាញជូននូវការយល់ឃើញក៏ដូចជាការកត់សម្គាល់របស់សហព្រះរាជអាជ្ញាទាក់ទិនទៅនឹងសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ នៅក្នុងការចូលរួមសវនាការ ហើយនិងការបំបែកនីតិវិធីចំពោះជនជាប់ចោទ អៀង ធីរិទ្ធ បន្ថែមទៀតទៅលើអ្វីដែលលោកសហការីអន្តរជាតិ ថារីក បានបង្ហាញជូនអម្បាញ់មិញនេះ។

[១៥:៤១:៣៥]

ខ្ញុំយល់ឃើញថា ក្នុងនាមសហព្រះរាជអាជ្ញាគឺអ្នកជំនាញខាងចិត្តសាស្ត្របានបញ្ជាក់រួចហើយនៅក្នុងរបាយការណ៍របស់ខ្លួននាពេលថ្មីៗនេះថា ជនជាប់ចោទ អៀង ធីរិទ្ធ មានកាយសម្បទាគ្រប់គ្រាន់អាចចូលរួមក្នុងសវនាការបានដោយផ្ទាល់។ មានន័យថា មានភាពប្រសើរជាងពេលមុន នេះជាចំណុចវិជ្ជមានសម្រាប់បញ្ជាក់ឲ្យអង្គជំនុំជម្រះសាលាដំបូងនៅពេលនេះ យល់កាន់តែច្បាស់ និងជាមូលដ្ឋានដ៏សំខាន់ និងចាំបាច់បំផុតដែលអង្គជំនុំជម្រះអាចទទួលស្គាល់ថា ជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវតែមានវត្តមានក្នុងពេលសវនាការនាពេលខាងមុខជាចាំបាច់។

[១៥:៤២:១៣]

ជនជាប់ចោទ អៀង ធីរិទ្ធ មានកាយសម្បទាអាចចូលរួមក្នុងសវនាការដោយផ្ទាល់បាន ព្រោះគាត់អាចនិយាយបាន អាចស្តាប់បាន អាចអង្គុយបាន ឬឈរនិយាយបាន បើទោះបីជាគាត់មិនអាចអង្គុយ ឬឈរបានយូរដូចមនុស្សទូទៅក្តី។ ក៏ប៉ុន្តែគាត់អាចសុំសម្រាកបន្តិច ហើយអាចបន្តចូលរួមក្នុងសវនាការជាថ្មីទៀតបាន។

ម្យ៉ាងវិញទៀត សតិបញ្ញាក្នុងខួរក្បាលរបស់គាត់ ក្នុងប្រព័ន្ធសរសៃប្រសាទរបស់គាត់ យោងតាមរបាយការណ៍បានបញ្ជាក់គាត់អាចវិភាគ អាចពិចារណា និងគិតយល់ដឹងខុស ឬត្រូវបាន មិនមែនខូចខាតទាំងស្រុង ឬមិនមែនខូចខាតជាអចិន្ត្រៃយ៍នោះទេ។ ម្យ៉ាងវិញទៀតការភ្លេចច្រើន ការមិនចងចាំល្អ ឬការមិនចាំច្បាស់នូវអ្វីដែលបានកើតឡើងនៅក្នុងអតីតកាល ឬបច្ចុប្បន្នកាលគឺជាសភាពធម្មតានៃសុខភាពខួរក្បាលរបស់មនុស្សទូទៅដែលមានសភាពអាយុច្រើន ដូចជារូបគាត់។

[១៥:៤៣:២០]

ហើយបន្ថែមលើសពីនេះ ជនជាប់ចោទ អៀង ធីរិទ្ធ មានសុខភាពមិនសូវល្អស្រាប់ផង បណ្ដាលឲ្យគាត់រឹតតែមានអារម្មណ៍មិនល្អ និងមានការភ្លេចភ្លាំងច្រើនថែមទៀត ក៏ប៉ុន្តែចំណុចនេះ មិនមែនមានន័យថា ជាឧបសគ្គសម្រាប់ការចូលរួមរបស់គាត់ក្នុងសវនាការនោះទេ។

បើផ្អែកតាមលទ្ធផលនៃការពិនិត្យសុខភាព និងសម្បទាដែលធ្វើឡើងដោយក្រុមគ្រូពេទ្យជំនាញ ដែលលោក លោកស្រីចៅក្រមបានស្ដាប់ការបំភ្លឺរួចហើយ គឺបានបង្ហាញឲ្យឃើញថា លទ្ធផលមានភាពវិជ្ជមាន។ ហើយជនជាប់ចោទ អៀង ធីរិទ្ធ បានឆ្លើយសំណួរខ្លះដែលគ្រូពេទ្យបានទទួលចម្លើយត្រឡប់តបមកវិញ គឺចម្លើយខ្លះមានលក្ខណៈខុសពីពេលមុនក៏ពិតមែន ក៏ប៉ុន្តែចម្លើយនោះបានបញ្ជាក់យ៉ាងច្បាស់ថា សម្បទារបស់គាត់មិនមានភាពធ្ងន់ធ្ងរនោះទេ។

[១៥:៤៤:១៩]

បានន័យថា គាត់អាចឆ្លើយបាននូវសំណួរដែលអ្នកជំនាញបានសួរទៅគាត់។ អ៊ីចឹងមានន័យថា គាត់អាចឆ្លើយបាន គាត់អាចដឹង គាត់អាចដឹងខុសត្រូវនូវអ្វីដែលអ្នកជំនាញបានសួរ។ បើសិនបី ឬបួនខែក្រោយ ឬក្នុងកាលៈទេសៈណាមួយបន្ទាប់ពីការពិនិត្យសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដែលបានលើកឡើងដោយគ្រូវពេទ្យជំនាញ ដែលបានបញ្ជាក់កន្លងមកនេះ ប្រសិនបើគេរកឃើញថា ឬក៏យើងឃើញសភាពការណ៍ជាក់ស្ដែងទៅលើសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ មានការប្រែប្រួលសុខភាព ឬសម្បទារបស់គាត់ ពេលនោះភាគីដែលពាក់ព័ន្ធអាចស្នើសុំឲ្យពិនិត្យសម្បទារបស់គាត់ជាថ្មីទៀតបាន។ ក្នុងន័យនេះ សហព្រះរាជអាជ្ញាយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងនឹងអាចពិនិត្យពិចារណាជាថ្មី ហើយសម្រេចជាថ្មីទៀត ទាក់ទិននឹងបញ្ហាការចូលរបស់គាត់នាពេលសវនាការខាងមុខ។ ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញាយល់ឃើញថា នៅក្នុងបរិបទនៃការជំរុញឲ្យមានសវនាការឆាប់រហ័ស ប្រកបដោយយុត្តិធម៌ និងត្រឹមត្រូវនោះ វត្តមានរបស់ជនជាប់ចោទ អៀង ធីរិទ្ធ គឺជាការចាំបាច់ ជាជាងការអវត្តមានរបស់គាត់ក្នុងពេលសវនាការ។ ព្រោះថា យើងរំពឹងទុកថា នៅពេលសវនាការខាងមុខនឹងមានសំណួរ ឬបញ្ហាជាច្រើនដែលអាចចោទឡើង ហើយត្រូវការការបកស្រាយជាចាំបាច់ ដើម្បីឲ្យដឹងការពិតទាក់ទិនទៅនឹងបទចោទប្រកាន់របស់គាត់ ដែលកន្លងមកអង្គសវនាការក៏ដូចជាសហព្រះរាជអាជ្ញាបានចោទប្រកាន់ទាក់ទិននឹងបទចោទប្រកាន់ចំពោះជនជាប់ចោទ អៀង ធីរិទ្ធ។ ដូច្នេះវត្តមានរបស់គាត់ គឺជាការចាំបាច់ដោយខានមិនបាន។

[១៥:៤៦:០៩]

លោក លោកស្រីចៅក្រម ជាទីគោរព ជនជាប់ចោទ បើនិយាយអំពីទម្លាប់នៅក្នុងតុលាការអន្តរជាតិនាពេលកន្លងមក ជាបទពិសោធន៍ ជនជាប់ចោទពីបទឧក្រិដ្ឋធំៗជាច្រើន សុទ្ធតែអះអាងថាមានការភ្លេចភ្លាំង ឬបាត់បង់ការចងចាំអំពីបទល្មើសដែលត្រូវចោទប្រកាន់។ ក៏ប៉ុន្តែចំណុចនេះមិនរារាំងដល់ការចូលរួមរបស់ជនជាប់ចោទទាំងនោះនៅក្នុងដំណើរការជំនុំជម្រះក្តីទេ។ គឺឲ្យតែជនជាប់ចោទមានសមត្ថភាពនៅក្នុងការយល់ដឹងអំពីភាពលម្អិតនៃភស្តុតាង និងនីតិវិធីរបស់តុលាការ។ ជនជាប់ចោទ អៀង ធីរិទ្ធ អាចសហការបើផ្អែកតាមឯកសាររបស់អ្នកជំនាញ គឺគាត់អាចសហការជាមួយនឹងមេធាវីរបស់គាត់បាន ហើយគាត់បានលើកឡើងថា នៅក្នុងរបាយការណ៍ មេធាវីការពារក្តីរបស់គាត់កំពុងព្យាយាមជួយដល់គាត់។ ជនជាប់ចោទ អៀង ធីរិទ្ធ គ្រាន់តែមានការលំបាកខ្លាំងចំពោះគាត់ នៅក្នុងការជួយដល់ការត្រៀមរៀបចំការពារក្តីរបស់គាត់។ ដោយសារតែការចុះអន់ថយនៃការចងចាំរបស់គាត់ចំពោះព្រឹត្តហេតុដែលបានកើតឡើងនាពេលកន្លងមក។ ក៏ប៉ុន្តែចំណុចនេះពុំមានន័យថា គាត់អត់លទ្ធភាព ឬគ្មានសមត្ថភាពទាំងស្រុងនោះទេ។

[១៥:៤៧:៣៧]

ពាក់ព័ន្ធមួយទៀត ទាក់ទងនឹងសមត្ថភាព ក្នុងការផ្តល់សក្ខីកម្ម ដែលប្រើស្មារតី ឬក៏គំនិតរបស់គាត់ ជនជាប់ចោទ អៀង ធីរិទ្ធ។ តំណាងអយ្យការនៅពេលនេះនៅតែយល់ឃើញថា គាត់អាចយល់ដឹងអំពីសំណួរទាំងឡាយដែលអាចនឹងសួរគាត់នៅក្នុងសវនាការនាពេលខាងមុខ ដោយជនជាប់ចោទនេះអាចប្រើប្រាស់ឲ្យអស់លទ្ធភាពនូវស្មារតី ឬគំនិតដើម្បីឆ្លើយទៅនឹងសំណួរទាំងឡាយដែលអាចចោទនៅពេលខាងមុខ។

[១៥:៤៨:១០]

តំណាងអយ្យការយល់ឃើញថា ចំណុចនេះ គឺអាចបង្ហាញពីជំហររបស់គាត់យ៉ាងច្បាស់ គឺគាត់ពិតជាមានសមត្ថភាព បើផ្អែមតាមរបាយការណ៍របស់អ្នកជំនាញ គឺសមត្ថភាពរបស់គាត់ គឺពិតជាគ្រប់គ្រាន់ដើម្បីផ្តល់សក្ខីកម្ម ពោលគឺមិនមានការលំបាកណាមួយសម្រាប់គាត់នៅក្នុងការយល់ដឹងអំពីសំណួរនោះទេ។ ហើយគាត់ពិតជាអាចឆ្លើយតបទៅនឹងសំណួរទាំងឡាយនៅក្នុងអំឡុងពេលសវនាការនាពេលខាងមុខបាន។

អង្គសវនាការទាំងមូលជាទីគោរព។ សហព្រះរាជអាជ្ញាយល់ឃើញថា ទៀតថាចំពោះការកំណត់អត្តសញ្ញាណ និងការពិនិត្យសាក្សីនៅក្នុងយុត្តាធិការ ជនជាប់ចោទ អៀង ធីរិទ្ធ អាចមើលស្គាល់

បុគ្គលទាំងឡាយ ដែលគាត់ធ្លាប់ស្គាល់ពីមុន។ បើទោះបីគាត់មិនអាចប្រាប់ពីឈ្មោះបុគ្គលទាំងនោះក៏ដោយ ឬមិនអាចចាំពីតួនាទីរបស់ពួកគាត់ឲ្យបានត្រឹមត្រូវក៏ដោយ ក៏ប៉ុន្តែចំណុចនេះមានន័យថា គាត់អាចជួយពន្យល់ដល់អង្គសវនាការនៅពេលខាងមុខ អំពីចម្លើយសាក្សី អំពីបុគ្គលដែលគាត់បានស្គាល់ ទាក់ទិននឹងបទចោទប្រកាន់ទាំងឡាយចំពោះគាត់បាន។

[១៥:៤៩:២៣]

ទាក់ទិននឹងការផ្តល់ចម្លើយជាមួយនឹងគ្រូពេទ្យជំនាញ ដែលបានធ្វើតេស្តកន្លងមក ជនជាប់ចោទ អៀង ធីរិទ្ធ បានផ្តល់ចម្លើយដែលមានការពាក់ព័ន្ធនឹងសំណួរ ដោយសារតែគាត់បានយល់ដឹងអំពីអត្ថន័យនៃសំណួរដែលបានសួរគាត់។ ហើយចម្លើយរបស់គាត់មានចរិតលក្ខណៈជាការការពារខ្លួនខ្លះៗ បើទោះបីចម្លើយទាំងនោះមិនមានលក្ខណៈស៊ីសង្វាក់ក៏ដោយ ដោយហេតុថា ពេលខ្លះចម្លើយទាំងនោះខុសគ្នាទាំងស្រុងទៅនឹងភស្តុតាងដែលគាត់បានផ្តល់ឲ្យ។ ចំណុចនេះសហព្រះរាជអាជ្ញាយល់ឃើញថា គឺបានបង្ហាញថា គាត់មានសមត្ថភាពឆ្លើយទៅនឹងសំណួររបស់ភាគី ឬក៏របស់លោក លោកស្រីចៅក្រមនៅក្នុងសវនាការបាន។ ពីព្រោះចម្លើយរបស់ដែលគាត់ឆ្លើយនៅក្នុងការធ្វើតេស្តរបស់ក្រុមអ្នកជំនាញបង្ហាញអំពីលទ្ធភាព និងសមត្ថភាពខាងសតិបញ្ញា និងការយល់ដឹងរបស់គាត់។

ដូច្នេះទាញចេញពីចំណុចនេះ យើងអាចសន្និដ្ឋាន គាត់អាចឆ្លើយនឹងសំណួរនេះនៅពេលសវនាការខាងមុខ ដែលភាគីបានសួរនៅក្នុងសវនាការនាពេលខាងមុខបាន។

ជនជាប់ចោទ អៀង ធីរិទ្ធ នឹងអាចតាមដានកិច្ចដំណើរការនីតិវិធីពីកន្លែងមួយផ្សេងទៀតនៃបន្ទប់សវនាការតាមរយៈប្រព័ន្ធបច្ចេកទេសសោតទស្សន៍ ហើយការធ្វើបែបនេះ គឺសហព្រះរាជអាជ្ញាយល់ថា អាចជួយដល់គាត់បានខ្លះៗ រួមគ្នាជាមួយនឹងជំនួយរបស់មេធាវីការពារក្តី និងបុគ្គលគាំពារដទៃទៀតដូចមានរៀបរាប់បញ្ជាក់នៅក្នុងកថាខណ្ឌ១១ នៃកម្រងសំណួររបស់សហព្រះរាជអាជ្ញា។ សូមអញ្ជើញមើលឯកសារ E111/2 ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១១ ព្រោះទោះជាយ៉ាងណាក៏ដោយ ក៏សហព្រះរាជអាជ្ញានៅតែយល់ថា ប្រព័ន្ធសោតទស្សន៍នៅតែជាមធ្យោបាយដែលអាចជាបង្កើតសមត្ថភាពអាចជួយសម្រួលដល់ការចងចាំ និងការរំឭកឡើងវិញរបស់គាត់ នៅក្នុងព្រឹត្តិហេតុដែលបានកើតឡើងក្នុងអតីតកាល គឺជួយចូលរួមចំណែកបំភ្លឺដល់អង្គសវនាការទាក់ទិននឹងបញ្ហាការជម្រះក្តី ទោះបីជាសតិបញ្ញារបស់គាត់មានការអន់ថយបន្តិចក៏ដោយ ឬក៏អន់ថយក្នុងកម្រិតមធ្យមក៏ដោយ។

[១៥:៥១:៣១]

តាមរយៈបច្ចេកទេសនេះ គឺការប្រើប្រាស់ប្រព័ន្ធនេះ ពិតជាអាចចូលរួមក្នុងបន្ទប់សវនាការនេះ ហើយដែលប្រព័ន្ធនេះអាចបន្តដំណើរការរបស់អង្គជំនុំជម្រះនៅពេលសម្រាក បន្ទាប់មកយើងអាចបន្តដោយយោងទៅលើបច្ចេកទេសប្រព័ន្ធសោតទស្សន៍ដែលយើងបានរៀបចំកន្លងមក។

លោក លោកស្រីចៅក្រមជាទីគោរព! អង្គជំនុំជម្រះនៅថ្ងៃនេះ ការសម្រេចរបស់អង្គជំនុំជម្រះនៅថ្ងៃនេះ គឺជាការសម្រេចមានលក្ខណៈសំខាន់ទាក់ទិននឹងសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ នៅក្នុងការចូលរួមការជម្រះក្តី។

សហព្រះរាជអាជ្ញាយល់ថាការសម្រេចរបស់ក្រុមប្រឹក្សាជម្រះនៅពេលនេះ គឺពិតជាមានសារៈសំខាន់បំផុតចំពោះសវនាការនៅពេលខាងមុខ។

សហព្រះរាជអាជ្ញាយល់ថា ក្រុមប្រឹក្សាជម្រះគួរគប្បីសម្រេចឲ្យជនជាប់ចោទអៀង ធីរិទ្ធ មានវត្តមាននៅក្នុងសវនាការនៅពេលខាងមុខ ចូលរួមសវនាការនៅពេលខាងមុខ ជាការប្រសើរ ជាងការមិនឲ្យចូលរួម។ ព្រោះដើម្បីជាផលប្រយោជន៍ដល់ប្រព័ន្ធយុត្តិធម៌ផង ប្រព័ន្ធច្បាប់ផង ជាពិសេសដើម្បីជាផលប្រយោជន៍ជាគុណប្រយោជន៍នៃការអនុវត្តនីតិវិធីជាធរមានរបស់យើង។

[១៥:៥២:៤៧]

ជនជាប់ចោទ អៀង ធីរិទ្ធ បើយោងតាមឯកសារមានរោគសញ្ញានៃការបាត់បង់សមត្ថភាពផ្នែកបញ្ញាស្មារតីក្នុងពេលឥឡូវនេះ ក្នុងពេលបច្ចុប្បន្ននេះ។ ក៏ប៉ុន្តែគាត់គ្មានជំងឺផ្លូវចិត្តណាធ្ងន់ធ្ងរទៀតទេ ដូចជាជំងឺធ្លាក់ទឹកចិត្ត ឬជំងឺរោគចិត្តនោះ ដូចខ្ញុំបានសួរនៅពេលព្រឹកមិញនេះចំពោះអ្នកជំនាញហើយ។

អ្នកជំនាញបានឆ្លើយយ៉ាងច្បាស់ថា គាត់គ្មានទេក្នុងករណីនេះ ដែលគាត់រកមិនឃើញអំពីរោគសញ្ញានេះទេ។ ជាពិសេសគឺអ្នកជំនាញបានឆ្លើយ ធ្វើការវិភាគទៅលើលក្ខណៈវិនិច្ឆ័យ អាយ.ស៊ី.ឌី ដប់។ សម្រាប់ជំងឺបាត់បង់សមត្ថភាពផ្នែកបញ្ញាស្មារតី ដូចមានបញ្ជាក់នៅក្នុងរបាយការណ៍របស់អ្នកជំនាញរួចហើយ។

ជនជាប់ចោទ អៀង ធីរិទ្ធ មានការចុះខ្សោយខាងចងចាំ មានត្រឹមកម្រិតមធ្យម ដែលបណ្តាលឲ្យមានការលំបាកខ្លាំងក្នុងការរស់នៅដោយឯករាជរបស់គាត់។ ការធ្លាក់ចុះនៃសមត្ថភាពសតិបញ្ញាដទៃទៀត មានកម្រិតស្រាលទៅមធ្យម ដែលកម្រិតនេះ ធ្វើឲ្យចុះខ្សោយដោយការបំពេញកិច្ចការប្រចាំថ្ងៃរបស់គាត់តែប៉ុណ្ណោះ បាត់បង់ភាពម្ចាស់ការក្នុងការរស់នៅប្រចាំថ្ងៃតែប៉ុណ្ណោះ។

[១៥:៥៣:៥២]

សហព្រះរាជអាជ្ញាយល់ឃើញថាចំណុចនេះ មិនមែនជាការប៉ះពាល់ធ្ងន់ធ្ងរទៅដល់ការចូលរួមរបស់គាត់ក្នុងអង្គជំនុំជម្រះនោះទេ។ ព្រោះថា ការសន្និដ្ឋានរបស់អ្នកជំនាញបានបកស្រាយបញ្ជាក់យ៉ាងច្បាស់ហើយថា គាត់មានលទ្ធភាព គាត់មានសមត្ថភាពចូលរួមក្នុងជម្រះក្តីបាន។

ជនជាប់ចោទ អៀង ធីរិទ្ធ មានការធ្លាក់ចុះផ្នែកគ្រប់គ្រងអារម្មណ៍ ភាពមិននឹងនរនៃអារម្មណ៍ ភាពមួម៉ៅក្តៅក្រហាយ ភាពប្រងើយកន្តើយ ការធ្វើឲ្យបាត់បង់នូវអស់នូវឥរិយាបទសង្គមក៏ពិតមែន ក៏ប៉ុន្តែចំណុចទាំងអស់នេះ គឺមិនប៉ះពាល់ទៅដល់ការចូលរួមរបស់គាត់នៅក្នុងសវនាការទេ ក្នុង *(ឮមិនច្បាស់)* ទេ។ មានន័យថាមេធាវីការពារក្តីអាចជួយគាត់បាននៅក្នុងកិច្ចការនេះ។ ជនជាប់ចោទ អៀង ធីរិទ្ធ អាចសន្ទនាគ្នា នៅមានសមត្ថភាពខ្លះក្នុងការបិទបាំងបញ្ហាចងចាំរបស់គាត់បាន ដោយការប្តូរប្រធានបទ និងការផ្តល់ចម្លើយបែបប្រយោល។

ចំណុចនេះគ្មានអ្វីចម្លែកទេ ចំពោះមនុស្សដែលមានការបាត់បង់សមត្ថភាពផ្នែកបញ្ហាស្មារតី។ ព្រោះសូម្បីតែមនុស្សទូទៅធម្មតាក៏មានករណីបែបនេះកើតមានឡើងដែរ។

[១៥:៥៥:០២]

ដូច្នេះសហព្រះរាជអាជ្ញាយល់ថា ចំណុចនេះក៏មិនមែនជាចំណុចដែលឧបសគ្គនៅក្នុងការចូលរួមរបស់គាត់ដែរ។ ម្យ៉ាងវិញទៀត ជនជាប់ចោទ អៀង ធីរិទ្ធ គាត់អាចប្រាស្រ័យទាក់ទងយ៉ាងច្បាស់ ដោយហេតុថាគាត់មានការលំបាកជាក់លាក់នៅក្នុងស្វែងរកពាក្យពេចន៍មកនិយាយនោះឡើយ។ គាត់គ្មានការលំបាកក្នុងការនិយាយទាក់ទងខ្លាំងក្លានោះទេ។ ហើយទម្រង់ និងរចនាសម្ព័ន្ធនៃឃ្លាប្រយោគដែលគាត់បានប្រើ ក៏មានលក្ខណៈប្រក្រតីដែរ។ ម្យ៉ាងទៀតបើតាមឯកសារបានបង្ហាញថា អត្រាលេកកម្ពស់សំឡេង និងចង្វាក់សំឡេងនៃសម្តីសំដៅរបស់គាត់របស់គាត់ក៏មានលក្ខណៈធម្មតាដែរ។ ដូច្នេះគាត់អាចនិយាយឆ្លើយឆ្លង ឆ្លើយសំណួរ និយាយក្នុងសវនាការបានដោយគ្មានឧបសគ្គទេ។ នេះជាការយល់ឃើញរបស់សហព្រះរាជអាជ្ញា។

[១៥:៥៥:៥៥]

ការយល់ឃើញរបស់សហព្រះរាជអាជ្ញាដូចបានជម្រាបជូនអង្គសវនាការនៅពេលនេះ សហព្រះរាជអាជ្ញាយល់ឃើញថា ជាការគ្រប់គ្រាន់ដែលសហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងនៅពេលនេះ សម្រេចឲ្យជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវតែមានវត្តមានជាចាំបាច់នៅក្នុងការចូលរួមជំនុំជម្រះក្តីនៅក្នុងសវនាការនាពេលខាងមុខ។ ព្រោះវត្តមានរបស់គាត់ពិតជាមានសារៈសំខាន់

ណាស់ ប៉ុន្តែលើកលែងតែក្នុងករណីណាដែលសុខភាព ឬសម្បទារបស់គាត់មិនអាចអនុគ្រោះឲ្យគាត់បាន ចូលរួមសវនាការបាន គឺអាស្រ័យលើករណីជាក់ស្តែង។

ការប្រែប្រួលជាយថាហេតុទាក់ទិននឹងសុខភាពនេះ សហព្រះរាជអាជ្ញាយល់ឃើញថាអង្គជំនុំជម្រះអាចសម្រេច និងពិចារណាជាថ្មីទៀតទាក់ទិនទៅនឹងសុខភាព ឬក៏សម្បទាជាក់ស្តែងរបស់គាត់នៅខណៈពេលណាមួយនោះ។

[១៥:៥៦:៤៩]

សហព្រះរាជអាជ្ញា-- ទោះយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាមិនត្រូវគប្បីឲ្យជនជាប់ចោទ អៀង ធីរិទ្ធ នៅក្រៅឃុំនោះទេ ព្រោះការឃុំខ្លួនរបស់គាត់នៅ អ៊ុ.ស៊ី.ស៊ុ.ស៊ី នៅទីនេះគឺមានលក្ខណៈសមស្រប និងមានលក្ខណៈល្អប្រសើរ សមស្របទៅនឹងលក្ខខណ្ឌនៃសុខភាពរបស់គាត់ដែលត្រូវការតាមដានជាការចាំបាច់នៅក្នុងការថែទាំសុខភាពរបស់គាត់ និងត្រួតពិនិត្យសុខភាពរបស់គាត់។

ចំពោះសំណួរដែលទាក់ទងការបំបែក អៀង ធីរិទ្ធ ពីដំណើរការនីតិវិធី សហព្រះរាជអាជ្ញាយល់ថាមិនមានលក្ខខណ្ឌដែលត្រូវបំបែកនោះទេ។

សហព្រះរាជអាជ្ញាយល់ឃើញថា មិនគួរគប្បីបំបែកទេ ដោយហេតុផលដូចតទៅ៖

ទី១) ជនជាប់ចោទ អៀង ធីរិទ្ធ មានលក្ខណៈកាយសម្បទា សម្បទារបស់គាត់អាចចូលរួមក្នុងសវនាការបាន។

ទី២) នៅក្នុងពេលសវនាការនាពេលខាងមុខ អាចមានសំណួរ ឬបង្ហាញខ្លះដែលលើកឡើងដោយភាគីណាមួយអាចត្រូវការឆ្លើយបំភ្លឺពីជនជាប់ចោទ អៀង ធីរិទ្ធ ជាចាំបាច់។ ការឆ្លើយបំភ្លឺរបស់គាត់ អាចនឹងមានទាក់ទិនទៅនឹងជនជាប់ចោទបីរូបដទៃទៀត ឬក៏ជនជាប់ចោទបីរូបដទៃទៀតអាចឆ្លើយសំណួរ ឬក៏អាចសួរសំណួរ ឬក៏អាចលើកបញ្ហាណាមួយ ដែលទាក់ទិនទៅនឹងជនជាប់ចោទ អៀង ធីរិទ្ធ ជាការចាំបាច់ដែលត្រូវឆ្លើយបំភ្លឺ ឆ្លងឆ្លើយគ្នាទៅវិញទៅមក។

[១៥:៥៨:០៥]

ដូច្នេះបើសិនជាការបំបែកក្នុងករណីនេះ ធ្វើឲ្យបញ្ហាឧសបគ្គជាចាំបាច់ ជាយថាហេតុដែលជៀសមិនរួចនៅពេលអនាគត។

ម្យ៉ាងវិញទៀត ចំណុចទី៣ សហព្រះរាជអាជ្ញាយល់ឃើញថា ជាជម្រើសដ៏ល្អបំផុតសម្រាប់ការអនុវត្តនីតិវិធី សម្រាប់សវនាការសំណុំរឿង០០២នេះ សហព្រះរាជអាជ្ញាយល់ឃើញថា ជម្រើស

ដ៏ល្អបំផុត គឺមិនគួរគប្បីបំបែកនីតិវិធីដោយឡែកនោះទេ ព្រោះគ្មានហេតុផលណាដែលរំខានទៅដល់ការអនុវត្តនីតិវិធីរបស់តុលាការទេ។ បើសិនជាការបំបែកដែលកើតមានជនជាប់ចោទផ្សេងទៀត អាចនឹងស្នើសុំបំបែកនីតិវិធីចំពោះជនជាប់ចោទបីរូបផ្សេងទៀត អាចនឹងស្នើសុំទៀត ដូច្នេះបង្កការលំបាក និងឧបសគ្គជាច្រើនដល់អង្គជំនុំជម្រះ ដែលនីតិវិធីនេះអាចអូសបន្លាយពេលវេលា ធ្វើឱ្យមានការខាតបង់ផលប្រយោជន៍ជាច្រើន។

ចំណុចមួយទៀតដែលសហព្រះរាជអាជ្ញាយល់ឃើញ គឺការបំបែកនីតិវិធីនេះ នឹងអូសបន្លាយពេលវេលា ខាតផលប្រយោជន៍សេដ្ឋកិច្ច ផលប្រយោជន៍ហិរញ្ញវត្ថុ ហើយបន្ថែមបន្ទុកការងារច្រើនថែមទៀតដល់អង្គជំនុំជម្រះ និងស្ថាប័ន អង្គភាពដែលពាក់ព័ន្ធទាំងអស់បន្ថែមទៀត។

ចំណុច៥) សហព្រះរាជអាជ្ញាយល់ឃើញថា សហព្រះរាជអាជ្ញាមិនយល់ឃើញថា ឬក៏មិនរកឃើញចំណុចណាមួយដែលគួរគប្បីបំបែកនីតិវិធីចំពោះជនជាប់ចោទ អៀង ធីរិទ្ធ នោះទេ។ ការដែលមិនបំបែកនីតិវិធី គឺជាការល្អបំផុត គឺជាជម្រើសល្អបំផុតសម្រាប់អង្គជំនុំជម្រះសាលាដំបូងនៅពេលនេះ។

ខ្ញុំសូមបញ្ចប់ការបកស្រាយរបស់ខ្ញុំប៉ុណ្ណេះ ដោយយោងទៅលើពេលវេលា ហើយសូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ក៏ដូចជាអង្គសវនាការទាំងមូលដែលបានតាមដានស្តាប់ការបកស្រាយរបស់ខ្ញុំ។ សូមអរគុណបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណតំណាងសហព្រះរាជអាជ្ញាជាតិ។ ជាកិច្ចបន្តអង្គជំនុំជម្រះប្រគល់វេទិកាជូនទៅសហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឡើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់នូវកិច្ចដំណើរការសវនាការនេះ ហើយមានរយៈដប់ប្រាំនាទី បានជម្រាបជូនរួចហើយ។

សូមអញ្ជើញ បាទ!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រីដែលមានវត្តមាន នៅទីនេះ។ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមាន នឹងមានយោបល់សន្និដ្ឋានមួយចំនួន ហើយសាកល្បងមិននិយាយដដែលទៅលើអ្វីដែលសហព្រះរាជអាជ្ញាបានលើកហើយនោះទេ។ ហើយជាទូទៅគឺមេធាវីនាំមុខឯកភាពជាមួយសហព្រះរាជអាជ្ញានៅក្នុងការលើកអំពីហេតុផលនានា ដែលបញ្ជាក់ថា

លោកស្រី អៀង ធីរិទ្ធ មានលទ្ធភាពនៅក្នុងការចូលនៅក្នុងសវនាការបាន។

[១៦:០១:០៣]

ហើយគ្រាន់តែលើកពីចំណុចមួយចំនួនបន្ថែមទៅលើអ្វីដែលបានលើកឡើង ដោយសហព្រះរាជអាជ្ញាតែប៉ុណ្ណោះ ដើម្បីចៀសវាងកុំឲ្យមានការខាតពេលច្រើនដល់អង្គសវនាការ។

ដូចបានលើកដោយអ្នកជំនាញហើយ លោកស្រី អៀង ធីរិទ្ធ គាត់មានលទ្ធភាពនៅក្នុងការនិយាយស្ដីធម្មតា។ គាត់ចេះភាសាបារាំង និងអង់គ្លេស លើភាសាខ្មែរដែលគាត់អាចនិយាយបាន ហើយនៅថែមពីលើនេះ អំ នាយកទទួលបន្ទុកពន្ធនាគារក៏បានបញ្ជាក់បន្ថែមថា លោកស្រីមានលទ្ធភាពនៅក្នុងការយល់ ឬក៏និយាយលេងសើចទៀតផង។ ដូច្នេះបញ្ជាក់ថា លោកស្រីមានលទ្ធភាពច្រើន ហើយលោកស្រីក៏បានយល់ផងដែរ នូវ-- ច្បាស់លាស់ថា អ្វីដែលថាពាក្យ "ឆ្កួតនោះ" ដែលលោកស្រីបានឆ្លើយជាមួយនឹងអ្នកជំនាញ ហើយចំពោះចំណុចមួយចំនួនដែលមានលើកនៅក្នុងកម្រងសំណួររបស់ការធ្វើតេស្ដអំពីសមត្ថភាពរបស់លោកស្រី អៀង ធីរិទ្ធ អឹម.អឹម.អេស.អ៊ី ដែលបាននិយាយថា លោកស្រីមានកម្រិតមធ្យមនៃសមត្ថភាពផ្នែកសតិបញ្ញារបស់គាត់។

ខ្ញុំសូមលើបន្ថែមពីរចំណុចនៅក្នុងនោះ ចំណុចទីមួយគឺថាពាក់ព័ន្ធទៅនឹងការអំពីសមត្ថភាពនៅក្នុងការដឹងអំពីថ្ងៃខែនេះ ដូចអ្នកជំនាញបាននិយាយហើយ គាត់មិនមាន មិនបានមើលអំពីកាឡង់យ៉េដែលមាននៅក្នុង-- ដែលមិនមាននៅក្នុងបន្ទប់ពន្ធនាគារ ហើយក៏នេះជាករណីទូទៅដែលមនុស្សជាច្រើនដែលនៅប្រទេសកម្ពុជា ដែលគាត់ជួនកាលគាត់អាចមិនដឹងអំពីថាតើថ្ងៃនេះ-- ថ្ងៃដែលគាត់កំពុងនៅនោះគឺជាថ្ងៃស្អី ហើយពេលវេលាដែលគាត់កំពុងតែនិយាយហ្នឹង គឺជាពេលវេលាណាមួយ។ មានករណីនេះដែលយើងមិនអាចបដិសេធបានទេ។ ហើយករណីមួយទៀតពាក់ព័ន្ធទៅនឹងអាយុ ការមិនដឹងអាយុរបស់លោកស្រី អៀង ធីរិទ្ធ វាជាការធម្មតាដូចគ្នាដែរ ដែលបុគ្គលជាច្រើនអាចដឹងពីថ្ងៃខែឆ្នាំកំណើតរបស់ខ្លួន ដែលខ្លួនចាំ ក៏ប៉ុន្តែកាលណាត្រូវនិយាយអំពីអាយុរបស់ខ្លួន ខ្លួនច្រើនតែត្រូវគិត ហើយធ្វើលេខដកដើម្បីដឹងពីអាយុរបស់ខ្លួន។

[១៦:០៤:០៥]

អ៊ីចឹងពាក់ព័ន្ធទៅនឹងបញ្ហាកម្រងសំណួរដែលបានលើកឡើងពាក់ព័ន្ធនឹងពីរចំណុចនេះ ខ្ញុំបាទខាងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីយល់ថា សំណួរនេះ វាមិនឆ្លើយតបទៅនឹងលក្ខណៈប្រពៃណីរបស់ខ្មែរនោះទេ។ កម្រងសំណួរគួរតែឆ្លើយតបទៅនឹងលក្ខណៈវប្បធម៌អ្នកដែលត្រូវគេធ្វើការ

ពិសោធន៍ផងដែរ។

ចំពោះសមត្ថភាពនៅក្នុងការចូលរួមរបស់លោកស្រី អៀង ធីរិទ្ធ នៅក្នុងសវនាការនេះទៀតសោត ការភ្លេចភ្លាំងរបស់គាត់ ប្រសិនបើមានការរំឭកអំពីប្រវត្តិ អំពីអតីតកាល នេះគឺជាវិធីមួយដែលអាចជួយឲ្យគាត់មានការចងចាំនឹកឃើញមកវិញ នូវអ្វីនៅក្នុងអតីតកាល ហើយដែលអាចឲ្យគាត់អាចមានលទ្ធភាពនៅក្នុងការឡើងធ្វើសក្ខីកម្មនៅក្នុងតុលាការបាន។

ដូច្នេះនេះជាវិធីមួយដែលជួយឲ្យគាត់មានលទ្ធភាពនៅក្នុងការចូលរួមសវនាការ។ ដោយសារថាចំណុចជាច្រើនដែលយើងខ្ញុំមានជាគំនិតសម្រាប់លើកនេះ ត្រូវលើកដោយសហព្រះរាជអាជ្ញារួចហើយ ខ្ញុំបាទសូមចូលទៅចំណុចដែលពាក់ព័ន្ធទៅនឹងការបំបែកនីតិវិធីក្នុងករណីលោកស្រី អៀង ធីរិទ្ធ នេះ គឺថា ជាគោលការណ៍គឺខាងមេធាវីនាំមុខឯកភាពជាមួយនឹងខាងតំណាងសហព្រះរាជអាជ្ញា ក៏ប៉ុន្តែក៏យើងត្រូវតែគិតផងដែរថា តើការទុកឲ្យលោកស្រី អៀង ធីរិទ្ធ នៅក្នុងនីតិវិធីជាមួយជនជាប់ចោទបីនាក់ទៀតនឹងមានការប៉ះពាល់យ៉ាងណាទៅដល់ដំណើរការនីតិវិធី ប្រសិនបើមានការប៉ះពាល់ខ្លាំងដល់ដំណើរការនីតិវិធី នាំឲ្យមានការព្យួរច្រើនលើកច្រើនគ្រា។ នេះជាការល្អដែរ ដែលគួរតែមានការបំបែកនីតិវិធី ហើយចំពោះករណីមេធាវីរបស់លោក នួន ជា ដែលបានលើកពាក់ព័ន្ធទៅនឹងការបំបែកនីតិវិធី ហើយរហូតទៅដល់លើកថា គួរតែមានការបំបែកនីតិវិធីដល់កូនក្តីរបស់គាត់ផងដែរ ករណីនេះគឺស្ថានភាពរបស់លោក នួន ជា មិនដូចជាករណីរបស់លោកស្រី អៀង ធីរិទ្ធ ទេ ហើយមិនគួរមានការបំបែកនីតិវិធីចំពោះករណីលោក នួន ជា ទេ ដោយសារសមត្ថភាពផ្នែកស្មារតីបញ្ញារបស់គាត់ មានលក្ខណៈភ្លឺស្វាងល្អណាស់ លើកលែងតែគាត់មិនអាចអង្គុយបានយូរតែប៉ុណ្ណោះ។ ដូច្នេះ នេះគឺជាយោបល់មួយចំនួន ហើយខ្ញុំសូមលោកប្រធានអនុញ្ញាត ដើម្បីឲ្យលោកស្រីមេធាវីអេលីហ្សាបេត ស៊ីម៉ុនណូហ្វត ដើម្បីធ្វើការសន្និដ្ឋានបន្ត។ សូមអរគុណ។

[១៦:០៧:១៨]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធានជាទីគោរព អស់លោក លោកស្រីចៅក្រមទាំងអស់ជាទីគោរព។ អង្គជំនុំជម្រះត្រូវតែវាយតម្លៃទៅលើសម្បទារបស់ អៀង ធីរិទ្ធ ទៅលើលក្ខណៈវិនិច្ឆ័យ ដែលត្រូវបានលើកឡើងយ៉ាងយូរ ហើយដែលមានជះឥទ្ធិពល ហើយនិងមានការតវ៉ា ហើយនិងមានការបកស្រាយយ៉ាងច្បាស់លាស់។ ដូច្នេះ ដើម្បីបញ្ចប់នេះ ខ្ញុំចង់និយាយអំពីឥរិយាបទពីររបស់លោកស្រី អៀង ធីរិទ្ធ ដែលត្រូវបានលើក

ឡើងដោយអ្នកជំនាញនៅក្នុងរបាយការណ៍គាត់។ នៅក្នុងកថាខណ្ឌទី៤១ អ្នកជំនាញបាននិយាយថា អៀង ធីរិទ្ធ បានបដិសេធនូវពិរុទ្ធភាពរបស់គាត់ គាតមិនដែលសម្លាប់មនុស្សទេ គាត់មិនដែលប្រព្រឹត្ត អំពើ ឬប្រព្រឹត្តអំពើនេះទេ ជាប្រជាជនរបស់ខ្ញុំ តើខ្ញុំអាចធ្វើបាបគាត់យ៉ាងម៉េចនឹងកើត គឺគាត់បដិសេធ ទាំងអស់។ ដូច្នេះខ្ញុំគិតថា នេះមិនមែនជាការបង្ហាញនូវអសមត្ថភាពនោះទេ ការបដិសេធគឺជាការ បង្ហាញនូវឆន្ទៈរបស់គាត់ ហើយវាគឺជាទម្លាប់អនុវត្តមួយដែលមានលក្ខណៈធម្មតា ចំពោះអ្នកដែលត្រូវ បានគេចោទប្រកាន់ និងកាត់ទោស ហើយដូចគ្នាដែរនៅក្នុងកថាខណ្ឌ៤២ នៃរបាយការណ៍របស់គាត់ អ្នកជំនាញបានបញ្ជាក់ថា លោកស្រី អៀង ធីរិទ្ធ គាត់បដិសេធក្នុងការលើកឡើងនូវបទចោទ ហើយនិង អត្ថន័យនៃការចោទប្រកាន់ទាំងអស់នេះ។

[១៦:០៨:៤២]

ហើយជាថ្មីម្តងទៀត ការបដិសេធគឺមិនមែនបង្ហាញនូវអសមត្ថភាពក្នុងការយល់ទេ ផ្ទុយទៅវិញ គឺជាការបង្ហាញនូវឆន្ទៈគឺថា ជាការបង្ហាញនូវជំហរ ការប្រកាន់ជំហរ និងធ្វើការសម្រេចចិត្តមួយ ហើយវាគឺជាការអនុវត្តមួយ ដែលមានលក្ខណៈជាធម្មតាចំពោះបុគ្គល ដែលត្រូវបានចោទប្រកាន់ ហើយនិងត្រូវបានចាត់ទោស។ នៅក្នុងកថាខណ្ឌ៤៦ នៃរបាយការណ៍របស់គាត់ដដែលនេះ អ្នកជំនាញ ការបានបញ្ជាក់ថា លោកស្រី អៀង ធីរិទ្ធ បានបដិសេធក្នុងការនិយាយអំពីផលប៉ះពាល់ នៃការកាត់ ទោសរបស់គាត់ ហើយនៅកន្លែងនេះម្តងទៀត វាមិនមែនជាការបង្ហាញនូវអសមត្ថភាពនៅក្នុងការយល់ ទេ គឺវាជាឆន្ទៈរឹងមាំរបស់គាត់នៅក្នុងអ្វីដែលគាត់បានធ្វើ ហើយវាក៏ជាអ្វីដែលធម្មតា ចំពោះអ្នកដែល ត្រូវបានគេកាត់ទោស។

ដូច្នេះផ្ទុយទៅវិញស្របទៅនឹងឥរិយាបទទាំងអស់នេះ លោកស្រី អៀង ធីរិទ្ធ គឺគាត់និយាយ ដោយគ្មានការរួញរា ហើយមានលក្ខណៈច្បាស់លាស់ចំពោះរឿងហេតុមួយចំនួន ហើយវាមិនមែនជា ភាពអសមត្ថភាពនោះទេ។ គាត់បាននិយាយថា ឃើញទេគេចោទថា ខ្ញុំឆ្កួត គឺដូច្នេះគេមិនត្រូវធ្វើអីទេ ចំពោះមនុស្សឆ្កួត។ អ៊ីចឹង ដូច្នេះខ្ញុំគិតថា អានេះវាច្បាស់លាស់ណាស់ គឺគាត់បានចាត់វិធានការច្បាស់ លាស់នូវអ្វីដែលបានកើតឡើង និងពិភាក្សាក្នុងរយៈពេលពីរបីថ្ងៃ កាលពីខែសីហា គឺថាគាត់គិតថា គាត់មិនអាចត្រូវការកាត់ទោសនោះទេ គឺគាត់បាននិយាយច្បាស់។ ដូច្នេះខ្ញុំចង់បញ្ជាក់ត្រង់ចំណុចនេះថា ឆន្ទៈរបស់គាត់ក្នុងការមិននិយាយ គឺអ្វីដែលពាក់ព័ន្ធទៅនឹងពិរុទ្ធភាពរបស់គាត់ពីព្រោះថាវាធ្វើឱ្យរំខាន ដល់គាត់ ហើយម្យ៉ាងទៀតគឺគាត់បានយល់ព្រមនិយាយពី-- និយាយអំពីអសមត្ថភាពរបស់គាត់ ហើយ

និងផលវិបាកដែលពាក់ព័ន្ធទៅនឹងអសមត្ថភាពរបស់គាត់នេះ។ ដូច្នេះនេះ តើនៅទីនេះវាមិនមែនជាការបង្ហាញអំពីការយល់ច្បាស់ ឬយ៉ាងច្បាស់ ហើយនិងវៃឆ្លាតរបស់គាត់ ហើយជាការឆ្លៀតឱកាសក្នុងការទាញយកផលចំណេញពីបញ្ហាប្រឈមនៃការកាត់សេចក្តីនេះ។

[១៦:១០:៥០]

ដូច្នេះ ខ្ញុំចង់និយាយពីរបីពាក្យពាក់ព័ន្ធទៅនឹងការបំបែកនីតិវិធីផងដែរ។ ចំពោះខ្ញុំហាក់-- គឺថាយើងនឹងសម្រេចទៅលើកាយសម្បទារបស់គាត់ ហើយនិងទៅលើការបំបែកនីតិវិធីនេះផងដែរ។ យើងមានការព្រួយបារម្ភទាំងអស់គ្នាគឺថាធ្វើយ៉ាងម៉េចឲ្យការជំនុំជម្រះនេះបានឆាប់រហ័ស ហើយនិងជំរុញឲ្យមានការជជែកដេញដោលគ្នាឲ្យបានឆាប់រហ័ស ដោយមានហេតុផលផ្សេងៗគ្នា។ ហើយចំពោះខ្លួនយើងវិញផ្ទាល់ គឺខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគឺយើងគិតទៅលើសុខភាពរបស់ជនជាប់ចោទ។ ហើយជួនកាលនោះ សេចក្តីសម្រេចគឺដើម្បីធ្វើឲ្យមានការពន្លឿននូវនីតិវិធីនេះ គឺវាមាន-- ធ្វើឲ្យមានឥទ្ធិពលបញ្ច្រាសទៅវិញទេ គឺវាអាចបង្កឲ្យផលវិបាកខាងផ្នែកច្បាប់គឺធ្វើឲ្យមានការពន្យារនូវការជជែកដេញដោលគ្នាទៅលើបញ្ហានេះ សម្បទានេះ។

[១៦:១១:៤៥]

ដូច្នេះខ្ញុំក៏បាន-- ចង់បដិសេធចំពោះអ្វីដែលខាងមេធាវី នួន ជា គាត់បាននិយាយកាលពីអម្បាញ់មិញនេះ។ ហើយយើងបានដឹងច្បាស់ណាស់ថា យើងបានវាស់ ខាងអង្គជំនុំជម្រះបានវាស់វែងនូវភាពស្មុគស្មាញទាំងអស់នេះ ហើយជាចុងក្រោយនេះ ខ្ញុំចង់បញ្ជាក់ថាអ្វីៗគឺតុលាការជាអ្នកសម្រេចទាំងអស់ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។

យ៉ាងម៉េចទៅលោកស្រី ដាយអាណា អេលីស?

[១៦:១២:២៣]

**លោកស្រី ដាយអាណា អេលីស៖**

លោកប្រធាន ថាតើយើងខ្ញុំមានសិទ្ធិទទួលបានការឆ្លើយតបដោយសង្ខេបទៅលើអ្វីដែលបានលើកឡើងនេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកស្រីធ្វើការឆ្លើយតប ប៉ុន្តែសូមលោកស្រីឆ្លើយតបដោយសង្ខេបបំផុត។

**លោកស្រី ដាយអាណា អេលីស៖**

សូមអរគុណច្រើនលោកប្រធាន។

ផលប្រយោជន៍នៃយុត្តិធម៌ គឺមិនបានបំពេញទៅបាននោះទេ ប្រសិនបើយើងរៀបចំសវនាការមួយសម្រាប់ជនជាប់ចោទ ដែលមិនមានសម្បទា ហើយដែលគ្រាន់តែមានវត្តមានរបស់ជនជាប់ចោទ គាត់មិនអាចធ្វើអ្វីបាននោះ។ យើងខ្ញុំយល់ឃើញថា នៅក្នុងយុត្តិសាស្ត្រអន្តរជាតិ ឧទាហរណ៍នានាគួរតែយកមកពិចារណានៅក្នុងតុលាការនេះ នៅក្នុងប្រទេសនេះ។ ភាពធ្ងន់ធ្ងរនៃបទចោទដែលបានដាក់បន្ទុកមកលើជនជាប់ចោទគឺគ្មានអ្វីជាការសង្ស័យនោះទេ វាជាការចោទប្រកាន់យ៉ាងធ្ងន់ធ្ងរ។ ហើយអង្គជំនុំជម្រះសាលាដំបូងត្រូវតែពិចារណាឲ្យបានជាក់លាក់លើបញ្ហានេះ ក៏ប៉ុន្តែមិនថាបទល្មើស បទចោទធ្ងន់ធ្ងរប៉ុណ្ណានោះទេ ប្រសិនបើជនជាប់ចោទគាត់មិនមានលទ្ធភាពអនុវត្តសិទ្ធិចូលរួមការជំនុំជម្រះក្ដីដោយយុត្តិធម៌នោះ។

[១៦:១៥:០៩]

ដូច្នេះ ការចោទប្រកាន់មិនគួរធ្វើការចោទប្រកាន់ដាក់បន្ទុកគាត់បន្តទៀតនោះទេ។ យើងខ្ញុំសូមរំឭកថានៅក្នុងតុលាការ អាយ.អ៊ឹម.ធី តុលាការយោធាអន្តរជាតិ នៅក្នុងឆ្នាំ១៩៤៥ ដែលវាពាក់ព័ន្ធទៅនឹងជនជាប់ចោទ លោក *អ៊ុលអ៊ែរី* (ប្រកបតាមសំឡេងដើម) ត្រូវបានរកឃើញថា គាត់មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះក្ដី ដោយសារតែរូបគាត់បានបាត់បង់នូវការផ្ដល់លទ្ធភាពផ្ដល់ផលហេតុផលនិងការចងចាំ។ យើងឃើញមានឧទាហរណ៍ផ្សេងទៀត ដែលវាជាបញ្ហាធ្ងន់ធ្ងរ ហើយគេមិនបានដំណើរការក្ដីទៅលើជនជាប់ចោទ។ រឿងក្ដី *ពីណូចេ* ក៏វាពាក់ព័ន្ធទៅនឹងការវង្វេងវង្វាន់។ *ណាហាក, ខ្វាំសេរិក* ពាក់ព័ន្ធទៅនឹងជំងឺឡប់សតិ ដូច្នេះហើយគេមិនជំនុំជម្រះក្ដីនោះទេ។ គេមិនគិតអំពីប្រភេទណានោះទេ។ យើងអង្គជំនុំជម្រះសាលាដំបូងត្រូវតែពិចារណាអំពីផលប៉ះពាល់ដែលកើតចេញអំពីស្ថានភាព និងសមត្ថភាពរបស់ជនជាប់ចោទ ដែលជាសមត្ថភាពក្នុងការធានាដល់ជនជាប់ចោទក្នុងការយល់ទៅលើបទចោទ។

ដូច្នេះជនជាប់ចោទប្រសិនបើគាត់មិនមានសមត្ថភាពនឹងអនុវត្តសិទ្ធិជំនុំជម្រះដោយយុត្តិធម៌

នោះទេ យើងមិនអាចធ្វើការជំនុំជម្រះ ដើម្បីជាប្រយោជន៍ទៅដល់ជនរងគ្រោះ និងសាធារណជននោះទេ។ ប្រជាជន និងជនរងគ្រោះ គឺមានផលប្រយោជន៍ដែលត្រូវទទួលបាននៅក្នុងអង្គជំនុំជម្រះសាលាក្តីនេះ ប៉ុន្តែយើងមិនអាចយកមកជំនុំជម្រះចំពោះបុគ្គលដែលមិនមានសម្បទា ដើម្បីជាផលប្រយោជន៍អ្នកដទៃនោះទេ។

[១៦:១៦:០៨]

យើងមិនបានស្តាប់ទៅលើសក្ខីកម្មរបស់លោកអ្នកជំនាញ តវ៉ាទៅលើរបាយការណ៍របស់ ខាំប៊ែល ដែលវាអាចធ្វើឲ្យប៉ះពាល់ទៅដល់លោកស្រី អៀង ធីរិទ្ធ នៅពេលនោះ។ ហើយការដែលបន្ថយថ្នាំនោះក៏មិនជួយឲ្យប្រសើរឡើងចំពោះសម្បទារបស់គាត់។ អ្នកជំនាញដែលមកផ្តល់សក្ខីកម្មនៅចំពោះមុខយើងនៅមុខយើងនៅក្នុងថ្ងៃនេះ គឺវាមានលក្ខណៈខុសបន្តិចទៅនឹងយោបល់របស់លោក ខាំប៊ែល ដូចដែលយើងបានលើកឡើង។ ដែលក្នុងនេះយើងអាចលើកឡើងថា ជនជាប់ចោទគាត់មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលការចូលរួមការជំនុំជម្រះក្តី។ យើងមិនមានអ្វីភ្ញាក់ផ្អើល ដែលអង្គសវនាការយកបញ្ហានេះមកជំនុំជម្រះនៅក្នុថ្ងៃនេះនោះទេ។

មិនមានចំណុចផ្សេងទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា លោកស្រី អៀង ធីរិទ្ធ ផ្ញើពុតទៅលើបញ្ហាសម្បទារបស់គាត់។ ហើយក៏មិនមានការលើកឡើងអំពីថាតើលោកស្រី អៀង ធីរិទ្ធ ដល់ដំណាក់កាលចុងក្រោយនៃការវង្វេងវង្វាន់ធ្វើឲ្យគាត់បាត់បង់នូវលទ្ធភាព និងមុខងារនៃខួរក្បាលរបស់គាត់ ដែលជំរុញឲ្យគាត់មិនអាចក្រោកចេញពីគ្រែរបស់គាត់។ អ្វីដែលអង្គជំនុំជម្រះទទួលបានព័ត៌មាននៅក្នុងថ្ងៃនេះ គឺគ្រាន់តែការចុះខ្សោយសតិបញ្ញារបស់គាត់ និងជំងឺវង្វេងវង្វាន់មានលក្ខណៈធ្ងន់ធ្ងរមធ្យមតែប៉ុណ្ណោះ។

[១៦:១៧:៥៧]

លោក លោកស្រីបានដឹងអំពីតេស្តមួយចំនួនដែលគេធ្វើកោសល្យវិច័យ ដើម្បីវាយតម្លៃទៅលើជនជាប់ចោទ។ ជាថ្មីម្តងទៀត ទោះបីជាគាត់អាចឆ្លើយតប ឬក៏ចងចាំព័ត៌មានលម្អិតតែមួយ ឬពីរនោះក្តី វាក៏មិនមែនថាគាត់មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះក្តីនោះទេ។ ការយល់ដូច្នេះ គឺជាការគិតផ្ទុយទៅនឹងសមត្ថភាពរបស់គាត់ក្នុងការចូលរួមការពារក្តី។

យើងខ្ញុំសូមឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា បញ្ហានេះជាបញ្ហាថ្មី មេធាវីការពារក្តីបានដាក់បញ្ហាហ្នឹងជូនអង្គជំនុំជម្រះសាលាដំបូងឲ្យពិចារណា។ ខ្ញុំសូមបញ្ជាក់ថា កាលពីលើកមុននៅក្នុងខែ

សីហា គឺយើងបានធ្វើតំណាងឱ្យលោកស្រី អៀង ធីរិទ្ធ ហើយយើងលើកបញ្ហាហ្នឹងទៅដល់សហចៅក្រមស៊ើបអង្កេត គឺបញ្ហាហ្នឹងយើងលើកនៅក្នុងឆ្នាំ២០០៩។ លោកស្រីចៅក្រមប្រហែលជាអាចគិតមើលឃើញហើយថា យើងបានលើកបញ្ហានេះទៅដល់ចៅក្រមស៊ើបអង្កេត នៅពេលដែលយើងឃើញការព្រួយបារម្ភនេះជាលើកដំបូង ហើយខ្ញុំក៏បានលើកឡើងរួចមកហើយដែរ ជូនអង្គជំនុំជម្រះសាលាដំបូង យើងបានព្យាយាមគិតគូរអំពីការស្នើសុំឱ្យមានអ្នកជំនាញបង្គាប់មកដល់យើង។ ដើម្បីឱ្យមានសម្ភារ និងឧបករណ៍គ្រប់គ្រាន់នៅមុនពេលការជំនុំជម្រះ។ ក៏ប៉ុន្តែបញ្ហាទាំងអស់នេះមិនមានកត់ត្រាបានត្រឹមត្រូវទៅលើសំណើ និងការស្នើឡើងរបស់យើង។ ហើយយើងបែរជាធ្វើការសម្រេចទៅលើបញ្ហានេះភ្លាមៗ។ ក្រៅពីការចូលរួមនៅក្នុងការស៊ើបសួរលោកស្រី អៀង ធីរិទ្ធ មិនបានចូលរួមនៅក្នុងកិច្ចសម្ភាសន៍នានា ដែលគេកោះហៅគាត់ឱ្យចូលរួមនៅក្នុងសវនាការទាំងអស់នោះ គឺយើងបានពិភាក្សារួចមកហើយ ដែលយើងចាំហើយថា លោកសាស្ត្រាចារ្យ ខាំប៊ែល បានមើលឌីវីឌី ហើយគាត់បានលើកឡើងថា ការយល់ឃើញរបស់លោកសាស្ត្រាចារ្យគឺបង្ហាញអំពីការចុះខ្សោយនៃសតិបញ្ញា និងការមិនមានលទ្ធភាពក្នុងការគិតគូរអំពីសតិបញ្ញារបស់គាត់ នេះនៅក្នុងកថាខណ្ឌទីប្រាំបួន។ បញ្ហាដែលយើងដាក់នៅចំពោះមុខ លោក លោកស្រីចៅក្រម ដូចដែលគេបានលើកឡើង គេថាអាចមានភាពប្រសើរឡើង។ លោក លោកស្រីចៅក្រម អាចពិចារណាថាតើមានការគាំទ្រទៅលើចំណុចនេះដែរឬទេតាមរយៈការផ្តល់ថ្នាំបន្ថែម?

[១៦:២១:១៤]

នៅក្នុងពេលនេះ ខ្ញុំសូមលើកឡើងថាភស្តុតាងបានបង្ហាញថា គាត់មិនមានសមត្ថភាពចូលរួមការជំនុំជម្រះក្តី។ ចំពោះហេតុផលនៃការបំបែកគាត់ ដើម្បីកុំឱ្យមានការពន្យារពេលនោះ ដោយហេតុថាគាត់មានសមត្ថភាពមិនគ្រប់គ្រាន់ក្នុងការផ្តល់ណែនាំទៅដល់មេធាវីការពារក្តី។ ចំណុចនេះ វានឹងធ្វើឱ្យមានភាពស្មុគស្មាញក្នុងការបំពេញទៅតាមការកំណត់សវនាការ។ ហើយយើងដឹងហើយថា ការចងចាំរបស់គាត់គឺវាអាចមានបញ្ហា ហើយយើងចង់ឱ្យមានភាពប្រសើរឡើងទៅលើការចងចាំរបស់គាត់ បើមិនដូច្នេះទេ គឺយើងមិនអាចធ្វើទៅបាន។ យើងបានឮហើយ ដោយសារតែគាត់មានការចងចាំ បញ្ហាដែលចងចាំយូរ និងចងចាំខ្លី។

លោកស្រី គឺគាត់មានបញ្ហាការចងចាំរយៈពេលវែង និងរយៈពេលខ្លី ដោយសារតែវ័យរបស់គាត់ ហើយវាពាក់ព័ន្ធទៅនឹងវ័យរបស់គាត់។ យើងបានឮហើយ ព្រឹកមិញតាមរយៈលោកសាស្ត្រាចារ្យ

ហ្វាស៊ែល ការចងចាំរយៈយូរគឺអ្នកដែលជាវ័យដែលមានវ័យចំណាស់នោះ ក៏អាចមានការចងចាំរយៈយូរដែរ មិនថាអត់នោះទេ។ ដូច្នេះ វាជាជំងឺនៃការបាត់បង់ការចងចាំ មិនមែនដោយសារវ័យនោះទេ គឺដោយសារការវង្វេងវង្វាន់នេះឯង។

ខ្ញុំសូមដាក់បញ្ហាទាំងអស់នេះ ឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណា ហើយយើងសូមធ្វើការសន្និដ្ឋានថា នៅក្នុងពេលបច្ចុប្បន្ន លោកស្រី អៀង ធីរិទ្ធ មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះក្តី ហើយមិនអាចអនុវត្តសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដោយពេញលេញនោះទេ។ សូមអរគុណ។

[១៦:២៣:១២]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណលោកស្រីមេធាវី។

ឥឡូវនេះ ឃើញថាដំណើរការនៃពិភាក្សាលើបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ឃើញថាដល់ទីបញ្ចប់ហើយ ហើយមុននឹងបញ្ចប់ អង្គជំនុំជម្រះសូមធ្វើការកត់សម្គាល់នូវបញ្ហាមួយចំនួន។ អង្គជំនុំជម្រះបានទទួលនូវសេចក្តីសង្កេតអំពីមេធាវីការពារក្តីលោក អៀង សារី ពាក់ព័ន្ធនឹងសិទ្ធិរបស់ជនជាប់ចោទរូបនេះ នៅក្នុងការអនុវត្តអវត្តមានពីកិច្ចដំណើរការនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះ ដោយមានភ្ជាប់នូវលិខិតលះបង់សិទ្ធិមិនចូលរួមនៅក្នុងសវនាការផងដែរ។

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការដាក់សេចក្តីសង្កេតជាទម្រង់បែបនេះ អង្គជំនុំជម្រះមិនអាចទទួលយកបានទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបង្គាប់ដល់ភាគីនានា មិនចាំបាច់ដាក់សេចក្តីឆ្លើយតប ឬការឆ្លើយតបចំពោះសេចក្តីសង្កេតនេះឡើយ។

[១៦:២៤:១៤]

អង្គជំនុំជម្រះសូមធ្វើការបញ្ជាក់ថា ដើម្បីជាប្រយោជន៍ដល់ភាគី និងសាធារណជន ជនជាប់ចោទទាំងអស់ រួមទាំង អៀង សារី ផង នឹងត្រូវកោះហៅឲ្យចូលខ្លួន និងនាំខ្លួនមកតុលាការ នៅមុនពេលចាប់ផ្តើមសវនាការនីមួយៗ។ ពេលមកដល់ នៅចំពោះមុខអង្គជំនុំជម្រះ ជនជាប់ចោទ អៀង សារី មានសិទ្ធិលះបង់សិទ្ធិរបស់ខ្លួនក្នុងការចូលរួមនៅក្នុងសវនាការ ហើយគាត់មិនអាចត្រូវបានបង្ខំឲ្យស្ថិតនៅក្នុងសាលសវនាការទេ ទោះជាយ៉ាងណាក្តីមេធាវីរបស់គាត់គួរតែផ្តល់យោបល់ដល់គាត់យ៉ាងពេញលេញពីផលវិបាកនូវការសម្រេចចិត្តរបស់គាត់បែបនេះ។ ជាពិសេសត្រង់ថា គាត់អាចនឹងស្ថិតនៅ

ក្នុងផលវិបាកនៃការមិនបានដឹង ឬមិនអាចតទល់យ៉ាងមានប្រសិទ្ធភាពចំពោះភាពលម្អិតនៃភស្តុតាងដែលដាក់បន្ទុកលើរូបគាត់។

[១៦:២៥:១៤]

អង្គជំនុំជម្រះសូមបញ្ជាក់បន្ថែមទៀតថា ប្រសិនបើជនជាប់ចោទពុំចង់មានវត្តមាននៅក្នុងកិច្ចដំណើរការនីតិវិធីដោយស្ម័គ្រចិត្ត ជនជាប់ចោទ អៀង សារី មិនអាចតវ៉ានៅពេលក្រោយ ថាខ្លួនមិនបានទទួលការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌នោះឡើយ។

បាទ នេះជាការបញ្ជាក់បន្ថែម ហើយឥឡូវនេះ កិច្ចដំណើរការនីតិវិធីសវនាការស្តាប់ការបង្ហាញអំពីការកំណត់ជាក់លាក់នូវសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងការដេញដោលអ្នកជំនាញអំពីរបាយការណ៍លើបញ្ហាកាយសម្បទា បញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ឃើញថាដល់ទីបញ្ចប់ហើយ។

[១៦:២៦:០២]

លោក លោកស្រី ក្នុងនាមខ្ញុំជាប្រធាន និងជំនួសមុខឲ្យចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង សូមថ្លែងអំណរគុណដល់មតិយោបល់ទាំងអស់ដែលបានលើកឡើងនៅក្នុងសវនាការនេះ។

ខ្ញុំសូមសម្តែងនូវអំណរគុណផងដែរ ដល់សហព្រះរាជអាជ្ញា សហមេធាវីការពារក្តីជនជាប់ចោទ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មន្ត្រីនៃអង្គភាពផ្នែកនៃការិយាល័យរដ្ឋបាល បុគ្គលិកសន្តិសុខ អនុរក្សមន្ទីរឃុំឃាំង មន្ត្រីក្រឡាបញ្ជីបុគ្គលិកនៃអង្គជំនុំជម្រះសាលាដំបូង និងអ្នកបកប្រែភាសាផ្ទាល់មាត់ផង ដែលបានខិតខំចូលរួមជួយជ្រោមជ្រែងធ្វើឲ្យកិច្ចដំណើរការសវនាការនេះ ប្រព្រឹត្តទៅបានល្អ ហើយទទួលបានជោយជ័យ។

[១៦:២៦:៤៩]

បន្ទាប់ពីស្តាប់នូវសក្ខីកម្ម និងទឡ្ហីករណ៍ផ្ទាល់មាត់ ពាក់ព័ន្ធនឹងការវាយតម្លៃបន្ថែមរបស់អ្នកជំនាញដែលបានផ្តល់ជូនអង្គជំនុំជម្រះសាលាដំបូងកន្លងមកនេះ អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចរបស់ខ្លួនទាក់ទិនទៅនឹងបញ្ហាសម្បទា និងបញ្ហាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការពេលនៅវេលាសមស្របនាពេលខាងមុខនេះ។

អនុរក្សមន្ទីរឃុំឃាំងឲ្យលោក អៀង សារី ដែលកំពុងតាមដាននូវកិច្ចដំណើរការសវនាការតាមប្រព័ន្ធបច្ចេកទេសសោតទស្សន៍នៅខាងក្រោមនោះ ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ។

អង្គជំនុំជម្រះសូមប្រកាសបិទសវនាការ៕

*(សវនាការបញ្ចប់នៅម៉ោង១៦:២៧នាទី)*